# សៀវភៅ មង្គលត្ថទីបនីប្រែ

ភាគទី១ នេះ

*ខ្ញុំអនុញ្ញាតឲ្យផ្សាយជាធម្មទានតាម វិបសាយ នេះ បានតាមត្រូវការ ។*


វត្តខ្មែរសាន់តាអាណា សហរដ្ឋអាមេរិក ថ្ងៃ ១៥ កើត ខែមាឃ ព.ស.២៥៥៨

2630 N, Grand Ave.
Santa Ana, CA 92705
*(714) 771-7344*


*ធម្មទានឈ្មះអស់ទានទាំងពួង*

# មង្គលត្ថទីបនីប្រែ

## ភាគទី១

*ប្រែនិងរៀបរៀងដោយ*

**ភិក្ខុវិនយធរោ**

(មហាឃិន-ឡឿន

*ផ្សាយជាធម្មទាន*

លើកទី១

*ចំនួន ១២០០ ក្បាល*

**រក្សាសិទ្ធិ**

**ព.ស.២៥៣៨**

# មង្គលត្ថទីបនីប្រែ

## ភាគទី ១

---

ភិក្ខុវិនយធរោ

(មហាពិន-ទៀន)

ប្រែនិងរៀបរៀង

ជំនួយដោយសមាគមសិក្សាពុទ្ធិកយុវសិក្សា

និង

ផ្សាយជាធម្មទាន លើកទី ១

ចំនួន ១.០០០ក្បាល

---

រក្សាសិទ្ធិ

ព.ស.២៥៣៨ គ.ស.១៩៩៥

# មង្គលត្ថទីបនី ប្រែ

## ភាគទី ១

-----

**ភិក្ខុវិនយធរោ**

*(មហាយិន-នឿន)*

ប្រែនិងរៀបរៀង

***ជំនួយដល់សមណសិស្សពុទ្ធិកមធ្យមសិក្សា***

និង

***ផ្សាយជាធម្មទាន    លើកទី ១***

ចំនួន ១.០០០ក្បាល

-----------

***រក្សាសិទ្ធិ***

ព.ស.២៥៣៨ គ.ស.១៩៩៥

***ហាមទិញ-លក់***



## ភិក្ខុ មហាឃិន-នឿន

មានដើមកំណើតនៅ

ភូមិ ខាងជើង ឃុំ ទួលព្រេច

ស្រុក មោងឫស្សី ខេត្ត បាត់ដំបង

សៀវភៅ **មង្គលត្ថទីបនីប្រែ ភាគទី ១** នេះ
សម្រាប់តម្កល់ទុកជា **សម្បត្តិសង្ឃ** ក្នុង

វត្ត________________________________
ឃុំ________________________________
ស្រុក________________________________
ខេត្ត________________________________
នៅថ្ងៃ___កើត____រោច ខែ______________
ឆ្នាំ______________ព.ស.២៥៣_____

**ចែកផ្សព្វផ្សាយជាធម្មទាន ចេញអំពី**
**សមាគមន៍ព្រះសង្ឃខ្មែរ និង ពុទ្ធិកសមាគមន៍សង្ឃ**
**នៅតាមវត្តនានា**
**ប្រចាំសហរដ្ឋអាមេរិក**

# មាតិការឿង

| ឈ្មោះ | ទំព័រ |
| --- | --- |
| ១- អារម្ភកថា របស់អ្នកប្រែនិងរៀបរៀង | ក-ឍ |
| ២- មង្គលសូត្រក្នុងខុទ្ទកបាឋៈ | ១ |
| ៣- បណាមគាថា | ៥ |
| ៤- ឧបត្តិកថា | ៧ |
| ៥- ការកំណត់ព្រះសូត្រ | ១៦ |
| ៦- ពណ៌នាសេចក្តីនៃនិទាននិងគាថាទូលសួរ | ១៨ |
| ៧- ពណ៌នាសេចក្តីនៃគាថាទី ១ | ៣១ |
| ៨- ពណ៌នាការសេពនិងមិនសេពពាលនិងបណ្ឌិត | ៣៣ |
| ៩- ពណ៌នាអំពីការបូជា | ១២៦ |
| ១០- ពណ៌នាសេចក្តីនៃគាថាទី ២ | ១៩៥ |
| ១១- ពណ៌នាអំពីការនៅក្នុងប្រទេសដ៏សមគួរ | ១៩៦ |
| ១២- ពណ៌នាភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន | ២២២ |
| ១៣- ពណ៌នាអំពីការតម្កល់ខ្លួនទុកដោយប្រពៃ | ២៦១ |
| ១៤- ពណ៌នាសេចក្តីនៃគាថាទី ៣ | ២៩៦ |
| ១៥- ពណ៌នាអំពីភាពជាអ្នកបានស្តាប់ច្រើន | ២៩៩ |
| ១៦- ពណ៌នាអំពីសិល្បៈ | ៣២៦ |

---

# អារម្ភកថា

---

សៀវភៅ **មង្គលត្ថទីបនីប្រែ ភាគទី ១** នេះ គឺខ្ញុំ ភិក្ខុ **ធិនយធរោ មហាឃិន - ឡឿន** បំរុងនឹងផ្តួចផ្តើមប្រែ រៀបរៀង មកជាភាសាខ្មែរយើង ជាយូរយារណាស់មកហើយ គឺតាំងពីពេលដែលខ្ញុំ កំពុងនៅសិក្សាមកម៉្លេះ (ព. ស. ២៥២៤ គ. ស. ១៩៨១ ) តែឱកាសពុំបានហុចឱ្យ ព្រោះជាប់រវល់ខ្លាំងពេក ក្នុងការសិក្សាភាសាបាលី ឱ្យបានរីកចំរើនឡើងជាបន្ថែមតទៅទៀតផង និងក្នុងពេលនោះ នឹងរកឧបករណ៍ក្បួនច្បាប់ ដែលជាភាសាខ្មែរសម្រាប់ជំនួយ ក៏គ្មានផងដែរ ។ គម្រោងការនេះ ខ្ញុំក៏ពុំបានបោះបង់ចោលដែរ ទោះបីជាខ្ញុំបានរសាត់អណ្តែតឆ្ងាយសែនឆ្ងាយ អំពីមាតុភូមិជាទីស្នេហា ហើយបានទៅរស់នៅឯបរទេស ជាប្រទេសដែលមិនកាន់ព្រះពុទ្ធសាសនា មានវប្បធម៌ ទំនៀមទំលាប់ ខុសប្លែកផ្សេងពីប្រទេសយើងក៏ដោយ ក៏គម្រោងការនេះនៅតែដក់ជាប់ក្នុងចិត្តខ្ញុំជានិច្ច ។

នៅក្នុងថ្ងៃពុធ ១១ រោច ខែពិសាខ ឆ្នាំវក ចត្វាស័ក ព.ស. ២៥៣៥ ត្រូវនឹងថ្ងៃទី ២៧ ខែឧសភា ១៩៩២ ( ឆ្នាំ

ដែលក្រុមអង្គការសហប្រជាជាតិ ចូលមកជួយរៀបចំធ្វើការបោះឆ្នោតនៅប្រទេសកម្ពុជា ) ខ្ញុំក៏បានវិលត្រឡប់ចូលមកទស្សនាមាតុភូមិរបស់ខ្ញុំផងដែរ ហើយបានចូលទៅពិនិត្យមើលការសិក្សាព្រះបរិយត្តិធម៌ ទាំងផ្នែកបាលី ទាំងផ្នែកព្រះធម្មវិន័យ ដែលព្រះសង្ឃកំពុងតែសិក្សានៅតាមវត្តនានា ដូចជាវត្តមហាមន្ត្រី វត្តលង្កា វត្តនិរោធរង្សីជាដើម ដោយមាន **សម្តេចព្រះមង្គលទេពាចារ្យ** ( **អ៊ុំ - ស៊ុំ** ) អគ្គាធិការពុទ្ធិកសិក្សា បាននាំដំណើរជូនទៅផងដែរ ។

ពេលនោះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាទីបំផុត ដោយបានឃើញនូវព្រះសង្ឃអង្គសាមណេរ ខិតខំយកព្រះទ័យទុកដាក់ ក្នុងការសិក្សាព្រះបរិយត្តិធម៌ គឺបានឮព្រះភិក្ខុសង្ឃសាមណេរអង្គខ្លះកំពុងទន្ទេញបាលីវេយ្យាករណ៍ អង្គខ្លះទន្ទេញប្រជុំកងធម៌ អង្គខ្លះហាត់ប្រែធម្មបទ លោកគ្រូអាចារ្យខ្លះកំពុងបង្ហាត់ប្រែលោតប្រយោគ តាមបែបពីបូរាណ... គំហើញ និងការឮសូរស័ព្ទព្រះធម៌ដ៏ពិរោះត្រចៀកនេះ រឹតតែធ្វើឱ្យខ្ញុំរំភើបចិត្តឥតឧបមា ព្រោះនឹកសង្ឃឹម ថា ព្រះពុទ្ធសាសនា ដែលបាន

វិនាសសាបសូន្យ ស្ទើរតែរលត់អស់ ដោយសារភ្លើងសង្គ្រាម ជាងពីរទសវត្សរ៍ មកហើយនោះ នឹងបានរីកចំរើនឡើងវិញ ដោយពិត ហើយបានជំរុញខ្ញុំ ឱ្យរឹតតែមានសទ្ធាជ្រះថ្លាឡើង ជាភិយ្យោភាព ...។ មួយទៀតសោត ធ្វើឲ្យខ្ញុំនឹកគិត ថា តើ នឹងរកពិធីជួយ ដល់សមណសិស្សបែបណា? ខ្ញុំយល់ឃើញ ថា សមណសិស្សដែលកំពុងសិក្សាពុទ្ធិកបឋមសិក្សា (ពេល នោះ) ដូចជាពុំមានបញ្ហាឡើយ ព្រោះមានគ្រូ និងក្បួនច្បាប់ សម្រាប់ជួយច្រើន តែចំណែកតទៅឆ្នាំក្រោយ ៗ ទៀត នឹង មានសមណសិស្សពុទ្ធិកមធ្យមសិក្សា ដោយពិត ឯគ្រូ និងក្បួន ច្បាប់ ខ្ញុំយល់ឃើញ ថា ដូចជាមានបញ្ហាខ្លះ ព្រោះពុំសូវមាន ច្រើន ។

ហេតុនេះហើយ ខ្ញុំមានគំនិតគិត ថា នឹងរកសៀវភៅ **មង្គលត្ថទីបនី** ដែលនៅជាភាសាបាលីទាំង ៤ ភាគ មកបកប្រែ ជាភាសាសម្រាយខ្មែរយើង ដើម្បីជាជំនួយ ដល់សមណសិស្ស ពុទ្ធិកមធ្យមសិក្សា ដែលនឹងមានក្នុងអនាគតកាល ហើយបាន ដើរស្រាវជ្រាវរកសៀវភៅទាំងនោះ តែរកពុំបានឡើយ សូម្បី

តែ **សម្តេចព្រះមង្គលទេព្វាចារ្យ** ( **អ៊ុំ - ស៊ុំ** ) ក៏ព្រះអង្គពុំទាន់មានដែរ ព្រោះរោងពុម្ពជប៉ុនពុំទាន់បានបោះពុម្ពជាជំនួយ ។

ក្រោយមក នៅថ្ងៃសៅរ៍ ១៥ កើត ខែបឋមាសាធ ឆ្នាំរកា បញ្ចស័ក ព.ស. ២៥៣៦ ត្រូវនឹងថ្ងៃទីថ្ងៃ ខែកក្កដា ឆ្នាំ ១៩៩៣ គឺត្រូវចំថ្ងៃបុណ្យបញ្ចុះសីមា **ខេមរពុទ្ធិការាម** វ៉ាស៊ីងតោនឌីស៊ី ខ្ញុំបានទៅចូលរួមក្នុងពិធីបុណ្យនោះដែរ ហើយបានទទួលសៀវភៅមង្គលត្ថទីបនី ភាសាបាលី ភាគទី ១-៤ (១) និងសៀវភៅបទានុក្រមធម្មបទ ៣ ក្បាល អំពីសម្តេចព្រះមង្គលទេព្វាចារ្យ ដែលព្រះអង្គបាននាំយកមកប្រទានឲ្យ ក្នុងពេលនោះដែរ ។ ខ្ញុំក៏បានទទួល ដោយសេចក្តីត្រេកអរជាទីបំផុត ។ លុះខ្ញុំត្រឡប់មកកាន់វត្តខេមរពុទ្ធិការាមវិញ ខ្ញុំបានយកសៀវភៅមង្គលត្ថទីបនី ភាគទី ១ នេះ មកបកប្រែជាភាសាសម្រាយខ្មែរយើង ដោយបានចាប់ផ្តើមបកប្រែ នៅថ្ងៃសៅរ៍ ២ រោច ខែបុស្ស ឆ្នាំរកា បញ្ចស័ក ព.ស. ២៥៣៦ ត្រូវនឹងថ្ងៃទី ៩ ខែមករា ១៩៩៣

---

*១- ភាគទី ២-៤ ខ្ញុំបានប្រែរួចមុនភាគទី ១ ព្រោះភាគទី ១ ខ្ញុំទើបតែនឹងបានទទួលអំពីសម្តេចព្រះមង្គលទេព្វាចារ្យ ។*

ហើយបានប្រែចប់សព្វគ្រប់ នៅថ្ងៃពុធ ៨ រោច ខែចេត្រ ឆ្នាំរកា បញ្ចស័ក ព.ស.២៥៣៦ ត្រូវនឹងថ្ងៃទី ១៤ ខែមេសា ឆ្នាំ ១៩៩៣ ។

លុះប្រែចប់ហើយ ខ្ញុំក៏បានផ្ញើរសំណៅមង្គលត្ថទីបនីនេះ ទៅប្រគេនព្រះតេជៈគុណព្រះ **ធម្មលិខិត លាស់-ឡាយ** វត្តសន្សំកុសល ក្រុងភ្នំពេញ ដើម្បីត្រួតពិនិត្យ ឱ្យបានត្រឹមត្រូវ ព្រះអង្គក៏បានជួយអនុគ្រោះ រហូតដល់បានសម្រេចជាស្ថាពរ ។

ក្នុងការបកប្រែពីភាសាមួយទៅភាសាមួយទៀតនេះ គឺពិតជាមានការពិបាកណាស់ ហើយពិតជាមានការភ្លាំងភ្លាត់ខុស ឃ្លាតចាកអំពីអត្ថន័យធម៌អាចខ្លះ ៗ ដោយអចេតនាខ្លះ ដោយការចេះមិនដល់ខ្លះ ជាពុំខានឡើយ ។ ក្នុងការប្រែនេះសោត គោលគំនិតរបស់ខ្ញុំ គឺប្រែរក្សាទុកភាសាបាលីភាគច្រើន មានន័យ ថា គឺមិនចង់ឱ្យឃ្លាតចាកអំពីភាសាបាលីច្រើនឡើយ ដើម្បីឱ្យអ្នកសិក្សាឆាប់រកស័ព្ទប្រែបានងាយ តែភាសាខ្មែរពិតជានឹងពិបាកស្តាប់បន្តិច ។

ហេតុដូច្នេះ ខ្ញុំអ្នកប្រែ សូមមេត្តាខន្តីអភ័យទោសអំពី

សំណាក់ព្រះតេជះគុណ និងអស់លោកដែលឆ្លៀវឈ្លាស ក្នុងអក្សរសាស្ត្របាលីក្តី ខ្មែរក្តី បើមានការខុសភ្លាំងភ្លាត់ត្រង់កន្លែងណាមួយនោះ ហើយសូមមេត្តាជួយឱ្យយោបល់ និងជួយកែតម្រូវ ដើម្បីធ្វើសៀវភៅនេះ ឱ្យរឹតតែបានល្អប្រសើរឡើង ។ សង្ឃឹម ថា ព្រះតេជះគុណ អស់លោក នឹងផ្តល់យោបល់ដ៏ល្អ ហើយអភ័យទោសដល់ខ្ញុំជាពុំខាន ។

ខ្ញុំសូមឧទ្ទិសសៀវភៅនេះ ដល់សមណសិស្សគ្រប់ព្រះអង្គ និងពុទ្ធសាសនិកជនទូទៅ សូមយកទៅសិក្សា ឱ្យបានឆាប់ចេះឆាប់យល់ ឆ្លៀវឆ្លាតក្នុងព្រះបរិយត្តិធម៌ ហើយយកព្រះធម៌នោះទៅផ្សព្វផ្សាយដល់ពុទ្ធបរិស័ទទាំងឡាយ ដើម្បីលើកស្ទួយព្រះពុទ្ធសាសនា ឱ្យបានរីកចំរើនឡើងរៀងតទៅ ។

មួយទៀត សូមឱ្យការសិក្សា នូវព្រះធម្មវិន័យ របស់សមណសិស្សគ្រប់ ៗ រូប និងពុទ្ធបរិស័ទទាំងអស់ បានសម្រេចសមដូចមនោរថ ដែលបានប្រាថ្នាហើយ កុំបីអាក់ខានឡើយ ។

ខ្ញុំសូមឧទ្ទិសបុណ្យកុសល ដែលកើតអំពីធម្មទាននេះជូនចំពោះបិតាឈ្មោះ **ឃិន - យឿម** មាតាឈ្មោះ **ហិង - អម**

ព្រមទាំងជីដូនជីតា ញាតិកាទាំង ៧ សន្តាន និងសព្វសត្វទាំងអស់ ដែលបានចែកឋានទៅហើយនោះ សូមឱ្យវិញ្ញាណក្ខន្ធរបស់លោកអ្នកទាំងនោះ បានទទួលអនុមោទនា នូវបុណ្យកុសលដែលខ្ញុំបានឧទ្ទិសផ្សាយទៅឱ្យនេះ ហើយសូមឱ្យបានសម្រេចនូវសម្បត្តិទាំងឡាយ ៣ ប្រការ គឺ សម្បត្តិមនុស្ស-ទេវតា និងសម្បត្តិព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។

**វត្តខេមរពុទ្ធិការាម**

*2100 W. Willow Street*

*Long Beach, CA 90810*

U. S. A

ថ្ងៃសៅរ៍ ១៥កើត ខែវិសាខ ឆ្នាំកុរ សប្តស័ក ព.ស.២៥៣៨

ត្រូវនឹងថ្ងៃទី ១៣ ខែឧសភា ១៩៩៥

## សេចក្ដីថ្លែងអំណរព្រះគុណនិងអរគុណ

១ ០ ១

ខ្ញុំសូមថ្លែងអំណរព្រះគុណ និងអរគុណដ៏ជ្រាលជ្រៅ

-ចំពោះ **សម្ដេចព្រះមង្គលទេពាចារ្យ អ៊ុំ - ស៊ុំ** អគ្គាធិការនៃពុទ្ធិកសិក្សា វត្តមហាមន្ត្រី ទីក្រុងភ្នំពេញព្រះរាជាណាចក្រកម្ពុជា ដែលព្រះអង្គបានផ្ដល់ព្រះយោបល់ដ៏ល្អ ៗ និងបានផ្ដល់នូវក្បួនច្បាប់ផ្សេង ៗ មានសៀវភៅមង្គលត្ថទីបនីនេះ និងបទានុក្រមធម្មបទជាដើម តាមសេចក្ដីត្រូវការ ។

-ចំពោះព្រះតេជះគុណ **ព្រះធម្មលិខិត លាស់- ឡាយ** វត្តសន្សំកុសល ទីក្រុងភ្នំពេញ ដែលបានចំណាយពេលវេលា ជួយត្រួតពិនិត្យ កែសម្រួលពាក្យពេចន៍ និងអត្ថន័យផ្សេង ៗ ដើម្បីធ្វើសៀវភៅនេះ ឱ្យបានល្អប្រសើរឡើង តាំងអំពីដើម រហូតដល់ចប់សព្វគ្រប់ ។

-ចំពោះ ព្រះតេជះគុណ **គង់ - ឈាន** ចៅអធិការ **វត្តខ្មែរ ខេមរពុទ្ធិការាម** ទីក្រុងឡុងប៊ិច សហរដ្ឋអាមេរិក

ដែលបានជួយផ្តល់យោបល់និងគំនិតផ្សេងៗ ។

-ចំពោះ ភិក្ខុ **ប៊ូ - ហួយ** ដែលបានឱ្យខ្ចីសៀវភៅ មង្គលត្ថទីបនីភាគទី ៣ និងភាគទី ៤ ដើម្បីយកមកប្រែ ។

-ចំពោះ ភិក្ខុ **អ៊ុង - អ៊ិន** វត្តព្រោះស្ទ្រ ក្រុងព្រោះស្ទ្រ សហរដ្ឋអាមេរិក, ភិក្ខុ **ប្រាជ្ញ - សាវ៉ាន** វត្តឧណ្ណាលោម កុដិលេខ ៤២ ទីក្រុងភ្នំពេញ និងលោកបណ្ឌិតកវីនិពន្ធ **ហៀម - គៀន** ដែលបានជួយយកសំណៅមង្គលត្ថទីបនីនេះ ទៅប្រគេន **ព្រះធម្មលិខិត លាស់ - ឡាយ** ដើម្បីត្រួតពិនិត្យ ឱ្យបានល្អត្រឹមត្រូវឡើង ។

-ចំពោះ ភិក្ខុ **មហា សោម - សុតា** វត្តធម្មចក្ការាម ស៊ីអាថុល វ៉ាស៊ីងតោនស្តេត និង ព្រះតេជះគុណ **ឯម-គៀង អតិបញ្ញោ មេគណ ខេត្តកំពត** ដែលបានជួយត្រួតពិនិត្យនូវ អក្ខរាវិរុទ្ធ និងពាក្យពេចន៍ ដើម្បីធ្វើសៀវភៅនេះ ឱ្យបានល្អ ល្អប្រសើរឡើង ។

-ចំពោះ ភិក្ខុ **ព្រះមហា សម - សក្តិ** សុវណ្ណរតនោ

ដែលបានជួយយកសៀវភៅមង្គលត្ថទីបនីនេះ ទៅចូលរោងពុម្ព ដើម្បីបោះពុម្ពឱ្យបានសម្រេច តាមសេចក្តីត្រូវការ ។

-ចំពោះ លោក **ឃឹម- ច័យ** និងលោក **ឃុំ - ឆយ** ដែលបានជួយកែសម្រួល និងជួយដំឡើងគ្រឿងកុំព្យូទ័រដោយយកចិត្តទុកដាក់ជាទីបំផុត ។

ម្យ៉ាងទៀត ខ្ញុំសូមថ្លែងអំណរព្រះគុណនិងអរគុណជាទីបំផុត ចំពោះព្រះតេជៈគុណ ព្រះថេរានុថេរៈ អស់លោក លោកស្រី ព្រមទាំងញាតិញោមជាពុទ្ធបរិស័ទទាំងអស់ ដែលបានជួយឧបត្ថម្ភ ក្នុងការបោះពុម្ពសៀវភៅនេះ ឱ្យបានសម្រេចជាស្ថាពរ ។

សូមប្រគេនមគ្គផល ដែលកើតពីធម្មទានានិសង្សនេះ ដល់ព្រះតេជៈគុណ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ សូមឱ្យព្រះអង្គមានព្រះជន្មាយុយឺនយូរ ជាងរយព្រះវស្សា ដើម្បីជាទីពឹង របស់ពុទ្ធសាសនិកជនទាំងឡាយ តរៀងទៅហោង ។

សូមឱ្យញាតិញោមទាំងឡាយ បានទទួលនូវបុណ្យកុសលនេះ ស្មើ ៗគ្នា និងសូមឱ្យបានជួបប្រទះតែនឹងសេចក្តី

សុខ-ចម្រើនគ្រប់ប្រការ កុំបីអាក់ខានឡើយ ។

សូមឱ្យព្រះរាជាណាចក្រកម្ពុជា ជាទីកំសត់ ឆាប់បានទទួលនូវសុខសន្តិភាព ដែលប្រកបដោយព្រះធម៌ នៃអង្គព្រះសម្មាសម្ពុទ្ធបរមគ្រូ ដោយពិត, សូមឱ្យរាជរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ និងគ្រប់គណៈបក្សទាំងអស់ ដឹកនាំប្រទេសជាតិ ព្រះរាជាណាចក្រកម្ពុជា ប្រកបដោយសម្មាទិដ្ឋិ ដើម្បីជោគជ័យ សេចក្ដីសុខ-ចម្រើន និងសុភមង្គល ជូនដល់ប្រជានុរាស្ត្រទូទាំងប្រទេស ដែលកំពុងក្រីក្រលំបាក ស្រេកឃ្លាន នូវសេចក្ដីសុខសន្តិភាព និងស្ងប់ខ្ញើមបំផុតនូវសង្គ្រាម សព្វថ្ងៃនេះ ។

សូមឧទ្ទិសកុសលនេះផងដែរ ដល់ពួកបញ្ញវន្ត អ្នកស្នេហាជាតិ យុវជនយុវតី ប្រជាពលរដ្ឋ អ្នកស្លូតត្រង់គ្រប់ជាន់គ្រប់ស្រទាប់ ដែលបានបូជាជីវិតដើម្បីមាតុភូមិ ដោយចិត្តស្មោះស្ម័គ្រ គ្រប់កាលៈទេសៈ សូមបានទទួលកុសលដែលកើតអំពីធម្មទាននេះ ហើយសូមឱ្យវិញ្ញាណក្ខន្ធ នៃអ្នកបានសោយសុខដ៏ប្រសើរ ក្នុងសុគតិភព កុំបីខានឡើយ ។

⊙ ⊙ ⊙

# ធម្មទានឈ្នះអស់ទានទាំងពួង

---

បើអស់លោក ញាតិញោម ពុទ្ធបរិស័ទមានបំណង ចង់យកសៀវភៅនេះទៅបោះពុម្ពចែកផ្សាយជាធម្មទាន សូមអញ្ជើញទាក់ទងនឹងសហគមន៍ព្រះសង្ឃខ្មែរ ឬទាក់ទងនឹងខ្ញុំផ្ទាល់ ហើយបញ្ជាក់អំពីគោលបំណង តាមអាស័យដ្ឋានដែលមាននៅក្នុងសៀវភៅនេះស្រាប់ ។

*សូមអរគុណ*

---


**សហគមន៍ព្រះសង្ឃខ្មែរ**

**មានទីស្នាក់ការបណ្ដោះអាសន្ននៅ**

**វត្តត្រៃរតនារាម**

21 Quigley Ave.
North Chelmsford,Ma 01863
Tel: (508) 251-1198
U.S.A

# គតិធម៌របស់អ្នកប្រែ

ooo

ត្រូវស្រឡាញ់ចូលចិត្តក្នុងកិច្ចការខ្លួន

ព្យាយាមចាំចូនកុំប្រហែស

យកចិត្តទុកដាក់កុំគេចវេះ

ត្រិះរិះពិចារណាសព្វកិច្ចការ

000

បើចង់បានសម្រេច កុំភ្លេចព្យាយាម

បើភ្លេចព្យាយាម មិនបានសម្រេច

ooo

# មង្គលសូត្រ ក្នុងខុទ្ទកបាឋៈ

( សូត្រនេះ ឈ្មោះមង្គលសូត្រ ) គឺខ្ញុំ ( ឈ្មោះអានន្ទ ) បានស្តាប់មកហើយ យ៉ាងនេះ ថា ៗ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ៗ គ្រានោះឯង ទេវតា ១ អង្គ, កាលរាត្រីបឋមយាម កន្លងទៅហើយ, មានរស្មីដ៏ល្អ ញ៉ាំងវត្តជេតពនទាំងមូលឲ្យភ្លឺស្វាងហើយ, ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ ក្នុងទីណា, ក៏ចូលទៅគាល់ ក្នុងទីនោះ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំចំពោះព្រះមានព្រះភាគហើយ ក៏បានឈរនៅ ក្នុងទីដ៏សមគួរ ៗ លុះទេវតានោះ ឈរនៅក្នុងទីដ៏សមគួរហើយ ទើបបានក្រាបទូលព្រះដ៏មានព្រះភាគ ដោយពាក្យជាគាថា (យ៉ាងនេះ) ថា ÷

“ ទេវតា និង មនុស្សទាំងឡាយជាច្រើន ប្រាថ្នានូវសេចក្តីសួស្តី បានគិតរិះរក នូវមង្គលទាំងឡាយ, សូមព្រះអង្គ ទ្រង់ព្រះមេត្តាសំដែងប្រាប់នូវមង្គលដ៏ឧត្តម ” ៗ (១)

---

១ ត្រៃបិដក ភាគទី ៥២ / ទំព័រទី ៤ ៗ

(ព្រះមានព្រះភាគ ទ្រង់ត្រាស់ នូវមង្គល ៣៨ ប្រការ ដោយព្រះពុទ្ធភាសិត ជាពាក្យគាថា យ៉ាងនេះ ថា) ÷

“ ១- ការមិនសេពគប់ នូវបុគ្គលពាលទាំងឡាយ ១ ការសេពគប់ នូវបុគ្គលជាបណ្ឌិតទាំងឡាយ ១ ការបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ ១ ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម ។

២- ការនៅក្នុងប្រទេស ដ៏សមគួរ ១ ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយ ក្នុងកាលមុន ១ ការដំកល់ខ្លួនដោយប្រពៃ ១ ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម ។

៣- ភាវៈនៃបុគ្គលបានស្តាប់បានរៀនមកដោយច្រើន ១ សិល្បៈ គឺ សេចក្តីឆ្លៀវឆ្លាសក្នុងហត្ថកម្ម របស់អ្នកបួសនិងគ្រហស្ថ ១ វិន័យដែលបុគ្គលសិក្សាដោយប្រពៃ ១ វាចាដែលជាសុភាសិត ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

៤- ការបំរើមាតា ១ ការបំរើបិតា ១ សេចក្តីសង្គ្រោះដល់បុត្រនិងភរិយា ១ ការងារ

ទាំងឡាយដែលមិនច្របូកច្របល់ ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

៥ - ការបរិច្ចាគទាន ១ ការប្រព្រឹត្តិធម៌ ១ សេចក្តីសង្គ្រោះដល់ញាតិទាំងឡាយ ១ ការងារទាំងឡាយ ដែលមិនមានទោស ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

៦ - ការមិនត្រេកអរក្នុងបាប និង ការវៀរចាកបាប ១ សេចក្តីសង្រួមចាកការផឹក នូវទឹកស្រវឹង ១ សេចក្តីមិនប្រមាទ ក្នុងធម៌ទាំងឡាយ ១ ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម ។

៧ - សេចក្តីគោរព ១ ការប្រព្រឹត្តិបន្ទាបខ្លួន ១ សេចក្តីត្រេកអរតាមមានតាមបាន ១ ភាវៈនៃបុគ្គលអ្នកដឹង នូវឧបការៈ ដែលអ្នកដទៃធ្វើហើយ ១ ការស្តាប់នូវធម៌ តាមកាល ១ ទាំង ៥ នេះ ជាមង្គលដ៏ឧត្តម ។

៨ - សេចក្តីអត់ធន់ ១ ភាវៈនៃបុគ្គលដែលគេប្រដៅបានដោយងាយ ១ ការជួបប្រទះនូវសមណៈទាំងឡាយ ១ ការសន្ទនាទៅវិញ

ទៅមកនូវធម៌ តាមកាល ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

៩ - សេចក្ដីព្យាយាមជាគ្រឿងដុតកំដៅ នូវបាបធម៌ ១ ការប្រព្រឹត្តិនូវធម៌ដ៏ប្រសើរ ១ ការឃើញនូវអរិយសច្ចទាំងឡាយ ១ ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

១០ - ចិត្តនៃបុគ្គលណា ដែលលោកធម៌ទាំងឡាយពាល់ត្រូវហើយ មិនរំភើបញាប់ញ័រ ១ មិនមានសេចក្ដីសោក ១ មានធុលី គឺរាគៈទៅប្រាសហើយ ១ ជាចិត្តដ៏ក្សេមក្សាន្ត ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

១១ - ទេវតានិងមនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយ ប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ ក្នុងទីទាំងពួង តែងដល់នូវសិរីសួស្ដីក្នុងទីទាំងពួង នេះ ជាមង្គលដ៏ឧត្តម របស់ទេវតា និង មនុស្សទាំងឡាយនោះ ” ។

មង្គលសូត្រ ចប់ ។

# មង្គលត្ថទីបនី ប្រែ

## ភាគទី ១

---

### បណាមគាថា

(១) ព្រះពុទ្ធអង្គឯណា ដែលពួលប្បីទូទៅ ថា " ជាមង្គល របស់ទេវតា និង មនុស្សទាំងឡាយ ដែលមានសេចក្តីប្រាថ្នា ដោយមង្គល " ព្រះអង្គជាអ្នកទ្រង់សំដែងនូវសេចក្តីនៃមង្គល, ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះពុទ្ធអង្គនោះ ដែលជាមង្គល ។

ព្រះធម៌ឯណា ដែលពួលប្បីសព្វសាយ ថា " ជាមង្គល របស់ទេវតា និង មនុស្សទាំងឡាយ ដែលមានសេចក្តីប្រាថ្នា ដោយមង្គល " ជាធម៌ ដែលបំភ្លឺ នូវសេចក្តីនៃមង្គល, ខ្ញុំព្រះករុណា សូមនមស្សការនូវព្រះធម៌នោះ ដែលជាមង្គល ។

ព្រះសង្ឃឯណា ដែលពួលប្បីសព្វសាយ ថា " ជាមង្គល របស់ទេវតា និង មនុស្សទាំងឡាយ ដែលមានសេចក្តីប្រាថ្នា ដោយមង្គល " ជាអ្នក

ដែលធ្វើ នូវសេចក្តីនៃមង្គល, ខ្ញុំព្រះករុណា សូមនមស្សការនូវព្រះសង្ឃនោះ ដែលជាមង្គល ។

ខ្ញុំព្រះករុណា ជាអ្នកបានធ្វើកិរិយានមស្សការ ល្អប្រពៃហើយ ដល់ព្រះរតនត្រៃ ដែលជាមង្គល យ៉ាងនេះ ដោយប្រការដូច្នេះ, ដោយអានុភាព នៃកិរិយានមស្សការថ្វាយបង្គំនោះ ខ្ញុំព្រះករុណា ជាអ្នកញ៉ាំងសេចក្តីអន្តរាយ ឲ្យវិនាសបានហើយ, ព្រះសូត្រឯណា ដែលសំដែងនូវមង្គល គឺព្រះពុទ្ធ ជាម្ចាស់ដែលជាមង្គល ទ្រង់ត្រាស់សំដែងទុក ល្អ ប្រពៃហើយ ប្រាកដដោយឈ្មោះថា មង្គលសូត្រ ដែលមានអាថ្ថាដ៏ក្រៃលែង និងអាថ្ថា នៃព្រះសូត្រ ឯណា ដែលបុគ្គលឯណាមួយ សំដែងទុកហើយ ដើម្បីជាមង្គល ដល់សត្វមានជីវិតទាំងឡាយ ក្នុង លោកនេះ បានផ្សព្វផ្សាយទៅហើយ ក្នុងសែន កោដិចក្រវាឡ, នឹងជ្រើសរើសយក នូវសេចក្តី ដែលជាសារៈ ក្នុងគម្ពីរផ្សេង ៗ នោះ មកហើយ សំដែងអត្ថនៃព្រះសូត្រនោះៗ, សូមអ្នកទាំងឡាយ តាំងចិត្តស្តាប់ នូវអត្ថនៃមង្គលសូត្រនោះចុះ ។

(២) អធិប្បាយថា ព្រះអាចារ្យកាលនឹងពណ៌នានូវសេចក្តីនៃព្រះសូត្រ ពោលហេតុកើតឡើងនៃព្រះសូត្រ និង ការកំណត់នៃព្រះសូត្រ ជាមុនហើយ ទើបពណ៌នាសេចក្តី ( នៃព្រះសូត្រនោះ ) ជាខាងក្រោយ, ព្រោះហេតុនោះ ខ្ញុំនឹងពោលហេតុកើតឡើងនៃព្រះសូត្រជាដើម ។ មែនពិត ព្រះសូត្រទាំងអស់ មានហេតុកើតឡើង ៤ យ៉ាង គឺ កើតព្រោះអធ្យាស្រ័យ របស់ខ្លួនឯង ១ កើតព្រោះអធ្យាស្រ័យ របស់អ្នកដទៃ ១ កើតព្រោះកើតមានរឿងឡើង ១ កើតព្រោះអំណាចនៃពាក្យសួរ ១ ។ ក្នុងហេតុកើតឡើងទាំង ៤ យ៉ាងនោះ ព្រះសូត្រទាំងឡាយ មានទ្វយតានុបស្សនាសូត្រជាដើម កើតឡើង ព្រោះអធ្យាស្រ័យរបស់ខ្លួនឯង, ព្រះសូត្រឡាយ មានមេត្តសូត្រជាដើម កើតឡើង ព្រោះអធ្យាស្រ័យ របស់អ្នកដទៃ, ឧគរសូត្រជាដើម កើតឡើង ព្រោះកើតមានរឿងឡើង, វម្មិកសូត្រជាដើម កើតឡើង ព្រោះអំណាចនៃពាក្យសួរ ។ បណ្តាហេតុកើតឡើងទាំងនោះ ហេតុកើតឡើង ដោយអំណាចពាក្យសួរលោកសំដៅយកហើយ ក្នុងមង្គលសូត្រនេះ ។ សូម្បីមង្គលសូត្រក៏កើតឡើង ដោយអំណាចនៃពាក្យដណ្តឹងសួរ ដោយពិតប្រាកដ ។

(៣) ក្នុងរឿងនោះ មានពាក្យពោលជាលំដាប់ ដូចតទៅនេះបានឮមកថា មហាជន ក្នុងជម្ពូទ្វីប បានប្រជុំគ្នា ក្នុងទីនោះៗ មាន

មាត់ទ្វារនគរ សណ្ឋាគារ (ផ្ទះទទួលភ្ញៀវ) និងទីប្រជុំជាដើម សូម្បីឲ្យប្រាក់និងមាសហើយ ញ៉ាំងបុគ្គលឲ្យនិយាយរឿង របស់ពួកជនដែលនៅខាងក្រៅព្រះពុទ្ធសាសនា មានប្រការផ្សេងៗ មានរឿងនាំនាងសីតាមកជាដើម ៗ រឿងមួយ ៗ ដោយកាលកន្លងទៅបាន ៤ ខែ ទើបបានចប់ ៗ ក្នុងថ្ងៃមួយ រឿងមង្គល បានកើតឡើងហើយ ក្នុងទីប្រជុំនោះ ថា " អ្វីទៅហ្ន៎ ? ដែលជាមង្គល , រូបដែលបុគ្គលបានឃើញហើយឬ ? ជាមង្គល, សំឡេងដែលបុគ្គលបានស្តាប់ហើយឬ ? ជាមង្គល, អារម្មណ៍ដែលបុគ្គលបានដឹងហើយឬ ? ជាមង្គល, អ្នកណាទៅ ដឹងនូវមង្គល ? " ។

## ( ទិដ្ឋមង្គល )

គ្រានោះ បុរសម្នាក់ ឈ្មោះថា ទិដ្ឋមង្គលិកៈ ( អ្នកយល់ថារូបដែលបុគ្គលឃើញហើយជាមង្គល ) និយាយឡើង ថា " ខ្ញុំបាទស្គាល់នូវមង្គល, រូបដែលបុគ្គលឃើញហើយ ជាមង្គល ក្នុងលោក, រូបដែលគេសន្មតថា ជាមង្គលដ៏ខ្ពង់ខ្ពស់ ឈ្មោះថា រូបដែលបុគ្គលបានឃើញហើយ, គឺ បុគ្គលពួកខ្លះ ក្នុងលោកនេះ បានក្រោកឡើងតាំងអំពីព្រឹកព្រលឹម ឃើញសត្វត្រដាងស្លាបហើរតាមខ្យល់ខ្លះ ពៅខ្ចីខ្លះ ស្ត្រីមានផ្ទៃពោះខ្លះ ពួកក្មេង ដែលប្រដាប់តាក់តែងហើយខ្លះ

ពាងទឹកដែលពេញហើយខ្លះ ត្រីឆ្អិនខ្លះ សេះអាជានេយ្យខ្លះ រទេះដែលទឹមដោយសេះអាជានេយ្យខ្លះ គោឧសភខ្លះ មេគោខ្លះ គោក្រហមខ្លះ ឬក៏ឃើញរូបយ៉ាងដូច្នោះ ឯណានីមួយ សូម្បីដទៃទៀតដែលគេសន្មតថា ជាមង្គលដ៏ខ្ពង់ខ្ពស់, នេះហៅថា រូបដែលបុគ្គលបានឃើញហើយជាមង្គល "ៗ

## ( សុតមង្គល )

បុរសម្នាក់ ឈ្មោះថា សុតមង្គលិក ( អ្នកយល់ថាសំឡេងដែលបុគ្គលស្ដាប់ហើយជាមង្គល ) បានឮពាក្យនោះហើយ ទើបបាននិយាយឡើងថា "ម្នាលអ្នកដ៏ចំរើន ធម្មតាភ្នែកនេះ រមែងឃើញនូវរូបស្អាតខ្លះ មិនស្អាតខ្លះ ប្រសើរខ្លះ មិនប្រសើរ ជាទីពេញចិត្តខ្លះ មិនជាទីពេញចិត្តខ្លះ, ប្រសិនបើរូប ដែលចក្ខុនោះ ឃើញហើយគប្បីជាមង្គល (មែន), ក៏គួរតែជាមង្គលទាំងអស់ពិត, ព្រោះដូច្នោះ រូបដែលបុគ្គលឃើញហើយ ទើបមិនមែនជាមង្គលឡើយ, ក៏សំឡេងដែលបុគ្គលស្ដាប់ហើយប៉ុណ្ណោះឯង ជាមង្គល, សំឡេងដែលគេសន្មតថា ជាមង្គលដ៏ខ្ពង់ខ្ពស់ ឈ្មោះថា សំឡេងដែលបុគ្គលស្ដាប់ហើយ, គឺ បុគ្គលពួកខ្លះ ក្នុងលោកនេះ ក្រោកឡើងពីព្រលឹមបានឮថា "ចំរើនឡើងហើយ" ដូច្នេះខ្លះ ថា "កំពុងចំរើនឡើង"

ដូច្នេះខ្លះ ថា 'ពេញហើយ' ដូច្នេះខ្លះ ថា 'ស' ដូច្នេះខ្លះ ថា 'ចិត្តល្អ' ដូច្នេះខ្លះ ថា 'សិរី' ដូច្នេះខ្លះ ថា 'ចំរើនដោយសិរី' ដូច្នេះខ្លះ ថា 'ថ្ងៃនេះ ឫក្សល្អ យាមល្អ ថ្ងៃល្អ មង្គលល្អ' ដូច្នេះ ឬក៏ស្តាប់នូវសំឡេង ដែលគេសន្មតថា ជាមង្គលដ៏ខ្ពង់ខ្ពស់ឯណានីមួយ, នេះ ឈ្មោះថា សំឡេងដែលបុគ្គលស្តាប់ហើយ ជាមង្គល " ។

## ( មុត្តមង្គល )

បុរសម្នាក់ ឈ្មោះថា មុតមង្គលិក ( អ្នកយល់ថា អារម្មណ៍ដែលបុគ្គលដឹងហើយ ជាមង្គល ) បានស្តាប់ពាក្យនោះហើយ ក៏បាននិយាយឡើងថា "ម្នាលអ្នកដ៏ចំរើន ធម្មតាត្រចៀកនោះ រមែងស្តាប់នូវសំឡេងល្អខ្លះ មិនល្អខ្លះ ជាទីពេញចិត្តខ្លះ មិនជាទីពេញចិត្តខ្លះ, ប្រសិនបើសំឡេង ដែលត្រចៀកនោះ បានស្តាប់ហើយ នឹងគប្បីជាមង្គល (មែន), ក៏នឹងគប្បីជាមង្គលទាំងអស់ពិត, ព្រោះហេតុនោះ សំឡេងដែលបុគ្គលស្តាប់ហើយ ទើបមិនមែនជាមង្គលឡើយ, ក៏អារម្មណ៍ ដែលបុគ្គលបានដឹងហើយប៉ុណ្ណោះឯង គឺជាមង្គល, ក្លិន រស និង ផោដ្ឋព្វៈ ដែលគេសន្មតថា ជាមង្គលដ៏ខ្ពង់ខ្ពស់ ឈ្មោះថា អារម្មណ៍ដែលបុគ្គលបានដឹងហើយ, គឺ បុគ្គលពួកខ្លះ ក្នុងលោកនេះ ក្រោកឡើងពីព្រឹកព្រលឹម រមែងហិត នូវក្លិន

នៃផ្កាមានផ្កាបទុមជាដើមខ្លះ ទំពាំខាំ នូវឈើជំរះធ្មេញដែលសខ្លះ ពាល់ត្រូវនូវប្រឹថពីខ្លះ ពាល់ត្រូវនូវសំទូងខ្លះ នូវអាចម៍គោស្រស់ខ្លះ នូវអណ្ដើកខ្លះ នូវរទេះដែលបន្ទុកហើយដោយល្ងខ្លះ នូវផ្កាឈើខ្លះ នូវផ្លែឈើខ្លះ លាបបូកដោយដីពណ៌ស យ៉ាងប្រពៃខ្លះ ស្លៀកសំពត់ពណ៌សខ្លះ ជួតនូវសំពត់ឈ្នួតក្បាលពណ៌សខ្លះ; ឬក៏ហិតក្លិន ក្រេបជញ្ជក់រស ពាល់ត្រូវផោដ្ឋព្វៈ យ៉ាងដូច្នោះ ដទៃទៀតឯណានីមួយ ដែលគេសន្មតថា ជាមង្គលដ៏ខ្ពង់ខ្ពស់, នេះ ឈ្មោះថាអារម្មណ៍ដែលបុគ្គលដឹងហើយ ជាមង្គល " ។

## (ការជជែកគ្នាអំពីរឿងមង្គលមិនចេះចប់)

បុរសទាំង ៣ នាក់នោះ មិនអាច ដើម្បីនឹងញុំាងគ្នានឹងគ្នាឲ្យយល់ព្រម បានឡើយ ។ ក៏បណ្ដាមនុស្សដទៃទៀត ក្រៅអំពីបុរសទាំង ៣ នាក់នោះ មនុស្សពួកខ្លះ បានជឿតាមពាក្យ របស់បុរសទាំង ៣ នាក់នោះ, មនុស្សពួកខ្លះ មិនបានជឿឡើយ, មនុស្សទាំងឡាយណា មិនជឿហើយ, មនុស្សទាំងឡាយនោះក៏បានជំទាស់ហើយ ជាមួយនឹង ពួកមនុស្សដែលបានជឿទាំងនោះ ។ មនុស្សទាំងឡាយណា ជឿហើយនូវពាក្យ របស់នាយទិដ្ឋមង្គលិក, មនុស្សទាំងឡាយនោះ ក៏ដល់នូវការជឿយ៉ាងស៊ប់ ថា "រូបដែល

បុគ្គលឃើញហើយប៉ុណ្ណោះ ជាមង្គល "ដូច្នេះ, មនុស្សទាំងឡាយឯណា ជឿហើយនូវពាក្យ របស់បុរសទាំង ២ នាក់ ក្រៅអំពីនេះ, មនុស្សទាំងឡាយនោះ ដល់នូវការជឿយ៉ាងស៊ប់ ថា "សំឡេងដែលបុគ្គលស្តាប់ហើយនុ៎ះឯង ជាមង្គល, អារម្មណ៍ដែលបុគ្គលដឹងហើយនុ៎ះឯង ជាមង្គល " ដូច្នេះ ៗ រឿងមង្គលនេះ បានប្រាកដហើយ ក្នុងជម្ពូទ្វីបទាំងមូល ដោយប្រការដូច្នេះ ៗ

## ( រឿងមង្គលល្បីទៅដល់អកនិដ្ឋភព )

(៤) គ្រានោះ មនុស្សទាំងឡាយ ក្នុងជម្ពូទ្វីបទាំងមូល ជាពួក ៗ នាំគ្នាគិតនូវមង្គល ថា "អ្វីទៅហ្ន៎ ? ជាមង្គល "ដូច្នេះ ៗ សូម្បីពពួកទេវតា អ្នកថែរក្សា នូវមនុស្សទាំងឡាយនោះ បានស្តាប់ពាក្យនោះ អំពីមនុស្សហើយ ក៏នាំគ្នាគិតរកមង្គលទាំងឡាយយ៉ាងដូច្នោះដែរ ៗ ដោយឧបាយនុ៎ះឯង ពួកភុម្មទេវតាដែលជាមិត្រ របស់ពួកទេវតា អ្នកថែរក្សាពួកមនុស្សទាំងឡាយ ទេវតាទាំងឡាយដែលស្ថិតនៅលើអាកាស ដែលជាមិត្រ របស់ពួកភុម្មទេវតាទាំងនោះ ពួកទេវតាជាន់ចាតុម្មហារាជិកា ដែលជាមិត្រ របស់ពួកអាកាសទេវតាទាំងនោះ ៗ ល ៗ ពួកអកនិដ្ឋទេវតា ដែលជាមិត្ររបស់ពួកសុទស្សីទេវតាទាំងនោះ សារុបទៅហើយថា ពួកទេវតា

និងព្រហ្មទាំងឡាយ បានស្ដាប់ពាក្យនោះ អំពីមិត្រសំឡាញ់ របស់ខ្លួននោះ ៗ ហើយ ជាពួក ៗ បានគិតរក នូវមង្គលទាំងឡាយ ៗ ការគិតរឿងមង្គល កើតឡើងហើយ ក្នុងទីគ្រប់កន្លែង រហូតដល់ក្នុងមួយម៉ឺនចក្រវាល ដោយប្រការដូច្នេះ ៗ ក៏ការគិតរឿងមង្គលដែលកើតឡើងហើយនោះ មិនទាន់បានវិនិច្ឆ័យដាច់ស្រេចនៅឡើយ ថា "នេះជាមង្គល" ដូច្នេះ បានតាំងនៅហើយ អស់រយៈពេល ១២ ឆ្នាំ ៗ

## ( ទេវតាក្រាបទូលបញ្ហានឹងព្រះសាស្ដា )

ក្នុងកាលនោះ ពួកទេវតានិងមនុស្សទាំងអស់ លើកលែងតែព្រះអរិយសាវ័កចេញ បានបែកគ្នាហើយ ជា ៣ ពួក ដោយអំណាចទិដ្ឋមង្គល សុតមង្គល និង មុតមង្គល ៗ សូម្បីបុគ្គលម្នាក់ ដែលបានសម្រេចចិត្ត តាមសេចក្ដីពិត ថា "នេះប៉ុណ្ណោះឯង ជាមង្គល" ដូច្នេះ មិនបានមានឡើយ ៗ

លំដាប់នោះ ពួកទេវតាជាន់សុទ្ធាវាស បានដឹងចិត្ត របស់ពួកមនុស្សហើយ ទើបទៅប្រាប់ ក្នុងទីលំនៅនៃមនុស្ស ថា "ដោយកាលកន្លងទៅ ១២ ឆ្នាំទៀត ព្រះសម្មាសម្ពុទ្ធ នឹងទ្រង់ត្រាស់សំដែងនូវមង្គល" ៗ ក្រោយមក ដោយកាលកន្លងទៅ ១២ ឆ្នាំ

ពួកទេវតានៅជាន់តាវត្តិង្ស បានមកប្រជុំព្រមគ្នាហើយ ក៏ចូលទៅគាល់សក្កទេវរាជដែលជាធំជាងទេវតា បានក្រាបទូល ថា "បពិត្រព្រះអង្គទ្រង់និរទុក្ខ បញ្ហាប្រារព្ធអំពីរឿងមង្គល បានតាំងឡើងព្រមហើយ, មនុស្សមួយពួក ពោល ថា 'រូបដែលបុគ្គលឃើញហើយជាមង្គល' មនុស្សមួយពួក ពោល ថា 'សំឡេងដែលបុគ្គលស្តាប់ហើយ ជាមង្គល' មនុស្សមួយពួក ពោល ថា 'អារម្មណ៍ដែលបុគ្គលដឹងហើយ ជាមង្គល' ដូច្នេះ, ក្នុងបញ្ហានោះ ទាំងពួកយើងខ្ញុំ ទាំងពួកជនដទៃទៀត មិនទាន់បានចុះសម្រុងគ្នានៅឡើយ, សូមប្រទានឱកាសផងចុះ សូមព្រះអង្គ ទ្រង់ព្យាករដល់ពួកយើងខ្ញុំទាំងឡាយតាមសេចក្តីពិត ឲ្យទានផង" ។

ស្តេចសក្កទេវរាជ ទ្រង់ត្រាស់សួរ ថា "រឿងមង្គលនេះគ្រាបំដូង បានតាំងឡើងហើយ នៅក្នុងទីឯណា ?" ។

ពួកទេវតា . ក្នុងមនុស្សលោក ។

ស្តេចសក្កទេវរាជ. ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងទីស្ថានឯណា ? ។

ពួកទេវតា . ក្នុងមនុស្សលោក ។

ស្តេចសក្កទេវរាជ ទ្រង់ត្រាស់ ថា "បើដូច្នោះ អ្នកទាំងឡាយ ចូរមកចុះ, ម្នាលអ្នកនិរទុក្ខទាំងឡាយ ពួកយើងនឹងក្រាប

ទូលសួរ នូវមង្គលបញ្ហានោះ នឹងព្រះដ៏មានព្រះភាគ” ដូច្នេះហើយ ទើបទ្រង់ត្រាស់បញ្ជាទេវបុត្រមួយអង្គ ថា “អ្នកចូរក្រាបទូលសួរនូវព្រះមានព្រះភាគ” ដូច្នេះហើយ ទ្រង់នាំគណៈទេវបុត្រ យាងមកកាន់វត្តជេតពន ។

លំដាប់នោះ ទេវបុត្រនោះ ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយ ក៏ឈរនៅក្នុងទីដ៏សមគួរ ហើយទូលសួរនូវមង្គលបញ្ហា ។ ព្រះដ៏មានព្រះភាគ កាលទ្រង់ឆ្លើយនូវបញ្ហានោះ របស់ទេវបុត្រនោះ ទើបទ្រង់បានត្រាស់ហើយ នូវព្រះសូត្រនេះ ដោយប្រការដូច្នេះ ។

ពណ៌នាអំពីហេតុកើតឡើង ក្នុងមង្គលសូត្រនេះ មានត្រឹមតែប៉ុណ្ណោះសិនចុះ ។

* * *

## ការកំណត់ព្រះសូត្រ

(៥) ក្នុងមង្គលសូត្រនោះ ពាក្យជាដើមហេតុថា “**ឯវមេ្វ សុតំ**” (ខ្ញុំបានស្ដាប់មកហើយ យ៉ាងនេះ) ជាដើម ព្រះអានន្ទត្ថេរ គឺព្រះមហាកស្សបត្ថេរ កាលសង្គាយនា នូវព្រះធម៌ ដណ្ដឹងសួរហើយ ពោលហើយ ដល់ព្រះអរហន្តទាំងឡាយ ៥០០ អង្គ ក្នុងកាលសង្គាយនាដ៏ធំ ក្នុងលើកទីមួយ ។

១ គាថា ថា “**ពហូ ទេវា មនុស្សា ច**” ដូច្នេះជាដើម ទេវតា បានពោលហើយ ។

១១ គាថា មានជាអាទិ៍ ថា “**អសេវនា ច ពាលានំ**” ព្រះមានព្រះភាគ ទ្រង់បានត្រាស់ហើយ ។

ចំណែកនិគមវចនៈ ថា “**ឥទមវោច ភគវា, អត្តមនា សា ទេវតា ភគវតោ ភាសិតំ អភិនន្ទិត្វា ភគវន្តំ អភិវាទេត្វា តត្ថេវន្តរធាយិ**” ដូច្នេះជាដើម គឺព្រះអានន្ទត្ថេរ បានពោលហើយ ។

ប្រមូលពាក្យនោះទាំងអស់ លោកហៅថា “មង្គលសូត្រ” ។

បើគេសួរ ថា “និទានវចនៈ និងនិគមវចនៈ មានប្រយោជន៍យ៉ាងដូចម្ដេច ?” ។ គប្បីឆ្លើយ ថា “មានប្រយោជន៍

ដើម្បីញុំាងសេចក្ដីល្អ ៣ យ៉ាង របស់ព្រះសូត្រ ឲ្យបានបរិបូណ៌ ។ មែនពិត ឯមង្គលសូត្រ ឈ្មោះថា ល្អខាងដើម ព្រោះនិទានវចនៈ, ឈ្មោះថា ល្អនៅទីបញ្ចប់ ព្រោះនិគមវចនៈ, ឈ្មោះថា ល្អត្រង់កណ្ដាល ព្រោះត្រង់កណ្ដាល នៃនិទានវចនៈ និង និគមវចនៈទាំង ២ យ៉ាងនោះ យ៉ាងដូច្នេះឯង ។

ការកំណត់ព្រះសូត្រ ក្នុងមង្គលសូត្រនេះ មានតែប៉ុណ្ណោះ ។

⁂

## ពណ៌នាសេចក្ដីនៃនិទាននិងគាថាទូលសួរ

---

(៦) ឥឡូវនេះ ពាក្យជាដើមហេតុឯណានោះ គឺ ព្រះអានន្ទត្ថេរ កាលនឹងសំដែងនូវហេតុកើតឡើង នៃមង្គលសូត្រ ដោយអំណាចនៃពាក្យដណ្ដឹងសួរ បានពោលហើយ, អ្នកសិក្សាគប្បីជ្រាបសេចក្ដីនៃពាក្យជាដើមហេតុនោះឯង, បណ្ដាពាក្យជាដើមហេតុនោះ ក្នុងពាក្យថា "**ឯវម្មេ សុតំ**" នេះ **មេ** ស័ព្ទមាន **មយា** ស័ព្ទ ជាអត្ថ, **សុតំ** ស័ព្ទ មានវិញ្ញាណអាស្រ័យសោតទ្វារ ជាអត្ថ, **ឯវំ** ស័ព្ទ មានអាការៈ និទស្សនៈ និងអវធារណៈ ជាអត្ថ ។

### ( ឯវំ ស័ព្ទ មានអាការៈជាអត្ថ )

មែនពិត ដោយ **ឯវំ** ស័ព្ទ ដែលមានអាការៈជាអត្ថនេះ ព្រះថេរៈ សំដែង ថា "ព្រះតម្រាស់ របស់ព្រះសាស្ដា បរិបូណ៌ទៅដោយន័យផ្សេងៗ ជ្រាលជ្រៅទៅដោយធម៌ អត្ថ ទេសនា និងបដិវេធ ជាសភាវៈដែលសព្វសត្វទាំងឡាយ នឹងគប្បីចូលទៅកំណត់តាមសមគួរដល់ភាសារបស់រៀងៗខ្លួនបាន, អ្នកណាទៅនឹងអាចដើម្បីដឹងជាក់ច្បាស់ នូវព្រះតម្រាស់នោះ ដោយប្រការទាំងពួងបាន,

តាមពិតហើយ សូម្បីខ្ញុំ (អានន្ទ) ក៏បានស្តាប់មកហើយ ដោយអាការៈនោះ គឺ ទ្រទ្រង់ទុកបានហើយ ដោយវិធីនៃសោតវិញ្ញាណ ដែលមានសោតវិញ្ញាណជាប្រធាន " ។

## ( ឯវំ សព្ទ មាននិទស្សនៈជាអត្ថ )

ដោយ ឯវំ សព្ទ ដែលមាននិទស្សនៈជាអត្ថ ព្រះថេរៈសំដែងបង្ហាញ នូវព្រះសូត្រទាំងអស់ ដែលគួរពោល ក្នុងពេលនេះ ។ មែនពិត ព្រះថេរៈនោះ កាលនឹងរំដោះខ្លួនថា "ខ្ញុំមិនមែនជាព្រះសយម្ភូទេ, ព្រះសូត្រនេះសោត ក៏ខ្ញុំមិនបានធ្វើឲ្យជាក់ច្បាស់ដែរ" ដូច្នេះហើយ ទើបពោលថា "ខ្ញុំបានស្តាប់មកហើយ យ៉ាងដូច្នេះ" ។ អធិប្បាយថា "ព្រះសូត្រយ៉ាងនេះ គឺ នេះ បានដល់ ដែលកំពុងតែពោល ខ្ញុំបានស្តាប់មកហើយ " ។

## ( ឯវំ សព្ទ មានអវធារណៈជាអត្ថ )

ដោយ ឯវំ សព្ទ ដែលមានអវធារណៈជាអត្ថ ព្រះថេរៈសំដែងថា "ព្រះសូត្រនោះ មិនខ្វះ មិនលើស ដោយអត្ថ ឬ ដោយព្យញ្ជនៈ យ៉ាងដូច្នេះ គឺ មិនគប្បីឃើញ ដោយប្រការដទៃទៀត" ។ មែនពិត ព្រះថេរៈនោះ កាលនឹងសំដែង នូវកម្លាំងនៃការទ្រទ្រង់ចាំ

របស់ខ្លួន ញុំាងភាពជាអ្នកប្រាថ្នាដើម្បីនឹងស្តាប់ ឲ្យកើតឡើង ដល់សត្វទាំងឡាយ ទើបពោលថា "ខ្ញុំបានស្តាប់មកហើយ យ៉ាងដូច្នេះ" ។ អធិប្បាយថា "ព្រះសូត្រនោះ គឺខ្ញុំបានស្តាប់មកហើយ យ៉ាងដូច្នេះ គឺ ប្រាកដដូច្នេះឯង" ។

(៧) ២ បទថា "**ឯកំ សមយំ**" គឺ កាលមួយ, ឬក្នុងកាលមួយ ។ បទថា "**សាវត្ថិយំ**" គឺ ក្បែរនគរ ដែលបានឈ្មោះថា "សាវត្ថី" ព្រោះជាស្ថានទីនៅអាស្រ័យ របស់តាបសឥសីឈ្មោះសវត្ថៈ មកអំពីមុន ។ ក៏សត្តមីវិភត្តិ ក្នុងបទថា "**សាវត្ថិយំ**" នេះ ចុះក្នុងអត្ថនៃសមីបៈ ប្រែថា ក្បែរ ។ បទថា "**វិហរតិ**" គឺ ទ្រង់បំបាត់នូវសេចក្ដីលំបាក នៃឥរិយាបថ ១ ដោយឥរិយាបថមួយទៀត ទ្រង់នាំ គឺ ទ្រង់ញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅ មិនឲ្យទ្រុឌទ្រោម ។ បទថា "**ជេតវនេ**" គឺ ក្នុងវត្ត ដែលបានឈ្មោះថា "ជេតពន" ព្រោះជាព្រះឧទ្យាន របស់ព្រះរាជកុមារទ្រង់ព្រះនាមជេត ព្រោះភារៈនៃព្រះឧទ្យាននោះ គឺ ព្រះរាជកុមារទ្រង់ព្រះនាមជេត ទ្រង់បានដាំ និងទំនុកបំរុង ឲ្យចំរើនឡើងហើយ ។ បទថា "**អនាថបិណ្ឌិកស្ស**" គឺ របស់គហបតី ដែលបានឈ្មោះថា "អនាថបិណ្ឌិកៈ" ព្រោះមានដុំបាយ ដើម្បីពួកជនអនាថា ។ បទថា "**អារាមេ**" គឺ ក្នុងមហាវិហារ ដែលអនាថបិណ្ឌិកសេដ្ឋី

នោះ កសាងហើយ ដោយការបរិច្ចាគប្រាក់ ៥៤ កោដិ ។

(៨) ស័ព្ទ ថា "**អថ**" ជានិបាត ចុះក្នុងអត្ថ ថា មិនដាច់ខ្សែរយៈ ។ ស័ព្ទ ថា "**ខោ**" ជានិបាត ចុះក្នុងអត្ថថា សំដែងរឿងដទៃទៀត ។ ដោយស័ព្ទទាំង ២ យ៉ាងនោះ ព្រះថេរៈសំដែងបង្ហាញ ថា "រឿងដទៃទៀត បានកើតឡើងហើយ ក្នុងវិហារ របស់ព្រះដ៏មានព្រះភាគនោះ មិនដែលដាច់ខ្សែរយៈឡើយ" ។ ដើម្បីនឹងដោះស្រាយពាក្យសួរ ថា "រឿងដទៃទៀតនោះ គឺអ្វីទៅ ?" ព្រះថេរៈ ទើបពោល ថា "ទេវតាមួយអង្គ" ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទ ថា "**អញ្ញតរា**" គឺ មួយអង្គ ដែលមិនបានប្រាកដ ដោយនាមនិងគោត្រ ។ មែនពិត ពាក្យ ថា "**ទេវតា**" នោះ ជាឈ្មោះដែលទូទៅទាំងស្រ្តីទាំងបុរស ។ តែក្នុងទីនេះ បុរសប៉ុណ្ណោះឯង គឺព្រះថេរៈ ហៅថា "ទេវតា" ។ សេចក្ដីថា "ទេវបុត្រ" ក៏បាន ។

២ បទ ថា "**អភិក្កន្តាយ រត្តិយា**" គឺ កាលបើរាត្រីកាលពោលគឺបឋមយាម អស់ទៅហើយ ។ មែនពិត ក្នុងពាក្យ ថា "**អភិក្កន្តាយ រត្តិយា**" នេះ **អភិក្កន្តៈ** ស័ព្ទ ប្រព្រឹត្តទៅ ក្នុងអត្ថថា អស់ទៅ, **រត្តិ** ស័ព្ទ ប្រព្រឹត្តទៅ ក្នុងអត្ថថា បឋមយាម ដូចជាក្នុងប្រយោគទាំងឡាយ ថា "បពិត្រព្រះអង្គដ៏ចំរើន រាត្រី កន្លង

ទៅហើយ, បឋមយាម កន្លងផុតទៅហើយ" ដូច្នេះជាដើម ។

បទ ថា "**អភិក្កន្តវណ្ណា**" គឺ មានស្បែករូបល្អ ។ មែនពិត **អភិក្កន្ត** ស័ព្ទ ក្នុងពាក្យ ថា "**អភិក្កន្តវណ្ណា**" នេះ ចុះក្នុងអត្ថ ថា រូបល្អស្អាត ដូចក្នុងប្រយោគទាំងឡាយ ថា "អ្នកណា មានរូបល្អ ស្អាត ញុំាងទិសទាំងពួង ឲ្យភ្លឺស្វាង" ដូច្នេះជាដើម, **វណ្ណ** ស័ព្ទ ចុះក្នុងអត្ថ ថា ស្បែក ដូចក្នុងប្រយោគទាំងឡាយ ថា "ព្រះមានព្រះភាគ ទ្រង់មានព្រះឆវីវណ្ណ ដូចជាមាស" ដូច្នេះជាដើម ។

បទ ថា "**កេវលកប្បំ**" គឺ មិនមានសេសសល់ដោយជុំវិញ ។ មែនពិត ក្នុងពាក្យ ថា "**កេវលកប្បំ**" នេះ ការមិនមានចំណែកសេសសល់ ជាអត្ថនៃ **កេវល** ស័ព្ទ ដូចក្នុងប្រយោគទាំងឡាយ ថា "ព្រះដ៏មានព្រះភាគ ទ្រង់ប្រកាស នូវព្រហ្មចរិយធម៌ បរិសុទ្ធ បរិបូណ៌ សព្វគ្រប់" ដូច្នេះជាដើម, ភាវៈដោយជុំវិញ ជាអត្ថនៃ **កប្ប** ស័ព្ទ ដូចក្នុងប្រយោគទាំងឡាយ ថា "ញុំាងវត្តវេឡុវន ឲ្យភ្លឺស្វាងហើយ ដោយជុំវិញ" ដូច្នេះជាដើម ។

បទ ថា "**ឱភាសេត្វា**" គឺ ផ្សាយរស្មីទៅ, អធិប្បាយ ថា "ធ្វើឲ្យមានរស្មីតែមួយ ដូចជាព្រះចន្ទ និងព្រះអាទិត្យ ដូច្នោះ" ។

ច្រើនបទ ថា "**យេន ភគវា តេនុបសង្កមិ**" គឺ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងទីឯណា, ក៏ទៅហើយ ក្នុងទីនោះ ។

មែនពិត ២ បទ ថា "យេន តេន" នេះ ជាតតិយាវិភត្តិ ប្រើក្នុងអត្ថនៃសត្តមីវិភ័ត្តិ ។ ម្យ៉ាងទៀត អធិប្បាយ ថា "ព្រះមានព្រះភាគ គឺទេវតានិងមនុស្សទាំងឡាយ គប្បីចូលទៅគាល់ ដោយហេតុពោលគឺសេចក្តីប្រាថ្នានូវគុណវិសេស មានប្រការផ្សេងៗ ឯណា, ទេវតានោះ ក៏ចូលទៅគាល់ហើយ ដោយហេតុនោះ" ។

(៩) ពាក្យ ថា "**ឧបសង្កមិត្វា**" ជាពាក្យសំដែងនូវទីបញ្ចប់នៃការចូលទៅគាល់ ។ ម្យ៉ាងទៀត អធិប្បាយ ថា "ទេវតានោះ ទៅហើយ យ៉ាងដូច្នោះ, គឺ ទៅកាន់ទីស្ថាន ដែលរាប់ ថា ជិតព្រះសាស្តា ដែលជិតជាងនោះ" ។

បទ ថា "**អភិវាទេត្វា**" បានដល់ ក្រាបថ្វាយបង្គំហើយ ។

បទ ថា "**ឯកមន្តំ**" គឺ ឱកាសមួយ បានដល់ មួយខាង ។ បទ ថា "**ឯកមន្តំ**" នេះ ជានបុំសកលិង្គ សំដែងនូវភាវៈ (ជានបុំសកលិង្គជិតកិរិយា), មួយវិញទៀត ពាក្យនោះ ជាទុតិយាវិភ័ត្តិ ប្រើក្នុងអត្ថនៃសត្តមីវិភ័ត្តិ, អធិប្បាយ ថា "ក្នុងឱកាសមួយ" ។

បទ ថា "**អដ្ឋាសិ**" បានដល់ សម្រេចហើយ នូវការឈរ, អធិប្បាយ ថា "ជាអ្នកបានឈរនៅហើយ" ។

មែនពិត ទេវតាអ្នកឈរវៀរចាកទោស នៃការឈរ ៦ យ៉ាង គឺ ឈរនៅខាងក្រោយហួសពេក ១ ឈរនៅខាងមុខហួស

ពេក ១ ឈរនៅក្នុងទីជិតហួសពេក ១ ឈរនៅក្នុងទីឆ្ងាយហួសពេក ១ ឈរនៅក្នុងទីច្រាសខ្យល់ (លើខ្យល់) ១ ឈរនៅក្នុងប្រទេសដ៏ខ្ពស់ ១ ឈ្មោះថា ឈរនៅក្នុងទីដ៏សមគួរ ។ សួរថា "ក៏ព្រោះហេតុអ្វី ? ទើបទេវតានេះមិនអង្គុយ"។ ឆ្លើយថា "ព្រោះប្រាថ្នាចង់វិលត្រឡប់ទៅវិញយ៉ាងប្រញាប់"។ មែនពិតទេវតាទាំងឡាយ អាស្រ័យនូវហេតុឯណាមួយប៉ុណ្ណោះ ទើបមកកាន់មនុស្សលោក ដែលប្រៀបដូចជាទីសម្រាប់បន្ទោបង់ នូវវច្ចៈដែលពោរពេញទៅដោយរបស់ដែលមិនស្អាត, ក៏តាមប្រក្រតីហើយមនុស្សលោក រមែងជាទីស្ថានដែលបដិកូល ដល់ទេវតាទាំងឡាយនោះ ចាប់តាំងអំពីទី ១០០ យោជន៍ឡើងទៅ ព្រោះមនុស្សលោកនោះ មានក្លិនស្អុយ, ពួកទេវតាទាំងឡាយនោះ ទើបមិនត្រេកអរក្នុងមនុស្សលោកនោះ; ព្រោះហេតុនោះ ទេវតានេះទើបមិនអង្គុយព្រោះប្រាថ្នាដើម្បីនឹងធ្វើកិច្ច របស់អ្នកមកហើយ ប្រញាប់ប្រញាល់ត្រឡប់ទៅវិញ ។

## ( ទេវតាក្រាបទូលសួរបញ្ហា )

(១០) ទេវបុត្រនោះ ឈរនៅក្នុងទីដ៏សមគួរ យ៉ាងនោះហើយ បានឃើញ នូវទេវតា និង ព្រហ្មទាំងឡាយ ក្នុងមួយម៉ឺន

ចក្រវាល ដែលប្រជុំគ្នា ក្នុងចក្រវាលនេះ ហើយនិមិត្តអត្តភាពដ៏ល្អិតសុខុម ១០ ខ្លះ ២០ ខ្លះ ៣០ ខ្លះ ៤០ ខ្លះ ៥០ ខ្លះ ៦០ ខ្លះ ៧០ ខ្លះ ៨០ ខ្លះ មានទំហំប៉ុនឱកាស នៃចុងបំផុតដីខ្សាច់មួយដុំ ហើយឈររុំព័ទ្ធ នូវព្រះមានព្រះភាគ ព្រះអង្គទ្រង់ភ្លឺស្វាងកន្លង នូវពួកទេវតានិងព្រហ្មទាំងពួងនោះ ទ្រង់គង់នៅ លើអាសនៈ របស់ព្រះពុទ្ធដ៏ប្រសើរ ដែលបុគ្គលក្រាលទុកហើយ ព្រោះប្រាថ្នាដើម្បីនឹងស្តាប់នូវមង្គលបញ្ហា ដឹងនូវសេចក្តីត្រិះរិះនៃចិត្ត របស់មនុស្សទាំងឡាយអ្នកអាស្រ័យនៅក្នុងជម្ពូទ្វីប សូម្បីមិនបានមក ក្នុងសម័យនោះ ដោយចិត្ត ហើយក៏ក្រាបទូលសួរ នូវព្រះដ៏មានព្រះភាគ ដើម្បីដកកូនសរ គឺសេចក្តីសង្ស័យ របស់ពួកទេវតានិងមនុស្សទាំងពួង ។ ដោយហេតុនោះ ទើបព្រះអានន្ទត្ថេរ ពោលពាក្យ ថា " **ឯកមន្តំ ឋិតា ខោ សា** " ដូច្នេះជាដើម ។

## ( ឆន្ទលក្ខណៈ )

(១១) ក្នុងពាក្យ ថា " **ឯកមន្តំ ឋិតា ខោ សា** " នោះ មានវិនិច្ឆ័យ ថា ÷ ក្នុងអដ្ឋកថា លោកបានពោល ថា " បទ ថា '**គាថាយ**' មានសេចក្តី ថា ដោយពាក្យដែលពោលកំណត់យកនូវអក្ខរបទ ។ ក្នុងពាក្យ ថា " **អក្ខរបទំ** " នោះ មានសេចក្តី ថា

"អក្ខរៈ ក្នុងបទពោលគឺបាទ ឈ្មោះថា អក្ខរបទ" ដូច្នេះ ទើបត្រូវ ។

ពិតមែនដូច្នោះ ក្នុងគម្ពីរឆន្ទវុត្តិបទីប លោកពោលថា ÷

**"ការនិយម សូម្បីអក្ខរៈ ក្នុង ១ បាទ ឈ្មោះថា ឆន្ទលក្ខណៈ, ចំណែកការនិយមគរុនិងលហុ ក្នុង ៤ បាទ ឈ្មោះថា ព្រឹត្តិលក្ខណៈ" ។**

ម្យ៉ាងទៀត (ក្នុងពាក្យថា អក្ខរបទនោះ) មានសេចក្ដីថា "បទគឺអក្ខរៈ ឈ្មោះថា អក្ខរបទ" ដូច្នេះ ទើបត្រឹមត្រូវ ព្រោះលោកពោលទុកហើយ ក្នុងគម្ពីរសន្និពាលាវតារ ថា "ការនិយមអក្ខរៈ គប្បីឈ្មោះថា ឆ័ន្ទ, ការនិយមគរុនិងលហុ គប្បីឈ្មោះថា ព្រឹត្តិ" ដូច្នេះ និង លោកពោលទុកហើយ ក្នុងដីកានៃសន្និពាលាវតារនោះ ថា "ការនិយម គឺវិធីវិសេស ដែលលោកបានកំណត់ទុកហើយ ដោយអក្ខរៈទាំងឡាយនេះ គឺ **យ, រ, ត, ភ, ជ, ស, ម, ន,** ពោលគឺ **យជមាន** (អ្នកបូជា), **រវិ** (ព្រះអាទិត្យ), **តោយ** (ទឹក), **ភូមិ** (ផែនដី), **ជលន** (ភ្លើង), **សោម** (ព្រះច័ន្ទ), **មារុត** (ខ្យល់), **នភ** (អាកាស) គប្បីឈ្មោះថា **ឆ័ន្ទ** ព្រោះអត្ថវិគ្រោះថា 'បិទបាំងនូវទោស' ដូច្នេះ ការកំណត់ ដោយគរុ និង លហុទាំងឡាយ គប្បីឈ្មោះថា **ព្រឹត្តិ**

ព្រោះអត្ថវិគ្រោះ ថា "ជាគ្រឿងពោល (គាថា)" ដូច្នេះ ។ ក៏គណៈទាំងឡាយ ៨ រមែងបានឈ្មោះថា **យ** គណៈជាដើម ដោយអំណាចនៃអក្ខរៈទាំងឡាយ ៨ ឯណា, អក្ខរៈ ៨ មាន **យ** អក្ខរៈជាដើមនោះឯង លោកប្រកាន់យកហើយ ដោយស័ព្ទ ថា អក្ខរៈ ក្នុងបទ ថា "**អក្ខបទំ**" នេះ ។ ក្នុងការនិយម ២ យ៉ាង នោះ ការនិយមអក្សរ បានក្នុងវណ្ណព្រឹត្តិ, ក៏ក្នុងវណ្ណព្រឹត្តិនោះ **ម** គណៈ មានគរុ ៣, **ន** គណៈ មានលហុ ៣ ។ ចំណែកឯ ការនិយមគរុនិងលហុ រមែងបានក្នុងមាត្រាព្រឹត្តិ, ក៏ក្នុងមាត្រា-ព្រឹត្តិនោះ **ម** គណៈ មានគរុ ២, **ន** គណៈ មានលហុ ៤ ។ ចំណែកគណៈទាំងឡាយ ដែលសេសសល់ ក្នុងព្រឹត្តិទាំង ២ នោះ រមែងដូចគ្នាតែមួយ ដូច្នេះឯង ។

(១២) បទ ថា "**អជ្ឈភាសិ**" ប្រែថា បានពោលហើយ, សេចក្តី ថា "ក្រាបទូលសួរហើយ" ។ ឯស័ព្ទ ថា "**អធិ**" នោះ គ្រាន់តែជាឧបស័គ្គ ។

បទ ថា "**ពហូ**" គឺ មិនមែនតែមួយ ។

ទេវតា ដោយកំណើត មានទេវតាជាន់ចាតុមហារាជិកា ជាដើម ឈ្មោះថា ទេវតា ។

ពួកជនអ្នកអាស្រ័យនៅ ក្នុងជម្ពូទ្វីប ឈ្មោះថា មនុស្ស ។

បទ ថា "**មង្គលានិ**" មានសេចក្តីថា នូវហេតុនៃការដល់នូវសេចក្តីចំរើន ដោយសម្បត្តិគ្រប់បែបយ៉ាង ។ ដោយហេតុនោះ ក្នុងអដ្ឋកថា ទើបលោកពោលទុក ថា "សត្វទាំងឡាយ រមែងដល់ អធិប្បាយ ថា 'រមែងដល់ នូវសេចក្តីសម្រេច និង សេចក្តីចំរើន ដោយហេតុទាំងឡាយនេះ ព្រោះហេតុនោះ ហេតុទាំងឡាយនេះ ទើបឈ្មោះថា មង្គល' ដូច្នេះ" ។ សូម្បីក្នុងគម្ពីរសទ្ទនីតិ លោកពោលនូវសេចក្តីនៃធាតុ ថា "ក្នុងបទ ថា '**មង្គលំ**' នេះ **មគិ** ធាតុ ប្រព្រឹត្តទៅ ក្នុងការដល់" ដូច្នេះហើយ ទើបពោលបទកិរិយា ថា "**មង្គតិ**" ( ប្រែថា រមែងដល់ ) ។ ក៏ **មគិ** ធាតុ ជា ឥ ការន្ត ព្រោះហេតុនោះ ក្នុងការសម្រេចរូប ទើបចុះ និគ្គហិតអាគម ។

បទ ថា "**អចិន្តយុំ**" ប្រែថា បានគិតគ្នាហើយ ។

បទ ថា "**អាកង្ខមានា**" បានដល់ កាលប្រាថ្នា គឺត្រូវការ ។

បទ ថា "**សោត្ថានំ**" ប្រែថា នូវសេចក្តីសួស្តី, អធិប្បាយ ថា "នូវភាវៈនៃធម៌ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និង សម្បរាយភព ដែលល្អគ្រប់បែបយ៉ាងមាន" ។

(១៣) បទ ថា "**ព្រូហិ**" ប្រែថា សូមទ្រង់ត្រាស់ប្រាប់ គឺ សូមទ្រង់ត្រាស់សំដែង ។ បទ ថា "**ឧត្តមំ**" ប្រែថា វិសេស គឺ ប្រសើរ បានដល់ នាំប្រយោជន៍សុខមក ដល់លោកទាំងពួង ។

ក៏ក្នុងគាថាទូលសួរនេះ បណ្ឌិតគប្បីជ្រាបសន្និដ្ឋាន ថា “សេចក្ដីខុសផ្សេងពីគ្នានៃវចនៈ គឺទេវតាធ្វើហើយ ដោយអំណាចនៃការសំឡឹងនូវប្រភេទ ថា ‘មង្គលានិ’ ដូច្នេះ និង ដោយអំណាចការសំឡឹងនូវជាតិកំណើត ថា ‘មង្គលំ’ ដូច្នេះ ប្រៀបដូចជា សេចក្ដីខុសផ្សេងពីគ្នានៃវចនៈ ដែលស្ដេចសក្កទេវរាជ ទ្រង់បានធ្វើហើយ ដោយអំណាចការសំឡឹងដល់ប្រភេទនិងជាតិ ក្នុងកន្លះគាថានេះ ថា

“បពិត្រព្រះរាជឥសី សូមព្រះអង្គទ្រង់ជ្រើសយកព្រះពរចុះ, ទូលបង្គំ នឹងថ្វាយព្រះពរ ៨ ប្រការដល់ព្រះអង្គ” ដូច្នោះឯង ។

ចំណែកក្នុងអដ្ឋកថា លោកពោល ថា “ព្រះដ៏មានព្រះភាគសូម្បីទេវបុត្រ អារាធនាហើយ ដើម្បីឲ្យព្រះអង្គត្រាស់មង្គលមួយដោយពាក្យ ថា ‘សូមព្រះអង្គ ទ្រង់ត្រាស់សំដែង នូវមង្គលដ៏ឧត្ដម’ ដូច្នេះ ប៉ុន្តែទ្រង់ត្រាស់ ក្នុងគាថាមួយ ៣ មង្គល ប្រៀបដូចជាបុរសអ្នកមានអធ្យាស្រ័យដ៏ទូលំទូលាយ ត្រូវគេសុំតែបន្តិចបន្តួច ក៏ឲ្យ (គេ) ច្រើន យ៉ាងដូច្នោះឯង” ។

(១៤) គាថានេះ ឈ្មោះថា បឋ្យាវត្ត ។

សមដូចជាពាក្យ ដែលលោកពោលទុក ក្នុងគម្ពីរវុត្តោទ័យ ថា

"បឋ្យាវត្ត លោកពោលហើយ ដោយ ជ គណៈ ខាងមុខអំពី ៤ អក្សរ ក្នុងបាទគូទាំងឡាយ " ។

បណ្តាបទទាំងនោះ បទ ថា "សមេសុ" បានដល់ ក្នុងបាទគូទាំងឡាយ ពោលគឺបាទទី ២ និង បាទទី ៤ ។

បទ ថា "សិន្ធុតោ" គឺ បន្ទាប់អំពី ៤ អក្សរឡើងទៅ ។ ពាក្យ ថា "បន្ទាប់អំពី ៤ អក្សរឡើងទៅ "នុ៎ះ គ្រាន់តែជានិទស្សនៈ ព្រោះក្នុងបាទនៃគាថា ថា "មង្គលានិ អចិន្តយុំ" នេះ សំដែងនូវ ជ គណៈ សូម្បីអំពីតួអក្សរខាងដើម ។

បទ ថា "ជេន" ប្រែថា ដោយ ជ គណៈ ។

បទ ថា "បកិត្តិតំ" គឺ ពោលហើយ ។

គាថានោះ ឈ្មោះថា បឋ្យា ព្រោះជាវាចា ដែលបុគ្គលត្រូវពោល និង ឈ្មោះថា វត្ត ព្រោះជាវាចា ដែលបុគ្គលត្រូវរាយដោយចតុរាវត្ត ព្រោះហេតុនោះ ទើបឈ្មោះថា បឋ្យាវត្ត ។

ចំណែកក្នុងបាទដែលមិនមែនជាគូ ពោលគឺបាទទី ១ និង បាទទី ៣ ស គណៈ និង ន គណៈ បន្ទាប់អំពីអក្សរតួខាងដើមឡើងទៅ មិនមាន, គណៈដទៃទៀត លោកមិនបានហាមឡើយ ។

ពណ៌នាសេចក្តីនៃគាថាទូលសួរ ចប់ ។

## ពណ៌នាសេចក្ដីនៃគាថាទី ១

---

(១៥) ព្រះដ៏មានព្រះភាគ គឺទេវតាបុត្រនោះ ក្រាបទូលសួរយ៉ាងដូច្នេះហើយ កាលទ្រង់វិសជ្ជនានូវបញ្ហានោះ ទ្រង់បានត្រាស់នូវព្រះគាថាទាំងឡាយ ១០ ដែលសំដែងនូវមង្គល ៣៨ ប្រការ មានជាអាទិ៍ ថា "**អសេវនា ច ពាលានំ**" ដូច្នេះ ។ បណ្ដាគាថាទាំងនោះ ខ្ញុំនឹងពណ៌នាសេចក្ដីនៃគាថាទី ១ ជាមុនសិន ។

(១៦) ការមិនគប់រក ឈ្មោះថា **អសេវនា** ។ បទ ថា "**ពាលានំ**" បានដល់ នូវបុគ្គលពាលទាំងឡាយ ។ ឆដ្ឋីវិភ័ត្តិ ប្រើក្នុងកម្ម ។ សូម្បីក្នុងបាទទី ២ ក៏ន័យនេះ ដូចគ្នាដែរ ។

ការបូជា ឈ្មោះថា **បូជា** ។ បទ ថា "**បូជនីយានំ**" បានដល់ ដល់វត្ថុដែលគួរបូជាទាំងឡាយ ។ ចតុត្ថីវិភ័ត្តិ ប្រើក្នុងសម្បទាន ។ អាចារ្យពួកខ្លះពោល ថា "ឆដ្ឋីវិភ័ត្តិ ប្រើក្នុងកម្ម" ដូច្នេះក៏មាន ។

បទ ថា "**ឯតំ**" ជាដើម មានសេចក្ដីថា កិរិយាមិនសេពគប់នូវបុគ្គលពាលទាំងឡាយ ១ កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ ១ កិរិយាបូជាដល់វត្ថុដែលគួរបូជាទាំងឡាយ ១, កម្មទាំង ៣ យ៉ាង មានការមិនសេពគប់ជាដើមនេះ ជាមង្គលដ៏ឧត្ដម" ។

មានព្រះតម្រាស់ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ទុក ថា "ម្នាលទេវតា បញ្ហាកម្មឯណា ដែលអ្នកសួរហើយ ថា 'សូមព្រះអង្គទ្រង់ត្រាស់សំដែងនូវមង្គលដ៏ឧត្តម' ដូច្នេះ, ក្នុងបញ្ហាកម្មនោះ អ្នកចូរប្រកាន់យក ថា 'កម្មទាំង ៣ យ៉ាង មានការមិនសេពគប់នូវបុគ្គលពាលទាំងឡាយ ជាដើមនោះ ជាមង្គលដ៏ឧត្តម' ដូច្នេះ" ។

សេចក្ដីសង្ខេប ក្នុងគាថាទី ១ នេះ មានតែប៉ុណ្ណេះ ។

ឯសេចក្ដីពិស្ដារ ក្នុងគាថាទី ១ នេះ មានដូចតទៅនេះ ÷

❀

❀ ❀

## ពណ៌នាការសេពនិងមិនសេពពាលនិងបណ្ឌិត

(១៧) ការមិនគប់រក ការមិនមានបុគ្គលពាលនោះជាសំឡាញ់ ការមិនចូលជាពួកជាមួយនឹងបុគ្គលពាលនោះ ឈ្មោះថា កិរិយាមិនសេពគប់ ។ សត្វទាំងឡាយ ឯណាមួយ ជាអ្នកប្រកបដោយអកុសលកម្មបថ ១០ មានបាណាតិបាតជាដើម, សត្វទាំងឡាយនោះ ឈ្មោះថា ពាល ។ មួយវិញទៀត គ្រូទាំងឡាយ ៦ នាក់នេះ គឺ បូរណ កស្សប, មក្ខលិ គោសាល, និគ្រន្ថ នាដបុត្រ, សញ្ជ័យ វេលដ្ឋបុត្រ, បកុទ្ធ កច្ចាយនៈ, អជិត កេសកម្ពល, និងបាបបុគ្គលទាំងឡាយ ដទៃទៀតក្រៅពីគ្រូទាំង ៦ នោះ មានភិក្ខុទេវទ័ត និង កោកាលិកភិក្ខុជាដើម គប្បីជ្រាបថា "បុគ្គលពាល" ។ មែនពិត ពួកបុគ្គលពាលទាំងអស់នោះឯង លោកហៅថា "ពាល" ព្រោះមិនរស់នៅ ដោយការរស់នៅដែលប្រកបដោយបញ្ញា រស់នៅដោយហេតុត្រឹមតែការដកដង្ហើម ។ ដោយហេតុនោះ ក្នុងអដ្ឋកថា ទើបលោក ពោលថា "ជនទាំងឡាយឯណា រស់នៅ អធិប្បាយថា ចិញ្ចឹមជីវិតនៅ ដោយហេតុត្រឹមតែការដកដង្ហើមចេញ-ចូល, មិនមែនរស់នៅ ដោយការរស់នៅប្រកបដោយបញ្ញាដ៏ប្រសើរឡើយ, ហេតុនោះ ជនទាំងឡាយនោះ ទើបឈ្មោះថាជនពាល" ។ សូម្បីក្នុងគម្ពីរសទ្ទនីតិ ក៏លោកពោលហើយ ថា

“ពល ធាតុ ប្រព្រឹត្តទៅ ក្នុងអត្ថថា ប្រាណ, ប្រាណ គឺការរស់នៅ និងការដកដង្ហើម; បុគ្គលឯណា តែងរស់នៅ គឺ ដកដង្ហើមចូល និង ដកដង្ហើមចេញ, មានពាក្យដែលលោកពោលទុក ថា ‘ចិញ្ចឹមជីវិត ដោយហេតុត្រឹមតែការដកដង្ហើមចូល-ចេញ, មិនមែនរស់នៅ ដោយការរស់នៅប្រកបដោយបញ្ញា ដ៏ប្រសើរឡើយ’ ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា បុគ្គលពាល” ។

## ( លក្ខណៈរបស់ជនពាល )

ចំណែកលក្ខណៈរបស់បុគ្គលពាល គប្បីជ្រាប ដោយអំណាចនៃទុច្ចរិត មានការគិតនូវរឿងដែលគិតមិនល្អជាដើម ។ មែនពិតបុគ្គលពាល សូម្បីកាលគិត ក៏រមែងគិត តែរឿងដែលគិតមិនល្អដោយអំណាច នៃអភិជ្ឈា ព្យាបាទ និងមិច្ឆាទិដ្ឋិ តែប៉ុណ្ណោះឯង, សូម្បីកាលនិយាយ ក៏រមែងនិយាយចំពោះតែពាក្យ ដែលនិយាយអាក្រក់ ផ្សេងដោយវចីទុច្ចរិត មានមុសាវាទជាដើម ប៉ុណ្ណោះឯង, សូម្បីកាលធ្វើ ក៏រមែងធ្វើចំពោះតែកម្ម ដែលធ្វើអាក្រក់ ដោយអំណាចនៃកាយទុច្ចរិត មានបាណាតិបាតជាដើម ប៉ុណ្ណោះឯង ។ ព្រោះហេតុនោះ ទុច្ចរិតទាំងឡាយ មានការគិតរឿងដែលគិតមិនល្អជាដើម របស់បុគ្គលនោះ ទើបលោកហៅ ថា “ពាលលក្ខណៈ”

ព្រោះវិគ្រោះ ថា "បុគ្គលពាល ជាហេតុដែលបុគ្គលកំណត់ គឺដឹងបាន" ដូច្នេះ, ហៅថា "ពាលនិមិត្ត" ព្រោះជាហេតុនៃការស្គាល់ច្បាស់នូវបុគ្គលពាល និង ហៅថា "ពាលាបទាន" ព្រោះបុគ្គលពាលប្រព្រឹត្តមិនដែលខាន ។

ដោយហេតុនោះ ក្នុងពាលបណ្ឌិតសូត្រ ក្នុងឧបរិបណ្ណាសកៈ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា "ម្នាលភិក្ខុទាំងឡាយ ពាលលក្ខណៈ ពាលនិមិត្ត ពាលាបទាន របស់បុគ្គលពាល មាន ៣ ប្រការនេះ, មាន ៣ ប្រការ គឺអ្វីខ្លះ ?, ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល ក្នុងលោកនេះ រមែងជាអ្នកគិតតែរឿងដែលគិតអាក្រក់, និយាយតែពាក្យដែលនិយាយអាក្រក់ និង ធ្វើតែកម្មដែលធ្វើអាក្រក់" ដូច្នេះ ។

(១៨) សត្វទាំងឡាយ ឯណាមួយ ជាអ្នកប្រកបដោយកុសលកម្មបថ ១០ មានការវៀរចាកការសម្លាប់សត្វជាដើម, សត្វទាំងឡាយនោះ ឈ្មោះថា បណ្ឌិត ។ ម្យ៉ាងទៀត ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះមហាសាវក ៨០ ព្រះសាវករបស់ព្រះតថាគតទាំងឡាយដទៃទៀត និង គ្រូសុនេត្រ និង អកិត្តិតាបសជាដើម ក្នុងអតីតកាល គប្បីជ្រាប ថា "ជាបណ្ឌិត" ។ អ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើម ទាំងអស់នោះ លោកហៅថា "ជាបណ្ឌិត"

ព្រោះធ្វើដំណើរទៅ ក្នុងប្រយោជន៍ទាំងឡាយ ដោយបញ្ញាគតិ ។ ដោយហេតុនោះ ក្នុងអដ្ឋកថា ទើបលោកពោលថា “ជនទាំងឡាយណា ទៅ អធិប្បាយថា ‘ធ្វើដំណើរទៅ ក្នុងប្រយោជន៍ទាំងឡាយដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្ន និង សម្បរាយិកភព ដោយញាណគតិ’ ព្រោះហេតុនោះ ជនទាំងឡាយនោះ ទើបឈ្មោះថា បណ្ឌិត” ។ សូម្បីក្នុងគម្ពីរសទ្ទនីតិ លោកក៏បានពោលទុក ថា “**បឌិ** ធាតុប្រព្រឹត្តទៅ ក្នុងកិរិយាទៅ, បញ្ញាឯណា រមែងទៅ គឺ ធ្វើដំណើរទៅ ក្នុងប្រយោជន៍ទាំងឡាយ សូម្បីដ៏ល្អិតសុខុម គឺ ដឹងនូវអាការៈសូម្បីមានជាអាទិ៍ គឺការបៀតបៀន នូវអរិយសច្ច មានសេចក្ដីទុក្ខជាដើម ហេតុនោះ បញ្ញានោះ ទើបឈ្មោះថា បណ្ឌា, បុគ្គលណាទៅ គឺ ធ្វើដំណើរទៅ បានដល់ ប្រព្រឹត្តទៅ ដោយបញ្ញាដែលមានឈ្មោះថា បណ្ឌា ហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា បណ្ឌិត, ម្យ៉ាងទៀត បញ្ញាដែលមានឈ្មោះថា បណ្ឌា របស់បុគ្គលនេះកើតព្រមហើយ ព្រោះហេតុនោះ បុគ្គលនេះ ទើបឈ្មោះថា បណ្ឌិត, បុគ្គលឯណា ទៅ គឺ ធ្វើដំណើរទៅ ដោយញាណគតិ ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា បណ្ឌិត” ។

( លក្ខណៈរបស់បណ្ឌិត )

ចំណែកលក្ខណៈ របស់បណ្ឌិត គប្បីជ្រាប ដោយអំណាច

នៃសុចរិតទាំងឡាយ មានការគិតនូវរឿងដែលគិតល្អជាដើម ដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុក ក្នុងពាលបណ្ឌិតសូត្រ យ៉ាងដូច្នេះថា " ម្នាលភិក្ខុទាំងឡាយ បណ្ឌិតលក្ខណៈ បណ្ឌិតនិមិត្ត បណ្ឌិតាបទាន របស់បណ្ឌិត មាន ៣ យ៉ាងនេះ, មាន ៣ យ៉ាង គឺអ្វីខ្លះ ?, ម្នាលភិក្ខុទាំងឡាយ បណ្ឌិត ក្នុងលោកនេះ រមែងជាអ្នកគិតតែរឿងដែលគិតល្អ ជាអ្នកនិយាយតែពាក្យដែលល្អ និងជាអ្នកធ្វើតែកម្មដែលល្អ " ដូច្នេះ ។ ក៏ពាក្យថា "សុចិន្តិតចិន្តី" ដូច្នេះជាដើម បណ្ឌិតគប្បីប្រកប ដោយអំណាចនៃសុចរិត មានមនោសុចរិតជាដើម ដូច្នេះឯង ។

(១៩) ន័យដទៃទៀត ។ ជនទាំងឡាយឯណា រមែងបានទទួល នូវប្រយោជន៍ទាំងឡាយ ២ គឺ ប្រតិបត្តិដើម្បីបានទទួលនូវប្រយោជន៍ទាំង ២ នោះ, ជនទាំងឡាយនោះ ឈ្មោះថាបណ្ឌិត ព្រោះព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ក្នុងឧភោអត្ថសូត្រ ក្នុងកោសលសំយុត្ត យ៉ាងដូច្នេះ ថា ÷

" ធីរជន លោកហៅថា 'បណ្ឌិត' ព្រោះទាញ
យកប្រយោជន៍ (ទាំង ២) បាន គឺ ប្រយោជន៍
ក្នុងបច្ចុប្បន្ន និងប្រយោជន៍ក្នុងសម្បរាយភព " ។

ជនទាំងឡាយឯណា កាត់ចោលនូវប្រយោជន៍ទាំង ២ យ៉ាង កាន់យក នូវហេតុដែលមិនមែនជាប្រយោជន៍ទាំង ២ យ៉ាង, ជនទាំងឡាយនោះ ឈ្មោះថា ពាល ។ មែនពិត ជនទាំងឡាយនោះ លោកហៅថា "ពាល" ក៏ព្រោះកាន់យកនូវហេតុដែលមិនមែនជាប្រយោជន៍ទាំងឡាយ ២ ប្រការ និង លោកហៅថា "ពាល" ក៏ព្រោះកាត់ផ្ដាច់ចោល នូវប្រយោជន៍ទាំងឡាយ ២ ប្រការ ។ កិរិយាស័ព្ទ ថា "**លន្តិ**" នោះ ចាត់ចូលក្នុងពួកធាតុ មាន **ភូ** ធាតុជាដើម ដោយការបង្គាប់ ថា "**លា** ធាតុ មាន **ទិ** ស័ព្ទ ជាបទប្រៀបធៀប ប្រព្រឹត្តទៅ ក្នុងអត្ថ ថា កាន់យក"។ កិរិយាស័ព្ទ ថា "**លុនន្តិ**" នោះ ចាត់ចូលក្នុងពួកធាតុ មាន **កី** ធាតុ ជាដើម ដោយការបង្គាប់ ថា "**លុ** ធាតុ មាន **ទិ** ស័ព្ទ ជាបទប្រៀបធៀប ប្រព្រឹត្តទៅ ក្នុងអត្ថ ថា កាត់ចោល" ដូច្នេះ ។

## ( បុគ្គលដែលគួរសេពគប់ និងមិនគួរសេពគប់ )

(២០) បណ្ដាជនពាលនិងបណ្ឌិតទាំង ២ ពួកនោះ ពួកបណ្ឌិតប៉ុណ្ណោះ គឺបុគ្គលត្រូវសេពគប់, ពួកជនពាល គឺបុគ្គលមិនត្រូវសេពគប់ឡើយ; ព្រោះពួកជនពាល ប្រៀបដូចជាត្រីស្អុយ, បុគ្គលអ្នកសេពគប់ជាមួយជនពាលនោះ ប្រៀបដូចជាស្លឹកឈើដែល

សម្រាប់ខ្ចប់នូវគ្រឿងស្អុយ ដល់នូវភាពជាអ្នក គឺពួកវិញ្ញូជនគប្បីបោះបង់ចោល និងស្អប់ខ្ពើម ។ (ចំណែក) បណ្ឌិត ប្រៀបដូចជាភ័ណ្ឌៈសម្រាប់វេចខ្ចប់ នូវគ្រឿងក្រអូប មានក្រស្នា និង មាលាជាដើម, បុគ្គលអ្នកសេពគប់ជាមួយនឹងបណ្ឌិតនោះ ក៏ប្រៀបដូចជាស្លឹកឈើដែលសម្រាប់ខ្ចប់ នូវគ្រឿងក្រអូប មានក្រស្នា និង មាលា ជាដើម ដល់នូវភាពជាអ្នកគួរសរសើរ និង គួរជាទីពេញចិត្ត នៃពួកវិញ្ញូជន ។ ក៏បុគ្គលណា សេពគប់នូវបុគ្គលណា, បុគ្គលនោះ រមែងមានបុគ្គលនោះជាគតិ ដោយពិត ។ ប៉ុន្តែដើម្បីនឹងសំដែង នូវសេចក្តីនេះ គប្បីពណ៌នារឿងកូនសត្វសេកជាដើម ( ដូចតទៅនេះ ) ÷

## ( រឿងកូនសត្វសេក )

(២១) បានឮមកថា ក្នុងអតីតកាល បានមានកូនសត្វសេក ២ បងប្អូននឹងគ្នា (នៅ) ក្នុងព្រៃរកា ក្បែរសានុបពិត ។ ក៏ក្នុងទីលើខ្យល់ នៃបព្វតា បានមានផ្ទះជាទីនៅអាស្រ័យ របស់ចោរ ៥០០ នាក់, ក្នុងទីខាងក្រោមខ្យល់ មានអាស្រមជាទីនៅអាស្រ័យ របស់តាបសឥសី ៥០០ រូប ។ ក្នុងពេលដែលរោមស្លាប របស់កូនសត្វសេកទាំងឡាយ មិនទាន់ដុះនៅឡើយ ក៏មានខ្យល់ព្យុះកំបុតត្បូងកើតឡើងហើយ ។ កូនសេកទាំង ២ នោះ

ត្រូវខ្យល់ព្យុះកំបុតត្បូងនោះ ផាត់ទៅធ្លាក់ហើយ (ក្នុងទី) ផ្សេង ៗ ពីគ្នា ។ បណ្ដាកូនសេកទាំង ២ នោះ កូនសេក ១ បានធ្លាក់ទៅក្នុងចន្លោះនៃគ្រឿងសស្ត្រាវុធ ក្នុងផ្ទះរបស់ចោរ ព្រោះធ្លាក់ទៅក្នុងទីនោះ ទើបពួកចោរដាក់ឈ្មោះ ថា "សត្តិគុម្ពៈ" ធាត់ធំឡើងហើយ ក្នុងចន្លោះនៃពួកចោរទាំងនោះ ។ កូនសេក ១ បានធ្លាក់ទៅក្នុងចន្លោះនៃផ្កាឈើ លើផ្ទៃនៃវាលដីខ្សាច់ ក្បែរអាស្រម ព្រោះហេតុដែលធ្លាក់ទៅ ក្នុងទីនោះ ទើបបានពួកតាបសឥសី ដាក់ឈ្មោះឲ្យ ថា "បុប្ផកៈ" បានធាត់ធំឡើងហើយ ក្នុងចន្លោះនៃពួកតាបសឥសីទាំងនោះ ។

ក្នុងគ្រានោះ ព្រះរាជាទ្រង់ព្រះនាម បញ្ចាលៈ ក្នុងនគរឈ្មោះឧត្តរបញ្ចាលៈ ទ្រង់ប្រដាប់គ្រឿងអលង្ការសព្វគ្រប់ហើយ ទ្រង់ស្ដេចយាងឡើងកាន់ព្រះរាជរថ យាងទៅកាន់ព្រៃ ដើម្បីទ្រង់បរបាញ់សត្វហើយ ទ្រង់មានព្រះរាជឱង្ការ ថា "សត្វម្រឹគ រត់ចេញទៅ តាមប្រឡោះ នៃបុគ្គលណា, បុគ្គលនោះឯង នឹងត្រូវមានទោស (អាជ្ញា)" ដូច្នេះហើយ ទ្រង់ស្ដេចយាងចុះអំពីព្រះរាជរថ ទ្រង់បានគង់កាន់ធ្នូ ក្នុងទីកំបាំងហើយ ។

ក្នុងខណៈនោះ ម្រឹគទ្រាយ ១, កាលបើពួកមនុស្សកំពុងវាយគុម្ពោតព្រៃ, ក៏បានក្រោកឡើង សំឡឹងរកមើលផ្លូវដើម្បី

នឹងទៅ ក៏ឃើញថាទីស្ថានដែលព្រះរាជាទ្រង់គង់នៅប៉ុណ្ណោះ ជាទីដែលស្រឡះ (ទំនេរ) ទើបបែរមុខឆ្ពោះទៅទិសខាងនោះ ហើយស្ទុះបោលគេចទៅ ។ ពួកមនុស្ស ក៏បានធ្វើការចំអក ជាមួយនឹងព្រះរាជាហើយ ។ ព្រះអង្គ ទ្រង់តាំងព្រះទ័យ ថា "អញនឹងចាប់ម្រឹគទ្រាយនោះឱ្យបាន ក្នុងពេលឥឡូវនេះ" ហើយ ទើបស្តេចទ្រង់ឡើងរាជរថ ហើយទ្រង់ដេញតាមម្រឹគទ្រាយទៅ យ៉ាងលឿន ។ ពួកបុរស មិនអាចតាមជាប់ព្រះអង្គបានឡើយ ។ ព្រះរាជាទ្រង់មាននាយសារថីជាគម្រប់ ២ ទតមិនឃើញម្រឹគទ្រាយហើយ ទើបទ្រង់ស្តេចយាងត្រឡប់មកវិញ ទ្រង់ស្រង់ទឹកនិងសោយទឹក ក្នុងជ្រោះភ្នំដែលជាទីគួរមនោរម្យហើយ ស្តេចទ្រង់បន្ទំ ក្រោមម្លប់ឈើក្បែរផ្ទះនៃចោរ ។

គ្រានោះ ពួកចោរ ក៏បានចូលទៅកាន់ព្រៃទាំងអស់គ្នាហើយ, ខាងក្នុងផ្ទះ នៅសល់តែសេកឈ្មោះសត្តិគុម្ពៈ ជាមួយនឹងអ្នកចំអិនភ័ត្តម្នាក់ ។ សេកសត្តិគុម្ពៈ ហើរចេញពីផ្ទះ ឃើញព្រះរាជាទ្រង់ព្រះបន្ទំ យ៉ាងដូច្នោះហើយ ក៏ (ហើរ) ចូលផ្ទះ បាននិយាយជាភាសាមនុស្ស ជាមួយនឹងអ្នកដាំស្ល ថា "ពួកយើង នឹងសម្លាប់ព្រះរាជាចោល ប្រមូលយកសំពត់និង គ្រឿងអលង្ការ របស់ព្រះអង្គ ហើយចាប់ព្រះអង្គ ត្រង់កព្រះបាទ ទាញអូសមកហើយ យក

ស្លឹកឈើទាំងឡាយ មកគ្របបិទបាំង ក្នុងទីកន្លែងមួយ"។ ព្រះរាជា ទ្រង់តើនពីព្រះបន្ទំហើយ ទ្រង់ព្រះសណ្តាប់សំឡេងនោះ ទ្រង់ជ្រាប ថា "ទីកន្លែងនេះ មានភ័យចំពោះមុខ" ហើយ ទ្រង់មានព្រះទ័យ ភ័យខ្លាច ទើបទ្រង់ស្តេចឡើងកាន់រាជរថ ហើយទ្រង់ចៀសចេញ ពីទីនោះ ស្តេចយាងទៅដល់អាស្រម របស់តាបសឥសីហើយ ។

ក្នុងគ្រានោះ ពួកតាបសឥសី ទៅហើយ ដើម្បីប្រយោជន៍ ដល់ផលាផល, ក្នុងអាស្រម នៅសល់តែសត្វសេកឈ្មោះ បុប្ផកៈ ប៉ុណ្ណោះ ។ សត្វសេកឈ្មោះ បុប្ផកៈនោះ ឃើញព្រះរាជា ហើយ ក៏បានធ្វើនូវបដិសណ្ឋារៈ ដោយន័យមានជាអាទិ៍ ថា ÷

(២២) "បពិត្រព្រះមហារាជ ព្រះអង្គទ្រង់ស្តេច[១]
យាងមកប្រពៃហើយ, មួយទៀត ព្រះរាជ
ដំណើរ របស់ព្រះអង្គ មិនមែនទាស់ទេ" ។

ព្រះរាជា ទ្រង់មានព្រះទ័យជ្រះថ្លា ក្នុងបដិសណ្ឋារៈ របស់សត្វសេកឈ្មោះ បុប្ផកៈនោះហើយ ទ្រង់ត្រាស់សរសើរ នូវ សេកឈ្មោះបុប្ផកៈ ទ្រង់បានតិះដៀល នូវសេកឈ្មោះសត្តិគុម្ពៈ ក្រៅនេះ ដោយព្រះតម្រាស់ ថា ÷

---

១ ត្រៃបិដក ភាគទី ៦០ / ទំព័រទី ៩៩ ។

"សត្វបក្សី ទ្វិជាតិនេះ ជាសត្វដ៏ល្អ ប្រកបដោយ(១)
ធម៌ដ៏ក្រៃលែង តើហ្ន៎, ចំឡែកតែបក្សីសេក
ក្រៅពីនេះនុ៎ះ និយាយតែពាក្យអាក្រក់ " ។

សេកឈ្មោះ បុប្ផកៈ ស្តាប់នូវព្រះរាជឱង្ការនោះហើយ ទើបបានក្រាបទូលថា "បពិត្រព្រះមហារាជ ទូលព្រះបង្គំ មានមាតាជាមួយគ្នា នឹងសត្វសេកសត្តិគុម្ពៈនោះ, ប៉ុន្តែសេកសត្តិគុម្ពៈនោះធាត់ធំឡើងហើយ ក្នុងសំណាក់នៃពួកមនុស្សមិនល្អ ត្រូវពួកមនុស្សមិនល្អទាំងនោះ ដឹកនាំហើយ ដោយចោរធម៌, (ចំណែក) ទូលព្រះបង្គំ ធាត់ធំឡើងហើយ ក្នុងសំណាក់នៃពួកមនុស្សល្អ ត្រូវបានពួកមនុស្សល្អទាំងនោះ ដឹកនាំហើយ ដោយឥសីធម៌, ហេតុនោះទើបទូលព្រះបង្គំទាំង ២ ផ្សេងពីគ្នា ដោយធម៌ " ដូច្នេះហើយកាលសំដែងធម៌ ដល់ព្រះរាជា ទើបបានពោលគាថាទាំងនេះ ថា ÷

(២៣) "បពិត្រព្រះរាជា ពិតណាស់ បុគ្គល
គប់រកនូវបុគ្គលបែបណាៗ ទោះជាសប្បុរស
ឬអសប្បុរស មានសីល ឬឥតសីល រមែង
លុះអំណាចបុគ្គលនោះឯង ។ បុគ្គលធ្វើ

១ ត្រៃបិដក ភាគទី ៦០ / ទំព័រទី ១០០ _ ១០១ ។

បុគ្គលបែបណា ឲ្យជាមិត្រ និង ចូលទៅគប់រក នូវបុគ្គលបែបណា, បុគ្គលនោះ ក៏មានអាការៈ បែបនោះដែរ, ព្រោះកិរិយានៅរួម ក៏រមែង ប្រាកដដូច្នោះ ។ អាចារ្យ ត្រូវកូនសិស្សគប់រក រមែងប្រឡាក់ នូវកូនសិស្សអ្នកគប់រក ត្រូវកូន សិស្សប៉ះពាល់ហើយ រមែងប្រឡាក់កូនសិស្ស អ្នកប៉ះពាល់ ដែលមិនបានប្រឡាក់ហើយ ប្រៀប ឧបមាដូចជា កូនសរដែលជ្រលក់ ដោយថ្នាំពិស តែងប្រឡាក់បំពង់សរ ដូច្នោះឯង, ព្រោះ ភ័យខ្លាចអំពីការប្រឡាក់ អ្នកប្រាជ្ញ ទើបមិនយក បុគ្គលពាលមកជាសំឡាញ់សោះឡើយ ។ ជនណា ខ្ចប់នូវត្រីស្អុយ ដោយចុងស្បូវភ្លាំង, សូម្បី ស្បូវភ្លាំង ក៏មានក្លិនស្អុយ ផ្សាយចេញទៅដែរ យ៉ាងណាមិញ, ការចូលទៅសេពគប់ នូវបុគ្គល ពាល (របស់ជននោះ) ក៏យ៉ាងដូច្នោះដែរ ។ ជនណា ខ្ចប់ខ្លឹមក្រស្នា ដោយស្លឹកឈើ, សូម្បី ស្លឹកឈើ ក៏មានក្លិនក្រអូប ផ្សាយចេញទៅដែរ យ៉ាងណាមិញ, ការចូលទៅសេពគប់ នូវអ្នក

ប្រាជ្ញ (របស់ជននោះ) ក៏យ៉ាងដូច្នោះដែរ ។ ព្រោះហេតុនោះ បុគ្គលជាបណ្ឌិត ដឹងច្បាស់នូវបញ្ញាចាស់ទុំ របស់ខ្លួន ដូចជាកញ្ចប់ស្លឹកឈើហើយ មិនគួរសេពគប់ នូវពួកអសប្បុរស គួរសេពគប់តែពួកសប្បុរស, (ត្បិត) ពួកអសប្បុរសតែងនាំទៅកាន់នរក, ពួកសប្បុរស តែងផ្ដល់នូវសុគតិ " ។

(២៤) បណ្ដាបទទាំងនោះ បទ ថា "**សន្តោ**" បានដល់ សប្បុរស ។ បទ ថា "**អសំ**" បានដល់ អសប្បុរស ។ បទ ថា "**សេវមានោ**" បានដល់ អាចារ្យ ។ បទ ថា "**សេវមានំ**" បានដល់ អន្តេវាសិក ។ បទ ថា "**សម្ផុដ្ឋោ**" បានដល់ អាចារ្យ ដែលអន្តេវាសិកពាល់ត្រូវហើយ ។ ២ បទ ថា "**សម្ផុសំ បរំ**" បានដល់ បុគ្គលដទៃ គឺ អន្តេវាសិកដែលប៉ះពាល់ នូវអាចារ្យ ។ បទ ថា "**អលិត្តំ**" មានសេចក្ដីថា អាចារ្យនោះ រមែងប្រឡាក់ នូវអន្តេវាសិកនោះ ជាអ្នកដែលបាបធម៌ មិនបានប្រឡាក់ហើយ ប្រៀបដូចជា កូនសរដែលកំណាច គឺ ដែលជ្រលក់ហើយ ដោយថ្នាំពិស ប្រឡាក់នូវបំពង់សរ ដែលមិនបានប្រឡាក់ យ៉ាងដូច្នោះឯង ។

ពិតណាស់ បុគ្គលអ្នកសេពគប់នូវបុគ្គលពាល សូម្បីមិនបានធ្វើនូវអំពើអាក្រក់ ក៏រមែងបានទទួល នូវការពោលតិះដៀល និងការនិន្ទា ថា "ជាអ្នកសេពគប់ជាមួយនឹងបុគ្គលពាល" ដូច្នេះដែរ, ហេតុនោះ ទើបសេកបុប្ផកៈពោល ថា "**ឯវំ ពាលូបសេវនា**" ។ ( ចំណែក ) បុគ្គលអ្នកសេពគប់ជាមួយនឹងអ្នកប្រាជ្ញ សូម្បីមិនអាចដើម្បីនឹងកើតជាអ្នកប្រាជ្ញបាន ក៏រមែងបានទទួល នូវឈ្មោះសំឡេងដ៏ល្អ ថា "ជាអ្នកសេពគប់ជាមួយនឹងកល្យាណមិត្រ" ដូច្នេះដែរ, ហេតុនោះ ទើបសេកបុប្ផកៈពោល ថា "**ឯវំ ធីរូបសេវនា**" ។

បទ ថា "**បត្តបុដស្សេវ**" គឺ ដូចជាស្លឹកឈើដែលសម្រាប់ខ្ចប់នូវគន្ធជាតិ មានក្រស្នាជាដើមនុ៎ះឯង ។

បទ ថា "*សម្បាកំ*" គឺ ដឹងថា ខ្លួនអប់រំហើយ ដោយអំណាចនៃការជាប់ជំពាក់ ជាមួយនឹងកល្យាណមិត្រ ។

បទ ថា "**សន្តោ**" មានសេចក្តីថា ពួកជនជាសម្មាទិដ្ឋិរមែងញ៉ាំងពួកសត្វ ដែលអាស្រ័យខ្លួន ឲ្យដល់ឋានសួគ៌តែម្យ៉ាង ។

ព្រះរាជា ទ្រង់ជ្រះថ្លាហើយ ក្នុងធម្មកថា របស់សត្វសេកបុប្ផកៈនោះ ទ្រង់ថ្វាយបង្គំនូវពួកតាឥសី ដែលត្រឡប់មកវិញហើយ ទ្រង់មានព្រះរាជឱង្ការ ថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើនទាំងឡាយ បើព្រះគុណម្ចាស់ទាំងឡាយ អនុគ្រោះយើងខ្ញុំ ក៏សូម

គង់នៅក្នុងព្រះនគរ របស់យើងខ្ញុំចុះ” ដូច្នេះហើយ ក៏ស្តេចយាង ទៅកាន់ព្រះនគរ ទ្រង់ព្រះរាជទានអភ័យ ដល់សត្វសេកទាំងឡាយ ហើយ ទ្រង់ត្រាស់ឲ្យគណៈតាភសី ដែលមកហើយ ក្នុងព្រះនគរនោះ នៅក្នុងព្រះរាជឧទ្យាន ទ្រង់បានទំនុកបំរុង រហូតអស់ព្រះជន្មាយុ ហើយ ទ្រង់បំពេញផ្លូវទៅកាន់ឋានសួគ៌ ។ ចំណែកសត្វសេក បុប្ផកៈ អាស្រ័យនៅ ក្នុងព្រៃ ទៅតាមយថាកម្មហើយ ។

រឿងសត្វសេក ក្នុងអដ្ឋកថាសត្តិគុម្ពជាតក ក្នុងវីសតិនិបាត ចប់ ។

## ( រឿងដំរី ឈ្មោះ មហិឡាមុខ )

(២៥) ក្នុងអតីតកាល ព្រះរាជាព្រហ្មទ័ត ក្នុងព្រះនគរ ពារាណសី បានមានដំរីមង្គល ឈ្មោះ មហិឡាមុខ ជាសត្វមានសីល បរិបូណ៌ដោយមារយាទ មិនចេះបៀតបៀនអ្នកណាម្នាក់ឡើយ ។

ក្រោយមក ថ្ងៃមួយ ក្នុងពេលរាត្រី ពួកចោរ មកហើយ បានអង្គុយប្រឹក្សាគ្នា នៅក្បែររោងដំរី របស់ព្រះរាជាអង្គនោះ ថា “ពួកយើង ត្រូវទំលាយឧម្មង្គ (រូង) យ៉ាងដូច្នេះ, ត្រូវធ្វើកម្ម គឺ ការកាត់ទីត យ៉ាងដូច្នេះ, ការដែលពួកយើង ទំលាយនូវឧម្មង្គ និង ធ្វើនូវការកាត់ទីតហើយ លួចយកនូវភ័ណ្ឌៈ ទើបគួរ, កាលនឹង លួចយក ត្រូវតែសម្លាប់ និងវាយដំ (ម្ចាស់ទ្រព្យ) ហើយ ទើប

លួចយកទៅ, កាលធ្វើយ៉ាងនេះ នឹងមិនមានអ្នកណាអាចដើម្បីនឹងក្រោកឡើង (តស៊ូបាន), ក៏ធម្មតាចោរ មិនត្រូវមានសីលាចារវត្តឡើយ, ត្រូវតែជាអ្នកកំណាច ឃោរឃៅ កាចសាហាវ" ដូច្នេះ ។ ពួកចោរទាំងនោះ ប្រឹក្សាគ្នា យ៉ាងដូច្នេះហើយ ក៏បានណាត់គ្នាទៅវិញទៅមកស្រេច ទើបនាំគ្នាទៅហើយ ។ ពួកចោរទាំងនោះមកប្រឹក្សាគ្នា ក្នុងទីនោះ ដោយឧបាយនេះឯង អស់ជាច្រើនថ្ងៃ ។

ដំរីបានស្ដាប់ពាក្យ របស់ពួកចោរទាំងនោះហើយ ក៏សម្គាល់ថា "ពួកចោរទាំងនេះ ញុំាងអញឲ្យសិក្សា" ហើយគិត ថា "ក្នុងពេលឥឡូវនេះ អញត្រូវតែជាសត្វកំណាច កាចឃោរឃៅសាហាវ" ដូច្នេះហើយ ក៏បានទៅជាសត្វ យ៉ាងដូច្នោះហើយ ។ ដំរីនោះ បានយកប្រមោយ ចាប់អ្នកថែរក្សាដំរី ដែលមកហើយ ។ អំពីព្រឹកព្រលឹមស្រាង បោកទៅលើផែនដី ឲ្យស្លាប់ហើយ ។

ពួកមនុស្ស បានក្រាបទូលហើយ ដល់ព្រះរាជា ។ ព្រះរាជា ទ្រង់បានបញ្ជូននូវអាមាត្យម្នាក់ទៅ ដោយព្រះរាជឱង្ការ ថា "នែបណ្ឌិត អ្នកចូរទៅចុះ, ចូរ (ពិនិត្យ) ឲ្យដឹងថា 'ព្រោះហេតុអ្វី ? បានជាដំរីនោះ ក្លាយទៅជាសត្វកាចសាហាវ' ដូច្នេះ" ។

អាមាត្យនោះ ទៅហើយ ក៏មិនឃើញមានរោគ ក្នុងខ្លួននៃដំរី ទើបគិតថា "ដំរីនេះ បានកាចសាហាវហើយ ព្រោះហេតុអ្វី ?"

ដូច្នេះ កាលពិចារណាទៅ ទើបធ្វើការសន្និដ្ឋាន ថា "ដំរីនោះ ពិតជាបានស្ដាប់ពាក្យអាក្រក់ របស់ជនពួកខ្លះ ក្នុងទីមិនឆ្ងាយ ដោយពិតទើបបានក្លាយទៅជាសត្វកាចសាហាវ" ហើយបានសួរពួកជនអ្នកថែរក្សាដំរី ថា "តើមានបុគ្គលណាខ្លះ ធ្លាប់និយាយអ្វីៗ ក្នុងពេលរាត្រី នៅក្បែររោងដំរី ដែរឬទេ ?"។ ពួកអ្នកថែរក្សាដំរីពោល ថា "បពិត្រនាយ មាន, ពួកចោរ បានមកប្រឹក្សាគ្នា"។ អាមាត្យនោះ ទៅហើយក្រាបទូល ថា "បពិត្រព្រះសម្មតិទេព ក្នុងខ្លួននៃដំរី មិនមានការចំឡែកអ្វីដទៃឡើយ, ដំរីនោះ បានស្ដាប់ពាក្យរបស់ពួកចោរហើយ ទើបបានជាសត្វកាចសាហាវ, ឥឡូវនេះគួរតែនិមន្តពួកសមណៈ និងព្រាហ្មណ៍ អ្នកមានសីល ឲ្យគង់អង្គុយនៅក្បែររោងដំរីហើយ សូត្ររឿងសីលនិងមារយាទ"។ ព្រះរាជា ទ្រង់ត្រាស់ឲ្យធ្វើហើយ យ៉ាងដូច្នោះ ។ សមណៈនិងព្រាហ្មណ៍ទាំងឡាយនោះ បានពោលរឿងសីល ថា "អ្នកមិនគួរចាប់អ្នកណាមួយឡើយ, មិនគួរសម្លាប់អ្នកណាម្នាក់ឡើយ, គួរជាអ្នកបរិបូណ៌ដោយសីល និង មារយាទ ប្រកបដោយខន្តី មេត្តា និងសេចក្ដីអនុគ្រោះ"។ ដំរីស្ដាប់ពាក្យនោះហើយ ទើបសម្គាល់ ថា "សមណៈនិងព្រាហ្មណ៍ទាំងនេះ ញ៉ាំងអញឲ្យសិក្សា" ហើយគិត ថា តាំងតែអំពីពេលនេះទៅ អញត្រូវតែមានសីល" ដូច្នេះហើយ ក៏បាន

ក្លាយទៅជាសត្វមានសីលហើយ ។

រឿងដំរីមហិឡាមុខ ក្នុងអដ្ឋកថាមហិឡាមុខជាតក ក្នុងឯកនិបាត ចប់ ។

## ( រឿងសេះឈ្មោះបណ្ឌវៈ )

(២៦) ក្នុងអតីតកាល បានមានព្រះរាជា ទ្រង់ព្រះនាមថា សាមៈ ក្នុងក្រុងពារាណសី ។ ព្រះពោធិសត្វបានជាអមាត្យ អ្នកបង្រៀនអត្ថនិងធម៌ របស់ព្រះរាជាអង្គនោះ ។ ក៏ព្រះរាជា ទ្រង់មានសេះមង្គល ឈ្មោះបណ្ឌវៈ ។ អ្នកគង្វាលសេះ របស់ព្រះអង្គ ឈ្មោះគិរិទត្ត ជាមនុស្សខ្វក ។ សេះឃើញអ្នក គង្វាលសេះនោះ ចាប់ខ្សែបង្ហៀរ (ដឹក) នាំមុខហើយ ក៏សម្គាល់ ថា "អ្នកគង្វាលសេះនេះ ញ៉ាំងអញឲ្យសិក្សា" ដូច្នេះហើយ ទើប យកតម្រាប់តាមអាការៈ របស់អ្នកគង្វាលសេះនោះ បានក្លាយទៅ ជាសេះខ្វកហើយ ។ ព្រះរាជា ទ្រង់ជ្រាបថា សេះរបស់ព្រះ អង្គនោះ ខ្វកហើយ ទើបទ្រង់បានត្រាស់បញ្ជូនពួកពេទ្យទៅ (ឲ្យ ត្រួតពិនិត្យមើល ) ។ ពួកពេទ្យទាំងនោះ ទៅហើយ មិនឃើញ រោគនៅក្នុងខ្លួន របស់សេះនោះ ទើប (ត្រឡប់មក) ក្រាបទូលព្រះ ព្រះរាជាថា "ទូលព្រះបង្គំ មិនឃើញរោគ របស់សេះនោះទេ" ។ ព្រះរាជា ទ្រង់បញ្ជូននូវព្រះពោធិសត្វទៅ ដោយព្រះរាជឱង្ការ ថា

“ចូរអ្នកទៅ (ត្រួតពិនិត្យមើលឲ្យ) ដឹងនូវហេតុក្នុងដំណើរនោះ” ។ ព្រះពោធិសត្វនោះ ទៅហើយ បានដឹងថា សេះនោះដើរខ្ចក ៗ ព្រោះការជាប់ទាក់ទងជាមួយគ្នា នឹងអ្នកគង្វាលសេះជើងខ្ចក ទើបបានក្រាបទូល ថា “បពិត្រព្រះមហារាជ សេះមានជើងខ្ចក យ៉ាងដូច្នេះ ព្រោះទោស នៃការជាប់ទាក់ទងជាមួយគ្នា” ដូច្នេះហើយ ទើបបានក្រាប់ទូល ថា “សេះនោះ បាននូវអ្នកគង្វាលសេះ ដែលល្អហើយ ក៏នឹងក្លាយជាសេះដូចដើមវិញ” ។ ព្រះរាជា ទ្រង់ត្រាស់បញ្ជាឲ្យធ្វើហើយ យ៉ាងដូច្នោះ ។ សេះបានតាំងនៅក្នុងភាពប្រក្រតីហើយ ។

រឿងសេះបណ្ឌវៈ ក្នុងអដ្ឋកថាគិរិទត្តជាតក ក្នុងទុកនិបាត ចប់ ។

## ( រឿងផ្លែស្វាយ )

(២៧) ក្នុងអតីតកាល ក្នុងក្រុងពារាណសី បានមានព្រះរាជា ទ្រង់ព្រះនាមថា ធទិវាហនៈ ។ ព្រះពោធិសត្វ ជាអមាត្យអ្នកបង្រៀនអត្ថនិងធម៌ របស់ព្រះអង្គ ។ ក្រោយមក ថ្ងៃមួយ ព្រះរាជា ទ្រង់ត្រាស់បញ្ជាឲ្យតាំងបន្ទាយ នៅទិសខាងជើង និងខាងត្បូង ក្នុងមហានទីហើយ ទ្រង់ក្រសាលព្រះវារី ។ ផ្លែស្វាយទុំជាគ្រឿងសោយ របស់ទេវតា មួយផ្លែ បានអណ្តែតមក អំពីស្រះកណ្ណមុណ្ឌ បានមកជាប់ ត្រង់បន្ទាយហើយ ។ ពួករាជបុរស

កាលតាំងបន្ទាយ ក៏ឃើញផ្លែស្វាយនោះហើយ ទើប (យកទៅ) ថ្វាយដល់ព្រះរាជា ។ ព្រះរាជា ទ្រង់ត្រាស់សួរពួកព្រានព្រៃ ថា "នេះជាផ្លែឈើអ្វី ?" ហើយ ទ្រង់ព្រះសណ្ដាប់ ថា "នេះ ជាផ្លែស្វាយ" ដូច្នេះ ទើបទ្រង់សោយហើយ ត្រាស់បញ្ជា ឱ្យបណ្ដុះគ្រាប់ ក្នុងព្រះឧទ្យាន របស់ព្រះអង្គស្រេចហើយ ទើបទ្រង់ត្រាស់បញ្ជាឱ្យយកទឹកដែលផ្សំដោយទឹកដោះ មកស្រោច ។ ដើមឈើ (ស្វាយ) បានធំឡើងហើយ ក៏ឱ្យផល ក្នុងឆ្នាំទី ៣ ។ ដើមស្វាយបានមានសក្ការៈដ៏ច្រើនហើយ ។ ពួកអ្នកនគរ យកទឹកដែលផ្សំដោយទឹកដោះស្រស់ មកស្រោច ឱ្យនូវការក្សិត ដោយគ្រឿងក្រអូប ៥ កន្លែង បំពាក់នូវកម្រងផ្កាទាំងឡាយ ទ្រោលប្រទីបដោយប្រេងក្រអូប ។ មួយទៀត បានមានការរុំព័ទ្ធដើមស្វាយនោះ ដោយសំពត់រនាំងរាំងនន ។ ផ្លែ (ស្វាយ) ទាំងឡាយបានមានរសជាតិដ៏ផ្អែមឆ្ងាញ់ មានពណ៌សម្បុរដូចជាមាស ។ ព្រះរាជា កាលទ្រង់បញ្ជូននូវផ្លែស្វាយទៅ ថ្វាយដល់ព្រះរាជាទាំងឡាយដ៏ទៃៗទៀត ទ្រង់បានត្រាស់បញ្ជា ឱ្យយកចុងដែកកណ្ដារ មកចោះត្រង់ទីកើតនៃពន្លកហើយ ទើបត្រាស់ឱ្យបញ្ជូនទៅ ។ គ្រាប់ស្វាយ ដែលព្រះរាជាទាំងនោះ សោយផ្លែស្វាយហើយ ទ្រង់ត្រាស់បញ្ជាឱ្យអមាត្យបណ្ដុះ មិនបានសម្រេចឡើយ ។

គ្រានោះ ព្រះរាជាមួយព្រះអង្គ ទ្រង់ជ្រាបនូវហេតុនោះ ទើបទ្រង់ព្រះរាជាទានទ្រព្យមួយពាន់ហើយ ទ្រង់បញ្ជូនបុរសអ្នកថែរក្សាឧទ្យានម្នាក់ទៅ ដោយព្រះរាជឱង្ការ ថា "ចូរអ្នកទៅចុះ, អ្នកចូរធ្វើរសជាតិនៃផ្លែស្វាយ របស់ព្រះបាទធទិវាហនៈ ឲ្យវិនាសហើយ ធ្វើឲ្យមានរសជាតិល្វីងវិញ"។ បុរសអ្នកថែរក្សាឧទ្យាននោះ ទទួលព្រះរាជឱង្ការ ថា "ព្រះករុណាថ្លៃវិសេស" ហើយ បានចូលទៅគាល់ព្រះរាជា ព្រះនាមធទិវាហនៈ បានក្រាបទូល ថា ខ្លួនជាអ្នកថែរក្សាឧទ្យានហើយ ទើបក្រាបទូលនូវអានុភាព របស់ខ្លួន ។ ព្រះរាជា ទ្រង់បញ្ជាឲ្យបុរសអ្នករក្សាឧទ្យាននោះ នៅក្នុងសំណាក់របស់អ្នករក្សាឧទ្យាន របស់ព្រះអង្គហើយ ។ តាំងអំពីពេលនោះមក ជនទាំង ២ នាក់ ក៏នាំគ្នាជួយថែរក្សានូវព្រះឧទ្យាន ។ បុរសអ្នកថែរក្សាព្រះឧទ្យានដែលទើបនឹងមកថ្មី ញ៉ាំងផ្កាឈើដែលមិនមែនជារដូវកាល ឲ្យរីកស្គុសស្គាយ ញ៉ាំងផ្លែឈើដែលមិនមែនជារដូវកាល ឲ្យមានផ្លែ បានធ្វើហើយនូវព្រះឧទ្យាន ឲ្យក្លាយទៅជារម្មណីយស្ថាន ។ ព្រះរាជា ទ្រង់សព្វព្រះរាជហឫទ័យហើយ ទ្រង់ដកអ្នកថែរក្សាព្រះឧទ្យានចាស់ចេញ ទ្រង់បានព្រះរាជទានហើយ នូវព្រះឧទ្យាន ដល់អ្នកថែរក្សាព្រះឧទ្យាន ដែលមកថ្មីនោះតែម្នាក់ឯងគត់ ។ អ្នកថែរក្សាព្រះឧទ្យាន ដែលមកថ្មីនោះ

ក៏ដាំដើមស្ដៅនិងវល្លិបណ្ដូលពេជ្រទាំងឡាយ ព័ទ្ធជុំវិញដើមស្វាយហើយ ។ ដើមស្ដៅនិងវល្លិបណ្ដូលពេជ្រទាំងនោះ ក៏បានដុះលូតលាស់ឡើងហើយ ដោយលំដាប់ ។ ឫសនិងមែកទាំងឡាយរបស់ដើមស្វាយ បានពាក់ព័ន្ធគ្នាហើយ ជាមួយនឹងឫសនិងមែកទាំងឡាយ (របស់ដើមស្ដៅនិងវល្លិបណ្ដូលពេជ្រ), ព្រោះការពាក់ព័ន្ធគ្នានឹងរបស់ដែលគ្មានរសជាតិផ្អែមនោះ ដើមស្វាយដែលមានរសជាតិផ្អែមប្រមាណប៉ុណ្ណោះ ទើបក្លាយទៅជាមានរសជាតិល្វីង ដូចជារសជាតិនៃស្លឹកស្ដៅ ។ អ្នកថែរក្សាព្រះឧទ្យាន ដឹងថា ផ្លែស្វាយមានរសជាតិល្វីងហើយ ក៏គេចចេញទៅហើយ ។ ព្រះរាជាទ្រង់ស្ដេចយាងទៅកាន់ព្រះឧទ្យាន កាលទ្រង់សោយផ្លែស្វាយទ្រង់មិនអាច ដើម្បីនឹងលេបសាច់នៃផ្លែស្វាយ ដែលដូចជាកាកនៃស្ដៅបានឡើយ ទ្រង់ខាក ស្ដោះចេញហើយ ទ្រង់ត្រាស់សួរព្រះពោធិសត្វ ថា " នែបណ្ឌិត ដើមឈើ (ស្វាយ) នេះ មិនមានការខូចខាត អំពីការបរិហារមុនៗឡើយ, កាលបើយ៉ាងដូច្នោះ ផ្លែរបស់ដើមស្វាយនោះ ក៏បានក្លាយទៅជាមានរសជាតិល្វីងវិញ, តើមានហេតុអ្វីទៅហ្ន៎ ? " ។

ព្រះពោធិសត្វនោះ កាលក្រាបទូល នូវហេតុនៃផ្លែស្វាយមានរសជាតិល្វីងនោះ ទើបបានក្រាបទូល ថា ÷

(២៨) " បពិត្រព្រះរាជាទ្រង់ព្រះនាមទធិវាហនៈ[១] ដើមស្វាយ របស់ព្រះអង្គ មានដើមស្ដៅដុះរួបរិត ជុំវិញ, ឫសច្រឡំគ្នាដោយឫស, មែកពាក់ព័ន្ធគ្នានឹងមែក, ដោយការនៅជាមួយនឹងដើមស្ដៅដែលមិនមានរសជាតិផ្អែម ព្រោះហេតុនោះ បានជាស្វាយត្រឡប់ជាមានផ្លែល្វីងទៅវិញ " ។

ដើមស្ដៅ ឈ្មោះថា **បុចិមន្ទៈ** ក្នុងគាថានោះ ។ មែករបស់ដើមស្ដៅ ឈ្មោះថា **សាខា** ។ ២ បទ ថា " **សាខំ និសេវរេ** " គឺ រមែងពាក់ព័ន្ធ នូវមែករបស់ដើមស្វាយ ។ បាទគាថា ថា " **អសាតសន្និវាសេន** " គឺ ព្រោះការនៅរួមជាមួយនឹងដើមស្ដៅដែលមិនមានរសជាតិផ្អែម ។ បទ ថា " **តេន** " ប្រែថា ព្រោះហេតុនោះ ។ បទ ថា " **កដុកប្ផលោ** " គឺ ប្រែត្រឡប់ទៅជាមានផ្លែល្វីងទៅវិញ ។

ព្រះរាជា ទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ទ្រង់ត្រាស់បញ្ជាឲ្យកាត់នូវដើមស្ដៅ និងវល្លិបណ្ដូលពេជ្រទាំងអស់ចោលហើយ ទ្រង់ឲ្យដកឫសចេញ ទ្រង់បានត្រាស់ឲ្យនាំយកអាចម៍ដីដែលមិនមានរសជាតិផ្អែម ដោយជុំវិញ ចេញហើយ ទ្រង់ត្រាស់ឲ្យដាក់អាចម៍ដី

១ ត្រៃបិដក ភាគទី ៥៨ / ទំព័រទី ៩១ ។

ដែលមានរសជាតិផ្អែម ទ្រង់បានត្រាស់បញ្ជាឲ្យស្រោចនូវដើមស្វាយ ដោយទឹកដែលផ្សំដោយទឹកដោះស្រស់ ទឹកផ្សំដោយស្ករ និងទឹកដែលផ្សំដោយគ្រឿងក្រអូបថ្មីទៀត ហើយទ្រង់បានប្រគល់នូវព្រះឧទ្យានឲ្យដល់អ្នកថែរក្សាព្រះឧទ្យានមុន ដូចដើមវិញម្តងទៀត ។ ស្វាយបានក្លាយទៅជាមានរសជាតិផ្អែមឆ្ងាញ់ ដូចដើមវិញម្តងទៀត ព្រោះជាប់ទាក់ទងគ្នានឹងរបស់ដែលមានរសជាតិផ្អែម ។

រឿងស្វាយ ក្នុងអដ្ឋកថាទធិវាហនជាតក ក្នុងទុកនិបាត ចប់ ។

(២៩) សូម្បីតែរបស់ដែលមិនមានជីវិត ក៏ក្លាយទៅជារបស់ដែលគេមិនត្រូវការចង់បាន ព្រោះប្រកបជាមួយនឹងរបស់ដែលគេមិនត្រូវការចង់បាន បានក្លាយទៅជារបស់ដែលគេប្រាថ្នាចង់បាន ព្រោះប្រកបដោយរបស់ដែលគេប្រាថ្នាចង់បាន ដូចពណ៌នាមកនេះឯង, នឹងចាំបាច់ពោលធ្វើអ្វី ក្នុងរបស់ដែលមានជីវិតនុ៎ះឡើយ ។

ដោយហេតុនោះ ក្នុងអត្ថុប្បត្តិហេតុ នៃទធិវាហនជាតក ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា "ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា ការនៅរួមជាមួយមនុស្សមិនល្អ ជារឿងដ៏លាមក បង្កើតតែរឿងរ៉ាវដែលគ្មានប្រយោជន៍, មិនចាំបាច់ពោលទៅធ្វើអ្វី ក្នុងការនៅរួមជាមួយនឹងមនុស្សមិនល្អនោះឡើយ ព្រោះការនៅរួមជាមួយនឹងមនុស្សអាក្រក់ ធ្វើសេចក្តីអន្តរាយមិនមែនជាប្រយោជន៍

ដល់បុគ្គលជាមនុស្សទាំងឡាយមុនសិន, សូម្បីដើមស្វាយ ដែលមិនមានចេតនា មានរសជាតិផ្អែម ប្រៀបស្មើនឹងរសជាតិទិព្វ អាស្រ័យការនៅរួមជាមួយគ្នានឹងដើមស្តៅ ដែលមានរសជាតិល្វីង មិនមានរសជាតិផ្អែម ក៏បានក្លាយទៅជាដើមឈើដែលមានរសជាតិមិនផ្អែម មានរសជាតិល្វីងទៅវិញ ក្នុងកាលមុន " ។

## ( ជនពាលដូចជាអមិត្រ បណ្ឌិតដូចជាញាតិ )

(៣០) មួយវិញទៀត បុគ្គលពាលទាំងឡាយ ប្រៀបដូចជាអមិត្រដែលមានដាវនៅនឹងដៃ, បណ្ឌិតទាំងឡាយ ប្រៀបដូចជាញាតិដែលជាទីស្រឡាញ់ ។ ពិតមែនដូច្នោះ ព្រះដ៏មានព្រះភាគ កាលទ្រង់ប្រថាប់គង់ ធ្វើតំបន់វេឡុវគ្រាម ដែលតាំងនៅមិនឆ្ងាយ ខាងទិសទក្សិណ នៃទីក្រុងវេសាលី ឲ្យជាគោចរគ្រាម បានកើតព្រះប្រឈួនធ្លាក់ព្រះលោហិត ។ ស្តេចសក្កទេវរាជទ្រង់ជ្រាបហេតុនោះហើយ ស្តេចយាងមកឧបដ្ឋាកនូវសាស្តា ទ្រង់មិនឲ្យអ្នកដទៃប៉ះពាល់នូវភាជនៈសម្រាប់រងសរីរវលញ្ជៈ (លាមកក្នុងសរីរៈ) របស់ព្រះសាស្តា សូម្បីដោយដៃឡើយ ទ្រង់ទូលលើព្រះសិរសីតែម្តង ហើយនាំយកទៅ ដូចជាបុគ្គលនាំយកភាជនៈសម្រាប់ដាក់គ្រឿងក្រអូបទៅដូច្នោះ ។ ស្តេចសក្កទេវរាជនោះ

ទ្រង់ឧបដ្ឋាក យ៉ាងដូច្នេះហើយ ក្នុងពេលដែលព្រះសាស្ដាទ្រង់បានសប្បាយ ទើបស្ដេចយាងទៅកាន់ទេវលោក ។

ពួកភិក្ខុទាំងឡាយ បាននិយាយគ្នាថា "គួរឱ្យអស្ចារ្យមែន ! ស្ដេចសក្កទេវរាជ មានសេចក្ដីស្រឡាញ់ ចំពោះព្រះសាស្ដា, ព្រះអង្គទ្រង់បានលះបង់ នូវទិព្វសម្បត្តិ ទ្រង់មកឧបដ្ឋាកហើយ " ។ ព្រះសាស្ដា ទ្រង់ត្រាស់ ថា " ម្នាលភិក្ខុទាំងឡាយ ស្ដេចសក្កទេវរាជ ទ្រង់ពិចារណាឃើញថា 'កិរិយាជួបប្រទះនូវព្រះអរិយៈទាំងឡាយក្ដី ភាវៈគឺកិរិយាមានការអង្គុយជាដើម ក្នុងទីកន្លែងជាមួយគ្នានឹងព្រះអរិយៈទាំងឡាយនោះក្ដី ភាវៈគឺការបានធ្វើនូវវត្តនិងវត្តតប ដល់ព្រះអរិយៈទាំងឡាយនោះក្ដី ជាហេតុញ៉ាំងប្រយោជន៍ឱ្យសម្រេចបាន' ដូច្នេះហើយ ទើបទ្រង់ស្ដេចយាងមកឧបដ្ឋាកនូវតថាគត " ដូច្នេះ កាលទ្រង់សំដែង (សេចក្ដីនោះ) ទើបទ្រង់បានភាសិតគាថាទាំងឡាយ ក្នុងរឿងនៃស្ដេចសក្កទេវិន្ទ ក្នុងសុខវគ្គ នៃធម្មបទ ថា ÷

(៣១) " មែនពិត បុគ្គលអ្នកប្រព្រឹត្តសេពគប់[(១)] ដោយជនពាល រមែងសោកសៅ អស់កាលដ៏យូរអង្វែង, ការនៅរួមគ្នាជាមួយនឹងជនពាល

---

១ ត្រៃបិដក ភាគទី ៥២ / ទំព័រទី ៦៤ _ ៦៥ ។

រមែងជាទុក្ខ សព្វកាល ដូចជាការនៅរួមជាមួយគ្នានឹងសត្រូវ, ចំណែកខាងបណ្ឌិត មានការនៅរួមជាសុខ ប្រៀបដូចជាការជួបជុំ នៃញាតិទាំងឡាយ, ព្រោះហេតុនោះឯង បុគ្គលគួរសេពគប់នូវសប្បុរស ជាអ្នកមាំមួនផង មានបញ្ញាផង មានសេចក្តីចេះដឹងច្រើនផង មានកិរិយានាំទៅនូវធុរៈជាប្រក្រតីផង មានសីលវ័ត និងធុតង្គវ័តផង ជាអ្នកឆ្ងាយចាកកិលេសផង មានបញ្ញាដ៏ល្អផង ប្រាកដដូច្នោះនោះ ឲ្យដូចជាព្រះច័ន្ទ គប់រកនូវផ្លូវនៃនក្ខត្តឫក្ស យ៉ាងដូច្នោះឯង " ។

បណ្តាបទទាំងនោះ បាទគាថា ថា " **ពាលសង្គតចារី ហិ** " មានសេចក្តីថា មែនពិត គឺ ពិតណាស់ បុគ្គលអ្នកមានកិរិយាប្រព្រឹត្តិសេពគប់ជាមួយនឹងជនពាល ។ បទ ថា " **ទីឃមទ្ធានំ** " មានសេចក្តី ថា ជាអ្នកមានឆន្ទៈដូចគ្នា ជាមួយនឹងជនពាល កាលធ្វើនូវកម្មអាក្រក់ មានការកាត់នូវទីតជាដើម ទើបបានជួបប្រទះនូវសេចក្តីទុក្ខ មានត្រូវគេកាត់ដៃជាដើម ឈ្មោះថា រមែងសោកសៅអស់កាលដ៏យូរអង្វែង ។ ការរស់នៅ ជាមួយគ្នា ឈ្មោះថា

ការនៅរួមគ្នា ។ បទ ថា "**អមិត្តេនេវ**" មានសេចក្តីថា ប្រៀប ដូចជាការនៅរួមជាមួយនឹងសត្រូវដែលមានដាវជាប់នឹងដៃ ឬសត្វសាហាវមានអាសិរពិសជាដើម ។ បទ ថា "**សព្វទា**" គឺ ការនៅរួមជាមួយនឹងពួកជនពាល រមែងជាទុក្ខជាប់ជានិច្ច ។ ការនៅរួមជាមួយនឹងបណ្ឌិតនោះ រមែងជាសុខ ព្រោះហេតុនោះ បណ្ឌិតទើបឈ្មោះថា មានការនៅរួមជាសុខ, អធិប្បាយថា "ការនៅរួមក្នុងទីជាមួយគ្នានឹងបណ្ឌិត ជាហេតុនាំសេចក្តីសុខមកឱ្យ" ។ ប្រៀបដូចជាអ្វី ? ។ ប្រៀបដូចជាសមាគម នៃពួកញាតិ ។ អធិប្បាយថា "ប្រៀបដូចជាការជួបជុំ នៃពួកញាតិទាំងឡាយដែលជាទីស្រឡាញ់ ជាហេតុឱ្យបានសុខ" ។ បទ ថា "**តស្មា ហិ**" មានសេចក្តីថា ការនៅរួមជាមួយជនពាល រមែងជាទុក្ខ ព្រោះហេតុណា, ការនៅរួមជាមួយបណ្ឌិត រមែងជាសុខ ព្រោះហេតុនោះ ។ បទ ថា "**ធីរំ**" គឺ ជាអ្នកដល់ព្រមដោយបញ្ញាជាគ្រឿងទ្រទ្រង់ចាំ ។ បទ ថា "**បញ្ញំ**" បានដល់ អ្នកដល់ព្រមដោយបញ្ញាដែលជាលោកិយៈ និង លោកុត្តរៈ ។ បទ ថា "**ពហុស្សុតំ**" គឺ ជាពហុស្សូត ដោយបរិយត្តិ បដិបត្តិ និង បដិវេធ ។ បទ ថា "**ធោរយ្ហសីលព្វតវន្តំ**" បានដល់ ឈ្មោះថា ជាអ្នកមានកិរិយានាំទៅនូវធុរៈ ព្រោះនាំទៅនូវធុរៈ ពោលគឺ

ការញ៉ាំងខ្លួន ឲ្យបានសម្រេចព្រះអរហត្តផល ជាអ្នកមានសីល និងមានធុតង្គ ។ បទ ថា "អរិយំ" ប្រែថា អ្នកស្ថិតនៅឆ្ងាយចាកកិលេស ។ បទ ថា "សុមេធំ" បានដល់ អ្នកមានបញ្ញាល្អ ។ បទ ថា "នក្ខត្តបថំ វ" មានសេចក្តីថា ប្រៀបដូចជាព្រះច័ន្ទ គឺ វិមាននៃព្រះច័ន្ទ គប់រកនូវអាកាសដែលជាផ្លូវ នៃនក្ខត្តឫក្សទាំងឡាយ ដូច្នោះឯង" ។

## ( តាបសឲ្យដម្បូន្មានដល់បុត្រ )

(៣២) សូម្បីព្រះពោធិសត្វ កាលកើតជាតាបសនៅ ក្នុងហិមវន្តប្រទេស កាលនឹងទូន្មាននូវតាបសកុមារ ជាបុត្ររបស់ខ្លួន ដែលធុញទ្រាន់ ប្រាថ្នាចង់ចេញអំពីព្រៃហើយ ទៅរស់នៅ ក្នុងទីលំនៅស្ថាននៃមនុស្ស ទើបបានពោលនូវគាថាទាំងឡាយនេះ ក្នុងហលិទ្ទរាគជាតក ក្នុងនវកនិបាត ថា ÷

"បុគ្គលណា មិនមានអំពើអាក្រក់ ដោយកាយ(១)
វាចា និងចិត្ត, អ្នកចេញអំពីព្រៃនេះទៅហើយ
ចូរតាំងខ្លួន ឲ្យដូចជាកូន ដែលកើតអំពីទ្រូង
ហើយ ចាំសេពគប់រក នូវបុគ្គលនោះចុះ ;

១ ត្រៃបិដក ភាគទី ៥៩ / ទំព័រទី ១៥៣ ។

មួយទៀត បុគ្គលណា ប្រព្រឹត្តតាមធម៌ ទោះបីកំពុងប្រព្រឹត្ត ក៏មិនប្រកាន់ខ្លួន, អ្នកចេញអំពីព្រៃនេះទៅហើយ ចូរសេពគប់នូវបុគ្គល ដែលជាអ្នកធ្វើអំពើដ៏បរិសុទ្ធ ប្រកបដោយបញ្ញានោះចុះ; នែបា បុគ្គលណា មានចិត្តដូចជាសំពត់ដែលជ្រលក់ល្មៀត មានចិត្តដូចសត្វស្វាត្រេកអរហើយ បែរជាមិនត្រេកអរវិញ បើទុកជាផ្ទៃនៃជម្ពូទ្វីបទាំងមូលនេះ មិនមានមនុស្សសោះក៏ដោយ; អ្នកចូរកុំសេពគប់នូវបុរសបែបនោះឡើយ, អ្នកចូរចៀសវាង (បុគ្គលបែបនោះ) អំពីចម្ងាយ ឲ្យដូចជាបុគ្គលអ្នកភ័យខ្លាច ចៀសវាងអាសិរពិសដ៏កាចសាហាវអំពីចម្ងាយ ឬដូចជាបុគ្គលឆ្អើមលាមក ចៀសវាងនូវផ្លូវធំដែលប្រឡាក់ដោយលាមក ឬដូចបុគ្គលអ្នកទៅដោយយាន ចៀសវាង នូវផ្លូវដែលមិនរាបស្មើ ដូច្នោះ; នែបា អំពើដែលមិនមែនជាប្រយោជន៍ទាំងឡាយ រមែងចំរើន ដល់បុគ្គលដែលសេពគប់ នូវបុគ្គលពាល

ជ្រុលពេក; អ្នកចូរកុំគប់រក ជាមួយនឹងបុគ្គលពាលឡើយ, ព្រោះការនៅរួមជាមួយនឹងបុគ្គលពាល ជាហេតុនាំសេចក្ដីទុក្ខមកឲ្យ ប្រៀបដូចជាការនៅរួមជាមួយនឹងសត្រូវ សព្វៗកាល, នៃបា ព្រោះហេតុនោះហើយ បានជាយើង សូមអង្វរអ្នក, ចូរអ្នកធ្វើតាមពាក្យ របស់យើង, ចូរអ្នកកុំគប់រក ជាមួយនឹងបុគ្គលពាលឡើយ, (ព្រោះ) ការសមាគម ជាមួយបុគ្គលពាលទាំងឡាយ រមែងជាហេតុនាំសេចក្ដីទុក្ខមកឲ្យ " ។

បណ្ដាបទទាំងនោះ បទ ថា " **ឱរសីវ** " មានសេចក្ដីថា ចូរតាំង គឺចូរតាំងចំពោះ (នូវខ្លួន) ឲ្យដូចជាកូនដែលកើតហើយអំពីទ្រូងនៃមាតា ដូច្នោះ ។ អធិប្បាយ ថា "អ្នកលុះតាំង (ខ្លួន) ទុក យ៉ាងដូច្នេះហើយ គប្បីសម្គាល់ឲ្យដូចជាមាតារបស់ខ្លួនហើយ សេពគប់នូវបុគ្គលនោះចុះ " ។

បទ ថា " **ធម្មេន** " បានដល់ ដោយធម៌ គឺសុចរិតទាំង ៣ យ៉ាងនុ៎ះឯង ។ បទ ថា " **ន មញ្ញតិ** " មានសេចក្ដីថា ម្យ៉ាងទៀត សូម្បីកាលប្រព្រឹត្ត យ៉ាងដូច្នោះ ក៏មិនធ្វើការប្រកាន់ខ្លួន ថា

"អាត្មាអញ ប្រព្រឹត្តនូវធម៌"។ បទ ថា "**វិសុទ្ធការី**" បានដល់ អ្នកធ្វើកម្មដែលបរិសុទ្ធ គឺ កុសលកម្មបថ ១០ ប្រការ ។

បទ ថា "**ហលិទ្ទរាគំ**" គឺ ឈ្មោះថា ជាអ្នកប្រៀបដូចជា សំពត់ដែលជ្រលក់ដោយល្មៀត ព្រោះជាអ្នកមានចិត្តមិនស្ថិតស្ថេរ ។ បទ ថា "**កបិចិត្តំ**" បានដល់ មានចិត្តកម្រើកញាប់ញ័រ គឺ មានចិត្តរំជើបរំជួល ។ បទ ថា "**បុរិសំ**" បានដល់ បុគ្គល ។ បទ ថា "**រាគវិរាគិនំ**" គឺ ត្រេកអរហើយ និងបែរជាមិនត្រេកអរ ទៅវិញ, អធិប្បាយ ថា "មានសភាវៈ គឺ ស្រឡាញ់ហើយ ស្អប់ ខ្ពើមទៅវិញ ក្នុងខណៈនោះភ្លាមៗ"។ បាទគាថា ថា "**និម្មនុស្សំបិ ចេ សិយា**" មានសេចក្ដីថា ក៏ទោះបីជា ផ្ទៃនៃ ជម្ពូទ្វីបទាំងមូល នឹងជាទីស្ថានដែលគ្មានមនុស្សក៏ដោយ, មានជន ពាលនោះ ជាមនុស្សស្ថិតនៅតែម្នាក់ឯងប៉ុណ្ណោះ, សូម្បីជាដូច្នោះ ក៏ដោយ ចូរអ្នកកុំសេពគប់ នូវបុគ្គលបែបនោះឡើយ ។

បាទគាថា ថា "**មិឡ្ហលិត្តំ មហាបថំ**" គឺ ប្រៀបដូចជា ផ្លូវដ៏ធំ ដែលប្រឡាក់ដោយលាមក ។ បទ ថា "**យានីវ**" គឺ ប្រៀបដូចជាបុគ្គលអ្នកធ្វើដំណើរទៅ ដោយយាន ។ បទ ថា "**វិសមំ**" បានដល់ មិនបានរាបស្មើ ដោយភាវៈជាទីដែលទំនាប និងទីដែលទួល និង ដោយវត្ថុមានដង្គត់ និង ថ្មជាដើម ។

បាទគាថា ថា "**ពាលំ អច្ចុបសេវតោ**" បានដល់ ជាអ្នកសេពគប់យ៉ាងស្និទ្ធស្នាល នូវបុគ្គលអ្នកមានបញ្ញាតិច ។ បទ ថា "**សព្វទា**" មានសេចក្តីថា ឈ្មោះថា ការនៅរួមជាមួយនឹងបុគ្គលពាល រមែងនាំសេចក្តីទុក្ខមកឲ្យ អស់កាលជានិច្ចតែម្តង ប្រៀបដូចជាការនៅរួមជាមួយនឹងសត្រូវ ដូច្នោះឯង ។

បទ ថា "**តន្តាហំ**" មានសេចក្តីថា ព្រោះហេតុនោះបានជាយើង (ឪពុក) សូមអង្វរអ្នក ។

## ( ភ័យឧបទ្រពនិងឧបស័គ្គ កើតមានព្រោះជនពាល )

(៣៣) មួយទៀតសោត ភ័យ ឧបទ្រព និងឧបស័គ្គទាំងឡាយណាមួយ ដែលមាន, ភ័យ ឧបទ្រព និងឧបស័គ្គទាំងឡាយទាំងអស់នោះ កើតឡើង ព្រោះអាស្រ័យបុគ្គលពាលទាំងស្រុង ។ មែនពិត បុគ្គលពាល កាលប្រាថ្នានូវភារៈជាព្រះរាជាក្តី ភារៈជាឧបរាជក្តី ឬក៏នូវមុខដំណែងដ៏ធំផ្សេងទៀត បបួលពួកអ្នកលេងធំៗ ចំនួន ២ - ៣ នាក់ ដែលស្មើនឹងខ្លួនបានហើយ និយាយ ថា "អ្នកទាំងឡាយ ចូរមកចុះ, ខ្ញុំនឹងធ្វើពួកអ្នកឲ្យជាធំ" ដូច្នេះហើយអាស្រ័យទីស្ថានស្ងាត់ៗ មានទីញៀតស្បាតនៃភ្នំជាដើម ហើយប្លន់ស្រុកដែលនៅដាច់ស្រយាល ប្លន់និគមខ្លះ ជនបទខ្លះ តាមលំដាប់ ។

មនុស្សទាំងឡាយ នាំគ្នាបោះបង់ចោលផ្ទះហើយ ប្រាថ្នានូវស្ថានទីដ៏ក្សេមក្សាន្ត គៀសខ្លួនចេញទៅ ។ ពួកភិក្ខុក្តី ពួកភិក្ខុនីទាំងឡាយក្តី ដែលនៅអាស្រ័យមនុស្សទាំងឡាយនោះ ក៏រមែងនាំគ្នាបោះបង់ចោលនូវទីលំនៅរបស់ខ្លួន ៗ ចៀសចេញទៅដែរ ។ ភិក្ខាក្តី សេនាសនៈក្តី ក្នុងពេលដែលភិក្ខុ និងភិក្ខុនីទាំងនោះ បានទៅហើយ ៗ ជារបស់រកបានដោយកម្រ ។ សូម្បីក្នុងបព្វជិតទាំងឡាយ ភិក្ខុពាល ២ រូប បង្កើតនូវវិវាទដល់គ្នានឹងគ្នាហើយ ចាប់ផ្តើមចោទគ្នាឡើង ។ ព្រោះហេតុនេះ សេចក្តីឈ្លោះប្រកែកគ្នាដ៏ធំ រមែងកើតឡើង ដល់ពួកបព្វជិតទាំងនោះ ប្រៀបដូចជាសេចក្តីឈ្លោះវិវាទគ្នា ដែលកើតឡើង ដល់ពួកភិក្ខុក្រុងកោសម្ពី ដូច្នោះ ។ ហេតុនៃសេចក្តីទុក្ខ មានភ័យជាដើម មកដល់ពួកបរិស័ទទាំង ៤ ព្រោះអាស្រ័យនូវជនពាល ដោយប្រការដូច្នេះឯង ។

ព្រោះហេតុនោះ ក្នុងលក្ខណសូត្រ(១) មុនព្រះសូត្រទាំងពួងក្នុងតិកនិបាត អង្គុត្តរនិកាយ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ថា “ម្នាលភិក្ខុទាំងឡាយ ភ្លើងតែងឆេះរាលអំពីផ្ទះបបុស ឬផ្ទះស្មៅ មកឆេះផ្ទះកំពូលទាំងឡាយ ដែលគេលាបទាំងខាងក្នុងទាំងខាងក្រៅ មិនមានខ្យល់ចូលបាន មានសន្ទះទ្វារដ៏ជិតស្និទ្ធ មានបង្អួចបិទជិតហើយ ដូចម្តេចមិញ, ម្នាលភិក្ខុទាំងឡាយ

១ ត្រៃបិដក ភាគទី ៤១ / ទំព័រទី ២ ។

ភ័យទាំងឡាយណាមួយ កើតឡើង, ភ័យទាំងអស់នោះ តែងកើតឡើង អំពីជនពាល, មិនមែនកើតឡើង អំពីបណ្ឌិតទេ; ឧបទ្រពទាំងឡាយណាមួយ កើតឡើង, ឧបទ្រពទាំងអស់នោះ តែងកើតឡើង អំពីជនពាល, មិនមែនកើតឡើង អំពីបណ្ឌិតទេ; ឧបស័គ្គទាំងឡាយណាមួយ កើតឡើង, ឧបស័គ្គទាំងអស់នោះ តែងកើតឡើង អំពីជនពាល, មិនមែនកើតឡើង អំពីបណ្ឌិតទេ ក៏យ៉ាងដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលប្រកបដោយភ័យដ៏ពន្លឹក, បណ្ឌិតមិនមានភ័យដ៏ពន្លឹកទេ, បុគ្គលពាលប្រកបដោយឧបទ្រពដ៏ពន្លឹក, បណ្ឌិតមិនមានឧបទ្រពដ៏ពន្លឹកទេ, បុគ្គលពាលប្រកបដោយឧបស័គ្គដ៏ពន្លឹក, បណ្ឌិតមិនមានឧបស័គ្គដ៏ពន្លឹកទេ, ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភ័យមិនមានមក អំពីបណ្ឌិត, ឧបទ្រព មិនមានមក អំពីបណ្ឌិត, ឧបស័គ្គមិនមានមក អំពីបណ្ឌិតឡើយ " ដូច្នេះ ។

(៣៤) អដ្ឋកថានៃលក្ខណសូត្រនោះ ថា "បណ្ដាបទទាំងនោះ បទ ថា "**នឡាគារា វា**" គឺ អំពីផ្ទះដែលគេប្រក់ (បាំង) ដោយបបុសទាំងឡាយ, ប៉ុន្តែគ្រឿងសម្ភារៈដែលសេសសល់ទាំងឡាយក្នុងផ្ទះនេះ រមែងសម្រេចដោយឈើពិតៗ ។ សូម្បីក្នុងផ្ទះស្មៅក៏មានន័យ ដូចនេះដែរ ។ បទ ថា "**កូដាគារានិ**" បានដល់

ផ្ទះដែលសង្គ្រោះដោយកំពូល ។ បទ ថា "**ឧល្លិត្តាវលិត្តានិ**" គឺ ដែលគេបូកហើយ ទាំងខាងក្នុងទាំងខាងក្រៅ ។ បទ ថា "**និវាតានិ**" គឺ បិទផ្លូវខ្យល់មិនឲ្យចូលទៅបាន ។ បទ ថា "**ផុសិតគ្គឡានិ**" គឺ ឈ្មោះថា មានសន្ទះទ្វារ ត្រង់ក្របខាងខ្នង បិទជិតល្អហើយ ព្រោះជារបស់ដែលនាយជាងទាំងឡាយ ដែលឆ្លាត ធ្វើទុកហើយ ។ បទ ថា "**បិហិតវាតបានានិ**" បានដល់ ដែលគេភ្ជាប់បង្អួចទុកហើយ ។ ដោយ ២ បទនេះ ព្រះដ៏មានព្រះភាគ ទ្រង់មិនបានត្រាស់ភាវៈនៃសន្ទះទ្វារ និងបង្អួចថាជារបស់ ដែលបុគ្គលបិទហើយ ជាប្រចាំឡើយ (តែ) ទ្រង់ត្រាស់ការដល់ ព្រម (នៃផ្ទះកំពូល) តែប៉ុណ្ណោះ ។ ក៏សន្ទះទ្វារនិងបង្អួចទាំង ឡាយនោះ គឺបុគ្គលតែងបិទនិងបើកបាន គ្រប់ពេលដែលខ្លួន ប្រាថ្នាហើយ ៗ ។ ២ បទ ថា "**ពាលតោ ឧប្បជ្ជន្តិ**" គឺ តែង កើតឡើង ព្រោះអាស្រ័យនូវបុគ្គលពាលទាំងស្រុង ។ សេចក្តី តក់ស្លុតនៃចិត្ត ឈ្មោះថា ភ័យ ។ អាការ គឺភាវៈនៃចិត្តមាន អារម្មណ៍មិនមែនតែមួយ ឈ្មោះថា ឧបទ្រព ។ អាការ គឺភាវៈ នៃចិត្តទើសទាក់ បានដល់ អាការ គឺភាវៈនៃចិត្តជាប់ជំពាក់នៅ ក្នុងអារម្មណ៍នោះ ៗ ឈ្មោះថា ឧបស័គ្គ " ដូច្នេះ ។

(៣៥) ដីកានៃលក្ខណសូត្រនោះ ថា " ពាក្យ ថា

"ឆន្នបរិច្ឆិន្នា" គឺ ខាងលើគេប្រក់បាំង ដោយដើមបបុសទាំងឡាយ ដោយសង្ខេបគឺការប្រក់បាំងដោយស្មៅ ដោយជុំវិញ គឺគេប្រក់បាំង ដោយដើមបបុសទាំងឡាយនោះដូចគ្នាដែរ ដោយទំនងនៃជញ្ជាំងឈើ (ក្តារ) ។ សេចក្តីតក់ស្លុតនៃចិត្ត របស់បុគ្គលដែលភ័យខ្លាចហើយ ឈ្មោះថា ភ័យ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា 'សេចក្តីតក់ស្លុតនៃចិត្ត' ។ សេចក្តីអន្តរាយ ឈ្មោះថា ឧបទ្រព ។ ក៏ព្រះអដ្ឋកថាចារ្យពោល ថា 'អាការគឺភាវៈនៃចិត្តមានអារម្មណ៍មិនមែនតែមួយ' ព្រោះសេចក្តីអន្តរាយនោះ ជាហេតុនៃសេចក្តីរាយមាយចិត្ត ។ សេចក្តីទើសទាក់ គឺការជួបប្រទះនូវសេចក្តីចង្អៀតចង្អល់ ព្រោះការធ្វើតបវិញមិនបាន ដោយហេតុមានត្រូវទេវតាបៀតបៀនជាដើម ឈ្មោះថា ឧបស័គ្គ ក៏ការជួបប្រទះ នូវសេចក្តីចង្អៀតចង្អល់នោះ ជាហេតុនៃសេចក្តីរញ្ជួររាស្ទាក់ស្ទើរ របស់បុគ្គលដែលកំពុងក្តៅក្រហាយ អ្នកមិនអាចដើម្បីធ្វើអ្វី ៗ បាន ដោយភាវៈគឺធ្វើតបវិញមិនបាន ព្រោះហេតុណា, ព្រោះហេតុនោះ ទើបលោកពោល ថា 'អាការគឺភាវៈដែលចិត្តជាប់ជំពាក់ ក្នុងអារម្មណ៍នោះ ៗ' ដូច្នេះ" ។

(៣៦) ព្រោះហេតុនោះ បុគ្គលពាលទាំងឡាយ គឺ អ្នកមានប្រាជ្ញា គប្បីជ្រាបថា ប្រៀបដូចជាផ្ទះ ដែលត្រូវភ្លើងឆេះហើយ

ដូច្នោះ ។ ព្រោះថា បុគ្គលពាលទាំងនោះ ជាអ្នកអាចក្នុងការនាំសេចក្តីទុក្ខមានភ័យជាដើមគ្រប់យ៉ាង មកប្រគល់ឲ្យ ដល់បុគ្គលទាំងឡាយអ្នកធ្វើតាមពាក្យរបស់ខ្លួន ។ គប្បីជ្រាបបណ្ឌិតទាំងឡាយប្រៀបដូចជាការថែរក្សា ក្នុងទីដែលមានភ័យ ប្រៀបដូចជាប្រទីបក្នុងទីដែលងងឹត និងប្រៀបដូចជាការបានទទួលបាយនិងទឹកជាដើមក្នុងវេលាដែលត្រូវសេចក្តីទុក្ខ មានការស្រេកនិងឃ្លានជាដើម មកគ្របសង្កត់ ដូច្នោះឯង ។ ព្រោះថា បណ្ឌិតទាំងឡាយនោះជាអ្នកអាច ក្នុងការកម្ចាត់សេចក្តីទុក្ខមានភ័យជាដើម គ្រប់យ៉ាងដល់បុគ្គលទាំងឡាយដែលធ្វើតាមពាក្យរបស់ខ្លួនបាន ដូច្នេះឯង ។ បុគ្គលជ្រាបនូវភាវៈនៃជនពាលទាំងឡាយ ប្រៀបស្មើនឹងរបស់ដែលស្មោកគ្រោកមានត្រីស្អុយជាដើម និងបណ្ឌិតទាំងឡាយ ប្រៀបស្មើនឹងគ្រឿងសំអាង មានគ្រឿងក្រអូបជាដើម ទាំងការសេពគប់រកនូវបុគ្គលពាលជាហេតុនាំឲ្យកើតទុក្ខ និងការសេពគប់រកនូវបណ្ឌិតជាហេតុនាំឲ្យបានសេចក្តីសុខ យ៉ាងដូច្នេះហើយ គប្បីសេពគប់រកតែបណ្ឌិតប៉ុណ្ណោះ មិនគួរសេពគប់រកបុគ្គលពាលឡើយ ។

សូម្បីព្រះដ៏មានព្រះភាគ កាលនឹងទ្រង់អប់រំទូន្មានព្រះឆន្នត្ថេរ ទ្រង់បានត្រាស់ហើយ នូវព្រះគាថានេះ ក្នុងបណ្ឌិតវគ្គនៃធម្មបទ ថា ÷

(៣៧) “អ្នកមានប្រាជ្ញា មិនគួរគប់មិត្រអាក្រក់[១] មិនគួរគប់បុរសថោកទាប, គួរគប់រកតែមិត្រ ដែលល្អប្រសើរ គួរគប់រកតែបុរសខ្ពង់ខ្ពស់” ។

បណ្ដាបទទាំងនោះ បទ ថា “**ភជេ**” មានសេចក្ដីថា បណ្ឌិតគួរគប់រក គឺ ចូលទៅអង្គុយជិត ។ បទ ថា “**បុរិសាធមេ**” បានដល់ នូវបុរសថោកទាប គឺ បុរសដែលអាក្រក់ ។ បទ ថា “**ភជេថ**” ប្រែថា គួរសេពគប់ ។ ក៏ក្នុងបុគ្គលទាំង ២ ពួកនេះ បុគ្គលទាំងឡាយណា រមែងត្រេកអរក្រៃលែង ក្នុងទុច្ចរិតទាំងឡាយ មានកាយទុច្ចរិតជាដើម, បុគ្គលទាំងនោះ ឈ្មោះថា បាបមិត្រ ។ ចំណែកបុគ្គលទាំងឡាយណា រមែងប្រកប ក្នុងទីមិនមែនជាឋានៈ មានការកាត់នូវទីតជាដើម ឬ ផ្សេងដោយកម្មមានអនេសនា ២១ ប្រការជាដើម, បុគ្គលទាំងឡាយនោះ ឈ្មោះថា បុរសថោកទាប ។ម្យ៉ាងទៀត បុគ្គលទាំង ២ ពួកនុ៎ះឯង ជាបាបមិត្រផង ជាបុរសដែលថោកទាបផង ។ បុគ្គលដែលផ្ទុយគ្នាអំពីបុគ្គលទាំង ២ ពួកនោះ ជាកល្យាណមិត្រផង ជាបុរសដ៏ខ្ពង់ខ្ពស់ផង ដូច្នេះឯង ។

(៣៨) ក៏ការសេពគប់នូវបណ្ឌិត សូម្បីតែអស់រយៈពេលមួយផង ក៏ឈ្មោះថា រមែងរក្សាឃុំគ្រងខ្លួនបាន, ការសេពគប់

[១] ត្រៃបិដក ភាគទី ៥២ / ទំព័រទី ៣៨ ។

នូវបុគ្គលពាល សូម្បីអស់កាលជាយូរ ក៏មិនឈ្មោះថា ជាការថែរក្សាឃុំគ្រងនូវខ្លួនបានឡើយ ។ ពិតមែនដូច្នោះ នន្ទព្រាហ្មណ៍បានទៅកាន់នគរឥន្ទបត្តបុរី ក្នុងទីបំផុតនៃផ្លូវចម្ងាយ ១២០ យោជន៍អំពីទីក្រុងតក្កសីលា កាលនឹងសំដែងធម៌ ដល់ព្រះរាជាទ្រង់ព្រះនាមមហាសុតសោម បានពោលគាថានេះ ក្នុងមហាសុតសោមជាតក ថា

"បពិត្រព្រះមហារាជ ទ្រង់ព្រះនាមសុតសោម[1] ការចួបប្រទះ ដោយសប្បុរសទាំងឡាយ សូម្បីអស់វារៈតែម្ដង, ការចួបប្រទះនោះ រមែងថែរក្សានូវបុគ្គលនោះបាន, ការចួបប្រទះដោយអសប្បុរសទាំងឡាយ អស់វារៈច្រើនផង រមែងថែរក្សានូវបុគ្គលនោះ មិនបានឡើយ" ។

បណ្ដាបទទាំងនោះ បទ ថា "**សកិទេវ**" ប្រែថា អស់វារៈមួយផងប៉ុណ្ណោះ ។ បទ ថា "**សព្ភិ**" ប្រែថា ដោយសប្បុរសទាំងឡាយ ។ ច្រើនបទ ថា "**សា នំ សង្គតិ**" មានសេចក្ដីថា ការសមាគម ដោយសប្បុរសទាំងឡាយនោះ សូម្បីប្រព្រឹត្តទៅអស់វារៈតែម្ដង រមែងឃុំគ្រង គឺ ថែរក្សានូវបុគ្គលនោះបាន ។ បាទគាថា ថា "**នាសព្ភិ ពហុ សង្គមោ**" មានសេចក្ដីថា ចំណែក

១ ត្រៃបិដក ភាគទី ៦១ / ទំព័រទី ២០២ ។

ការសមាគម គឺ ការនៅអាស្រ័យ ក្នុងទីស្ថានជាមួយគ្នា ដោយពួកអសប្បុរសទាំងឡាយ ដែលបុគ្គលបានធ្វើហើយ សូម្បីអស់កាលដ៏យូរ ក៏រមែងឃុំគ្រង (បុគ្គលនោះ) មិនបានឡើយ, អធិប្បាយ ថា "មិនមែនជាការស្ថិតស្ថេរបានឡើយ" ។

(៣៩) ហេតុនោះ បុគ្គលគួរសេពគប់តែពួកបណ្ឌិតប៉ុណ្ណោះ មិនគួរសេពគប់ពួកជនពាលឡើយ ។ មិនមែនតែមិនគួរសេពគប់នូវពួកជនពាល គួរសេពគប់តែពួកបណ្ឌិត តែម្យ៉ាងប៉ុណ្ណោះទេ, តាមពិតហើយ បុគ្គលនឹងធ្វើបុណ្យអ្វីមួយ ក៏គួរតែធ្វើសេចក្តីប្រាថ្នាផងដែរ ថា "ដោយបុណ្យនេះ ខ្ញុំគប្បីចួបប្រទះ តែពួកបណ្ឌិតទាំងឡាយប៉ុណ្ណោះ មិនគួរចួបប្រទះនូវពួកជនពាលឡើយ" ដូច្នេះ ប្រៀបដូចជាអកិត្តិបណ្ឌិត យ៉ាងដូច្នោះឯង ។

## ( អកិត្តិបណ្ឌិតមិនចង់ចួបប្រទះជនពាល )

បានស្តាប់មក ថា អកិត្តិបណ្ឌិតនោះ កើតជាបុត្រ របស់ព្រាហ្មណ៍មហាសាល អ្នកមានទ្រព្យសម្បត្តិដល់ទៅ ៨០ កោដិ ក្នុងទីក្រុងពារាណសី, កាលបើមាតានិងបិតាបានស្លាប់ចោលទៅហើយ, ក៏បានលះបង់ទ្រព្យសម្បត្តិទាំងអស់ហើយ ក៏បួសជាតាបសឥសី បានមកដល់ទីក្រុងឈ្មោះកបិឡរដ្ឋ ដោយលំដាប់ ហើយក៏អាស្រ័យនៅ

ក្នុងឧទ្យាន ក្បែរទីក្រុងកបិឡរដ្ឋ ញ៉ាំងឈាននិងអភិញ្ញាឲ្យកើតឡើងហើយ ក៏ហោះមកតាមអាកាស ចុះត្រង់កោះដើមដង្កៀបក្ដាមនៅក្បែរកោះដើមខ្នឹង អាស្រ័យនូវដើមដង្កៀបក្ដាមដ៏ធំហើយ ក៏បានសាងបណ្ណសាលានៅ ក្នុងកោះដើមខ្នឹងនោះហើយ ។ តាបសឈ្មោះអកិត្តិបណ្ឌិតនោះ មិនបាននិមន្តទៅ ក្នុងទីណាមួយឡើយ ព្រោះជាអ្នកមានសេចក្ដីប្រាថ្នាតិច ក្នុងពេលដែលដើមឈើនោះមានផ្លែ ក៏ឆាន់ផ្លែ ក្នុងពេលមានសន្លឹក ក៏ឆាន់សន្លឹកដែលស្រុសដោយទឹកក្ដៅ ។ អាសនៈរបស់ស្ដេចសក្កទេវរាជ បានក្ដៅហើយ ព្រោះតេជះនៃសីលរបស់តាបសនោះ ។ ស្ដេចសក្កទេវរាជ ទ្រង់ជ្រាបហេតុនោះហើយ ទ្រង់បានផ្លាស់ភេទជាព្រាហ្មណ៍ ទ្រង់ស្ដេចយាងទៅប្រថាប់ឈរ ធ្វើទំនងដូចជាអ្នកសុំ នៅក្នុងកោះនោះ ។ តាបសស្រុសស្លឹកដង្កៀបក្ដាមហើយ ដាក់ចុះ (អំពីជើងក្រាន) ហើយបានគង់នៅត្រង់មាត់ទ្វារបណ្ណសាលា ដោយតាំងចិត្តថា "អាត្មាអញនឹងឆាន់ស្លឹកដង្កៀបក្ដាមដែលត្រជាក់ហើយ" ដូច្នេះហើយ បានឃើញស្ដេចសក្កទេវរាជនោះ ក៏សោមនស្ស បានដាក់ស្លឹកដង្កៀបក្ដាមទៅក្នុងភាជនៈភិក្ខា របស់ស្ដេចសក្កទេវរាជនោះ មិនបានទុកឲ្យនៅសល់សំរាប់ខ្លួនសោះឡើយ មិនបានស្រុសម្ដងទៀត ហើយញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយសេចក្ដីសុខដែលកើតអំពីបីតិតែប៉ុណ្ណោះឯង ។

ចំណែកស្តេចសក្កទេវរាជ ទ្រង់បានទទួលយកស្លឹកជង្រៀបក្តាមនោះហើយ ស្តេចយាងទៅបន្តិច ទ្រង់បានបាត់ទៅហើយ ។ ស្តេចសក្កទេវរាជ ទ្រង់ស្តេចយាងទៅ ដោយឧបាយនោះឯង រហូត ៣ ថ្ងៃ ។ ចំណែកតាបស ក៏បានថ្វាយអាហារទាំងអស់ ដល់ស្តេចសក្កទេវរាជនោះ រហូតទាំង ៣ ថ្ងៃ ខ្លួនឯងក៏បានអត់អាហារហើយ ។ ក្រោយមក ក្នុងថ្ងៃទី ៣ ស្តេចសក្កទេវរាជ ទ្រង់ជ្រះថ្លាហើយ ក៏ទ្រង់បានប្រទានពរ ដល់តាបសនោះ ។

តាបសនោះ កាលនឹងទទួលនូវពរ បានពោលគាថានេះ ក្នុងអកិត្តិជាតក ក្នុងតេរសនិបាត ថា ៖

(៤០) "អាត្មាសូមកុំឲ្យចួបប្រទះនឹងមនុស្សពាល[១]
សូមកុំឲ្យឮដំណឹងមនុស្សពាល សូមកុំឲ្យនៅរួម
នឹងមនុស្សពាល សូមកុំឲ្យបានធ្វើ ទាំងកុំឲ្យពេញ
ចិត្តនឹងការចរចាទៅមក នឹងមនុស្សពាល " ។

បណ្តាបទទាំងនោះ បទ ថា "ន សុណេ" មានសេចក្តីថា អាត្មាមិនគប្បីបានឮ ដោយត្រចៀកទាំងសងខាងនេះ ថា "ជនពាលរស់នៅក្នុងទីឈ្មោះនោះ" ដូច្នេះឡើយ ។

ស្តេចសក្កទេវរាជ ទ្រង់ព្រះសណ្តាប់ នូវពាក្យនោះហើយ

---

១ ត្រៃបិដក ភាគទី ៥៩ / ទំព័រទី ២៨៧ ។

កាលនឹងទ្រង់ត្រាស់សួរហេតុ ក្នុងការមិនចង់ចួបប្រទះ នូវមនុស្សពាលនោះ ទ្រង់បានត្រាស់គាថានេះ ថា ៖

(១)
" បពិត្រកស្សបៈ ជនពាលបានធ្វើអ្វី ដល់លោក ?,
សូមលោកមេត្តាប្រាប់ហេតុ, បពិត្រកស្សបៈ
ព្រោះហេតុអ្វី ? បានជាលោក មិនប្រាថ្នាចង់ចួប
នូវមនុស្សពាល " ។

បណ្ដាបទទាំងនោះ ច្រើនបទ ថា "កឹ នុ តេ អករំ" សេចក្ដីថា មាតា ឬ បិតា របស់លោកត្រូវជនពាលសម្លាប់ហើយឬ ? ឬក៏បុគ្គលពាល បានធ្វើនូវសេចក្ដីវិនាសអ្វីមួយដទៃទៀត ដល់លោក ? ។

តាបសនោះ កាលទូលហេតុដល់ស្ដេចសក្កៈនោះ បានពោល ថា

" បុគ្គលពាល រមែងណែនាំនូវអំពើដែលមិនគួរ
ណែនាំ រមែងប្រកប ក្នុងកិច្ចមិនមែនជាធុរៈ,
ការណែនាំទៅរកអាក្រក់ ជាការប្រសើរ (របស់
ជនពាលនោះ), ជនពាល បើទុកជាគេនិយាយ
ត្រូវក៏នៅតែខឹង, ជនពាលនោះមិនដឹងវិន័យទេ,
ការមិនចួបប្រទះជនពាលនោះ ជាការប្រពៃ " ។

---

១ ត្រៃបិដក ភាគទី ៥៩ / ទំព័រទី ២៨៧ ។

បណ្ដាបទទាំងនោះ ២ បទ ថា "**អនយំ នយតិ**" មានសេចក្ដីថា បុគ្គលពាល ប្រកាន់យករបស់ដែលមិនមែនជាហេតុ ថា "ជាហេតុ" នឹកគិតតែអំពើដែលគ្មានប្រយោជន៍ យ៉ាងដូច្នេះ ថា "អញនឹងធ្វើនូវកម្មទាំងឡាយ មានបាណាតិបាតជាដើម ហើយចិញ្ចឹមជីវិត" ដូច្នេះ ។ បទ ថា "**អធុរាយំ**" គឺ មិនប្រកបក្នុងសទ្ធាធុរៈ សីលធុរៈ និងបញ្ញាធុរៈទាំងឡាយ (បែរជា) ប្រកបក្នុងរឿងដែលមិនគួរប្រកបវិញ ។ បទ ថា "**ទុន្នយោ**" មានសេចក្ដីថា ការណែនាំអាក្រក់ប៉ុណ្ណោះ ជាការប្រសើរ របស់បុគ្គលពាលនោះ ។ គឺ បុគ្គលពាលនោះ តែងប្រកាន់ យ៉ាងនេះ ថា "ការសមាទានកម្ម គឺការទ្រុស្តសីល ៥ យ៉ាង ហើយប្រព្រឹត្តនុ៎ះឯង ជាការប្រសើរ" ។ ម្យ៉ាងទៀត បុគ្គលពាលនោះ គឺបណ្ឌិតណែនាំបានដោយលំបាក គឺជាអ្នកដែលបុគ្គលណាមួយ មិនអាចដើម្បីនឹងណែនាំ ក្នុងខប្រតិបត្តិដែលមានប្រយោជន៍បានឡើយ ។ បទ ថា "**សម្មា**" គឺ សូម្បីអ្នកដទៃនិយាយហើយ ដោយហេតុ គឺ ដោយការណ៍ ។ បទ ថា "**វិនយំ**" មានសេចក្ដីថា ជនពាលមិនស្គាល់ច្បាស់ នូវមារយាទនិងឧបាយគ្រឿងណែនាំ ថា "គប្បីឈានទៅខាងមុខ យ៉ាងនេះ" ដូច្នេះជាដើម និងមិនព្រមទទួលយកនូវឱវាទឡើយ ។ បទ ថា "**សាធុ តស្ស**" មានសេចក្ដីថា ដោយហេតុទាំងឡាយនេះ

ការមិនចួបប្រទះ នូវជនពាលជាដាច់ខាត ជាការប្រសើរណាស់ ។

តាបស កាលនឹងទទួលពរជទៃថ្មីទៀត ទើបបានពោល ថា ៖

“ អាត្មាភាព សូមឲ្យបានចួបប្រទះតែនឹងអ្នកប្រាជ្ញ(១) សូមឲ្យបានស្តាប់ព្ទតែអ្នកប្រាជ្ញ សូមឲ្យបាននៅរួមគ្នាជាមួយនឹងអ្នកប្រាជ្ញ សូមឲ្យបានធ្វើទាំងសូមឲ្យបានចូលចិត្ត នូវការចរចាប្រាស្រ័យគ្នាទៅវិញទៅមក ជាមួយនឹងអ្នកប្រាជ្ញនោះ ” ។

ស្តេចសក្កទេវរាជ ទ្រង់បានត្រាស់សួរ ថា ៖

“ បពិត្រកស្សបៈ អ្នកប្រាជ្ញ បានធ្វើប្រយោជន៍អ្វីខ្លះ ដល់លោក ?, សូមលោកប្រាប់នូវហេតុ, បពិត្រកស្សបៈ ព្រោះហេតុអ្វី ? បានជាលោកចង់ចួបប្រទះតែនឹងអ្នកប្រាជ្ញ ” ។

តាបស បានទូលហើយ ថា ៖

“ អ្នកប្រាជ្ញ មិនណែនាំនូវហេតុដែលមិនគួរណែនាំ រមែងមិនប្រកប ក្នុងកិច្ចដែលមិនមែនជាធុរៈ ,

១ ត្រៃបិដក ភាគទី ៥៩ / ទំព័រទី ២៨៨ ។

ការណែនាំល្អ ជាការប្រសើរ របស់អ្នកប្រាជ្ញនោះ, អ្នកប្រាជ្ញ បើទុកជាគេនិយាយត្រូវហើយ ក៏នៅតែមិនក្រោធខឹងដែរ, អ្នកប្រាជ្ញនោះ រមែងដឹងច្បាស់នូវឧបាយគ្រឿងណែនាំ, កាសេពគប់រកជាមួយនឹងអ្នកប្រាជ្ញនោះ ជាការប្រពៃណាស់ " ។

(៤១) មែនពិត ការចួបប្រទះនឹងបណ្ឌិត ជាហេតុនាំឲ្យបាននូវសេចក្ដីសុខ, ឯការចួបប្រទះនឹងបុគ្គលពាល ជាហេតុនាំឲ្យបាននូវសេចក្ដីទុក្ខ ; ដោយហេតុនោះ ក្នុងសក្កទេវិន្ទវត្ថុ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ថា ÷

"ការចួបប្រទះនូវព្រះអរិយទាំងឡាយ ជាការប្រពៃ,[១] ការនៅរួមជាមួយគ្នា ជាហេតុឲ្យបានសេចក្ដីសុខក្នុងទីសព្វ ៗ កាល, បុគ្គលគប្បីជាអ្នកមានសេចក្ដីសុខ អស់កាលជានិច្ចនិរន្តរ៍ ដោយពិតប្រាកដបាន ព្រោះការមិនចួបប្រទះ នូវជនពាលទាំងឡាយ " ។

បណ្ដាបទទាំងនោះ បទ ថា "**អរិយានំ**" មានសេចក្ដីថា ម្នាលភិក្ខុទាំងឡាយ កិរិយាចួបប្រទះនូវសប្បុរសទាំងឡាយ គឺ

---

១ ត្រៃបិដក ភាគទី ៥២ / ទំព័រទី ៦៤ ។

បណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើម ជាការប្រពៃ គឺជាការប្រសើរ បានដល់ ជាការល្អ, អធិប្បាយ ថា "ជាហេតុឲ្យបានសេចក្តីសុខ" ។ មិនមែនតែការបានចួបប្រទះ នូវព្រះអរិយទាំងឡាយនោះ តែម្យ៉ាង ប៉ុណ្ណោះទេ (ជាការប្រសើរ), តាមពិតហើយ សូម្បីភាវៈគឺការអង្គុយជាដើម ក្នុងទីជាមួយគ្នានឹងព្រះអរិយទាំងឡាយនោះ ក៏ជាការប្រសើរបានដូចគ្នាដែរ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ ថា "ការនៅរួមជាមួយគ្នា" ដូច្នេះជាដើម ។

បទ ថា "**អទស្សនេន**" គឺ ព្រោះហេតុនៃការមិនចួបប្រទះ ។ បទ ថា "**សុខី**" គឺ បុគ្គលអ្នកមានសេចក្តីសុខ ។

បាឋៈ ថា "**សុខិ**" ដូច្នេះ ក៏មានខ្លះដែរ ។

(៤២) មែនពិត បុគ្គលអ្នកសេពគប់នូវជនពាលជាប្រក្រតី កាលធ្វើតាមពាក្យរបស់ជនពាល រមែងចួបប្រទះ នូវសេចក្តីទុក្ខ, ចំណែកបុគ្គលអ្នកសេពគប់នូវបណ្ឌិតជាប្រក្រតី កាលធ្វើតាមពាក្យរបស់បណ្ឌិត រមែងបាននូវសេចក្តីសុខ ។ ក៏ក្នុងដំណើរនេះ មានភិក្ខុអ្នកប្រាថ្នាចង់សឹក ជាឧទាហរណ៍ ។

## ( រឿងវិព្ភន្តិកភិក្ខុ )

បានឮមក ថា ភិក្ខុរូបនោះ ជាសទ្ធិវិហារិក របស់ព្រះថេរៈ

ឈ្មោះព្រះមហាកស្សបៈ ជាអ្នកបានសម្រេចចតុត្ថជ្ឈាន បានឃើញនូវអារម្មណ៍ដែលជាសឹកសត្រូវ ក្នុងផ្ទះរបស់ឳពុកធំ របស់ខ្លួនហើយ ក៏មានចិត្តប្រតិព័ទ្ធ ក្នុងអារម្មណ៍នោះ សឹកមកហើយ ត្រូវគេដេញចេញអំពីផ្ទះ ព្រោះជាអ្នកខ្ជិលច្រអូស ជឿតាមពាក្យរបស់ពួកជនដែលជាបាបមិត្រ ដើរធ្វើការចិញ្ចឹមជីវិត ដោយចោរកម្ម ។ ក្នុងថ្ងៃមួយ បុរសនោះ ត្រូវពួករាជបុរសចាប់បានខ្លួន ចងស្លាបសេកយ៉ាងជាប់ហើយ យកផ្តៅមកវាយ មួយកន្លែង ៤ ។ នាំបណ្តើរទៅកាន់ស្ថានទីសម្លាប់ តាមមាត់ទ្វារខាងត្បូង នៃទីក្រុងរាជគ្រឹះ ។

ក្នុងថ្ងៃនោះ ព្រះមហាកស្សបៈ និមន្តចូលទៅកាន់ព្រះនគរដើម្បីនឹងបិណ្ឌបាត ឃើញបុរសនោះហើយ ក៏បានឱ្យពួករាជបុរសបន្ធូរខ្សែចំណងហើយ បានពោល ថា "ចូរអ្នកនឹកពិចារណាយកកម្មដ្ឋានដែលអ្នកធ្លាប់បានអប់រំហើយ ក្នុងកាលមុន សាឡើងវិញ" ។ បុរសនោះ ជឿតាមពាក្យ របស់ព្រះថេរៈហើយ ក៏បានញុំាងឈានទី ៤ ឱ្យកើតឡើងម្តងទៀត ត្រូវពួករាជបុរសទាំងនោះ នាំបណ្តើរទៅកាន់ទីស្ថានសម្លាប់ហើយ ឱ្យដេកផ្ងារនៅលើចម្រូងដែកក្តី ត្រូវរាជបុរសសម្លុត ដោយគ្រឿងអាវុធទាំងឡាយក្តី ក៏មិនភិតភ័យ ។ ពួករាជបុរសទាំងឡាយ ឃើញនូវបុរសនោះ មិនភ័យខ្លាច ក៏បានក្រាបទូល ដល់ព្រះបាទពិម្ពិសារ ។ ព្រះរាជាទ្រង់ត្រាស់

ថា "អ្នកទាំងឡាយ ចូរដោះលែងបុរសនោះទៅចុះ" ដូច្នេះហើយ ស្ដេចយាងទៅកាន់វត្តវេឡុវ័ន បានក្រាបទូលព្រះសាស្ដាហើយ ។ ព្រះសាស្ដា ទ្រង់គង់ ក្នុងវត្តវេឡុវ័ន ទ្រង់បានផ្សាយព្រះរស្មីទៅ ហើយទ្រង់សំដែងធម៌ ដល់បុរសនោះ ។ បុរសនោះ បានអង្គុយស្ដាប់ព្រះធម៌ទេសនា នៅលើចុងចម្រូងដែកនេះឯង ពិចារណានូវសង្ខារទាំងឡាយ លើកឡើងកាន់ត្រៃលក្ខណ៍ ក៏បានសម្រេចជាព្រះសោតាបន្នហើយ បានទៅកាន់សំណាក់ នៃព្រះសាស្ដា តាមវេហាស៍ បួសហើយក៏បានសម្រេចព្រះអរហត្ត នៅត្រង់កណ្ដាលពួកបរិស័ទព្រមទាំងព្រះរាជានុ៎ះឯង ដោយប្រការដូច្នេះ ។

រឿង វិត្តន្តិកភិក្ខុ ក្នុងគណ្ឋាវគ្គ នៃធម្មបទ ចប់ ។

(៤៣)ម្យ៉ាងទៀត បុគ្គលពាលទាំងឡាយ រមែងញ៉ាំងខ្លួន និងពួកជនដែលធ្វើតាមពាក្យ របស់ខ្លួនឲ្យវិនាស ដោយហេតុដែលខ្លួនប្រកាន់ហើយមិនល្អ ដូចជាបាបជនទាំងឡាយ មានព្រះភិក្ខុឈ្មោះទេវទ័តជាដើម យ៉ាងដូច្នោះឯង ។

## ( រឿងភិក្ខុទេវទ័ត )

បានឮថា ភិក្ខុទេវទ័ត បួសតាមព្រះសាស្ដា ជាអ្នកបានឫទ្ធិជាបុថុជ្ជន ក្រោយមក បានជាអ្នកមានលាភសក្ការ គឺព្រះបាទ

អជាតសត្រូវទ្រង់ធ្វើថ្វាយហើយ ។ ព្រះទេវទ័តនោះ ត្រូវលាភសក្ការគ្របសង្កត់ហើយ បានញ៉ាំងចិត្តដ៏លាមក ឲ្យកើតឡើងហើយថា “អាត្មាអញនឹងគ្រប់គ្រងនូវព្រះភិក្ខុសង្ឃ” ដូច្នេះហើយ ក៏បានវិនាសសាបសូន្យចាកឫទ្ធិ ព្រមទាំងការកើតឡើងនៃចិត្ត, ថ្ងៃមួយបាននិមន្តទៅកាន់វត្តវេឡុវ័ន ថ្វាយបង្គំព្រះសាស្តាហើយ ក្រាបទូលថា “បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ព្រះដ៏មានព្រះភាគ ទ្រង់ចាស់ជរា ចម្រើនវ័យ ចាស់គ្រាំគ្រាណាស់ទៅហើយ សូមទ្រង់មានសេចក្តីខ្វល់ខ្វាយតិច ប្រកបនៅជាសុខជានិច្ច ក្នុងបច្ចុប្បន្នចុះ, ទូលព្រះបង្គំ នឹងគ្រប់គ្រងព្រះភិក្ខុសង្ឃ, សូមព្រះអង្គប្រគល់ឲ្យនូវភិក្ខុសង្ឃ ដល់ទូលព្រះបង្គំចុះ” ដូច្នេះហើយ ត្រូវព្រះសាស្តាមិនទ្រង់ជ្រះថ្លាហើយ ទ្រង់បដិសេធ ដោយវាទៈថាព្រះទេវទ័តជាអ្នកស៊ីនូវបច្ច័យ ៤ ដូចជាទឹកមាត់ ទើបខូចចិត្ត ក៏បានចងគំនុំក្នុងព្រះសាស្តាហើយ បានចៀសចេញទៅ ។ ក្រោយមក ព្រះទេវទ័តនោះបានប្រឹក្សាជាមួយនឹងព្រះបាទអជាតសត្រូវហើយ បញ្ជូនពួកខ្មាន់ធ្នូទៅ ដើម្បីនឹងធ្វើគត់ដល់ព្រះសាស្តា, កាលបើពួកខ្មាន់ធ្នូទាំងនោះសម្រេចនូវផលទី ១ ហើយ ត្រឡប់មកវិញ, ក៏បានឡើងទៅលើភ្នំគិជ្ឈកូដ ដោយខ្លួនឯង ប្រមៀលដុំសីលា ធ្វើកម្មគឺការញ៉ាំងព្រះលោហិតឲ្យរងជាំហើយ ឲ្យលែងដំរីឈ្មោះនាឡាគិរីទៅ ដើម្បីនឹង

ធ្វើគត់ព្រះសាស្តា ម្តងទៀតឲ្យទាល់តែបាន ក៏មិនអាចដើម្បីនឹងធ្វើគត់ព្រះអង្គបានឡើយ ។ ព្រះទេវទ័តនោះ មានលាភនិងសក្ការសាបសូន្យហើយ តាំងតែអំពីពេលនោះមក ជាអ្នកមានបំណងនឹងចិញ្ចឹមជីវិត ដោយការបោកបញ្ឆោតគេ ទើបចូលទៅគាល់ព្រះសាស្តាហើយ ក្រាបទូលសុំនូវវត្ថុ ៥ យ៉ាង ថា "បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់ប្រទានឱកាស, ភិក្ខុទាំងឡាយ គប្បីជាអ្នកនៅក្នុងព្រៃជាវត្ត, គប្បីជាអ្នកត្រាច់ទៅបិណ្ឌបាតជាវត្ត, គប្បីប្រើប្រាស់សំពត់បំសុកូលជាវត្ត, គប្បីជាអ្នកនៅក្រោមដើមឈើជាវត្ត, មិនគួរឆាន់នូវត្រីនិងសាច់ រហូតអស់មួយជីវិត" ។ ព្រះសាស្តាមិនទ្រង់យល់ព្រមឡើយ ។ ព្រះទេវទ័តនោះ ពោល ថា "ភិក្ខុរូបណា ប្រាថ្នាចង់រួចចាកសេចក្តីទុក្ខ, ភិក្ខុរូបនោះ ចូរនិមន្តមកជាមួយនឹងខ្ញុំចុះ" ដូច្នេះ, ភិក្ខុទាំងឡាយណា ជឿនូវពាក្យ របស់ព្រះទេវទ័តនោះ, ក៏បបួលនូវភិក្ខុទាំងឡាយនោះទៅហើយ ញ៉ាំងជនដែលជ្រះថ្លាហើយ ក្នុងវត្ថុដែលសៅហ្មង ឲ្យយល់ព្រម ដោយវត្ថុទាំងឡាយ ៥ យ៉ាង ឲ្យសូម (បច្ច័យ៤) ក្នុងត្រកូលទាំងឡាយយកមកឆាន់ ព្យាយាមដើម្បីនឹងបំបែកសង្ឃ ក្នុងថ្ងៃឧបោសថ បានគង់រួមជាមួយនឹងបរិស័ទ របស់ខ្លួន ហើយពោល ថា "វត្ថុទាំងឡាយ ៥ យ៉ាងនេះ រមែងសមគួរ ដល់ភិក្ខុរូបណា, ភិក្ខុរូបនោះ

ចូរចាប់នូវសលាកចុះ ”ដូច្នេះ, កាលបើភិក្ខុទាំងឡាយ ៥០០ រូប អ្នកមិនឆ្លាត ក្នុងព្រះធម្មវិន័យ នាំគ្នាចាប់សលាកហើយ, ក៏បំបែកសង្ឃស្រេចហើយ ទើបបានទៅកាន់គយាសីសវិហារ ។ តាំងតែអំពីពេលនោះមក ព្រះទេវទ័តនោះ ក៏កើតអាពាធ រហូត ៩ ខែ ជាអ្នកប្រាថ្នាចង់គាល់ព្រះសាស្តា ត្រូវបានពួកសាវ័ក របស់ខ្លួន សែងនឹងគ្រែតូច ទៅកាន់ទីក្រុងសាវត្ថី បានទៅដល់មាត់ស្រះបោក្ខរណី ដែលស្ថិតនៅខាងក្រៅវត្តជេតពនហើយ ក៏បានចូលទៅកាន់ផែនដីបានទៅកើត ក្នុងអវិចីនរកហើយ ។

រឿង ព្រះទេវទ័ត ចប់ ។

## ( រឿង ព្រះបាទអជាតសត្រូវ )

(៤៤) ចំណែកព្រះបាទអជាតសត្រូវ អាស្រ័យភិក្ខុទេវទ័តហើយ បានកាត់ផ្តាច់នូវឧបនិស្ស័យ នៃមគ្គនិងផល ខាងដើម ដែលព្រះអង្គត្រូវបាន ក្នុងបច្ចុប្បន្ន (តែ) ទ្រង់បានទទួល នូវសេចក្តីវិនាសដ៏ធំ ព្រោះទ្រង់ធ្វើកម្ម គឺការធ្វើគត់ព្រះបិតា ។

បានឮថា ព្រះបាទអជាតសត្រូវអង្គនោះ ក្នុងពេលដែលព្រះអង្គជាព្រះឧបរាជ ទ្រង់ជ្រះថ្លាហើយ ក្នុងឥទ្ធិបាដិហារិយ៍ របស់ព្រះទេវទ័ត ទ្រង់បានស្តេចយាងទៅកាន់ទីឧបដ្ឋាក របស់ព្រះទេវទ័តនោះ

ទាំងពេលព្រឹក ទាំងពេលល្ងាច រៀងរាល់ថ្ងៃ ។ ក្រោយមក ថ្ងៃមួយ ព្រះទេវទ័ត បានចូលទៅរកព្រះបាទអជាតសត្រូវនោះហើយ ថ្វាយព្រះពរ ថា "បពិត្រព្រះរាជកុមារ ក្នុងកាលមុន មនុស្សទាំងឡាយ ជាអ្នកមានអាយុវែង, ឥឡូវនេះ មនុស្សទាំងឡាយ ជាអ្នកមានអាយុខ្លី, បើដូច្នោះ ចូរព្រះអង្គទ្រង់ធ្វើគត់នូវព្រះរាជបិតាហើយ ឡើងជាព្រះរាជា (ដោយព្រះអង្គឯង), (ចំណែក) អាត្មាភាពធ្វើគត់ព្រះដ៏មានព្រះភាគហើយ នឹងឡើងជាព្រះពុទ្ធ" ។ ព្រះបាទអជាតសត្រូវនោះ ទ្រង់ជឿនូវពាក្យ របស់ព្រះទេវទ័តនោះហើយ ទ្រង់កាន់យកនូវកាំបិតស្នៀត យាងចូលទៅខាងក្នុងនៃព្រះនគរ ក្នុងវេលាថ្ងៃត្រង់ ។ អាមាត្យទាំងឡាយ ចាប់បានព្រះបាទអជាតសត្រូវនោះហើយ ក៏បានក្រាបទូលសាកសួរហើយ ទើបបានក្រាបទូលរឿងនោះ ថ្វាយដល់ព្រះរាជា ។

ព្រះរាជា ទ្រង់ត្រាស់សួរ ថា "នែព្រះកុមារ អ្នកប្រាថ្នាដើម្បីនឹងធ្វើគត់បិតា តើដើម្បីប្រយោជន៍អ្វីទៅ ?" ។

ព្រះបាទអជាតសត្រូវ ក្រាបទូល ថា "បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំ ជាអ្នកត្រូវការ ដោយរាជសម្បត្តិ" ។

ព្រះរាជា ទ្រង់បានព្រះរាជទានរាជសម្បត្តិ ដល់ព្រះបាទអជាតសត្រូវនោះហើយ ។ ព្រះបាទអជាតសត្រូវនោះ ទ្រង់

បានពិតដល់ព្រះទេវទ័ត ថា "សេចក្ដីប្រាថ្នា របស់ខ្ញុំព្រះករុណា បានសម្រេចហើយ" ។

ព្រះទេវទ័ត . ព្រះអង្គទ្រង់ប្រៀបបាននឹងបុរសដែលឃាំងឆ្កែចចក ទុកខាងក្នុង (ស្គរ) ហើយ ដាស់ស្គរទុក ដូច្នោះឯងទ្រង់សម្គាល់ ថា 'អាត្មាអញ ជាអ្នកធ្វើកិច្ចការដ៏ល្អ' ដូច្នេះ, ដោយរយៈពេល ២-៣ ថ្ងៃប៉ុណ្ណោះ ព្រះបិតារបស់ព្រះអង្គ នឹងទ្រង់ព្រះតម្រិះនូវការមើលងាយ ដែលព្រះអង្គទ្រង់បានធ្វើហើយ ក៏នឹងទ្រង់ឡើងជាព្រះរាជាខ្លួនព្រះអង្គឯង ដោយពិតប្រាកដ" ។

ព្រះបាទអជាតសត្រូវ . បពិត្រលោកម្ចាស់ តើខ្ញុំព្រះករុណានឹងធ្វើដូចម្ដេចទៅ ? ។

ព្រះទេវទ័ត . ចូរព្រះអង្គ ទ្រង់ធ្វើគត់ព្រះបិតានោះចុះ ។

ព្រះបាទអជាតសត្រូវ . បពិត្រលោកម្ចាស់ ព្រះរាជបិតារបស់ខ្ញុំព្រះករុណា ជាអ្នកដែលគេមិនគួរធ្វើគត់ ដោយសស្ត្រាវុធមិនមែនទេឬ ? ។

ព្រះទេវទ័ត . ចូរព្រះអង្គ ទ្រង់ធ្វើគត់ព្រះរាជបិតារបស់ព្រះអង្គនោះ ដោយការបង្អត់ព្រះក្រយាស្ងោយចុះ ។

ព្រះបាទអជាតសត្រូវនោះ ទ្រង់ត្រាស់បញ្ជាឲ្យរាជបុរសចាប់ឃុំឃាំងព្រះរាជបិតា ទុកក្នុងពន្ធនាគារដែលក្ដៅ ពោលគឺពន្ធនាគារ

ដែលពោរពេញទៅដោយផ្សែងភ្លើង ដែលគេសាងហើយ ដើម្បីសម្រាប់ដាក់នូវទណ្ឌកម្ម ហើយត្រាស់បញ្ជា ថា "លើកលែងតែព្រះវរមាតារបស់យើងចេញ ពួកអ្នកចូរកុំឱ្យអ្នកដទៃចូលគាល់បាន"។

ព្រះរាជទេវី ទ្រង់បានដាក់ព្រះក្រយាស្ងោយ ក្នុងផ្តិលមាស ទ្រង់ដាក់នឹងថ្នក់ព្រះភូសា យាងចូលទៅ ថ្វាយដល់ព្រះរាជា ។

ព្រះបាទពិម្ពិសារអង្គនោះ ទ្រង់ញ៉ាំងព្រះអត្តភាព ឱ្យប្រព្រឹត្តទៅដោយព្រះក្រយាស្ងោយនោះ ។

ព្រះបាទអជាតសត្រូវ ទ្រង់ត្រាស់សួរ ថា "ព្រះរាជបិតារបស់ខ្ញុំ ទ្រង់ញ៉ាំងព្រះវរកាយ ឱ្យប្រព្រឹត្តទៅ យ៉ាងដូចម្តេច ?" ដូច្នេះហើយ ទ្រង់ព្រះសណ្តាប់នូវរឿងនោះ ទើបទ្រង់ត្រាស់ ថា "អ្នកទាំងឡាយ ចូរកុំឱ្យព្រះរាជមាតា របស់យើង ស្តេចវេចខ្ចប់ព្រះក្រយាស្ងោយ ក្នុងថ្នក់ព្រះភូសា យាងចូលទៅឡើយ" ។

ព្រះរាជទេវី ទ្រង់បានដាក់ព្រះក្រយាស្ងោយ ក្នុងព្រះមោលីហើយ ស្តេចយាងចូលទៅ ។

ព្រះបាទអជាតសត្រូវ ទ្រង់ព្រះសណ្តាប់រឿងនោះហើយ ទើបទ្រង់ត្រាស់ ថា "អ្នកទាំងឡាយ ចូរកុំឱ្យព្រះរាជមាតា របស់យើងស្តេចចងព្រះមោលី យាងចូលទៅឡើយ" ។

ព្រះរាជទេវី ទ្រង់ដាក់ព្រះក្រយាស្ងោយ ក្នុងព្រះសុព៌ណ៌បាទុក

ទ្រង់បិទជិតហើយ ទើបទ្រង់ឆ្លងព្រះបាទុក ស្តេចយាងចូលទៅ ។

ព្រះបាទអជាតសត្រូវ ទ្រង់ព្រះសណ្តាប់រឿងនោះហើយ ទើបទ្រង់ត្រាស់ ថា "អ្នកទាំងឡាយ ចូរកុំឱ្យព្រះវរមាតា របស់យើងទ្រង់ឆ្លងព្រះបាទុក ស្តេចយាងចូលទៅឡើយ" ។

ព្រះរាជទេវី ទ្រង់បានស្រង់ (ព្រះវរកាយ) ដោយទឹកដែលមានក្លិនក្រអូប ទ្រង់លាបព្រះវរកាយ ដោយគ្រឿងក្រអូប ៤ យ៉ាងហើយ ទ្រង់ព្រះភូសា ស្តេចយាងចូលទៅ ។

ព្រះរាជា ទ្រង់លិទ្ធព្រះវរកាយ របស់ព្រះរាជទេវីហើយ ទ្រង់ញ៉ាំងព្រះវរកាយ ឱ្យប្រព្រឹត្តទៅ ។

មានពាក្យសួរ ថា "ការស្លាប់ ដោយសេចក្តីព្យាយាម របស់ខ្លួនឯង (គឺ សម្លាប់ខ្លួនឯង) មិនគួរទេឬ ?" ។

មានពាក្យឆ្លើយ ថា "មែនពិត ព្រះអរិយសាវ័កទាំងឡាយ រមែងមិនញ៉ាំងខ្លួន ឱ្យធ្លាក់ចុះ (សម្លាប់ខ្លួនឯង) ឡើយ" ។

ព្រះបាទអជាតសត្រូវ ទ្រង់ត្រាស់សួរ ម្តងទៀតហើយ ទ្រង់ព្រះសណ្តាប់រឿងនោះហើយ ទើបទ្រង់ត្រាស់បញ្ជា ថា "ចាប់តាំងអំពីពេលនេះទៅ អ្នកទាំងឡាយ ចូរហាមប្រាម កុំឱ្យព្រះវរមាតា របស់យើង ស្តេចយាងចូលទៅឡើយ" ។

ព្រះរាជទេវី ទ្រង់គង់នៅ ក្បែរមាត់ទ្វារហើយ ទ្រង់បាន

ក្រាបទូល ថា “បពិត្រព្រះបាទពិម្ពិសារ ព្រះរាជស្វាមី ឥឡូវនេះ នេះជាការចូលគាល់ព្រះអង្គនៅគ្រាចុងក្រោយ, តាំងអំពីថ្ងៃនេះទៅ ទូលព្រះបង្គំ នឹងមិនបានចូលគាល់ព្រះអង្គឡើយ, បពិត្រព្រះសម្មតិទេព បើទោសរបស់ទូលព្រះបង្គំមាន, សូមព្រះអង្គ ទ្រង់អត់ទោសផងចុះ” ដូច្នេះ ទ្រង់ព្រះកន្សែងហើយ ទើបស្តេចយាងត្រឡប់ទៅវិញ ។

តាំងអំពីពេលនោះមក ព្រះរាជាទ្រង់អត់ព្រះក្រយាស្ងោយ ទ្រង់ញ៉ាំងព្រះវរកាយ ឲ្យប្រព្រឹត្តទៅ ដោយការស្តេចយាងចង្ក្រម ដែលប្រកបដោយសេចក្តីសុខ ដែលកើតអំពីមគ្គនិងផល ។ ក៏ព្រះវរកាយ របស់ព្រះអង្គនោះ ទ្រង់ភ្លឺស្វាងរុងរឿង យ៉ាងក្រៃលែង ។

ព្រះបាទអជាតសត្រូវ ទ្រង់ត្រាស់សួរ ថា “តើព្រះរាជបិតា របស់យើង ទ្រង់ញ៉ាំងព្រះវរកាយឲ្យប្រព្រឹត្តទៅ យ៉ាងដូចម្តេច ?” ដូច្នេះ ទ្រង់ព្រះសណ្តាប់ ថា “ដោយការស្តេចយាងចង្ក្រម” ហើយ ទ្រង់បានបញ្ជូន នូវខ្ញាន់ព្រះកេសទាំងឡាយទៅ ដោយព្រះរាជឱង្ការ ថា “អ្នកទាំងឡាយ ចូរយកកាំបិតកោរ អារព្រះបាទទាំងទ្វេ របស់ព្រះរាជបិតា របស់យើង ហើយប្រទ្បាក់ប្រេងដែលផ្សំដោយអំបិលស្រេចហើយ យករងើកភ្លើងឧសសង្កែ មករោល” ។

ខ្ញាន់ព្រះកេសទាំងនោះ បានទៅក្រាបបង្គំទូលព្រះរាជឱង្ការ

ដល់ព្រះរាជា ត្រូវបានព្រះអង្គទ្រង់ត្រាស់ ថា "អ្នកទាំងឡាយ ចូរធ្វើ (តាម) ព្រះរាជហឫទ័យនៃព្រះរាជា របស់អ្នកទាំងឡាយចុះ" ដូច្នេះហើយ ទើបក្រាបទូល ថា "បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់គង់ចុះ, ទូលព្រះបង្គំទាំងឡាយ នឹងធ្វើ (តាម) ព្រះរាជអាជ្ញារបស់ព្រះរាជា, សូមព្រះអង្គ កុំទ្រង់ព្រះពិរោធ ដល់ពួកទូលព្រះបង្គំឡើយ, កម្មនេះ ជាកម្មមិនសមគួរ ដល់ព្រះរាជាដែលទ្រទ្រង់នូវធម៌ ដូចជាព្រះអង្គឡើយ" ដូច្នេះហើយ ក៏បានធ្វើតាមព្រះរាជបញ្ជាដូច្នោះហើយ ។

## ( បុព្វកម្មរបស់ព្រះបាទពិម្ពិសារ )

បានឮ ថា ក្នុងកាលមុន ព្រះរាជាទ្រង់បានទ្រង់ព្រះបាទុកលើលានព្រះចេតិយ ដែលជាស្ថានទីបូជា ដោយគ្រឿងសក្ការទាំងឡាយ មានគ្រឿងក្រអូបនិងផ្កាជាដើម ។ អាចារ្យពួកខ្លះពោល ថា "ព្រះបាទពិម្ពិសារអង្គនោះ ទ្រង់យាងលើកន្ទេលដែលគេក្រាលហើយ ដើម្បីប្រយោជន៍ដល់ការគង់ របស់ព្រះភិក្ខុសង្ឃ ដោយព្រះបាទទាំង ២ ដែលមិនបានលាងហើយ, នេះគឺជាផលនៃកម្មនោះ" ដូច្នេះ ក៏មានដែរ ។

ព្រះរាជា ទ្រង់ទទួលវេទនាដ៏ធ្ងន់ ទ្រង់នឹករឮកតែម្យ៉ាង

ប៉ុណ្ណោះ ថា “អស្ចារ្យមែន! ព្រះពុទ្ធ, អស្ចារ្យមែន! ព្រះធម៌, អស្ចារ្យមែន! ព្រះសង្ឃ” ដូច្នេះ ស្ដេចទ្រង់ចុតិ ទៅកើតជាយក្ស ឈ្មោះជនវសភៈ ជាអ្នកបំរើស្ដេចវេស្សវណ្ណ ក្នុងទេវលោកជាន់ចាតុមហារាជិកា ដោយអំណាចនៃការសព្វព្រះរាជហឫទ័យ ដែលព្រះអង្គទ្រង់បានអប់រំមកដ៏យូរអង្វែង ព្រោះព្រះអង្គទ្រង់ធ្លាប់បានទៅកើត ក្នុងទេវលោកជាន់ចាតុមហារាជិកានោះជាច្រើនដង ។

ព្រះបាទអជាតសត្រូវអង្គនោះ ទ្រង់បានធ្វើគត់ព្រះវររាជបិតា ដូចបានពណ៌នាមកហើយនេះ ខាងក្រោយមក ក៏ទ្រង់កើតសេចក្ដីស្រឡាញ់ចំពោះព្រះវរបិតា ទើបទ្រង់ព្រះកន្សែង ខ្សឹកខ្សួលហើយទ្រង់បានថ្វាយព្រះភ្លើងព្រះសព របស់ព្រះបាទពិម្ពិសារនោះហើយ ។

## ( ព្រះបាទអជាតសត្រូវទ្រង់នឹកឃើញកំហុស )

បន្ទាប់ពីនោះមក ព្រះភិក្ខុទេវទត្ត បានប្រឹក្សាគ្នាជាមួយនឹងព្រះបាទអជាតសត្រូវនោះ ហើយធ្វើអំពើអាក្រក់ រាប់តាំងអំពីបញ្ជូននាយខ្មាន់ធ្នូទៅ ដើម្បីធ្វើគត់ព្រះសាស្ដាជាដើម រហូតទល់គ្នានឹងការបំបែកបំបាក់ព្រះសង្ឃ ហើយក៏បានចូលទៅកាន់ផែនដី (ផែនដីស្រូប) ដោយន័យដែលបានពោលមកហើយនុ៎ះឯង ។

ព្រះរាជា ទ្រង់ព្រះសណ្ដាប់រឿងនោះហើយ ទ្រង់មានព្រះ

រាជហឫទ័យភិតភ័យតក់ស្លុត ដោយទ្រង់ព្រះតម្រិះ ថា "ផែនដីនឹងគប្បីស្រូបនូវអាត្មាអញផងដែរ ឬក៏ទេហ្ន៎ ?" ដូច្នេះហើយ ទើបទ្រង់មិនបានសោយសេចក្ដីសុខ ក្នុងព្រះរាជសម្បត្តិ មិនទ្រង់បានទទួលនូវការសព្វព្រះទ័យ ក្នុងការបន្ទំឡើយ ទ្រង់រសាប់រសល់ស្ដេចយាងទៅ ប្រៀបដូចជាសត្វប្រេតដែលត្រូវគេចាក់ដោយគ្រឿងសម្រាប់ដាក់ទណ្ឌកម្ម ដូច្នោះឯង ។ ក៏ព្រះបាទអជាតសត្រូវអង្គនោះ ទ្រង់ពិចារណាឃើញព្រះកាយព្រះអង្គ ដូចជាត្រូវផែនដីស្រូបដូចជាកំពុងតែចេញ អំពីអណ្ដាតភ្លើងអវិចីនរក និងប្រៀបដូចជាត្រូវនាយពេជ្ឈឃាត កំពុងតែឲ្យផ្ទំផ្ងារ នៅលើផែនដី ហើយបុកច្រំដោយលំពែងដែក ។ ដោយហេតុនោះ កាលបើព្រះបាទអជាតសត្រូវអង្គនោះ ទ្រង់រសាប់រសល់ ប្រៀបដូចជាសត្វមាន់ដែលត្រូវគេប្រហារ យ៉ាងដូច្នោះ ទើបទ្រង់មិនបានមានសេចក្ដីស្ងប់ព្រះព្រះរាជហឫទ័យ ត្រឹមមួយរំពេចសោះឡើយ ។ ព្រះរាជាអង្គនោះ សូម្បីតែទ្រង់មានព្រះបំណងចង់គាល់ព្រះសាស្ដា និងក្រាបទូលសួរបញ្ហា ហើយទ្រង់ញ៉ាំងព្រះសាស្ដាឲ្យទ្រង់អត់ទោសឲ្យ ក៏ទ្រង់មិនអាច ដើម្បីនឹងចូលទៅគាល់ព្រះសាស្ដាបានឡើយ ព្រោះព្រះអង្គទ្រង់មានទោសកំហុសដ៏ធំផង ។ ក្នុងថ្ងៃពេញបូរមី ថ្ងៃមួយព្រះបាទអជាតសត្រូវអង្គនោះ ទ្រង់ត្រាស់សួរគ្រូពេទ្យជីវកកោមារភ័ច្ច

ថា "ឥឡូវនេះ តើព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងទីណា ?" ។ គ្រូពេទ្យជីវក ក្រាបទូល ថា "ក្នុងឧទ្យានព្រៃស្វាយនៃទូលព្រះបង្គំ" ។

បានឮថា ក្នុងកាលមុន គ្រូពេទ្យជីវក បានធ្វើទីសម្រាប់សម្រាកក្នុងវេលាយប់ និងវេលាថ្ងៃ ទីសម្ងំ កុដិនិងមណ្ឌបជាដើមឲ្យសម្រេចហើយ និងបានឲ្យនាយជាងកសាងព្រះគន្ធកុដិ ដើម្បីព្រះសាស្តា ក្នុងឧទ្យានព្រៃស្វាយនោះ ធ្វើឧទ្យានអម្ពវ័ន ដែលព្រះបាទពិម្ពិសារទ្រង់បានព្រះរាជទានហើយ ដល់ខ្លួននោះ ឲ្យជាវត្តហើយវេរប្រគេនហើយ ។ ពាក្យនោះ គ្រូពេទ្យជីវក បានពោលសំដៅយកឧទ្យាននោះ ។

គ្រានោះ ព្រះរាជាទ្រង់បានធ្វើគ្រូពេទ្យជីវក ឲ្យជាមគ្គនាយកហើយស្តេចយាងទៅកាន់ជីវកម្ពវនារាម ក្នុងពេលរាត្រី ក្នុងថ្ងៃនោះភ្លាម ទ្រង់បានថ្វាយបង្គំព្រះសាស្តា និងធ្វើអញ្ជលីកម្ម ដល់ព្រះភិក្ខុសង្ឃ ទ្រង់គង់ ក្នុងទីដ៏សមគួរហើយ ក្រាបទូលសួរបញ្ហាដោយន័យ ដែលបានពោលហើយ ក្នុងសាមញ្ញផលសូត្រនុ៎ះឯង ។

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះតម្រិះ ថា "ព្រះរាជាព្រះអង្គនេះ ចាប់តាំងអំពីពេលដែលព្រះអង្គ ទ្រង់ត្រាស់បញ្ជាឲ្យពួកអាមាត្យធ្វើគត់ព្រះរាជបិតាមក ទ្រង់មិនបានព្រះបន្ទំ រហូតទាំងយប់ទាំងថ្ងៃឡើយ, ព្រោះថា ព្រះរាជាអង្គនោះ ប្រៀបដូចជាត្រូវគេ

ចាក់នឹងលំពែង ១០០ ដើម កាលបើគ្រាន់តែទ្រង់ធ្មេចព្រះនេត្រចុះ ដោយទ្រង់មានព្រះបំណង ថា "អាត្មាអញ នឹងថ្លៃ" ដូច្នេះប៉ុណ្ណោះ ក៏ស្តេចបែរជាទ្រង់តើនឡើង រសាប់រសល់ទៅវិញ, ក៏ក្នុងថ្ងៃនេះ ព្រះរាជអង្គនេះ ស្តេចយាងមករកតថាគតហើយ ក៏នឹងទ្រង់ចូលកាន់ព្រះបន្ទំ ចាប់តាំងអំពីពេលដែលព្រះអង្គទ្រង់បានព្រះសណ្តាប់ព្រះធម្មទេសនានេះហើយ ក៏នឹងទ្រង់ធ្វើសក្ការ ដល់ព្រះរតនត្រៃ, ឈ្មោះថា បុគ្គលអ្នកដល់ព្រមដោយសទ្ធាជាបុថុជ្ជន ដូចជាព្រះរាជាព្រះអង្គនេះ នឹងមិនមានឡើយ, មួយទៀត ក្នុងវេលាចប់ទេសនា ព្រះរាជាអង្គនេះ នឹងទ្រង់តាំងនៅក្នុងព្រះត្រ័យសរណៈ, ក៏ព្រះរាជាព្រះអង្គនេះ ទ្រង់បានដល់នូវព្រះត្រ័យសរណៈ ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះរាជាព្រះអង្គនេះ ក៏នឹងទ្រង់ទៅកើត ក្នុងនរកឈ្មោះលោហកុម្ភី ហើយធ្លាក់ចុះទៅដល់បាតក្រោម មកដល់បាតឆ្នាំងដោយកាលប្រមាណ ៣ ម៉ឺនឆ្នាំ បានផុសឡើងមកដល់ខាងលើម្តងទៀត ហើយបានមកដល់មាត់ឆ្នាំង អស់កាលប្រមាណ ៣ ម៉ឺនឆ្នាំ ហើយ ក៏នឹងបានរួចផុត ប្រៀបឧបមាដូចជាបុគ្គលពួកខ្លះ ធ្វើការសម្លាប់បុរស គប្បីបានរួចផុត អំពីអាជ្ញា ដោយវត្ថុត្រឹមតែផ្កាមួយក្តាប់ យ៉ាងដូច្នោះឯង ព្រោះព្រះសាសនា របស់តថាគតជាព្រះសាសនាដ៏ធំ, ម្យ៉ាងទៀត ព្រះរាជាព្រះអង្គនេះ នឹង

ទ្រង់បានជាព្រះបច្ចេកពុទ្ធ ព្រះនាមថា ជីវិតវិសេសហើយ នឹងទ្រង់បរិនិព្វាន ក្នុងអនាគតកាល" ដូច្នេះហើយ ទ្រង់ជ្រាបអានិសង្សដ៏ច្រើន ដែលព្រះរាជាអង្គនោះគប្បីបាន ព្រោះទ្រង់ព្រះសណ្ដាប់នូវព្រះធម៌នេះ កាលនឹងទ្រង់ព្យាករនូវបញ្ហា របស់ព្រះរាជាអង្គនោះ ទើបទ្រង់សំដែងសាមញ្ញផលសូត្រ ក្នុងសីលក្ខន្ធវគ្គ ។

ក្នុងវេលាចប់ទេសនា ព្រះរាជាទ្រង់បានសាបសូន្យហើយចាកព្រះសោតាបត្តិផល ព្រោះព្រះអង្គជាអ្នកមានឧបនិស្ស័យ នៃមគ្គគឺព្រះអង្គបានកាត់ផ្ដាច់ហើយ ទើបទ្រង់បានដល់នូវព្រះត្រ័យសរណៈដោយទ្រង់បានថ្វាយនូវព្រះអង្គ ។ ក៏ប្រសិនបើ ព្រះរាជបិតានឹងមិនត្រូវព្រះបាទអជាតសត្រូវអង្គនោះ ទ្រង់បានធ្វើគត់ហើយ, ព្រះបាទអជាតសត្រូវនោះ ក៏នឹងបានសម្រេចជាព្រះសោតាបន្ន ក្នុងទីទ្រង់គង់នោះតែម្ដង, តែសេចក្ដីអន្តរាយនៃមគ្គ បានកើតឡើងហើយ ដល់ព្រះអង្គ ព្រោះទ្រង់សេពគប់នឹងបាបមិត្រ ។

ព្រះរាជាទ្រង់ដល់នូវសរណៈ យ៉ាងដូច្នេះហើយ ទ្រង់បានប្រកាសនូវទោសកំហុស ដែលព្រះអង្គទ្រង់បានធ្វើហើយ ចំពោះព្រះភក្ត្រនៃព្រះសាស្ដា ទ្រង់ញ៉ាំងព្រះសាស្ដាឲ្យអត់ទោសឲ្យហើយ ទើបទ្រង់ស្ដេចក្រោកចាកអាសនៈ ទ្រង់ធ្វើប្រទក្សិណ ៣ ជុំ ហើយទ្រង់ប្រណមអញ្ជលីដាក់លើព្រះសិរសី ទ្រង់បានបែរព្រះភក្ត្រតម្រង់

ឆ្ពោះព្រះសាស្តាហើយ ទ្រង់ស្តេចយាងថយក្រោយចេញមក ដរាបដល់ស្ថានទីដែលទ្រង់ទតព្រះនេត្រឃើញ ទ្រង់ថ្វាយបង្គំ ដោយកិរិយាតិកល់ចុះចំពោះនូវអវយវៈប្រកបដោយអង្គប្រាំ លើផែនដីក្នុងស្ថានទីដែលទ្រង់ទតព្រះនេត្រមិនឃើញហើយ ទើបស្តេចយាងគេចចេញទៅ ។

រឿង ព្រះបាទអជាតសត្រូវ ក្នុងអដ្ឋកថាសាមញ្ញផលសូត្រ ចប់ ។

## ( កិរិយាប្រកាន់ខ្លួន នាំឲ្យធ្លាក់នរក )

(៤៥) ក្នុងអតីតកាល សូម្បីបងប្រុស របស់និគ្រន្ថឈ្មោះទីឃវិថៈ មានអត្តភាពប្រមាណ ៦០ យោជន៍ ជាអ្នកដេកផ្ងារធ្លាក់ទៅឆេះ ក្នុងមហានរក អស់ ៤ ពុទ្ធន្តរ ព្រោះកម្មដែលខ្លួនបានប្រកាន់ខុស ។ ត្រកូលទាំង ៥០០ ដែលរាប់អាននូវទិដ្ឋិ របស់គេនោះ បានចូលដល់ភាពសំឡាញ់ របស់អ្នកនោះឯង ហើយក៏ឆេះក្នុងមហានរក ( ដូចគ្នាដែរ ) ។

រឿងនេះ មកហើយ ក្នុងអដ្ឋកថា ។

## ( ជនពាលតែងធ្វើខ្លួនមិនឲ្យមានសិរី )

(៤៦) សូម្បីគ្រូទាំង ៦ មានបូរណកស្សបៈជាដើម ប្តេជ្ញាថា "ពួកយើង ជាអ្នកបានសម្រេច នូវអនុត្តរសម្មាសម្ពោធិញ្ញាណ"

ដូច្នេះ រមែងធ្វើខ្លួនឲ្យវិនាស ព្រោះអំពើដែលខ្លួនប្រកាន់ខុស ។ សូម្បីពួកជនអន្ធពាលទាំងឡាយដ៏ច្រើន ដែលចូលចិត្តនូវទិដ្ឋិ របស់គ្រូទាំង ៦ នាក់នោះ ក៏តែងដល់នូវសេចក្តីវិនាស ។ មែនពិត ជនពាលទាំងនោះ ជាអ្នកមានទុគតិប្រព្រឹត្តទៅខាងមុខគ្រប់ៗគ្នា ។

សួរ ថា "ក៏គ្រូទាំង ៦ នាក់នោះ បានឈ្មោះថា បូរណៈ ជាដើម តើព្រោះហេតុអ្វី ?" ។ ខ្ញុំនឹងឆ្លើយ ដូចតទៅ ។

## ( ប្រវត្តិរបស់បូរណកស្សបៈ )

បានឮថា ត្រកូលមួយ មានខ្ញុំបម្រើ ៩៩ នាក់ ខ្ញុំបម្រើម្នាក់ បានកើតមកគម្រប់ ( ត្រូវជា ១០០ នាក់ល្មម ) ។ ព្រោះហេតុដូច្នោះ ពួកចៅហ្វាយនាយ ទើបបានដាក់ឈ្មោះ អ្នកបម្រើនោះ ថា "បូរណៈ" ។ ក៏ពួកចៅហ្វាយនាយ អ្នកដែលពោល ថា "ការងារ គឺនាយបូរណៈនោះ ធ្វើល្អហើយ ធ្វើមិនល្អ" ដូច្នេះ ឬក៏ "ការងារ គឺនាយបូរណៈនោះ មិនបានធ្វើហើយ ឬបានធ្វើហើយ" ដូច្នេះ មិនមានឡើយ ព្រោះនាយបូរណៈនោះ ជាអ្នកបម្រើដែលមានសិរីសួស្តី ។ នាយបូរណៈនោះ គិត ថា "នឹងមានប្រយោជន៍អ្វីទៅដល់អាត្មាអញ ដោយការរស់នៅ ក្នុងទីនេះ" ដូច្នេះហើយ ក៏បានរត់គេចចេញទៅ ។

គ្រានោះ ពួកចោរក៏ដណ្តើមយកសំពត់ទាំងឡាយរបស់នាយបូរណៈនោះហើយ ។ នាយបូរណៈនោះ កាលមិនដឹងស្លឹកឈើ ដើម្បីនឹងបិទបាំង ដោយស្មៅនិងស្លឹកឈើ ក៏ជាអ្នកអាក្រាត ចូលទៅកាន់ស្រុកមួយ ។ មនុស្សទាំងឡាយ ឃើញនាយបូរណៈនោះហើយ ក៏សម្គាល់ ថា "បុរសនេះ ជាសមណៈ ជាព្រះអរហន្ត ជាអ្នកមានសេចក្តីប្រាថ្នាតិច, បុគ្គលដទៃទៀត ដែលស្មើនឹងបុរសនេះ រមែងមិនមាន" ហើយ ទើបបានឲ្យហើយនូវវត្ថុទាំងឡាយមាននំនិងភត្តជាដើម ។ នាយបូរណៈនោះ គិត ថា "នំនិងភត្តជាដើមនេះ បានកើតឡើងហើយ ព្រោះអញមិនស្លៀកសំពត់" ដូច្នេះ តាំងអំពីពេលនោះមក សូម្បីបានសំពត់ហើយ ក៏មិនព្រមស្លៀកពាក់ បានប្រកាន់យកនូវភេទអាក្រាតនោះឯង ធ្វើជាបព្វជ្ជា ។ ពួកមនុស្ស ៥០០ នាក់ បានបួសហើយ ក្នុងសំណាក់ របស់នាយបូរណៈនោះ ។ នាយបូរណៈនោះឯង បាននូវឈ្មោះ ដោយអំណាចនៃគោត្រ ថា "កស្សបៈ" ។

## ( ប្រវត្តិរបស់មក្ខលិគោសាល )

ចំណែកបុរសម្នាក់ ជាអ្នកបម្រើ របស់ចៅហ្វាយនាយម្នាក់ សែងក្រឡប្រេង ដើរទៅលើផែនដីដែលមានភក់ ត្រូវចៅហ្វាយនាយប្រាប់ ថា "នែអ្នក ចូរកុំរអិលដួលឡើយ" ដូច្នេះ ក៏រអិលដួល

ដោយសេចក្ដីប្រមាទហើយ បានប្រារព្ធដើម្បីនឹងរត់គេចទៅ ព្រោះភ័យខ្លាចចៅហ្វាយនាយ ។ ចៅហ្វាយនាយ បានរត់តាមទៅចាប់ជាយសំពត់ ។ បុរសនោះ បានបោះចោលសំពត់ ជាអ្នកអាក្រាត បានរត់គេចទៅហើយ ។ ពាក្យដែលសេសសល់ ក៏ដូចគ្នានឹងនាយបូរណកស្សបៈនុ៎ះឯង ។ នាយមក្ខលិនោះឯង គេហៅថា "គោសាលៈ" ដូច្នេះក៏មាន ព្រោះជាអ្នកកើត ក្នុងក្រោលគោ ។

## ( ប្រវត្តិរបស់និគ្រន្ថ នាដបុត្រ )

ចំណែកបុរសម្នាក់ បានឈ្មោះថា "និគ្រន្ថ" ព្រោះជាអ្នកមានប្រក្រតីពោល យ៉ាងនេះ ថា "ពួកយើង មិនមានកិលេសដែលជាគ្រឿងចងរឹត, ពួកយើង ជាអ្នកប្រាសចាកកិលេសដែលជាគ្រឿងចងរឹត" ដូច្នេះ និងគេហៅថា "នាដបុត្រ" ព្រោះគេជាកូនរបស់អ្នករបាំ ។

ក៏កិលេសជាគ្រឿងចងរួបរឹត ឈ្មោះថា "កិលេសជាគ្រឿងចងរឹត" ក្នុងពាក្យនោះ ។

កិលេសមានរាគៈជាដើម របស់បុរសនោះ មានការជាប់ជំពាក់ក្នុងផ្ទះសម្បែងជាកិច្ច មានស្រែ ចំការ បុត្រនិងភរិយាជាដើមជាអារម្មណ៍ ។

( ប្រវត្តិរបស់សញ្ជ័យ វេលដ្ឋបុត្រ )

ចំណែកបុរសម្នាក់ គេហៅថា "សញ្ជ័យ" ដោយអំណាចនៃឈ្មោះ និងគេហៅថា "វេលដ្ឋបុត្រ" ព្រោះគេជាកូនរបស់ជាងត្បាញផែង ។

( ប្រវត្តិរបស់បកុធ កច្ចាយនៈ )

ចំណែកបុរសម្នាក់ គេហៅថា "បកុធ" ដោយអំណាចនៃឈ្មោះ និងគេហៅថា "កច្ចាយនៈ" ដោយអំណាចគោត្រ ។ បុរសនេះ ជាអ្នកបដិសេធនូវទឹកត្រជាក់ ។ មែនពិត បុរសនោះបន្ទោបង់ឧច្ចារៈក្តី បរិភោគភោជនក្តី របស់មិនស្អាតឯណាមួយប្រទង្វាក់ក្តី ក៏មិនធ្វើកិច្ចជម្រះដោយទឹក (ត្រជាក់) ដែរ, បានទឹកក្តៅ ឬ ទឹកបាយហើយទើបធ្វើ; ឆ្លងទន្លេ ឬ ទឹកកណ្តាលផ្លូវ ក៏គិត ថា "សីលអញធ្លុះធ្លាយហើយ" ដូច្នេះ ពូនដីខ្សាច់ជាពំនូក ដោយអំណាចវត្តហើយ ក៏អធិដ្ឋានសីលស្រេចហើយ ទើបដើរទៅ ។ បុរសនេះ ប្រកាន់នូវលទ្ធិដែលមិនមានសិរី យ៉ាងដូច្នេះ ។

( ប្រវត្តិរបស់អជិតកេសកម្ពល )

ឯបុរសម្នាក់ គេហៅថា "អជិតៈ" ដោយអំណាចឈ្មោះ និងគេហៅថា "កេសកម្ពល" ព្រោះអត្ថ ថា "ទ្រទ្រង់នូវសំពត់

កម្ពុលដែលគេធ្វើហើយ ដោយសក់មនុស្សទាំងឡាយ" ដូច្នេះឯង ។

រឿងគ្រូទាំង ៦ នាក់ មកក្នុងអដ្ឋកថាសាមញ្ញផលសូត្រ ។

ពួកជនពាល រមែងញ៉ាំងខ្លួន និងពួកជនអ្នកដែលធ្វើតាមពាក្យរបស់ខ្លួន ឲ្យវិនាស ព្រោះកម្មដែលខ្លួនប្រកាន់យកហើយមិនល្អ ដោយប្រការដូច្នេះឯង ។

## ( បណ្ឌិតធ្វើខ្លួននិងជនអ្នកធ្វើតាមខ្លួនឲ្យចំរើន )

(៤៧) ចំណែកបណ្ឌិតទាំងឡាយ រមែងមិនញ៉ាំងខ្លួននិងពួកជនអ្នកធ្វើតាមពាក្យរបស់ខ្លួន ឲ្យវិនាសឡើយ រមែងឲ្យបានដល់ (តែ) សេចក្ដីចំរើន ព្រោះកម្មដែលខ្លួនបានប្រកាន់យកហើយល្អ ដូចជាអ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើម ។ មែនពិត ព្រះពុទ្ធ ទ្រង់បានសម្រេចនូវព្រះសព្វញ្ញុតញ្ញាណ ដែលប្រដាប់ដោយគុណទាំងពួង ព្រោះកម្មដែលព្រះអង្គទ្រង់ប្រកាន់យកល្អហើយ , ព្រះថេរៈទាំងឡាយ មានព្រះសារីបុត្រជាដើម ក៏ដូច្នោះដែរ បានសម្រេចគុណជាតមានសាវកបារមីញាណជាដើម ។ ក៏ទេវតានិងមនុស្សទាំងឡាយ ប្រមាណមិនបាន អាស្រ័យព្រះពុទ្ធហើយ ក៏បានសម្រេចនូវអាសវក្ខយញ្ញាណហើយ បានចូលទៅកាន់ព្រហ្មលោក , ត្រកូល ៨ ម៉ឺន ញ៉ាំងចិត្តឲ្យជ្រះថ្លា ក្នុងព្រះសារីបុត្តត្ថេរហើយ

ឧបត្ថម្ភព្រះថេរៈ ដោយបច្ច័យ ៤ បានកើតហើយ ក្នុងឋានសួគ៌, មួយទៀត ត្រកូលទាំង ៨ ម៉ឺន ញុំាងចិត្តឲ្យជ្រះថ្លាហើយ ក្នុងព្រះមហាសាវ័កទាំងពួង មានព្រះមហាមោគ្គល្លាន និងព្រះមហាកស្សបៈជាដើម ក៏យ៉ាងដូច្នោះដែរ ។

## ( រឿងគ្រូសុនេត្រ )

(៤៨) ក្នុងអតីតកាល ព្រះពោធិសត្វ មានព្រះនាមថា សុនេត្រ ជាសាស្តានៃគណៈ ធ្វើលទ្ធិដូចជាកំពង់ ជាទីចុះកាន់សុគតិ ជាអ្នកប្រាសចាកសេចក្តីតម្រេក ក្នុងកាមទាំងឡាយ ដោយអំណាចនៃវិក្ខម្ភនបហានៈ ដែលព្រះសាស្តា ទ្រង់ត្រាស់សំដៅយកក្នុងសត្តសុរិយសូត្រ ក្នុងសត្តកនិបាត អង្គុត្តរនិកាយ ថា " ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង គ្រូសុនេត្រ បានអប់រំចិត្តប្រកបដោយមេត្តា រហូត ៧ ឆ្នាំ, លុះបានអប់រំមេត្តាចិត្ត អស់ ៧ ឆ្នាំហើយ ទើបមិនបានមកកាន់លោកនេះ ម្តងទៀត រហូត ៧ សំវដ្តវិវដ្តកប្ប, ម្នាលភិក្ខុទាំងឡាយ បានឮថា កាលបើលោកវិនាស, គ្រូសុនេត្រនោះ ជាអ្នកចូលទៅដល់ព្រហ្មលោកជាន់អាភស្សរៈ, កាលបើលោកចំរើន រមែងចូលទៅកាន់វិមានព្រហ្ម ដែលស្ងាត់សូន្យ " ។

បណ្តាបទទាំងនោះ ២ បទ ថា " **មេត្តចិត្តំ ភាវេត្វា** "

គឺ លុះអប់រំចិត្តដែលប្រកបព្រម ដោយមេត្តាដែលប្រកបដោយតិកឈាន និងចតុក្កឈាន ធ្វើឲ្យប្រណីតហើយ ។ ក៏ក្នុងបទទាំង ២ នេះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សមាធិ ដោយស័ព្ទគឺចិត្តជាប្រធាន ព្រោះហេតុនោះ ទើបមានសេចក្តីថា " លុះញុំាងមេត្តាសមាធិ គឺមេត្តាព្រហ្មវិហារ ឲ្យកើតហើយ និងឲ្យចំរើនឡើងហើយ " ។ ២ បទ ថា " **សត្ត សំវដ្ដវិវដ្ដកប្បេ** " គឺ អស់ មហាកប្ប ៧ ។ សូម្បីកប្បដែលតាំងនៅក្នុងផ្លូវវិនាសនិងកប្បដែលតាំងនៅក្នុងផ្លូវចំរើន ក៏ព្រះមានព្រះភាគទ្រង់ប្រកាន់យកហើយ ដោយសំវដ្ដនិងវិវដ្ដស័ព្ទនុ៎ះឯង ។ ២ បទ ថា " **ឥមំ លោកំ** " គឺ កាន់កាមលោក ។ បទ ថា " **សំវដ្ដមានេ សុទំ** " មានសេចក្តីថា កាលបើលោកវិនាស គឺ ត្រូវភ្លើងឆេះ បានដល់វិនាសសាបសូន្យ ។ ឯពាក្យ ថា " **សុទំ** " គ្រាន់តែជានិបាត ។ បទ ថា " **លោកេ** " គឺ កាលបើកប្ប ។ បទ ថា " **អាភស្សរូបគោ** " គឺ គ្រូសុនេត្រ ចូលទៅកាន់ព្រហ្មលោកជាន់អាភស្សរៈ ដោយអំណាចការចាប់បដិសន្ធិ ក្នុងព្រហ្មលោកជាន់អាភស្សរៈនោះ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងកប្បដែលវិនាសព្រោះភ្លើង ដោយពាក្យនោះ ។ បទ ថា " **វិវដ្ដមានេ** " គឺ តាំងនៅ បានដល់កើតមាន ។ បទ ថា " **សុញ្ញំ** " គឺ ឈ្មោះថា ស្ងាត់សូន្យ ព្រោះ

មិនមានសត្វណាមួយកើត ក្នុងព្រហ្មលោកនោះ, អធិប្បាយ ថា "វិមានព្រហ្ម ពោលគឺភូមិនៃបឋមឈានឯណា កើតហើយ ខាងដើម, គ្រូសុនេត្រ រមែងកើតឡើង គឺ ចូលដល់វិមានព្រហ្មនោះ ដោយអំណាចនៃការចាប់បដិសន្ធិ" ។

បានឮថា ក្នុងកាលនោះ ព្រះពោធិសត្វ សូម្បីជាអ្នកបាននូវសមាបត្តិ ៨ ជាប្រក្រតី យ៉ាងដូច្នោះក៏ដោយ ក៏នៅតែត្រួតមើលនូវប្រយោជន៍សុខដើម្បីសត្វ និងការបំពេញបារមីរបស់ខ្លួន ញ៉ាំងសេចក្តីត្រេកអរ ឲ្យកើតឡើងហើយ ក្នុងភូមិនៃឈានទាំង ២ យ៉ាងនោះឯង បានអន្ទោលទៅមក ដោយអំណាចនៃមេត្តាព្រហ្មវិហារ ។ ក៏គ្រូសុនេត្រ មានសាវ័កជាច្រើនរយនាក់ ។ ពួកសាវ័កទាំងអស់នោះ បានស្តាប់ទេសនា របស់ព្រះពោធិសត្វហើយ ក៏ស្ថិតនៅក្នុងឱវាទ នៃព្រះពោធិសត្វនោះហើយ ជាអ្នកមានសុគតិជាទីប្រព្រឹត្តទៅឰដ៏ខាងមុខ ។ ក៏បណ្តាសាវ័កទាំងនោះ សាវ័កពួកខ្លះ បានចូលទៅដល់ព្រហ្មលោក, សាវ័កពួកខ្លះ បានចូលទៅដល់កាមាវចរសួគ៌ ៦ ជាន់, សាវ័កពួកខ្លះ បានចូលទៅដល់ភាពជាខត្តិយមហាសាល ព្រាហ្មណ៍មហាសាលនិងគហបតីមហាសាល ដូច្នេះ ។

## ( រឿងពាណិជ ៧០០ នាក់ )

(៤៩) ក្នុងអតីតកាល ពួកពាណិជ ៧០០ នាក់ បានឆ្លង

សមុទ្រដោយសំពៅ ។ ក្នុងថ្ងៃទី ៧ សំពៅ ក៏បានលិចកណ្ដាលមហាសមុទ្រ ។ ទឹកបានសំផុលឡើងហើយ ។ ពួកពាណិជជួបប្រទះភ័យហើយ ក៏បានកំណត់យកឈ្មោះ នៃពួកទេវតា របស់ខ្លួន ៗ ហើយធ្វើកម្មផ្សេងៗ មានការសុំបួងសួងជាដើម ។

ក៏នៅកណ្ដាល នៃពាណិជទាំងនោះ មានបុរសម្នាក់ រលឹកដល់ទានដែលខ្លួនបានប្រគេនហើយ ដល់ព្រះភិក្ខុសង្ឃ និងសរណៈនិងសីលដែលខ្លួនបានទទួលហើយ ក្នុងថ្ងៃដែលខ្លួនចុះសំពៅ បានអង្គុយមិនតក់ស្លុតសោះឡើយ ។ ពួកពាណិជក្រៅពីនេះ ឃើញបុរសនោះមិនភិតភ័យហើយ ទើបសួរនូវហេតុនៃការមិនភិតភ័យ ។ បុរសនោះ បានប្រាប់នូវហេតុនោះ ដល់ពួកពាណិជទាំងនោះ ។

ពួកពាណិជ . នៃនាយ ! ក៏សីលរមែងសមគួរ ដល់ជនទាំងឡាយឯទៀត ដែរឬទេ ? ។

បុរស . មែនហើយ សីលរមែងសមគួរដល់ជនទាំងនោះ ។

ពួកពាណិជ . បើដូច្នោះ ចូរអ្នកឲ្យសីល ដល់ពួកយើងខ្ញុំទាំងឡាយផងចុះ ។

បុរសនោះ បានរៀបចំមនុស្សទាំងនោះ មួយពួកមួយរយ ៗ ចែកចេញជា ៧ ពួក ហើយទើបបានឲ្យនូវសីល ៥ ។

បណ្ដាមនុស្សទាំង ៧០០ នាក់នោះ មនុស្ស ១០០ នាក់

ទី ១ បានឈរនៅក្នុងទឹកប្រមាណត្រឹមកជើងហើយ ទទួលនូវសីល,
ទី ២ បានឈរនៅក្នុងទឹកប្រមាណត្រឹមជង្គង់ហើយ ទទួលនូវសីល,
ទី ៣ បានឈរនៅក្នុងទឹកប្រមាណត្រឹមចង្កេះហើយ ទទួលនូវសីល,
ទី ៤ បានឈរនៅក្នុងទឹកប្រមាណត្រឹមផ្ចិតហើយ ទទួលនូវសីល,
ទី ៥ បានឈរនៅក្នុងទឹកប្រមាណត្រឹមដោះហើយ ទទួលនូវសីល,
ទី ៦ បានឈរនៅក្នុងទឹកប្រមាណត្រឹមកហើយ ទទួលនូវសីល,
ទី ៧, កាលបើទឹកប្រៃ កំពុងហូរចូលក្នុងមាត់, បានឈរទទួលសីល ។

បុរសនោះ បានឲ្យសីលដល់ជនទាំងឡាយនោះហើយ ទើបប្រកាស ថា "ទីពឹងដទៃ របស់អ្នកទាំងឡាយមិនមានឡើយ, អ្នកទាំងឡាយ ចូររលឹកចំពោះសីលតែម្យ៉ាងចុះ" ដូច្នេះហើយ ក៏បានស្លាប់ទៅកើត ក្នុងភពតាវត្តិង្ស ។ ចំណែកពួកជនទាំង ៧០០ នាក់នោះ ក៏បានកើតហើយ ក្នុងភពតាវត្តិង្សនោះដូចគ្នាដែរ ព្រោះអាស្រ័យសីលដែលខ្លួនបានទទួលហើយ ក្នុងពេលទៀបនឹងស្លាប់ ។

ទេវបុត្រទាំងអស់នោះ លោកហៅថា "**សតុល្លបកាយិកា** ( អ្នកស្ថិតនៅក្នុងគណៈ ដែលលើកតម្កើងនូវសេចក្ដីល្អ )" ព្រោះជាអ្នកលើកតម្កើងនូវធម៌ របស់ពួកសប្បុរស ដោយអំណាចនៃការសមាទានហើយ ទៅកើតក្នុងពួកទេវតាក្នុងឋានសួគ៌ ។

វិមានរបស់ពួកទេវបុត្រទាំងនោះ កើតឡើងហើយ ដោយ

អំណាចការបៀតត្រសៀតគ្នាតែម្តង យ៉ាងដូច្នេះ គឺ បណ្តាពួកទេវបុត្រទាំងនោះ វិមានមាស របស់ទេវបុត្រជាអាចារ្យ មានប្រវែងប្រមាណ ១០០ យោជន៍ កើតឡើងហើយ នៅកណ្តាលនៃវិមានទាំងពួង, វិមានទាំងឡាយ របស់ពួកទេវបុត្រដែលជាអន្តេវាសិកកើតឡើងលោមព័ទ្ធជុំវិញ នូវវិមានរបស់ទេវបុត្រជាអាចារ្យនោះ, វិមានថ្នាក់ទាបជាងគេទាំងអស់ របស់ទេវបុត្រទាំងនោះ មានប្រវែងប្រមាណ ១២ យោជន៍ ។

ទេវបុត្រទាំងឡាយនោះ នឹករលឹកនូវកម្ម ក្នុងខណៈដែលខ្លួនកើតហើយនុ៎ះឯង ដឹងនូវការបានសម្បត្តិ ព្រោះអាស្រ័យអាចារ្យហើយ ជាអ្នកមានបំណងចង់ពោលសរសើរគុណរបស់អាចារ្យ ក្នុងសំណាក់នៃព្រះសាស្តា ទើបនាំគ្នាមកកាន់វត្តជេតពន ក្នុងចន្លោះនៃមជ្ឈិមយាម ថ្វាយបង្គំព្រះសាស្តាហើយ ទើបបានឈរនៅ ក្នុងទីដ៏សមគួរ ។ បណ្តាទេវបុត្រទាំងនោះ ទេវតា ៦ អង្គ ប្រាថ្នាចង់ពោលគាថា មួយអង្គមួយគាថា ៗ តាមលំដាប់ បានពោលគាថាទាំងឡាយ ៦ ធ្វើបាទ ទី ៤ ឱ្យខុសផ្សេងពីគ្នា និង ៣ បាទក្រៅអំពីនេះ ឱ្យដូចគ្នាតែមួយ ថា ÷

[១] “ បុគ្គលគប្បីគប់រកនឹងពួកសប្បុរសតែម្យ៉ាង,[(១)]

១ ត្រៃបិដក ភាគទី ៦១ / ទំព័រទី ២០២ ។

គប្បីធ្វើនូវការស្និទ្ធស្នាលនឹងពួកសប្បុរស, ព្រោះដឹងព្រះសទ្ធម្មរបស់ពួកសប្បុរស គុណធម៌ដ៏ប្រសើររមែងកើតមាន មិនមែនជាទោសដ៏លាមកទេ ។

[២] បុគ្គលគប្បីគប់រក នឹងពួកសប្បុរស តែម្យ៉ាង, គប្បីធ្វើនូវការស្និទ្ធស្នាលនឹងពួកសប្បុរស, ព្រោះដឹងនូវព្រះសទ្ធម្មរបស់ពួកសប្បុរស បុគ្គលតែងបាននូវបញ្ញា, នឹងបានអំពីបុគ្គលដទៃ មិនបានឡើយ ។

[៣] បុគ្គលគប្បីគប់រក នឹងពួកសប្បុរស តែម្យ៉ាង, គប្បីធ្វើនូវការស្និទ្ធស្នាលនឹងពួកសប្បុរស, ព្រោះដឹងនូវព្រះសទ្ធម្មរបស់ពួកសប្បុរស បុគ្គលរមែងមិនសោកសោក ក្នុងកណ្ដាលនៃបុគ្គលអ្នកសោកសោក ។

[៤] បុគ្គលគប្បីគប់រក នឹងពួកសប្បុរស តែម្យ៉ាង, គប្បីធ្វើនូវការស្និទ្ធស្នាលនឹងពួកសប្បុរស, ព្រោះដឹងនូវព្រះសទ្ធម្ម របស់ពួកសប្បុរស បុគ្គលរមែងរុងរឿង ក្នុងកណ្ដាលនៃញាតិ ។

[៥] បុគ្គលគប្បីគប់រក នឹងពួកសប្បុរស តែម្យ៉ាង, គប្បីធ្វើនូវការស្និទ្ធស្នាលនឹងពួកសប្បុរស, ព្រោះដឹងនូវព្រះសទ្ធម្ម របស់ពួកសប្បុរស សត្វទាំងឡាយ

រមែងទៅកាន់សុគតិ ។

[៦] បុគ្គលគប្បីគប់រក នឹងពួកសប្បុរស តែម្យ៉ាង, គប្បីធ្វើនូវការស្និទ្ធស្នាលនឹងពួកសប្បុរស, ព្រោះដឹងនូវព្រះសទ្ធម្មរបស់ពួកសប្បុរស សត្វទាំងឡាយរមែងស្ថិតនៅ អស់កាលដ៏យូរអង្វែង " ។

គ្រានោះ ទេវតាដទៃទៀត ក្រាបទូលសួរ ថា " បពិត្រព្រះដ៏មានព្រះភាគ ពាក្យរបស់អ្នកណាទៅ ជាសុភាសិត ? " ។

ព្រះសាស្ដា ទ្រង់ត្រាស់ ថា " ពាក្យរបស់អ្នកទាំងអស់គ្នាជាសុភាសិត ដោយបរិយាយ, ចូរអ្នកទាំងឡាយស្ដាប់នូវពាក្យរបស់តថាគតខ្លះផង " ដូច្នេះហើយ ទ្រង់ត្រាស់គាថានេះ ថា ÷

" បុគ្គលគប្បីសេពគប់ នឹងពួកសប្បុរស តែម្យ៉ាង, គប្បីធ្វើនូវការស្និទ្ធស្នាលនឹងពួកសប្បុរស, ព្រោះដឹងនូវព្រះសទ្ធម្ម របស់ពួកសប្បុរស បុគ្គលរមែងបានរួចផុតចាកសេចក្ដីទុក្ខទាំងពួង " ។

(៥០) បណ្ដាបទទាំងនោះ បទ ថា " សព្ភិរេវ " ប្រែថា ជាមួយនឹងបណ្ឌិតទាំងឡាយ គឺ ជាមួយនឹងពួកសប្បុរស តែម្យ៉ាង ។

អក្សរ រ ធ្វើនូវការគបទ ។ បទ ថា "សមាសេថ" ប្រែថា គប្បីអង្គុយរួមជាមួយ ។ ក៏ពាក្យនុ៎ះ ជាប្រធានដើមបទនៃទេសនាតែប៉ុណ្ណោះ ។ សេចក្តីថា "បុគ្គលគប្បីសម្រេចឥរិយាបថទាំងពួងជាមួយនឹងសប្បុរសទាំងឡាយតែប៉ុណ្ណោះ" ។ បទ ថា "កុព្វេថ" ប្រែថា គប្បីធ្វើ ។ បទ ថា "សន្ថវំ" បានដល់ នូវការស្និទ្ធស្នាល ដូចជាមិត្រសំឡាញ់ ។ មែនពិត ការស្និទ្ធស្នាលដោយភាពជាមិត្រសំឡាញ់ បុគ្គលគប្បីធ្វើ ជាមួយនឹងព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវ័ករបស់ព្រះពុទ្ធ, ចំណែកការស្និទ្ធស្នាលដោយអំណាចតណ្ហា បុគ្គលមិនត្រូវធ្វើជាមួយនឹងអ្នកណាមួយឡើយ ។ បទ ថា "សតំ" គឺ របស់សប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើម ។ បទ ថា "សទ្ធម្មំ" បានដល់ ព្រះសទ្ធម្ម ដែលផ្សេងដោយសីល ៥ សីល ១០ និងសតិបដ្ឋាន ៤ ជាដើម ។ ប៉ុន្តែក្នុងទីនេះ ទេវបុត្រទាំងឡាយ សំដៅយកសីល ៥ ។ បទ ថា "អញ្ញាយ" បានដល់ ព្រោះដឹង គឺ ព្រោះហេតុនៃការដឹង ។ បទ ថា "សេយ្យោ" គឺ សេចក្តីចំរើន ។ បទ ថា "ន បាបិយោ" មានសេចក្តីថា សេចក្តីលាមក រមែងមិនមានបន្តិចសោះឡើយ ។

(៥១) គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី ២ (ដូចតទៅ) ÷ បទ ថា "នាញ្ញតោ" មានសេចក្តីថា រមែងមិនបាននូវបញ្ញា

អំពីបុគ្គលដទៃ គឺ អំពីបុគ្គលអន្ធពាល ។ ពិតមែនដូច្នោះ ធម្មតាបញ្ញា គឺបុគ្គលណាមួយ រមែងមិនបាន អំពីបុគ្គលអន្ធពាលឡើយ ដូចជាបុគ្គលមិនបាននូវវត្ថុមានប្រេងជាដើម អំពីវត្ថុទាំងឡាយមានដីខ្សាច់ជាអាទិ៍បានឡើយដូច្នោះ, បុគ្គលដឹងនូវធម៌ របស់សប្បុរសទាំងឡាយ សេពគប់នឹងបណ្ឌិតតែប៉ុណ្ណោះ រមែងបាន ប្រៀបដូចជាបុគ្គល បានវត្ថុទាំងឡាយ មានប្រេងជាដើម អំពីវត្ថុមានល្ងជាដើម យ៉ាងដូច្នោះឯង ។

(៥២) គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី ៣ (ដូចតទៅនេះ) បទ ថា "**សោកមជ្ឈេ**" មានសេចក្ដីថា នៅក្នុងកណ្ដាល នៃសត្វទាំងឡាយ ដែលជាទីតាំងនៃសេចក្ដីសោក ឬជាអ្នកដែលទៅតាមនូវសេចក្ដីសោក រមែងមិនសោកសៅ ប្រៀបដូចជាឧបាសិកា របស់ពន្ធុលសេនាបតី និងប្រៀបដូចជាសង្កិច្ចសាមណេរ ក្នុងកណ្ដាលនៃពួកចោរ ៥០០ នាក់ ដូច្នោះឯង ។

## (រឿង ព្រះនាងមល្លិកា)

បានឮមកថា ក្នុងទីក្រុងកុសិនារា មានព្រះរាជបុត្រ របស់ព្រះបាទមល្លរាជ ព្រះនាមពន្ធុលៈ ទ្រង់បានសិក្សាសិល្បសាស្ត្រ ក្នុងសំណាក់នៃអាចារ្យតែមួយ ជាមួយគ្នានឹងព្រះបាទបសេនទិ ។

ពន្ធុលសេនាបតីនោះ នាំព្រះនាងទេវីព្រះនាមមល្លិកា ស្តេចយាងទៅកាន់ក្រុងសាវត្ថី ចាកទីក្រុងកុសិនារា ទ្រង់បានជាសេនាបតី របស់ព្រះបាទបសេនទិ ។ ព្រះនាងមល្លិកា អាស្រ័យពន្ធុលសេនាបតីនោះ បានប្រសូត នូវព្រះរាជបុត្រទាំងឡាយ ផ្ទោះ ដល់ទៅ ១៦ ដង ។ ព្រះរាជបុត្រទាំងអស់អង្គនោះ ជាអ្នកក្លាហាន បរិបូណ៌ដោយកម្លាំងខ្លាំងក្លា ទ្រង់បានសម្រេចនូវសិល្បសាស្ត្រគ្រប់បែបយ៉ាង ។ បណ្តាព្រះរាជបុត្រទាំងនោះ ព្រះរាជបុត្រមួយអង្គ ៗ ទ្រង់មានបុរសមួយពាន់នាក់ជាបរិវារ ។

ក្រោយមកថ្ងៃមួយ មនុស្សទាំងឡាយ អ្នកដែលបានបរាជ័យព្រោះក្តីកោង បានឃើញពន្ធុលសេនាបតីយាងមកហើយ ទើបបានក្រាបទូល នូវហេតុនៃការកាត់សេចក្តីមិនយុត្តិធម៌ របស់ពួកអាមាត្យអ្នកវិនិច្ឆ័យ ដល់ពន្ធុលសេនាបតីនោះ ។ ពន្ធុលសេនាបតីនោះស្តេចយាងទៅកាន់ទីវិនិច្ឆ័យហើយ ពិចារណានូវសេចក្តីនោះ ទ្រង់បានធ្វើអ្នកម្ចាស់នុ៎ះឯង ឲ្យទៅជាម្ចាស់ (ដូចដើម) ។ មហាជនបានថ្វាយសាធុការពរហើយ ។ ព្រះរាជា ទ្រង់បានព្រះសណ្តាប់សំឡេងនោះហើយ ទើបទ្រង់ត្រាស់សួរ ទ្រង់ជ្រាបសេចក្តីនោះហើយ ទ្រង់ត្រាស់បញ្ជាឲ្យបណ្តេញ នូវពួកអាមាត្យអ្នកវិនិច្ឆ័យចេញហើយ ទ្រង់ព្រះរាជទានការវិនិច្ឆ័យ ដល់ពន្ធុលសេនាបតីនុ៎ះឯង ។

តាំងពីនោះមក ពន្ធុលសេនាបតីនោះ ក៏កាត់សេចក្ដីដោយត្រឹមត្រូវ ។

ក្នុងពេលនោះ ពួកអាមាត្យអ្នកដែលកាត់សេចក្ដីជំនាន់ចាស់ កាលមិនបានការស៊ីសំណូក ជាអ្នកមានលាភតិច ទើបនាំគ្នាក្រាបទូលចាក់ដោត ដល់ព្រះរាជា ថា "ពន្ធុលសេនាបតី ប្រាថ្នាចង់បាននូវរាជសម្បត្តិ" ។ ព្រះរាជាទ្រង់ជឿពាក្យរបស់ពួកអាមាត្យទាំងនោះហើយ ទ្រង់ត្រាស់បញ្ជាពួកបុរសដែលព្រះអង្គទ្រង់ប្រកបហើយឱ្យប្លន់ស្រុកជាយដែនហើយ ទ្រង់បញ្ជូនពន្ធុលសេនាបតីទៅ ដោយព្រះរាជឱង្ការ ថា "បានឮថា បច្ចន្តជនបទ កើតចលាចលហើយ, ចូរអ្នកទៅជាមួយនឹងកូនទាំងឡាយ របស់អ្នក ហើយចាប់ពួកចោរឱ្យបាន" ដូច្នេះហើយ ទើបទ្រង់បានបញ្ជូនពួកទាហានធំ ៗ ដែលមានសមត្ថភាពផ្សេងទៀតទៅ ដោយព្រះរាជឱង្ការ ថា "អ្នកទាំងឡាយ ចូរកាត់ក្បាលរបស់ពន្ធុលសេនាបតី ព្រមទាំងកូនទាំងឡាយ ៣២ នាក់ ក្នុងទីនោះតែម្ដង" ។ នាយទាហានធំ ៗ ទាំងនោះបានធ្វើហើយ យ៉ាងដូច្នោះ ។

ក្នុងថ្ងៃនោះ ព្រះនាងមល្លិកា បាននិមន្តព្រះអគ្គសាវ័កទាំង ២ ព្រះអង្គ មួយអន្លើដោយភិក្ខុទាំងឡាយ ៥០០ អង្គ ។ ក្នុងខណៈនោះ មនុស្សទាំងឡាយ បានបញ្ជូនព្រះចុតហ្មាយទៅថ្វាយព្រះនាងមល្លិកា ក្នុងវេលាព្រឹក មានសេចក្ដីថា "ទាហានទាំងឡាយ

កាត់ព្រះសិរសី របស់ព្រះស្វាមីរបស់ព្រះអង្គ ព្រមទាំងព្រះរាជបុត្រទាំងឡាយ ”។ ព្រះនាងមល្លិកានោះ ទ្រង់ជ្រាបហេតុនោះហើយ មិនទ្រង់មានព្រះបន្ទូលអ្វីៗ ដល់អ្នកណាមួយឡើយ ទ្រង់សៀតនូវចុតហ្មាយក្នុងថ្នក់ហើយ ទ្រង់អង្គាសនូវព្រះភិក្ខុសង្ឃរឿយ ៗ ។

គ្រានោះ នាងបរិចារិកា របស់ព្រះនាងមល្លិកានោះ កាលនាំភាជនៈនៃទឹកដោះថ្លាមក ក៏បានធ្វើភាជនៈបែក នៅខាងមុខនៃព្រះថេរៈទាំងឡាយ ។ ព្រះធម្មសេនាបតី ពោល ថា “របស់របរមានការបែកធ្លាយជាធម្មតា បែកទៅហើយ, ព្រះនាងមិនគួរគិតដល់ឡើយ ”។ ព្រះនាងមល្លិកានោះ ទ្រង់បាននាំយកចុតហ្មាយចេញមកអំពីថ្នក់ហើយ មានព្រះបន្ទូល ថា “ខ្ញុំព្រះករុណា សូម្បីបានស្តាប់រឿងនោះហើយ ក៏មិនបានគិតឡើយ, បពិត្រព្រះគុណម្ចាស់ដ៏ចំរើន កាលបើភាជនៈនៃទឹកដោះថ្លាបែកហើយ, ខ្ញុំព្រះករុណា នឹងគិតដល់ យ៉ាងដូចម្តេចទៅ ”។ ព្រះថេរៈ បានសំដែងធម៌ដល់ព្រះនាងហើយ ទើបបាននិមន្តទៅវត្តហើយ ។ ព្រះនាងមល្លិកានោះ ទ្រង់ត្រាស់ឲ្យយាងព្រះសុណិសាទាំង ៣២ មកហើយ ត្រាស់ប្រទានឱវាទ ថា “ស្វាមីទាំងឡាយ របស់អ្នកទាំងឡាយ ជាអ្នកមិនមានកំហុស បានទទួលនូវផលកម្មពីបុព្វជាតិ របស់ខ្លួនហើយ, អ្នកទាំងឡាយ ចូរកុំសោកសៅឡើយ និងចូរកុំធ្វើសេចក្តីក្រោធខឹង ចំពោះ

ព្រះរាជាឡើយ" ដូច្នេះហើយ ទ្រង់មិនសោកសៅ ក្នុងកណ្ដាលនៃព្រះនាងសុណិសា ដែលបានដល់នូវការសោកសៅទាំងនោះ ។

ន័យនេះ លោកបានពោលហើយ ក្នុងអដ្ឋកថាភទ្ទសាលជាតកជាដើម ។

## ( រឿងសង្កិច្ចសាមណេរ )

(៥៣) ចំណែកសង្កិច្ចសាមណេរ ជាកូនប្រុសរបស់ព្រាហ្មណមហាសាល ក្នុងទីក្រុងសាវត្ថី ក្នុងពេលដែលមានអាយុ ៧ ឆ្នាំ ក៏បានបួស ក្នុងសំណាក់នៃព្រះសារីបុត្តត្ថេរ ហើយបានសម្រេចនូវព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ក្នុងពេលដែលកំពុងកោរសក់រួចនុ៎ះឯង ។ សាមណេរនោះ ក្នុងពេលនៅជាសាមណេរ កាលរស់នៅក្នុងព្រៃ ជាមួយនឹងភិក្ខុទាំងឡាយ ៣០ រូប ត្រូវពួកចោរ ៥០០ ចាប់ឃាំងទុក ក្នុងទីដ៏សមគួរមួយ ដោយប្រឹក្សាគ្នាថា "ពួកយើង នឹងសម្លាប់សាមណេររូបនេះហើយ ធ្វើពលីកម្ម ដល់ទេវតា" ដូច្នេះ ក៏គង់ចូលឈាន ក្នុងទីនោះឯង ។ មេចោរ បានបញ្ជាឲ្យកូនចៅធ្វើកិច្ច មានការដុតភ្លើងជាដើមហើយ យកដាវមកកាប់ក របស់សាមណេរ ។ ដាវបានរមូរបត់មកប៉ះមុខនឹងមុខគ្នា ។ មេចោរបានពត់ដាវនោះឲ្យត្រង់ហើយ ក៏កាប់ជាថ្មីម្ដងទៀត ។ ដាវបានរមូរកោងមកដល់គល់នៃដង ប្រៀប

ដូចជាស្លឹកត្នោត ។ ពួកចោរទាំងអស់នោះ ឃើញហេតុអស្ចារ្យ
នោះ និងបានស្តាប់នូវព្រះធម៌ទេសនា របស់សង្កិច្ចសាមណេរនោះ
ហើយ ក៏ជ្រះថ្លាបានបួស ក្នុងសំណាក់របស់សង្កិច្ចសាមណេរនោះ
ហើយ ទើបបាននិមន្តទៅកាន់វត្តជេតពន ជាមួយនឹងសាមណេរនោះ
បានស្តាប់ព្រះធម៌ទេសនា របស់ព្រះសាស្តាហើយ ក៏បានសម្រេចព្រះ
អរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ។

ន័យនេះ លោកបានពោលហើយ ក្នុងអដ្ឋកថាធម្មបទ ជាដើម ។

(៥៤) គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី ៤ ( ដូចតទៅ ) ÷
បទ ថា "ញាតិមជ្ឈេ វិរោចតិ" មានសេចក្តីថា រមែងល្អប្រសើរ
ក្នុងកណ្តាលនៃពួកញាតិ ដូចជាអធិមុត្តកសាមណេរ ដូច្នោះឯង ។

## ( រឿងអធិមុត្តកសាមណេរ )

បានឮថា អធិមុត្តកសាមណេរនោះ ត្រូវជាខ្មួយ របស់ព្រះ
សង្កិច្ចត្ថេរ ។ អធិមុត្តកសាមណេរនោះ ត្រូវបានព្រះថេរៈបញ្ជូន
ទៅ ដោយពាក្យ ថា "ចូរអ្នកនិមន្តទៅចុះ, ចូរអ្នកសួរនូវអាយុ
ហើយ ត្រឡប់មកវិញ, ខ្ញុំនឹងឲ្យអ្នកឧបសម្បទ" ដូច្នេះហើយ
ទើបចាប់បាត្រនិងចីពរ និមន្តទៅកាន់ផ្ទះរបស់បងស្រី ធ្វើភត្តកិច្ច
ក្នុងផ្ទះនោះស្រេចហើយ ទើបបានសួរនូវអាយុ ។ បងស្រី

របស់សាមណេរនោះ ពោល ថា “នាងខ្ញុំមិនដឹងទេ, មាតារបស់យើងនឹងដឹង”។ អធិមុត្តកសាមណេរនោះ ពោលថា “សូមអ្នកនៅសិនចុះ, អាត្មានឹងទៅកាន់សំណាក់នៃមាតា” ហើយ ទើបបានចូលទៅកាន់ព្រៃនៃចោរ ។ ពួកចោរទាំងឡាយ ចាប់សាមណេរនោះហើយ, ពួកខ្លះបានពោល ថា “យើងនឹងសម្លាប់សាមណេរនេះ” ពួកខ្លះពោល ថា “ពួកយើងនឹងលែងសាមណេរនេះ”។ សាមណេរគិត ថា “អាត្មាអញជាសេក្ខបុគ្គល ជាអ្នកមានកិច្ចដែលត្រូវធ្វើ, អញនឹងចរចាជាមួយនឹងពួកចោរទាំងនេះហើយ នឹងធ្វើខ្លួនឲ្យមានសេរីសួស្ដី” ហើយពោល ថា “បើអ្នកទាំងឡាយ សម្លាប់អាត្មាចោល, បើយ៉ាងដូច្នោះ ពួកអ្នកដើរផ្លូវ ដឹងរឿងនោះហើយ ក៏នឹងមិនមក, ការសាបសូន្យចាកទ្រព្យ ក៏នឹងមានដល់អ្នកទាំងឡាយ”។ ចោរទាំងឡាយនោះ គិត ថា “សាមណេរនេះ និយាយត្រូវ” ដូច្នេះហើយក៏ពោល ថា “បើអ្នកបានឃើញមនុស្សឯទៀតៗ ដែលដើរផ្លូវជួបគ្នានឹងមិនប្រាប់ទេ, ក៏ចូរលោកនិមន្តទៅចុះ” ដូច្នេះ, កាលបើសាមណេរនោះ ទទួលព្រម ថា “ចំរើនពរ” ដូច្នេះហើយ, ទើបលែងសាមណេរនោះទៅហើយ ។ សាមណេរត្រូវពួកចោរទាំងនោះស្រាយលែងហើយ កាលនិមន្តទៅ សូម្បីបានជួបនូវញាតិទាំងឡាយ មានមាតានិងបិតាជាដើមហើយ ក៏មិនបានប្រាប់ ដល់ញាតិ

ទាំងឡាយ មានមាតាបិតាជាដើមនោះដែរ ។ ពួកចោរទាំងឡាយ ចាប់ពួកមនុស្សទាំងនោះ ដែលដើរមកដល់តាមក្រោយបានហើយ ក៏បានធ្វើបាបបៀតបៀន ។

លំដាប់នោះ ចំណែកមាតារបស់សាមណេរ កាលខ្សឹកខ្សួល ត្រូវពួកចោរសួរហើយ ទើបបានប្រាប់ ថា "នាងខ្ញុំជាមាតា របស់អធិមុត្តកសាមណេរ, អ្នកនេះ ជាបិតា, អ្នកទាំងឡាយនេះ ជាបងប្រុសប្អូនប្រុស" ។ ពួកចោរ គិត ថា "សមណៈរូបនេះ ជាអ្នកពោលពាក្យពិតត្រង់" ហើយ ក៏បានជ្រះថ្លា ដោះលែងញាតិទាំងឡាយ របស់សាមណេរនោះទៅ ហើយក៏បានបួសក្នុងសំណាក់របស់សាមណេរនោះឯង ។ អធិមុត្តកសាមណេរនោះ បាននាំយកសាមណេរទាំងនោះ ទៅកាន់សំណាក់នៃព្រះសង្កិច្ចត្ថេរហើយ ក៏បានឧបសម្បទខ្លួនឯងជាមុន ក្រោយមក ទើបបានឲ្យសាមណេរទាំងនោះឧបសម្បទ ធ្វើឲ្យជាអន្តេវាសិករបស់ខ្លួន ។ ភិក្ខុទាំងឡាយនោះ ស្ថិតនៅក្នុងឱវាទ របស់ព្រះអធិមុត្តកត្ថេរហើយ ក៏បានសម្រេចនូវព្រះអរហត្ត ។

(៥៥) គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី ៦ (ដូចតទៅនេះ) បទ ថា "សាតតំ" មានសេចក្តីថា ស្ថិតនៅជាសុខ អស់កាលជានិច្ច ឬ ស្ថិតនៅជាសុខ អស់កាលដ៏យូរអង្វែង ។

បទ ថា “វោ” ប្រែថា របស់អ្នកទាំងឡាយ ។ បទ ថា “បរិយាយេន” គឺ ដោយហេតុ ។ បទ ថា “សព្វទុក្ខា” មានសេចក្តីថា នឹងមានគុណដ៏ប្រសើរ តែម្យ៉ាងក៏ទេ, មួយទៀត បុគ្គលរមែងបាននូវបញ្ញា តែម្យ៉ាងក៏ទេដែរ, រមែងមិនសោកសៅក្នុងកណ្តាលនៃសត្វដែលសោកសៅ, រមែងរុងរឿង ក្នុងកណ្តាលនៃញាតិ, តែងទៅកើតក្នុងសុគតិភព ឬរមែងស្ថិតនៅជាសុខអស់កាលដ៏យូរអង្វែង, តាមពិតហើយ រមែងរួចផុតចាកសេចក្តីទុក្ខក្នុងវដ្តសំសារទាំងអស់បានមែនពិត ដូច្នេះឯង ។

រឿង សមុទ្ទវាណិជ មកក្នុងអដ្ឋកថាទេវតាសំយុត្ត ។

បណ្ឌិតទាំងឡាយ រមែងមិនញុំាងខ្លួន និងពួកជនអ្នកដែលធ្វើតាមពាក្យរបស់ខ្លួន ឲ្យវិនាស ដោយប្រការដូច្នេះឯង ។

(៥៦) បុគ្គលណា មិនសេពគប់នូវពួកបុគ្គលពាល, បុគ្គលនោះ ឈ្មោះថា សេពគប់នូវពួកបណ្ឌិត, បុគ្គលណា សេពគប់នូវពួកបណ្ឌិត, បុគ្គលនោះ ឈ្មោះថា មិនសេពគប់នូវពួកបុគ្គលពាល ព្រោះហេតុណា ; ព្រោះហេតុនោះ ពាក្យទាំង ២ យ៉ាងនោះ ដោយសេចក្តី ក៏ជាពាក្យជាមួយគ្នានុ៎ះឯង, ជាពាក្យជាមួយគ្នា ក៏ពិតមែនហើយ ; ទោះបីជាដូច្នោះក៏ដោយ បណ្តាពាក្យទាំង ២ យ៉ាងនោះ ពាក្យនេះ ថា “ការមិនសេពនូវជនពាលទាំងឡាយ ១”

ដូច្នេះ សូម្បីក្នុងគាថាទី ១ នេះ គប្បីជ្រាប ថា “ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ដើម្បីឲ្យដឹងច្បាស់ សូម្បីនូវសេចក្ដីដែលផ្ទុយពីគ្នានេះ ថា ‘ការសេពគប់នូវបុគ្គលពាលទាំងឡាយ មិនមែនជាមង្គល’ ដូច្នេះ, ពាក្យនេះ ថា “ការសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ ១” ដូច្នេះ គប្បីជ្រាប ថា “ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ដើម្បីឲ្យដឹងច្បាស់ សូម្បីនូវសេចក្ដីដែលផ្ទុយពីគ្នានេះ ថា ‘ការមិនសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ មិនមែនជាមង្គល’ ដូច្នេះ ប្រៀបដូចជាបុរសដែលឆ្លាតក្នុងផ្លូវ កាលបង្ហាញប្រាប់នូវផ្លូវ បានបង្ហាញប្រាប់នូវផ្លូវ ដែលមិនគួរកាន់យកជាមុនសិនហើយ ទើបបង្ហាញប្រាប់នូវផ្លូវដែលគួរកាន់យក ជាខាងក្រោយ យ៉ាងដូច្នេះ ថា “ចូរអ្នកលះបង់ចោលនូវផ្លូវខាងឆ្វេង, ចូរអ្នកកាន់យកនូវផ្លូវខាងស្ដាំ” ដូច្នេះ, បុគ្គលណា លះបង់នូវផ្លូវខាងឆ្វេង, បុគ្គលនោះ ឈ្មោះថា កាន់យកនូវផ្លូវខាងស្ដាំ, បុគ្គលណា កាន់យកនូវផ្លូវខាងស្ដាំ, បុគ្គលនោះ ឈ្មោះថា លះបង់ចោលនូវផ្លូវខាងឆ្វេង ព្រោះហេតុណា ; ព្រោះហេតុនោះ សូម្បីពាក្យទាំង ២ យ៉ាងនោះ ដោយសេចក្ដី គឺជាពាក្យតែមួយនុ៎ះឯង, ជាពាក្យតែមួយ ក៏ពិតមែនហើយ, ទោះបីជាយ៉ាងដូច្នោះក៏ដោយ បណ្ដាពាក្យទាំង ២ យ៉ាងនោះ ពាក្យនេះ ថា “ចូរអ្នកលះបង់ចោល

នូវផ្លូវខាងឆ្វេង" ដូច្នេះ គប្បីជ្រាប ថា "បុរសនោះ ពោលហើយ ដើម្បីឲ្យដឹងជាក់ច្បាស់សូម្បីនូវសេចក្តីដែលផ្ទុយគ្នានេះ ថា 'ចូរអ្នកកុំលះបង់ចោលនូវផ្លូវខាងស្តាំ' ដូច្នេះ, ពាក្យនេះ ថា "ចូរអ្នកកាន់យកនូវផ្លូវខាងស្តាំ" ដូច្នេះ គប្បីជ្រាប ថា "បុរសនោះ ពោលហើយ ដើម្បីឲ្យដឹងជាក់ច្បាស់សូម្បីនូវសេចក្តីដែលផ្ទុយគ្នានេះ ថា 'ចូរអ្នកកុំកាន់យក នូវផ្លូវខាងឆ្វេងឡើយ' យ៉ាងដូច្នោះឯង ; ក៏ព្រោះធ្វើអត្ថាធិប្បាយយ៉ាងដូច្នេះ ទើបព្រះដ៏មានព្រះភាគ មិនទ្រង់ត្រាស់នូវការសេពគប់នូវបណ្ឌិតទុកជាមុន (តែ) ទ្រង់ត្រាស់ការមិនសេពគប់នូវបុគ្គលពាលទុកជាមុន ។ ក៏ប្រសិនបើព្រះអង្គគប្បីត្រាស់ នូវការសេពគប់នូវបណ្ឌិតទុកជាមុន, សេចក្តីនៃពាលស័ព្ទ គឺវិនេយ្យសត្វ ក៏រមែងមិនយល់ជាក់ច្បាស់បានឡើយ ព្រោះទ្រង់ត្រាស់នូវបណ្ឌិត (ជាមុន), កាលបើអត្ថនៃពាលស័ព្ទនោះ គឺវិនេយ្យសត្វ មិនបានដឹងជាក់ច្បាស់ហើយ, ចំណែកឯការសេពគប់នូវបុគ្គលពាល ក៏វិនេយ្យសត្វ រមែងមិនដឹងជាក់ច្បាស់ដូចគ្នាផងដែរ ។ ក៏ព្រោះព្រះដ៏មានព្រះភាគ ទ្រង់ប្រាថ្នាដើម្បីឲ្យវិនេយ្យសត្វបានដឹងច្បាស់ នូវការសេពគប់នូវបុគ្គលពាលជាមុន ដូច្នោះ ទើបព្រះអង្គទ្រង់ត្រាស់ការមិនសេពគប់បុគ្គលពាលនុ៎ះឯងទុកជាមុន ។ មែនពិត ព្រះដ៏មានព្រះភាគ ទ្រង់

ត្រាស់ ថា "ការមិនសេពគប់នូវបុគ្គលពាលទាំងឡាយ ១" ដូច្នេះ ចំណែកការសេពគប់បុគ្គលពាល ក៏ឈ្មោះថា រមែងឲ្យវិនេយ្យសត្វដឹងជាក់ច្បាស់ផងដែរ ។ ព្រោះព្រះដ៏មានព្រះភាគ ប្រៀបដូចជាបុរសដែលឆ្លាតក្នុងផ្លូវ, ហេតុដូច្នោះ ព្រះអង្គទ្រង់ញ៉ាំងឲ្យវិនេយ្យសត្វដឹងច្បាស់ នូវការសេពគប់នូវបុគ្គលពាល ពោលគឺការមិនសេពគប់បណ្ឌិត ដែលមិនគួរកាន់យក ប្រៀបដូចជាផ្លូវខាងឆ្វេង ជាមុនហើយ ទើបទ្រង់ញ៉ាំងឲ្យវិនេយ្យសត្វបានដឹងច្បាស់ នូវការមិនសេពនូវបុគ្គលពាល ពោលគឺការសេពគប់នូវបណ្ឌិតដែលគួរកាន់យក ប្រៀបដូចជាផ្លូវខាងស្តាំ ឮដ៏ខាងក្រោយ ។

## ( សេពគប់នូវបុគ្គលពាលមិនមែនជាមង្គល )

(៥៧) មែនពិត សូម្បីការសេពគប់រក នូវបុគ្គលពាល ក៏ឈ្មោះថា មិនមែនជាមង្គល ព្រោះជាហេតុនៃសេចក្តីវិនាស, ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា ÷

" បុគ្គលមានពួកអសប្បុរស ជាទីស្រឡាញ់(១),
បុគ្គលនោះ រមែងមិនធ្វើសេចក្តីស្រឡាញ់ចំពោះ
ពួកសប្បុរសទេ, គេតែងស្រឡាញ់ពេញចិត្ត

១ ត្រៃបិដក ភាគទី ៥៤ ទំព័រទី ៣៧ ។

ចំពោះតែធម៌ របស់ពួកអសប្បុរស, កម្មទាំង ៣ យ៉ាងនោះ ជាប្រធាននៃបុគ្គលអ្នកដែលវិនាស " ។

បណ្តាបទទាំងនោះ បទ ថា "**អសន្តស្ស**" មានសេចក្តីថា ពួកអសប្បុរស គឺ មនុស្សមិនល្អទាំងឡាយ មានគ្រូទាំង ៦ នាក់ ជាដើម រមែងជាទីស្រឡាញ់ របស់បុគ្គលនោះ ។

បាទគាថា ថា "**សន្តេ ន កុរុតេ បិយំ**" មានសេចក្តីថា បុគ្គលនោះ រមែងមិនធ្វើនូវសប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើម ឲ្យជាទីស្រឡាញ់ របស់ខ្លួនឡើយ ។

ក៏ក្នុងបាទគាថានេះ ព្រះមានព្រះភាគទ្រង់ធ្វើការខុសផ្សេងគ្នានៃវចនៈ ថា "**សន្តេ បិយំ**" ដោយអំណាចវេនេយ្យសត្វ ។

ទិដ្ឋិ ៦២ និងអកុសលកម្មបថ ១០ ឈ្មោះថា ធម៌របស់អសប្បុរស, បុគ្គលនោះ រមែងចូលចិត្ត គឺ ស្រឡាញ់ បានដល់សេពគប់នូវធម៌របស់អសប្បុរសនោះ ។

បទ ថា "**តំ**" មានសេចក្តីថា កម្ម ៣ យ៉ាង គឺ ភាពជាអ្នកមានអសប្បុរសដែលជាទីស្រឡាញ់ ១ ភាពជាអ្នកមានសប្បុរសមិនជាទីស្រឡាញ់ ១ ការស្រឡាញ់ពេញចិត្តធម៌ របស់អសប្បុរស ១

ព្រះមានព្រះភាគ ទ្រង់ត្រាស់ ថា ជាប្រធាន របស់បុគ្គលអ្នកវិនាស គឺ ជាហេតុនៃសេចក្ដីវិនាស របស់បុគ្គលអ្នកវិនាស គឺ អ្នកដែលកំពុងតែវិនាស, មែនពិត បុគ្គលដែលប្រកបព្រម ដោយកម្មទាំង ៣ ប្រការនោះ រមែងវិនាស គឺ រមែងសាបសូន្យ បានដល់ រមែងមិនបានសម្រេចនូវសេចក្ដីចំរើន ទាំងក្នុងលោកនេះ ទាំងក្នុងលោកខាងមុខ ដោយពិតប្រាកដ, ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ ថា "ជាប្រធាន នៃបុគ្គលអ្នកវិនាស" ដូច្នេះឯង ។

ពណ៌នាអំពីការសេពនិងមិនសេពពាលនិងបណ្ឌិត ចប់ ។

* * *

ប្រែចប់ថ្ងៃស្រុក ១៣ កើត ខែកត្តិក ឆ្នាំរកា បញ្ចស័ក ព.ស.២៥៣៦
ត្រូវនឹងថ្ងៃ ទី ២៦ ខែវិច្ឆិកា ១៩៩៣
វេលាព្រឹក ម៉ោង ៩:០០

# ពណ៌នាអំពីការបូជា

## ( ការបូជាមាន ២ យ៉ាង )

(៥៨) ឈ្មោះថា ការបូជា មាន ២ យ៉ាង ដោយអំណាចនៃអាមិសបូជា និងបដិបត្តិបូជា ។

បណ្ដាការបូជាទាំង ២ យ៉ាងនោះ ការបូជាដោយគ្រឿងសក្ការមានផ្កាឈើជាដើម និងដោយបច្ច័យ ៤ ឈ្មោះថា ការបូជាដោយអាមិស ។ ការបូជា ដោយសេចក្ដីប្រតិបត្តិ ឈ្មោះថា បដិបត្តិបូជា ។ ចំណែកក្នុងអដ្ឋកថា លោកពោលហើយ ថា "ការធ្វើសក្ការ, គោរព, រាប់អាន និងកិរិយាក្រាបថ្វាយបង្គំ ឈ្មោះថា ការបូជា" ។ ដោយការកំណត់យកបុគ្គលដែលប្រសើរខ្ពង់ខ្ពស់បំផុត ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះអរិយសាវ័កទាំងឡាយ ឈ្មោះថា បុគ្គលដែលគួរបូជា ។ មែនពិត បុគ្គលដ៏ប្រសើរទាំងឡាយ មានព្រះពុទ្ធជាដើមនោះ លោកហៅថា "ជាបូជនេយ្យបុគ្គល" ព្រោះធ្វើនូវភារៈនៃការបូជាដែលបុគ្គលបានធ្វើហើយ ក្នុងខ្លួន សូម្បីមានចំនួនដ៏តិចតួចក៏ដោយ នាំប្រយោជន៍ និងសេចក្ដីសុខមកប្រគល់ឲ្យបាន អស់ដ៏យូរអង្វែង ព្រោះហេតុជាទក្ខិណេយ្យបុគ្គល ។

ក្នុងបទ ថា "**បូជនេយ្យា**" នោះ គប្បីជ្រាបអត្ថវិគ្រោះដូចតទៅនេះ ÷ ដែលបុគ្គលតែងបូជា ឈ្មោះថា ការបូជា, ចុះ **យុ** បច្ច័យ ក្នុងភាវសាធនៈ ខាងមុខ **បូជ** ធាតុ, បុគ្គលទាំងឡាយណា រមែងគួរនូវការបូជា គឺជាអ្នកសមគួរ ដល់ការបូជា ព្រោះហេតុនោះ បុគ្គលទាំងឡាយនោះ ឈ្មោះថា បូជនេយ្យ (អ្នកសមគួរដល់ការបូជា), អធិប្បាយ ថា "ជាអ្នកគួរនូវការបូជា គឺ សមគួរដល់ការបូជា" ។ ចុះ **ឯយ្យ** បច្ច័យ ដោយសូត្រក្នុងសទ្ទនីតិបករណ៍ ថា "បច្ច័យ គឺ **ឦយ** និង **ឯយ្យ** ចុះក្នុងអត្ថ ថា គួរ" ។ តែក្នុងពេលឥឡូវនេះ ពុទ្ធសាសនិកជន តែងសូត្រ ថា "**បូជនីយានំ**" ដូច្នេះក៏មានដែរ ។ ចុះ **ឦយ** បច្ច័យ ដោយសូត្រនោះ ដូចគ្នាដែរ ។ អាចារ្យពួកខ្លះ ពោល ថា "ចុះ **អនីយ** បច្ច័យ" ។ តែពាក្យនោះ មិនសម (ដោយពាក្យ) ក្នុងអដ្ឋកថា ថា "បទ ថា '**បូជនេយ្យានំ**' បានដល់ អ្នកដែលគួរនូវការបូជា" ។

## ( ពុទ្ធបូជាមានអានិសង្សច្រើន )

(៥៩) ក៏ឈ្មោះថា ការបូជា ក្នុងបូជនេយ្យបុគ្គលទាំងឡាយ មានព្រះពុទ្ធជាដើម សូម្បីតិចតួច ក៏រមែងនាំប្រយោជន៍សុខមកប្រគល់ឲ្យ អស់កាលដ៏យូរអង្វែង ។

ក្នុងដំណើរនោះ មាននាយសុមនមាលាការជាដើម ជាឧទាហរណ៍ ។

## ( រឿងនាយសុមនមាលាការ )

បានឮថា ក្នុងក្រុងរាជគ្រឹះ មាននាយមាលាការម្នាក់ ឈ្មោះសុមនៈ ។ នាយសុមនមាលាការនោះ កាលបម្រើព្រះបាទពិម្ពិសារ ដោយផ្កាម្លិះ ៨ នាឡិ អំពីព្រឹកព្រលឹម ជារៀងរាល់ថ្ងៃ រមែងបាននូវទ្រព្យ ៨ កហាបណៈ ។ ថ្ងៃមួយ នាយសុមនមាលាការនោះ កាន់ផ្កាឈើដើរទៅកាន់ទីឧបដ្ឋាកព្រះរាជា បានឃើញព្រះសាស្ដា ដែលមានព្រះភិក្ខុសង្ឃចោមរោមហើយ ទ្រង់បញ្ចេញព្រះរស្មីដែលមានពណ៌ ៦ ប្រការ ទ្រង់ស្ដេចយាងចូលទៅកាន់ព្រះនគរ ដើម្បីទ្រង់បិណ្ឌបាត ក៏មានចិត្តជ្រះថ្លាហើយ បានគិត ថា "ព្រះរាជាទ្រង់មិនបាននូវផ្កាឈើទាំងឡាយនេះ ទ្រង់សម្លាប់អាត្មាអញក្ដី ទ្រង់និរទេសអាត្មាអញ ចាករាជធានីក្ដី, ព្រោះព្រះអង្គសូម្បីទ្រង់ព្រះរាជាទានដល់អាត្មាអញ ក៏គប្បីព្រះរាជាទានទ្រព្យ ដើម្បីប្រយោជន៍ដល់ការចិញ្ចឹមជីវិត ក្នុងបច្ចុប្បន្ននេះតែប៉ុណ្ណោះឯង, ចំណែកការបូជាព្រះសាស្ដា មានផលានិសង្សរាប់មិនបាន រមែងនាំប្រយោជន៍សុខមកប្រគល់ឲ្យ អស់កាលដ៏យូរអង្វែង, អាត្មាអញនឹងបូជាព្រះសាស្ដា ដោយផ្កាឈើទាំងនេះ" ដូច្នេះហើយ ក៏បាន

លះបង់ជីវិតរបស់ខ្លួនហើយ ទើបបោះផ្កាទាំង ៨ នាឡិទៅ ចាត់ជា ៨ ក្តាប់ ។ ក៏ផ្កា ២ ក្តាប់ ដែលនាយសុនមាលាការ បានបោះទៅហើយ ជាដំបូង បានក្លាយទៅជាពិតានមាលា អណ្តែតនៅពួដីខាងលើ នៃព្រះសាស្តា, ផ្កា ២ ក្តាប់ ដែលបានបោះទៅហើយលើកទី ២ បានស្ថិតនៅ ពួដីខាងស្តាំ, ផ្កា ២ ក្តាប់ដែលបានបោះទៅហើយ លើកទី ៣ បានស្ថិតនៅ ពួដីខាងក្រោយ, ផ្កា ២ ក្តាប់ដែលបានបោះទៅហើយ លើកទី ៤ បានស្ថិតនៅ ពួដីខាងឆ្វេងសរុបទៅហើយ ផ្កា ៦ ក្តាប់ បានក្លាយទៅជាគ្រឿងមាលាសម្រាប់បិទបាំង បានស្ថិតនៅហើយ ពួដីខាងទាំង ៣ ។ ពួដីខាងព្រះភ័ក្ត្របានមានត្រឹមតែមាត់ទ្វារ សម្រាប់ស្តេចយាងទៅ តែប៉ុណ្ណោះ ។ ទងផ្កាទាំងឡាយ មាននៅខាងក្នុង, ត្របកផ្កា មាននៅ ខាងក្រៅ, ព្រះសាស្តា ប្រៀបដូចជាត្រូវចោមរោមហើយ ដោយសន្លឹកប្រាក់ស្តេចយាងទៅហើយ ។ សូម្បីផ្កាទាំងឡាយ ក៏មិនបានរបេះ មិនបានជ្រុះរោយឡើយ អណ្តែតទៅស្ថិតនៅ ត្រង់ទីដែលព្រះអង្គគង់ ជាមួយនឹងព្រះសាស្តាតែម្តង ។ ព្រះនគរទាំងមូល បានផ្អើលឆោឡោហើយ ព្រោះឃើញហេតុដ៏អស្ចារ្យនោះ ។ ក៏ខាងក្នុងព្រះនគរមានមនុស្ស ៩ កោដិ ។ បណ្តាមនុស្សទាំងនោះ សូម្បីមនុស្សម្នាក់ ឈ្មោះថា មិនកាន់នូវភិក្ខាហើយ ចេញទៅក្រៅ មិនមាន ។

មហាជន ធ្វើនូវការស្រែកហ៊ោកញ្ជៀវ ១.០០០ និងការលើកឡើងនូវទង់ជ័យ ១.០០០ ត្រាច់ទៅ ជាមួយនឹងព្រះសាស្ដា ។ ចំណែកនាយមាលាការ បូជា សរសើរ ថ្វាយបង្គំ នូវព្រះសាស្ដា យ៉ាងដូច្នេះហើយ ក៏កាន់យកតែកញ្ច្រែងទទេនុ៎ះឯង ត្រឡប់ទៅផ្ទះ ត្រូវភរិយាដណ្ដឹងសួរ ថា "ផ្កាទាំងឡាយ នៅឯណា ?" ដូច្នេះហើយ ប្រាប់ ថា "ខ្ញុំបានយកផ្កាទាំងនោះ ទៅបូជាព្រះសាស្ដាអស់ហើយ" ។

ភរិយាសួរ ថា "ឥឡូវនេះ បងនឹងធ្វើអ្វី ដល់ព្រះរាជា ?" ។

នាយមាលាការ ពោល ថា "ព្រះរាជា ចូរសម្លាប់ខ្ញុំក្ដី ចូរនិរទេសខ្ញុំ ចាករដ្ឋធានីក្ដី, ខ្ញុំលះបង់ជីវិតហើយ បូជាព្រះសាស្ដា, ការបូជាដោយផ្កា យ៉ាងដូច្នេះ កើតមានហើយ" ដូច្នេះ បានប្រាប់ហើយ នូវរឿងរ៉ាវទាំងពួង ។

ក៏ភរិយារបស់នាយមាលាការនោះ ជាស្រ្តីអន្ធពាល មិនធ្វើសេចក្ដីជ្រះថ្លា ក្នុងការអស្ចារ្យនេះឡើយ ជេរប្រទេចនាយមាលាការនោះហើយពោល ថា "ធម្មតាព្រះរាជាទាំងឡាយ ជាអ្នកកាចសាហាវទ្រង់ក្រោធខឹងមួយរំពេច រមែងធ្វើនូវសេចក្ដីវិនាសដ៏ច្រើនណាស់, សេចក្ដីវិនាស គប្បីមានដល់ខ្ញុំផង ព្រោះកម្មដែលអ្នកបានធ្វើហើយ" ដូច្នេះហើយ ក៏បាននាំកូនទាំងឡាយ ចូលទៅគាល់ព្រះរាជា ក្រាបទូលនូវពាក្យ ដែលនាយមាលាការនោះនិងខ្លួនពោលហើយ គ្រប់សព្វ

ហើយ បានក្រាបទូល ថា "បពិត្រព្រះសម្មតិទេព កម្មដែលនាយមាលាការនោះ បានធ្វើហើយ ជាកម្មដែលធ្វើល្អឬធ្វើអាក្រក់, កម្មនោះ ចូរជាកម្មរបស់នាយមាលាការនោះម្នាក់ឯងចុះ, សូមព្រះអង្គទ្រង់ជ្រាប ថា ទូលព្រះបង្គំបានលែងលះនាយមាលាការនោះហើយ" ។

ព្រះបាទពិម្ពិសារ ទ្រង់ព្រះសណ្ដាប់រឿងនោះហើយ ទ្រង់ព្រះតម្រិះ ថា " ឱហ្ន៎ ! ស្ត្រីនេះ ជាមនុស្សអន្ធពាល មិនញ៉ាំងសេចក្ដីជ្រះថ្លា ឲ្យកើតឡើងហើយ ក្នុងគុណយ៉ាងនេះឡើយ "ដូច្នេះហើយ ទ្រង់ធ្វើដូចជាទ្រង់ព្រះពិរោធហើយ ទ្រង់ត្រាស់សួរ ថា "ស្វាមីរបស់នាងនោះ បានធ្វើការបូជា ដោយផ្កាសម្រាប់ឧបដ្ឋាកយើងឬ ? " កាលបើនាងក្រាបទូល ថា "បពិត្រព្រះសម្មតិទេព ត្រឹមត្រូវហើយ " ដូច្នេះ, ទើបទ្រង់ត្រាស់ ថា "ការដែលនាងបានលែងលះស្វាមីរបស់នាងនោះ ចាត់ថា នាងបានធ្វើល្អហើយ, ការបូជាដោយផ្ការបស់យើង គឺស្វាមីរបស់នាងបានធ្វើហើយ, យើងនឹងដឹងនូវកិច្ចដែលយើងគប្បីធ្វើ ដល់ស្វាមីរបស់នាងនោះ"ដូច្នេះ ទ្រង់បានបញ្ជូននាងទៅហើយ ទើបស្ដេចយាងទៅកាន់សំណាក់នៃព្រះសាស្ដា ដោយប្រញាប់ ទ្រង់ស្ដេចយាងទៅ ជាមួយនឹងព្រះសាស្ដានុ៎ះឯង ។

ព្រះសាស្ដា ទ្រង់ជ្រាបនូវសេចក្ដីជ្រះថ្លានៃព្រះរាជហឫទ័យនៃព្រះរាជាហើយ ដើម្បីទ្រង់ធ្វើនូវគុណ របស់នាយមាលាការ

ឲ្យប្រាកដ ទើបទ្រង់ស្តេចយាងទៅ តាមមាគ៌ានៃភេរីចរណ៍ ក្នុងព្រះនគរ ដែលមានទីប្រមាណ ៣ គាវុត មិនទ្រង់ប្រទានបាត្រ ដល់បុគ្គលណាម្នាក់ឡើយ ទ្រង់ស្តេចយាងទៅកាន់ព្រះលាន នៃព្រះរាជាហើយ ក៏ទ្រង់ប្រទានបាត្រ ដល់ព្រះរាជា ដែលទ្រង់មានព្រះបំណងចង់ទទួលយក ទ្រង់មិនបានយាងចូលទៅកាន់ព្រះរាជសំណាក់ឡើយ ទ្រង់គង់នៅ ក្នុងទីស្ថាននោះតែម្តង ទ្រង់បានព្រះរាជាអង្គាសហើយ ដោយព្រះក្រយាហារដ៏ប្រណីត ក្នុងវេលាស្រេចភត្តកិច្ចហើយ ទ្រង់បានធ្វើអនុមោទនាស្រេច ទើបស្តេចយាងទៅកាន់ព្រះវិហារ ហើយ ស្តេចយាងចូលទៅកាន់ព្រះគន្ធកុដី ។ ចំណែកផ្កាទាំងឡាយ, កាលបើព្រះសាស្តា ទ្រង់ស្តេចយាងទៅ, ក៏អណ្តែតទៅដែរ, កាលបើព្រះសាស្តា ទ្រង់ស្តេចគង់, ក៏ឈប់នៅដែរ, កាលបើព្រះសាស្តា ទ្រង់យាងចូលទៅកាន់ព្រះគន្ធកុដីហើយ, ក៏ធ្លាក់ទៅក្នុងស៊ុមមាត់ទ្វារ ។

ចំណែកព្រះរាជា ទ្រង់ស្តេចយាងតាមព្រះសាស្តាហើយ ទ្រង់ស្តេចយាងត្រឡប់មកវិញ ទ្រង់ត្រាស់បញ្ជាឲ្យហៅនាយមាលាការមកហើយ ទ្រង់មានព្រះទ័យជ្រះថ្លាក្នុងនាយមាលាការនោះ ទ្រង់បានព្រះរាជាទាន នូវដំរីជាដើម មួយមុខ ៨ ៗ ៧ យ៉ាង គឺ ដំរី, សេះ, ខ្ញុំប្រុស, ខ្ញុំស្រី, ពួកនារីដែលប្រដាប់តាក់តែងហើយដោយ

គ្រឿងអលង្ការគ្រប់យ៉ាង, ស្រុកដ៏ប្រសើរ, កហាបណៈមួយពាន់ និងគ្រឿងប្រដាប់ ឈ្មោះ មហាបសាធនៈ ដល់នាយមាលាការនោះ ។

ព្រះសាស្តា ស្តេចយាងទៅកាន់ព្រះវិហារហើយ ត្រូវព្រះអានន្ទត្ថេរ ក្រាបទូលសួរ ថា "បពិត្រព្រះអង្គដ៏ចំរើន តើវិបាកនឹងមាន ដល់នាយមាលាការ យ៉ាងដូចម្តេចទៅហ្ន៎ ?" ដូច្នេះហើយ ទើបទ្រង់ត្រាស់ ថា "ម្នាលអានន្ទ នាយមាលាការនេះ លះបង់ជីវិតដើម្បីតថាគត ធ្វើការបូជាដោយផ្កា នឹងមិនទៅកាន់ទុគតិឡើយ អស់មួយសែនកប្ប អន្ទោលទៅមក ក្នុងទេវតានិងមនុស្សទាំងឡាយ ហើយ នឹងបានជាព្រះបច្ចេកពុទ្ធ ព្រះនាមសុមនៈ" ដូច្នេះ កាលទ្រង់សំដែងធម៌ ទើបត្រាស់គាថានេះ ក្នុងពាលវគ្គ នៃធម្មបទ ថា ÷

"បុគ្គលធ្វើកម្មណាហើយ រមែងមិនក្តៅក្រហាយ(១)
ជាខាងក្រោយ ឬដល់នូវសេចក្តីពេញចិត្ត មាន
ចិត្តល្អ ទទួលផលនៃកម្មណា, កម្មដែលគេធ្វើ
ហើយនោះឯង ឈ្មោះថា ជាកម្មដ៏ប្រសើរ" ។

ក្នុងទីបញ្ចប់គាថា ការបានសម្រេចធម៌ បានមានហើយ ដល់សត្វ ៨ ម៉ឺន ៤ ពាន់ ដោយប្រការដូច្នេះឯង ។

រឿង នាយសុមនមាលាការ ចប់ ។

---

១ ត្រៃបិដក ភាគទី ៥២ / ទំព័រទី ៣៥ ។

## ( រឿង ព្រះសុធាបិណ្ឌិយត្ថេរ )

(៦០) បានឮថា កុលបុត្រម្នាក់ បានបំពេញបុណ្យបារមី ទុកមកហើយ ក្នុងព្រះពុទ្ធអំពីមុនទាំងឡាយ កសាងសន្សំបុណ្យទុក ក្នុងភពនោះ ៗ ក្នុងកាលនៃព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមសិទ្ធត្ថ បានមកកើត ក្នុងផ្ទះនៃត្រកូល, កាលបើព្រះដ៏មានព្រះភាគ ទ្រង់ស្តេចធរមាននៅឡើយ, មិនអាចដើម្បីនឹងបំពេញបុណ្យបានឡើយ កាលបើព្រះដ៏មានព្រះភាគ ទ្រង់បានបរិនិព្វានទៅហើយ, បានដាក់ដុំនៃកំបោរស ១ ដុំ ក្នុងចន្លោះនៃដុំឥដ្ឋទាំង ២ ដុំ កាលដែលមហាជននាំគ្នាធ្វើបន្ទប់សម្រាប់បញ្ចុះ នូវព្រះធាតុចេតិយ របស់ព្រះដ៏មានព្រះភាគអង្គនោះ ។ ដោយបុញ្ញកម្មនោះ កុលបុត្រនោះ បានអន្ទោលទៅមក ក្នុងទេវតានិងមនុស្សទាំងឡាយនុ៎ះឯង អស់ ៩៤ កប្ប ក្នុងពុទ្ធុប្បាទនេះ បានមកកើតហើយ ក្នុងផ្ទះនៃត្រកូល ១ ដល់នូវការដឹងក្តីហើយ កើតជ្រះថ្លាក្នុងព្រះសាស្តា បួសមិនយូរប៉ុន្មានឡើយ ក៏បានសម្រេចជាព្រះអរហន្ត ។ លោកបានប្រាកដនាម ថា “ព្រះសុធាបិណ្ឌិយត្ថេរ” ។

ព្រះថេរៈនោះ កាលប្រកាស នូវការមិនខាតរយៈ នៃកិរិយាប្រព្រឹត្តិ ក្នុងកាលមុន របស់ខ្លួន ទើបបានពោលហើយ នូវគាថាទាំងឡាយនេះ ថា ៖

“បុគ្គលណាមួយ ក៏មិនអាច ដើម្បីនឹងរាប់បុណ្យ របស់បុគ្គលអ្នកបូជា នូវបុគ្គលដែលគួរបូជាទាំងឡាយ គឺ ព្រះពុទ្ធ ឬក៏ ពួកសាវ័ក ជាអ្នកកន្លងនូវធម៌ជាគ្រឿងធ្វើឲ្យយឺតយូរបានហើយ ជាអ្នកឆ្លងផុតសេចក្ដីសោក និងការខ្សឹកខ្សួលបានហើយ ថា ‘បុណ្យនេះ មានប្រមាណប៉ុណ្ណោះឯង’ បានឡើយ ។ មួយទៀត អ្នកណាមួយ ក៏មិនអាចដើម្បីនឹងរាប់បុណ្យរបស់បុគ្គលអ្នកបូជា នូវបូជារហបុគ្គលទាំងឡាយនោះ ជាអ្នកមិនញាប់ញ័រដោយលោកធម៌ ជាអ្នករលត់ហើយ ជាអ្នកមិនមានភ័យមកអំពីទីណាៗ ថា ‘បុណ្យនេះ មានប្រមាណប៉ុណ្ណោះឯង’ ដូច្នេះ បានឡើយ ។ មួយទៀត បុគ្គលណាក្នុងលោកនេះ គប្បីគ្រប់គ្រងនូវភាពជាឥស្សរៈ (ជាធំ) នៃទ្វីបទាំង ៤, ទ្រព្យទាំងអស់ របស់បុគ្គលនោះនុ៎ះ រមែងមិនដល់នូវចំណែកទី ១៦ នៃការបូជានេះឡើយ ។ ខ្ញុំមានចិត្តជ្រះថ្លាហើយ បានយកដុំកំបោរ ( បាយអ ) ដាក់ហើយក្នុងចន្លោះនៃដុំឥដ្ឋ ក្នុងព្រះចេតិយ របស់ព្រះពុទ្ធ

ទ្រង់ព្រះនាមសិទ្ធត្ថ ព្រះអង្គប្រសើរជាងនរជន ។ ខ្ញុំបានធ្វើហើយ នូវអំពើណាមួយ ក្នុងកាលនោះ, ព្រោះអំពើនោះ ទើបខ្ញុំមិនដែលបានស្គាល់ទុគតិ រហូតអស់ ៩៤ កប្ប អំពីភទ្ទកប្បនេះទៅ, នេះ គឺជាផលនៃការជួសជុល ។ ក្នុងកប្បទី ៣០ អំពីភទ្ទកប្បនេះឯង ខ្ញុំបានកើតជាស្តេចចក្រពត្តិ ទ្រង់មានព្រះនាមថា ព្រះបាទបដិសង្ខារៈ ជាអ្នកដល់ព្រមហើយដោយរតនៈ ៧ ប្រការ រហូតអស់ ១៣ លើក, ធម៌ទាំងឡាយនេះ គឺ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ, ពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ " ។

(៦១) យោជនា ថា " បណ្តាបទទាំងឡាយនោះ បទ ថា 'បូជារហេ' មានសេចក្តីថា 'បុគ្គលទាំងឡាយ មានព្រះពុទ្ធ, ព្រះបច្ចេកពុទ្ធ, ព្រះសាវ័ក, អាចារ្យ, ព្រះឧបជ្ឈាយ៍, មាតានិងបិតា និងគ្រូជាដើម ឈ្មោះថា បូជារហាបុគ្គល (បុគ្គលដែលគួរបូជា), អ្នកណាមួយ ក៏មិនអាច ដើម្បីនឹងរាប់នូវបុណ្យ របស់បុគ្គលអ្នក

បូជានូវបូជារហបុគ្គលទាំងនោះ ដោយវត្ថុទាំងឡាយ មានផ្កាកម្រង, គ្រឿងប្រទីប, ធូប, គ្រឿងក្រអូប, គ្រឿងប្រដាប់តាក់តែង និងបច្ច័យ ៤ ជាអាទិ៍ និងដោយកិច្ចមានការថ្វាយបង្គំជាដើម ថា 'បុណ្យនេះ មានប្រមាណប៉ុណ្ណេះ' ដូច្នេះ បានឡើយ" ។

ឥឡូវនេះ ព្រះថេរៈ ពោលពាក្យ ថា "**ពុទ្ធេ**" ដូច្នេះជាអាទិ៍ ដើម្បីសំដែង នូវបូជារហបុគ្គលទាំងឡាយ ដោយអំណាចការកំណត់បូជារហបុគ្គលយ៉ាងប្រសើរខ្ពង់ខ្ពស់ ។

បណ្ដាបទទាំងនោះ បទ ថា "**ពុទ្ធេ**" គឺ ទាំងព្រះសម្មាសម្ពុទ្ធ ទាំងព្រះបច្ចេកពុទ្ធទាំងឡាយ ។ ពាក្យ ថា "**យទិ ច**" មានសេចក្ដីថា ឬថា ។ បទ ថា "**សាវកេ**" បានដល់ ពួកព្រះសាវ័ក របស់ព្រះពុទ្ធ ។ បាទគាថា ថា "**បបញ្ចសមតិក្កន្តេ**" បានដល់ ជាអ្នកមានធម៌គ្រឿងយឺតយូរ គឺ តណ្ហា ទិដ្ឋិ និងមានះ បានកន្លងហើយ ។ បាទគាថា ថា "**តិណ្ណសោកបរិទ្ទវេ**" បានដល់ ឆ្លងហើយ គឺ កន្លងផុតហើយ នូវសេចក្ដីសោក និងការខ្សឹកខ្សួល ។

ព្រះថេរៈ ពោល ថា "**តេ តាទិសេ**" ដូច្នេះជាដើម ដើម្បីនឹងសំដែងសេចក្ដី ថា "អ្នកណាមួយ ក៏មិនអាចដើម្បីនឹងរាប់បុណ្យរបស់បុគ្គលអ្នកបូជានូវបូជារហបុគ្គលទាំងឡាយ មានព្រះពុទ្ធជាដើម ដែលទ្រង់ធរមាននៅឡើយ តែម្យ៉ាងប៉ុណ្ណោះ ក៏ទេដែរ, សូម្បីក្នុង

បុណ្យរបស់បុគ្គលអ្នកបូជានូវបូជារហបុគ្គលមានព្រះពុទ្ធជាដើម ដែលទ្រង់បរិនិព្វានទៅហើយក្តី នូវព្រះចេតិយនិងព្រះបដិមាករ ជាដើម របស់បូជារហបុគ្គលទាំងឡាយនោះក្តី ក៏ន័យនេះ ដូចគ្នាដែរ" ។

បណ្តាបទទាំងនោះ បទ ថា "**តេ**" បញ្ចូល **ពុទ្ធាទិកេ** មក ( ប្រែថា នូវបូជារហបុគ្គលមានព្រះពុទ្ធជាដើម ) ។ បទ ថា "**តាទិសេ**" គឺ ជាអ្នកប្រកបដោយគុណ នៃបុគ្គលជាអ្នកនឹងធឹង ដោយអំណាចគុណ តាមដែលបានពោលមកហើយ ។ បទ ថា "**និព្វុតេ**" គឺ ជាអ្នករលត់ហើយ ដោយការរលត់នូវកិលេស មានរាគៈជាដើម ។ ភ័យ អំពីទីណា ៗ គឺ អំពីភព ឬ អំពីអារម្មណ៍ រមែងមិនមាន ដល់បូជារហបុគ្គលទាំងឡាយមានព្រះពុទ្ធជាដើមនោះ ព្រោះហេតុនោះ បូជារហបុគ្គលទាំងឡាយ មានព្រះពុទ្ធជាដើមនោះ ឈ្មោះថា មិនមានភ័យអំពីទីណា ៗ ។ បទ ថា "**ឥមេត្តំ**" មានសេចក្តីថា អ្នកណាមួយ ក៏មិនអាច ដើម្បីនឹងរាប់ គឺ ដើម្បីនឹងធ្វើនូវការរាប់ បានដល់ ដើម្បីនឹងរៀបរាប់ ដោយអំណាចចំនួនមានមួយរយ និងមួយពាន់ជាដើម ថា "បុណ្យនេះ មានប្រមាណប៉ុណ្ណោះ" ដូច្នេះ បានឡើយ ។ បទ ថា "**អបិ កេនចិ**" ប្រែថា គឺអ្នកណាមួយ គឺបុគ្គលសូម្បីជាអ្នកមានអានុភាពច្រើន ។ មួយយ៉ាងទៀត មានសេចក្តីថា បណ្តាការរាប់ ៣ យ៉ាង ដោយ

អំណាចនៃការវាស់ ការថ្លឹង និងការវាល់ ដោយការរាប់ឯណានីមួយ ។ បណ្ដាការរាប់ទាំង ៣ យ៉ាងនោះ ការកំណត់យកសេចក្ដីថា "របស់នេះ មានប្រមាណប៉ុណ្ណេះ" ដូច្នេះ ឈ្មោះថា ការវាស់ ។ ការថ្លឹង ដោយជញ្ជីង ឈ្មោះថា ការថ្លឹង ។ ការវាល់ឲ្យពេញ ក្នុងគ្រឿងសម្រាប់វាល់ទាំងឡាយមានកន្លះទូកដៃ ១ ទូកដៃ និង ១ នាឡិជាដើមហើយរាប់ ឈ្មោះថា ការវាល់ ។ ឥឡូវនេះ ដើម្បីនឹងសំដែងនូវការបូជានោះ ទើបលោកពោល ថា "**ចតុទ្ទិបិ ច ទីបានំ**" ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទ ថា "**ទីបានំ**" បានដល់ ទ្វីបធំទាំងឡាយដែលមានទ្វីបតូចៗ ២ ពាន់ ជាបរិវារ ។ បទ ថា "**ឥស្សរំ**" មានសេចក្ដី ថា គប្បីឲ្យធ្វើភាពជាឥស្សរៈ គឺភាពជាស្ដេចចក្រព័ត្តិក្នុងផ្ទៃនៃចក្រវាឡទាំងមូល រួមទ្វីបទាំងឡាយ ដូចបានពោលមកហើយ ចូលជាមួយគ្នា ។ បាទគាថា ថា "**ឯតិស្សា បូជនាយេតំ**" មានសេចក្ដី ថា ទ្រព្យទាំងអស់ មានរតនៈ ៧ ប្រការជាដើម ក្នុងសកលទ្វីបនោះ រមែងមិនដល់នូវចំណិតទី ១៦ នៃការបូជា ព្រោះដុំកំបោរមួយដុំ ក្នុងបន្ទប់សម្រាប់បញ្ចុះព្រះធាតុ ក្នុងព្រះចេតិយ ។

បទ ថា "**កលំ**" មានសេចក្ដី ថា រមែងមិនដល់នូវចំណិតនៃចំណែកទី ១៦ ដែលបានបែងចែក អស់ ១៦ ដង ១៦ លើក

នៃកិរិយាបូជា ដែលបុគ្គលបានធ្វើហើយ ក្នុងព្រះចេតិយ" ។

បទ ថា "**នរគ្គស្ស**" មានសេចក្តីថា កាលបើមហាជននាំគ្នាធ្វើការបូកដោយកំបោរ ក្នុងបន្ទប់សម្រាប់បញ្ចុះព្រះធាតុ ក្នុងព្រះចេតិយ របស់ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថាសិទ្ធត្ថ ព្រះអង្គទ្រង់ប្រសើរខ្ពង់ខ្ពស់ជាងនរជនទាំងឡាយ ។ បទ ថា "**ឥដ្ឋកន្តរេ**" គឺ ត្រង់កណ្តាលចន្លោះ នៃដុំឥដ្ឋទាំង ២ ។ មយ៉ាងទៀត មានសេចក្តីថា ក្នុងចន្លោះ នៃទីដែលជាកំពូលនៃទីជាទីទ្រនូវផ្កា ។ បទ ថា "**ទិន្នោ**" ប្រែថា បានដាក់ហើយ ។

រឿង ព្រះសុធាបិណ្ឌិយត្ថេរ មកក្នុងទសមវគ្គ នៃអបទាន ។

សូម្បីរឿងសុវណ្ណចេតិយ ក្នុងពុទ្ធវគ្គ នៃធម្មបទ ក៏គប្បីសំដែងផងដែរ ។

## ( រឿង កោសាតកីទេពធីតា )

(៦២) កាលបើព្រះបាទអជាតសត្រូវ ទ្រង់បាននាំយកព្រះសរីរធាតុ របស់ព្រះដ៏មានព្រះភាគ ដែលព្រះអង្គបានទទួលហើយ កាលព្រះដ៏មានព្រះភាគ ទ្រង់បានបរិនិព្វានកន្លងទៅហើយ ទ្រង់បានសាងព្រះស្តូប និងការឆ្លងព្រះស្តូប, ឧបាសិកាអ្នកអាស្រ័យនៅក្នុងទីក្រុងរាជគ្រឹះម្នាក់ ជម្រះសរីរៈរាងកាយ តាំងពីព្រលឹមស្រាង

កាន់យកផ្កាល្វីននោងព្រៃ ៤ ទង ដោយតាំងចិត្ត ថា "អាត្មាអញនឹងបូជាព្រះស្តូប របស់ព្រះសាស្តា" ដូច្នេះ ជាអ្នកមានចិត្ត គឺកម្លាំងនៃសទ្ធា ឲ្យប្រឹងប្រែងព្រមហើយ មិនទាន់បានត្រួតមើលនូវសេចក្តីអន្តរាយតាមផ្លូវផង ក៏បានដើរ មានមុខចំពោះទៅព្រះស្តូប ។

គ្រានោះ មេគោកូនខ្ចី បោលឆ្លោះមក យ៉ាងលឿន ជល់នាងឲ្យដល់នូវការអស់ទៅនៃជីវិតហើយ ។ នាងបានធ្វើកាលកិរិយាក្នុងទីនោះមួយរំពេចហើយ ក៏បានទៅកើត ក្នុងពួកទេវតាជាន់តាវតឹង្ស បានប្រាកដហើយ ព្រមទាំងរថ ក្នុងកណ្តាលនៃបរិវាររបស់ស្តេចសក្កទេវរាជ ដែលទ្រង់ស្តេចយាងទៅ ដើម្បីទ្រង់ព្រះក្រសាលក្នុងព្រះឧទ្យាន ។ ស្តេចសក្កទេវរាជ ទ្រង់ទតព្រះនេត្រឃើញនាងហើយ កាលទ្រង់ត្រាស់សួរ ទ្រង់បានត្រាស់ហើយនូវគាថាទាំងឡាយនេះ ថា ÷

(១)

"ម្នាលនាងដ៏ចំរើន អ្នកមានសំពត់លឿង មានទង់លឿង ស្អិតស្អាងដោយគ្រឿងប្រដាប់មានពណ៌លឿង មានអវយវៈលាបដោយខ្លឹមចន្ទន៍លឿង ទ្រទ្រង់ផ្កាឧប្បលលឿង មានប្រាសាទនិងទីដេកលឿង មានទីអង្គុយលឿង មានភោជន

១ ត្រៃបិដក ភាគទី ៥៥ / ទំព័រទី ៩៩ ។

ពណ៌លឿង មានឆ័ត្រលឿង មានរថលឿង
មានសេះលឿង មានផ្លិតលឿង ក្នុងភពជា
មនុស្ស ក្នុងកាលមុន នាងបានធ្វើកម្មដូចម្ដេច ?,
ម្នាលនាងទេវធីតា យើងសួរហើយ នាងចូរ
ប្រាប់ចុះ, នេះគឺ ជាផលនៃកម្មអ្វី ? " ។

បណ្ដាបទទាំងនោះ បទ ថា "**បីតចន្ទនលិត្តង្គេ**" គឺ ជាអ្នកមានសរីរៈ ដែលប្រដាប់ហើយ ដោយខ្លឹមចន្ទន៍ មានពណ៌ដូចមាស ។ បាទគាថា ថា "**បីតប្បាសាទសយនេ**" គឺ ប្រកបព្រមហើយ ដោយប្រាសាទដែលសម្រេចហើយដោយមាស និងដោយទីដេកដែលគេបិទបាំងដោយមាស ។ ស្ដេចសក្កទេវរាជ ទ្រង់ប្រកាន់យកមាសទាំងអស់ ដោយបីតស័ព្ទ ទាំងខាងក្រោម ទាំងខាងលើ ដោយប្រការដូច្នេះឯង ។

(៦៣) លំដាប់នោះ ទេវធីតានោះ កាលនឹងក្រាបទូលដល់ស្ដេចសក្កទេវរាជនោះ ទើបបានពោលគាថាទាំងនេះ ថា ÷

" បពិត្រព្រះអង្គដ៏ចំរើន ! មានវល្លិ៍ននោងព្រៃ[១]
ជាវល្លិ៍មានជាតិល្វីង ដែលគេមិនត្រូវការហើយ,

---

១ ត្រៃបិដក ភាគទី ៥៥ / ទំព័រទី ៩៩ ។

ខ្ញុំម្ចាស់ មានចិត្តជ្រះថ្លាហើយ បានយកផ្កានៃនាង
ព្រៃនោះ ៤ ទង ទៅបូជាព្រះស្តូប ឧទ្ទិសចំពោះ
ព្រះសរីរៈ របស់ព្រះសាស្តា, ខ្ញុំម្ចាស់កំពុងមាន
ចិត្តប្រព្រឹត្តទៅ ក្នុងព្រះធាតុ នៃព្រះមានព្រះភាគ
នោះ មិនបានក្រឡេកមើលផ្លូវមេគោនោះផង,
គ្រានោះ ស្រាប់តែមេគោ មកជល់ខ្ញុំម្ចាស់ ដែល
មានអធ្យាស្រ័យមិនទាន់ដល់ព្រះស្តូប (ស្លាប់ទៅ),
បើខ្ញុំម្ចាស់គប្បីសន្សំបុណ្យនោះសម្រេច, ម្ល៉េះ
សមជាមានសម្បត្តិដ៏លើសលុបជាងនេះពិតមែន,
បពិត្រព្រះអង្គជាធំជាងទេវតា នាមមឃវៈ ជា
ទេវកុញ្ជរ ខ្ញុំម្ចាស់បានលះបង់រាងកាយជាមនុស្ស
មកកើតជាមួយនឹងព្រះអង្គ ព្រោះកម្មនោះ" ។

បណ្តាបទទាំងនោះ បទ ថា "លតត្ថិ" កាត់បទជា លតា
អត្ថិ (មានវល្លិ៍) ។ នាងទេពធីតា ហៅស្តេចសក្កទេវរាជ
ដោយសេចក្តីគោរព ថា "បពិត្រព្រះអង្គដ៏ចំរើន" ។ បទ ថា
"អនភិជ្ឈិតា" ប្រែថា ដែលគេមិនត្រូវការហើយ ។

បទ ថា "សរីរំ" បានដល់ ព្រះធាតុដែលជាព្រះសរីរៈ ។

ស័ព្ទនេះ ជាស័ព្ទហៅរួម ប្រើក្នុងសេចក្ដីសង្ខេប តែប៉ុណ្ណោះ ដូចជាឧទាហរណ៍ ថា "សំពត់ត្រូវភ្លើងឆេះ" និង ថា "ខ្ញុំបានឃើញសមុទ្រហើយ" ដូច្នេះឯង ។

បទ ថា "**អស្សុ**" បញ្ចូល **គោរូបស្ស** (ប្រែថា រូបគោ)។ បទ ថា "**មគ្គំ**" គឺ ផ្លូវជាទីមក ។ បទ ថា "**ន អវេក្ខិស្សំ**" គឺ មិនទាន់បានក្រឡេកមើលហើយ ។ បាទនៃគាថា ថា "**តទគ្គមនសា សតិ**" មានសេចក្ដីថា ខ្ញុំម្ចាស់កំពុងតែមានចិត្តប្រព្រឹត្តទៅ ក្នុងព្រះស្តូបនៃព្រះសាស្ដានោះតែម្យ៉ាង ។ អធិប្បាយថា "ព្រោះខ្ញុំម្ចាស់កំពុងតែមានចិត្តប្រព្រឹត្តទៅ ក្នុងព្រះស្តូប របស់ព្រះសាស្ដា តែប៉ុណ្ណោះ មិនបានមានចិត្តប្រព្រឹត្តទៅ ក្នុងមេគោនោះឡើយ ; ដូច្នោះ ទើបខ្ញុំម្ចាស់ មិនទាន់បានក្រឡេកមើលផ្លូវ របស់មេគោនោះ ។ បាលី ថា "**តទង្គមនសា**" ដូច្នេះ ក៏មានដែរ ។ សេចក្ដីថា "ចិត្តរបស់ខ្ញុំម្ចាស់នេះ ប្រព្រឹត្តទៅ ក្នុងអង្គនៃព្រះស្តូបនោះ គឺ ក្នុងព្រះសរីរៈ បានដល់ ក្នុងព្រះធាតុ របស់ព្រះសាស្ដានោះ ព្រោះហេតុនោះ ខ្ញុំម្ចាស់នេះ ទើបឈ្មោះថា មានចិត្តប្រព្រឹត្តទៅក្នុងព្រះសរីរៈ របស់ព្រះសាស្ដាអង្គនោះ" ។

បទ ថា "**ថូបំ**" គឺ ព្រះចេតិយ ។ បទ ថា "**អប្បត្តមានសំ**" គឺ មានអធ្យាស្រ័យ មិនទាន់ដល់ព្រមហើយ ។ ក៏ឆន្ទៈ មានក្នុង

ចិត្ត ព្រោះហេតុនោះ ទើបឈ្មោះថា មានសៈ គឺ អធ្យាស្រ័យ បានដល់ មនោរថ ។ នាងទេពធីតា ពោលហើយ យ៉ាងដូច្នោះ ព្រោះភាវៈនៃមនោរថ ដែលកើតឡើងហើយ ថា " អាត្មាអញ នឹងចូលទៅកាន់ព្រះស្តូបហើយ បូជាដោយផ្កាទាំងឡាយ " ដូច្នេះ មិនទាន់បានបរិបូណ៌នៅឡើយ ។ ក៏នាងទេពធីតានោះ បានកើតឡើងហើយ ក្នុងទេវលោក ដោយចិត្តគិតនឹងបូជាដោយផ្កា ក្នុងព្រះស្តូបឯណា, ចិត្តគិតនឹងបូជាដោយផ្កា ក្នុងព្រះស្តូប របស់នាងនោះ បានសម្រេចហើយ ដោយពិតប្រាកដ ។

បទ ថា " **តំ** " បានដល់ បុណ្យនោះ ។ បទ ថា " **ចាហំ** " កាត់បទជា **ចេ អហំ** ។ បទ ថា " **អភិសញ្ញេយ្យំ** " មានសេចក្តីថា ខ្ញុំម្ចាស់ គប្បីដល់ចំពោះ គឺ ចូលទៅដល់ព្រះស្តូបហើយ កសាង គឺសន្សំ ដោយប្រពៃ ដោយការបូជាដោយផ្កា តាមដែលបានពោលមកហើយ ។ ពាក្យ ថា " **ភិយ្យោ នូន ឥតោ** " មានសេចក្តីថា " ម្ល៉េះសមមានសម្បត្តិ ដ៏លើសលុប ជាងសម្បត្តិតាមដែលខ្ញុំម្ចាស់បានហើយ " ។

បទ ថា " **មឃវា** " ជាអាលបនៈ ( ពាក្យសម្រាប់ហៅ ) ។ បទ ថា " **ទេវកុញ្ជរ** " គឺ ជាអ្នកប្រាកដស្មើនឹងស្តេចដំរី ក្នុងពពួកទេវតា ដោយគុណវិសេសទាំងឡាយ មានកម្លាំងនិងសេចក្តីព្យាយាម

ប្រឹងប្រែង គ្រប់បែបយ៉ាងជាដើម ។ បទនេះ ជាបទវិសេសនៈនៃបទ ថា **មឃវា** នោះ ។ បទ ថា "**សហព្យតំ**" គឺ កាន់ភាពជាសំឡាញ់ ។

## ( ស្ដេចសក្កទេវរាជសំដែងធម៌ដល់ពួកទេវតា )

(៦៤) ស្ដេចសក្កទេវរាជ ទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ កាលនឹងសំដែងធម៌ដល់ពពួកទេវតា មានមាតលិទេវបុត្រជាប្រធាន ទើបទ្រង់បានត្រាស់នូវគាថាទាំងឡាយនេះ ថា ÷

"ម្នាលមាតលិ អ្នកចូរមើលនូវសេចក្ដីអស្ចារ្យ[១] នេះជាផលនៃកម្មដ៏វិចិត្រ, ទេយ្យធម៌សូម្បីតែបន្តិចបន្តួច ដែលបុគ្គលបានធ្វើហើយ, បុណ្យត្រឡប់ទៅជាមានផលច្រើន, កាលបើចិត្តជ្រះថ្លាហើយ ចំពោះព្រះតថាគត ជាព្រះសម្ពុទ្ធ ព្រះបច្ចេកពុទ្ធ ឬសាវ័ក របស់ព្រះតថាគតនោះ, ទក្ខិណាទាន ឈ្មោះថា មានផលតិចតួចមិនមែនសោះឡើយ, ម្នាលមាតលិ អ្នកចូរមកចុះ, សូម្បីយើងទាំងឡាយ ក៏នឹងបូជាព្រះធាតុ របស់

---

១ ត្រៃបិដក ភាគទី ៥៥ / ទំព័រទី ១០០ ។

ព្រះតថាគត ឲ្យលើសលុប ជាងនេះទៅទៀត, ការសន្សំនូវបុណ្យទាំងឡាយ ជាហេតុនាំឲ្យមានសេចក្ដីសុខ, សូម្បីកាលព្រះតថាគត ទ្រង់ឋិតនៅក្ដី បរិនិព្វានទៅហើយក្ដី, បើតាំងចិត្តស្មើ, ផលក៏មានស្មើ, ដ្បិតថា សត្វទាំងឡាយ អ្នកមានការតម្កល់ចិត្តទុកជាហេតុ ទើបទៅកាន់សុគតិបាន, ទាយកទាំងឡាយ រមែងទៅកាន់ស្ថានសួគ៌បាន ព្រោះធ្វើការបូជា ចំពោះព្រះតថាគតទាំងឡាយណា, ព្រះតថាគតទាំងឡាយនោះ ទ្រង់កើតឡើងក្នុងលោក ដើម្បីប្រយោជន៍ដល់ជនច្រើនហ្ន៎ " ។

យោជនា ថា "បណ្ដាបទទាំងនោះ បទ ថា 'ចិត្តំ' ប្រែថា ដ៏វិចិត្រ គឺ ដែលគេមិនគួរគិត ។ បទ ថា 'កម្មផលំ' មានសេចក្ដីថា អ្នកចូរមើលនូវផល នៃបុញ្ញកម្ម សូម្បីកាលបើទេយ្យធម៌ជារបស់ដែលមិនប្រសើរ ត្រឡប់ជាប្រសើរទៅវិញ ព្រោះការដល់ព្រមនៃខេត្តគឺអ្នកទទួល និងព្រោះការដល់ព្រមនៃចិត្ត (ចេតនា)" ។ បទ ថា "កតំ" គឺ ប្រកបហើយ ក្នុងខេត្តដែលជាទីកើត ដោយ

អំណាចនៃសក្ការៈតែម្យ៉ាង ។ របស់ដែលទាយកគប្បីឲ្យ ឈ្មោះថា ទេយ្យទាន ។ កម្មដែលជាបុណ្យ ឈ្មោះថា បុណ្យ ។

បុណ្យដែលបុគ្គលបានធ្វើហើយ បន្តិចបន្តួច ក្នុងបុញ្ញខេត្តណា ជាបុណ្យមានផលច្រើន, ឥឡូវនេះ ស្តេចសក្កទេវរាជ កាលនឹងសំដែងនូវបុញ្ញខេត្ត (ស្រែបុណ្យ) នោះ ធ្វើឲ្យបានប្រាកដ ទើបទ្រង់ត្រាស់នូវគាថា ថា "**នត្ថិ ចិត្តេ**" ដូច្នេះ ជាដើម ។

បណ្តាបទទាំងនោះ បទ ថា "**សម្ពុទ្ធេ**" គឺ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។ **ច** អក្សរ បញ្ចូលមកនូវព្រះបច្ចេកពុទ្ធផងដែរ ។

បទ ថា "**អម្ហេបិ**" ប្រែថា សូម្បីយើងទាំងឡាយ ។ បទ ថា "**មហេម សេ**" គឺ នឹងឆ្លង បានដល់ នឹងបូជា ។

បាទគាថា ថា "**ចេតោបណិធិហេតូ ហិ**" មានសេចក្តីថា ជាអ្នកមានការតាំងចិត្ត របស់ខ្លួនទុកដោយប្រពៃមែនពិត ជានិមិត្ត, អធិប្បាយ ថា "ព្រោះការតម្កល់ខ្លួនទុក ដោយប្រពៃ" ។

ស្តេចសក្កទេវរាជ លុះទ្រង់ត្រាស់សំដែង យ៉ាងដូច្នេះហើយ ទ្រង់រម្ងាប់នូវព្រះឧស្សាហ៍ ក្នុងការស្តេចយាងទៅប្រពាត ក្នុងព្រះឧទ្យាន ស្តេចយាងត្រឡប់អំពីទីនោះឯងហើយ ទ្រង់ធ្វើការបូជាក្នុងព្រះចូឡាមណីចេតិយ រហូតមួយសប្តាហ៍ ក្នុងកាលក្រោយមក ទ្រង់បានត្រាស់នូវរឿងរ៉ាវនោះ ដល់ព្រះនារទត្ថេរ ដ៏មានអាយុ

ដែលកំពុងតែត្រាច់ទៅកាន់ទីចារិក ក្នុងទេវលោក ដោយគាថាទាំងឡាយនេះ ។ ក្នុងពេលដែលធ្វើបឋមសង្គាយនា ព្រះថេរៈបានសំដែងប្រាប់ហើយ ដល់ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ។ ព្រះថេរៈទាំងឡាយ បានលើកយកពាក្យនោះឡើងកាន់សង្គាយនាហើយ យ៉ាងដូច្នោះឯង ។

រឿង នាងកោសាតកីទេពធីតា ក្នុងអដ្ឋកថាបីតវិមាន ចប់ ។

ពុទ្ធបូជា រមែងនាំមកនូវប្រយោជន៍សុខ អស់កាលដ៏យូរអង្វែង ដូចបានពណ៌នាមកហើយនេះឯង ។

## ( រឿង នាងបញ្ចបាបា )

(៦៥) ក្នុងអតីតកាល ក្នុងក្រុងពារាណសី មាននាងធីតារបស់អ្នកក្រីក្រម្នាក់ បានជាន់ដីស្អិតលាបជញ្ជាំងផ្ទះ ។

គ្រានោះ ព្រះបច្ចេកពុទ្ធមួយអង្គ បានចូលទៅកាន់នគរ ដើម្បីសុំនូវដីស្អិត ដើម្បីបូកនូវជញ្ជាំងនៃគូហា របស់ខ្លួនហើយ បានឈរនៅក្នុងទីមិនឆ្ងាយពីនាងធីតានោះ ។ នាងធីតានោះ ក្រោធហើយ មើលបណ្តើរ ពោលបណ្តើរ ថា "បពិត្រសមណៈ តើព្រះគុណម្ចាស់ មិនបានដីស្អិតខ្លះទេឬ ?" ហើយ ក៏បានដាក់ដុំនៃដីស្អិតយ៉ាងធំ ក្នុងបាត្ររបស់ព្រះបច្ចេកពុទ្ធអង្គនោះ ។ ព្រះបច្ចេកពុទ្ធ

បានទទួលយកដីស្អិតនោះហើយ ក៏និមន្តទៅ ។ នាងច្យុតចាកអំពីអត្តភាពនោះហើយ ក៏បានមកកើតជាធីតា របស់អ្នកទីទាល់ក្រម្នាក់ ក្នុងស្រុកក្បែរមាត់ទ្វារពួដ៏ទិសខាងកើត នៃទីក្រុងឈ្មោះពារាណសី ។ ដៃ, ជើង, មាត់, ភ្នែក និងច្រមុះ របស់នាងកើតជារបស់អាក្រក់អាក្រី ខុសពីប្រក្រតី ព្រោះនាងក្រោធខឹងហើយក្រឡេកមើលព្រះបច្ចេកពុទ្ធ ។ ដោយហេតុនោះ ពួកជនទាំងឡាយ ទើបបានស្គាល់នាងច្បាស់ ថា "បញ្ចបាបា" ។ ប៉ុន្តែសរីរៈរបស់នាង បានដល់ព្រមដោយសម្ផស្ស ព្រោះផលនៃការប្រគេនដុំនៃដីស្អិត ។

គ្រានោះ មានព្រះរាជាក្រុងពារាណសី ទ្រង់ព្រះនាមថា ពកៈ ។ ក្នុងរាត្រីថ្ងៃមួយ ព្រះរាជាអង្គនោះ ទ្រង់ស្តេចយាងត្រួតព្រះនគរ ដោយបន្លំភេទមិនឱ្យអ្នកណាមួយដឹង ទ្រង់ស្តេចយាងទៅដល់ទីស្ថាននោះហើយ ។

ចំណែកនាងបញ្ចបាបា កំពុងតែលេងជាមួយនឹងពួកក្មេងស្រីអ្នកស្រុក មិនទាន់ដឹងផង ក៏ចាប់ព្រះហស្តរបស់ព្រះរាជា ។ ព្រះរាជា ប្រៀបដូចជាត្រូវសម្ផស្សទិព្វពាល់ត្រូវហើយ ទ្រង់មិនអាចដើម្បីនឹងស្ថិតនៅ ដោយភាពជាព្រះអង្គឯងបានឡើយ ទ្រង់បានសព្វព្រះទ័យហើយ ដោយអំណាចសេចក្តីត្រេកត្រអាល ក្នុងផស្សៈ

ទើបទ្រង់ត្រាស់សួរ ថា " តើនាងជាធីតា របស់អ្នកណា ? " ។

នាងបានឆ្លើយតប ថា " នាងខ្ញុំជាធីតា របស់អ្នករស់ក្បែរមាត់ទ្វារ (ព្រះនគរ) " ។

ព្រះរាជាអង្គនោះ ទ្រង់ត្រាស់សួរនូវភាវៈ នៃនាងជាអ្នកមិនមានស្វាមីហើយ ទ្រង់ត្រាស់ ថា " ខ្ញុំនឹងជាស្វាមី របស់នាង, ចូរនាងទៅចុះ, ចូរនាងញ៉ាំងមាតាបិតាឱ្យយល់តាមផងចុះ " ។ នាងបញ្ចបាបានោះ បានទៅផ្ទះហើយ ប្រាប់ដល់មាតាបិតាហើយ ។ មាតាបិតាទាំងនោះ បានអនុញ្ញាតឱ្យហើយ ។ នាងបានត្រឡប់មកក្រាបទូល ដល់ព្រះរាជាហើយ ។ ព្រះរាជា ទ្រង់ស្ដេចយាងទៅកាន់ផ្ទះ (របស់នាង) មួយអន្លើនឹងនាង ទ្រង់គង់នៅរួមរស់ហើយ ទើបស្ដេចយាងទៅព្រះរាជសំណាក់តាំងពីព្រឹកព្រលឹម ។ តាំងអំពីពេលនោះមក ព្រះអង្គមិនទ្រង់ប្រាថ្នា ដើម្បីនឹងទតព្រះនេត្រនូវស្ត្រីដទៃទៀត ទ្រង់ស្ដេចយាងទៅ ក្នុងទីនោះ ជាប់ជានិច្ចដោយបានដំណែងភេទ មិនឱ្យអ្នកណាមួយដឹង ។

ក្រោយមក ថ្ងៃមួយ រោគធ្លាក់ឈាម បានកើតឡើងហើយដល់បិតា របស់នាងបញ្ចបាបានោះ ។ បាយបាយាស ដែលផ្សំហើយដោយទឹកដោះស្រស់ ទឹកឃ្មុំ និងស្ករក្រួស ដែលមិនបានផ្សំ (ដោយវត្ថុឯទៀត) ជាដើម ជាថ្នាំសម្រាប់កែរោគ របស់បិតានាងនោះ ។

ជនទាំងឡាយនោះ មិនអាចដើម្បីនឹងញ៉ាំងបាយបាយាសនោះ ឲ្យកើតឡើងបានឡើយ ព្រោះជាអ្នកទីទាល់ក្រ ។ គ្រានោះ មាតារបស់នាង បានពោល ថា "ម្នាលនាង ស្វាមីរបស់នាង នឹងអាចដើម្បីនឹងញ៉ាំងបាយបាយាស ឲ្យកើតឡើងបានឬទេ ?" ។ នាងបញ្ចាបាបានោះ បានក្រាបទូលសេចក្ដីនោះ ដល់ព្រះរាជា ក្នុងពេលដែលព្រះអង្គស្ដេចយាងមក ។

ព្រះរាជា ទ្រង់ត្រាស់ ថា "ម្នាលនាងដ៏ចំរើន នេះជាថ្នាំសម្រាប់កែរោគរបស់អ្នកធំ, ខ្ញុំនឹងបានមកអំពីទីណា ?" ដូច្នេះហើយ ទ្រង់មានព្រះបំណងនឹងនាំនាងទៅ ខាងក្នុងព្រះរាជសំណាក់ដោយឧបាយកល ព្រឹកឡើង ទើបស្ដេចយាងទៅកាន់ព្រះរាជសំណាក់ទ្រង់ត្រាស់ឲ្យចំអិនបាយបាយាសដូច្នោះ ហើយទ្រង់បានធ្វើជាពីរកញ្ចប់ ទ្រង់បានដាក់ផ្អូងសក់កែវមណី ក្នុងកញ្ចប់មួយ ស្រេចហើយទ្រង់ស្ដេចយាងមក ក្នុងរាត្រី ទ្រង់ត្រាស់ ថា "ម្នាលនាងដ៏ចំរើនក្នុងថ្ងៃនេះ បិតារបស់នាង ចូរបរិភោគកញ្ចប់បាយបាយាសនេះចុះ, ថ្ងៃស្អែកឡើង ចូរបរិភោគកញ្ចប់បាយបាយាសនេះចុះ" ។ នាងបានធ្វើហើយ តាមព្រះរាជតម្រាស់នោះ ។ រោគរបស់បិតានាងបានស្ងប់រម្ងាប់ហើយ ។

ក្នុងថ្ងៃស្អែកឡើង ព្រះរាជា ទ្រង់បានស្ដេចយាងទៅកាន់ព្រះ

រាជសំណាក់ ទ្រង់លាងព្រះភ័ក្ត្រហើយ ទើបទ្រង់ត្រាស់ថា "អ្នកទាំងឡាយ ចូរនាំយកនូវផ្លូងសក់កែវមណីមកឲ្យយើង"។

ពួករាជបុរស បានក្រាបទូល ថា "បពិត្រព្រះសម្មតិទេព ពួកទូលព្រះបង្គំ រកមិនឃើញទេ" ។ ព្រះរាជា ទ្រង់ត្រាស់ ថា "ពួកអ្នកទាំងឡាយ ចូរត្រួតពិនិត្យមើល ក្នុងទីគ្រប់កន្លែង តាំងអំពីខាងក្នុងព្រះនគរ រហូតដល់ខាងក្រៅព្រះនគរ ដោយទីបំផុតទៅសូម្បីក្នុងកញ្ចប់បាយ" ។ ពួករាជបុរស កាលត្រួតមើលទៅក៏បានឃើញកែវមណី ក្នុងផ្ទះរបស់នាងបញ្ចបាបា ហើយបានចាប់ចងមាតាបិតារបស់នាង នាំយកទៅហើយ ។

គ្រានោះ បិតានាងបញ្ចបាបានោះ បានប្រាប់ ថា "ពួកយើងខ្ញុំ មិនមែនជាចោរទេ, កែវមណីនេះ កូនប្រសា (របស់ពួកយើង) បាននាំយកមក" ។ ពួករាជបុរស បានសួរ ថា "តើកូនប្រសារបស់ពួកអ្នកនោះ នៅក្នុងទីណា ?" ។ បិតារបស់នាងបញ្ចបាបានោះ ប្រាប់ ថា "កូនស្រីរបស់ខ្ញុំស្គាល់" ដូច្នេះហើយ ទើបបានសួរនាងបញ្ចបាបានោះ ។ នាងបានឆ្លើយប្រាប់ ថា "បពិត្រលោកឳពុក ស្វាមីនាងខ្ញុំនោះ មកក្នុងវេលាងងឹត ហើយទៅវិញ ក៏ក្នុងវេលាងងឹតដូចគ្នាដែរ, ដោយហេតុនោះ ទើបនាងខ្ញុំ មិនស្គាល់រូបរបស់ស្វាមីនោះ, តែនាងខ្ញុំ អាចស្គាល់ស្វាមីនោះ

បាន ដោយការសម្ផស្សនៃដៃ" ។ បិតារបស់នាងនោះ បានប្រាប់ហើយដល់ពួករាជបុរស ។ ឯពួករាជបុរសទាំងនោះ ក៏បានក្រាបទូលហើយ ដល់ព្រះរាជា ។ ព្រះរាជាទ្រង់ធ្វើដូចជាមិនទ្រង់ជ្រាប ទ្រង់ត្រាស់ ថា "បើដូច្នោះ ពួកអ្នកទាំងឡាយ ចូរដាក់ស្ត្រីនោះ ខាងក្នុងរាំងនន ក្នុងព្រះលាននៃព្រះរាជា ហើយចោះប្រហោងរាំងននប្រមាណប៉ុនដៃ ស្រេចហើយឲ្យនាងចាប់ចោរដោយការសម្ផស្សនៃដៃ" ។ ពួករាជបុរសទាំងនោះ បានធ្វើយ៉ាងដូច្នោះហើយ ញុំាងពួកនគរទាំងមូល ឲ្យប្រជុំគ្នាហើយ ។ នាងបញ្ចបាបានោះ បានចាប់ដៃមនុស្សដែលមកហើយៗ លាតដៃ (ឲ្យចាប់) ពោល ថា "បុរសនេះ មិនមែនជាបុរសនុ៎ះទេ" ។ ពួកមនុស្សទាំងឡាយ ជាប់ចិត្តក្នុងសម្ផស្សរបស់នាង ដូចជាជាប់ចិត្តក្នុងសម្ផស្សដែលជាទិព្វ នឹកគិត ថា "បើស្ត្រីរូបនេះ ជាអ្នកគួរដល់អាជ្ញា, ពួកយើងសូម្បីជាត្រូវបង់ពិន័យក្តី ចូលដល់ភាពជាទាសកម្មករក្តី ក៏នឹងធ្វើស្ត្រីនេះ ទុកក្នុងផ្ទះ" ដូច្នេះ មិនអាចដើម្បីចាកចេញទៅបានឡើយ ។ ខណៈនោះ ពួករាជបុរសទាំងឡាយបានយកដំបងវាយមនុស្សទាំងនោះ ឲ្យចេញទៅហើយ ។ ពួកជនទាំងឡាយ មានឧបរាជជាដើម ក៏ដូចជាមនុស្សឆ្កួតគ្រប់ៗគ្នា ។

គ្រានោះ ព្រះរាជា ទ្រង់ត្រាស់ ថា "ទំនងដូចជាអាត្មាអញ

ទេដឹងហ្ន៎ ?" ដូច្នេះហើយ ទើបទ្រង់បានលាតព្រះហស្តទៅ ។ នាងបញ្ចាបាបានោះ ចាប់ព្រះហស្តបានភ្លាមហើយ ក៏ស្រែកយ៉ាងខ្លាំងថា "នាងខ្ញុំចាប់ចោរបានហើយ" ។ ព្រះរាជា ទ្រង់បានប្រាប់ហើយតាមសេចក្តីពិត ទ្រង់អភិសេកនាងបញ្ចាបាបានោះ ធ្វើជាព្រះអគ្គមហេសី ទ្រង់ព្រះរាជទានឥស្សរិយយស ដល់មាតាបិតា របស់នាងបញ្ចាបាបានោះ ចាប់តាំងអំពីពេលនោះមក ទ្រង់មិនក្រឡេកមើលឡើយ នូវពួកស្រ្តីស្នំដទៃទៀត ។ ពួកស្រីស្នំទាំងនោះខឹងចំពោះព្រះនាងបញ្ចាបាបានោះហើយ ស្វែងរកមើលកំហុស ។

ក្រោយមក ថ្ងៃមួយ ព្រះនាងបញ្ចាបាបានោះ ទ្រង់ព្រះសុបិននិមិត្តឃើញថា ព្រះនាងនឹងបានជាព្រះអគ្គមហេសី របស់ព្រះរាជាទាំងឡាយ ២ ព្រះអង្គ ទើបបានក្រាបទូលដល់ព្រះរាជាហើយ ។

គ្រានោះ ពួកស្រីស្នំទាំងនោះ បានដឹងហេតុនោះហើយ ទើបបានឲ្យហើយ នូវសំណូក ដល់ពួកអ្នកទាយសុបិនទាំងឡាយ ។ ពួកអ្នកទាយសុបិនទាំងនោះ ត្រូវព្រះរាជាត្រាស់សួរហើយ ក៏បានក្រាបទូល ថា "បពិត្រព្រះមហារាជ ការដែលព្រះនាងទេវី (ទ្រង់ព្រះសុបិន) ថា ទ្រង់បានគង់នៅលើ កដំរីសសុទ្ធ គឺជាបុព្វនិមិត្តនៃការទ្រង់ចូលទិវង្គត របស់ព្រះអង្គ និងការដែលព្រះនាងទេវី (ទ្រង់ព្រះសុបិន) ថា ទ្រង់ស្ថិតនៅលើកដំរី ទ្រង់ចាប់ពាល់ព្រះ

ច័ន្ទ ជាបុព្វនិមិត្តនៃការនាំមកនូវព្រះរាជាដែលជាបច្ចាមិត្រ ចំពោះព្រះអង្គ" ដូច្នេះ, កាលបើព្រះរាជាអង្គនោះ ទ្រង់ត្រាស់សួរ ថា "តើឥឡូវនេះ យើងគួរធ្វើ យ៉ាងដូចម្ដេច ?" ដូច្នេះហើយ, ទើបក្រាបទូល ថា "បពិត្រព្រះសម្មតិទេព ការដែលព្រះអង្គទ្រង់សម្លាប់ព្រះនាងទេវីនេះចោល មិនសមគួរទេ, (ប៉ុន្តែ) គួរតែដាក់ព្រះនាងទេវីទៅ ក្នុងទូកហើយ បណ្ដែតចោលទៅក្នុងទន្លេ" ។ ព្រះរាជាទ្រង់បានដាក់ព្រះនាងទេវីនោះទៅ ក្នុងទូកហើយ ទ្រង់ត្រាស់បញ្ជាឲ្យបណ្ដែតទៅហើយ ក្នុងរាត្រី ព្រមទាំងព្រះក្រយាហារ ព្រះភូសានិងគ្រឿងអលង្ការទាំងឡាយ ។

គ្រានោះ ព្រះរាជាមួយព្រះអង្គ ទ្រង់ព្រះនាមថា ទីបាវារិកៈ ទ្រង់ព្រះក្រសាលទឹក ខាងក្រោម ទ្រង់ទតព្រះនេត្រឃើញព្រះនាងបញ្ចបាបានោះ ក្នុងទូកដែលអណ្ដែតមក ទើបទ្រង់ត្រាស់សួរ ថា "នាងដូចជាបិសាច តើឈ្មោះអ្វី ?" ។ ព្រះនាងបញ្ចបាបានោះទ្រង់ធ្វើនូវការសើចហើយ ទ្រង់បានក្រាបទូលភាពនៃព្រះនាងជាព្រះអគ្គមហេសីនៃព្រះរាជាព្រះនាមពកៈ ។ បានឮថា ព្រះនាងទេវីនោះ ទ្រង់បានប្រាកដហើយ ក្នុងសកលជម្ពូទ្វីប ថា "បញ្ចបាបា" ។

គ្រានោះ ព្រះរាជាបានចាប់ព្រះនាងហើយ ទ្រង់សព្វព្រះរាជហឫទ័យ ដោយអំណាចសេចក្ដីត្រេកត្រអាល ក្នុងផស្សៈ

ទ្រង់មិនបានធ្វើសូម្បីនូវសេចក្ដីសម្គាល់ ចំពោះពួកស្រីស្នំដទៃទៀតឡើយ ទ្រង់បានធ្វើព្រះនាងបញ្ចាបាបានោះ ឲ្យជាព្រះអគ្គមហេសី ។

ព្រះរាជា ព្រះនាមពកៈ ទ្រង់ព្រះសណ្ដាប់ហេតុនោះហើយ ទ្រង់ព្រះតម្រិះ ថា “អាត្មាអញ នឹងមិនឲ្យព្រះនាងបញ្ចាបាបានោះដល់ព្រះរាជាព្រះនាមទីឃាវារិកៈនោះទេ” ហើយទ្រង់ប្រមូលកងទ័ពទៅតាំងបន្ទាយ នៅត្រង់ព្រំប្រទល់ជាយដែន របស់ព្រះរាជាព្រះនាមទីឃាវារិកៈនោះ ហើយទ្រង់បញ្ជូនព្រះរាជសាសន៍ទៅ មានសេចក្ដី ថា “ព្រះបាទទីឃាវារិកៈ នឹងទ្រង់ប្រទាននូវព្រះជាយា ឬក៏ការធ្វើសង្គ្រាម” ។

ចំណែកព្រះបាទទីឃាវារិកៈ ទ្រង់បានស្ដេចត្រៀមដើម្បីនឹងធ្វើសង្គ្រាមស្រេចហើយ ។ ពួកអាមាត្យ របស់ព្រះរាជាទាំង ២ ព្រះអង្គ បានប្រឹក្សាគ្នា ថា “ការស្លាប់ ព្រោះអាស្រ័យនូវស្ត្រី មិនគួរឡើយ, ព្រះនាងបញ្ចាបានេះ រមែងដល់ព្រះរាជាព្រះនាមពកៈ ព្រោះព្រះអង្គជាព្រះរាជស្វាមីមកអំពីមុន, រមែងដល់ព្រះរាជាព្រះនាមទីឃាវារិកៈ ព្រោះព្រះអង្គបានព្រះនាងលើទូក; ព្រោះហេតុនោះ ព្រះនាងបញ្ចាបា ចូរទ្រង់គង់នៅ ក្នុងព្រះរាជដំណាក់នៃព្រះរាជាមួយអង្គ ៗ មួយសប្ដាហ៍” ដូច្នេះហើយ ទើបបានក្រាបទូលឲ្យព្រះរាជាទាំង ២ ព្រះអង្គ ទ្រង់យល់ព្រមហើយ ។

ព្រះរាជាទាំង ២ ព្រះអង្គនោះ ទ្រង់មានព្រះរាជហឫទ័យត្រេកអរ ទើបទ្រង់បានត្រាស់បញ្ជាឲ្យសាងព្រះនគរ ២ ត្រង់ទីកំពង់នៃព្រំដែន ទ្រង់គង់នៅហើយ ។ ព្រះនាងបញ្ចបាបានោះបានគ្រប់គ្រងភាពជាព្រះអគ្គមហេសី នៃព្រះរាជាទាំង ២ ព្រះអង្គដោយប្រការដូច្នេះឯង ។

រឿង ព្រះនាងបញ្ចបាបា មកក្នុងអដ្ឋកថាកុណាលជាតក ។

## ( រឿង នាងបទុមវតី )

(៦៦) ក្នុងអតីតកាល មានស្ត្រីម្នាក់ ក្នុងស្រុកមួយ ក្នុងទីក្រុងពារាណសី បានធ្វើការងារ ដោយដៃរបស់ខ្លួនហើយ ចិញ្ចឹមជីវិត ។ ថ្ងៃមួយ នាងទៅខ្ទមស្រែ បានឃើញនូវផ្កាឈូករីកតាំងពីព្រឹកព្រលឹម ក្នុងស្រះមួយ ត្រង់ចន្លោះផ្លូវ ទើបបានចុះទៅកាន់ស្រះនោះហើយ កាច់ផ្កាឈូកនោះឯង និងស្លឹកឈូក ដើម្បីប្រយោជន៍ដល់ការវេចខ្ចប់នូវលាជ បានក្តិចនូវទងស្រូវសាលីទាំងឡាយ ក្បែរភ្លឺស្រែ ហើយអង្គុយលើខ្ទម បែងចែកលាជហើយរាប់បាន ៥០០ គ្រាប់ ។

ក្នុងខណៈនោះ ព្រះបច្ចេកពុទ្ធមួយព្រះអង្គ បានចេញអំពីនិរោធសមាបត្តិ លើភ្នំគន្ធមាទន៍ បាននិមន្តមកឈរនៅ ក្នុងទីមិន

ឆ្ងាយអំពីនាង ។ នាងបានឃើញព្រះបច្ចេកពុទ្ធអង្គនោះហើយ ក៏បានកាន់យកផ្កាឈូក ព្រមទាំងលាជ ចុះមកអំពីខ្ទមហើយ ដាក់លាជទៅក្នុងបាត្ររបស់ព្រះបច្ចេកពុទ្ធហើយ យកស្លឹកឈូកបិទបាត្រប្រគេនហើយ, កាលបើព្រះបច្ចេកពុទ្ធនិមន្តទៅបានបន្តិចហើយ, ទើបគិត ថា "ធម្មតាបព្វជិតទាំងឡាយ ជាអ្នកមិនត្រូវការដោយផ្កាឈូកទេ, អាត្មាអញ នឹងទៅយកផ្កាឈូកមកប្រដាប់" ដូច្នេះហើយ បានទៅយកផ្កាឈូក អំពីព្រះហស្តព្រះបច្ចេកពុទ្ធ ហើយបានគិតសាជាថ្មីទៀត ថា "បើព្រះគុណម្ចាស់ដ៏ចំរើន នឹងមិនត្រូវការដោយផ្កាឈូកទេ, គង់នឹងមិនឲ្យដាក់លើបាត្រឡើយ, ព្រះគុណម្ចាស់ដ៏ចំរើន គង់នឹងត្រូវការ ដោយពិត" ដូច្នេះហើយ ក៏បានដើរទៅតាម ដាក់ (ផ្កាឈូក) លើបាត្រ សូមខមាទោសព្រះបច្ចេកពុទ្ធហើយ ក៏បានធ្វើសេចក្តីប្រាថ្នា ថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ដោយផលានិសង្សនៃលាជ របស់នាងខ្ញុំទាំងនេះ នាងខ្ញុំសូមឲ្យមានបុត្រ តាមចំនួននៃលាជ, ដោយផលានិសង្សនៃផ្កាឈូក សូមឲ្យផ្កាឈូកផុសឡើង ដើម្បីនាងខ្ញុំ គ្រប់ៗជំហាន ក្នុងទីដែលនាងខ្ញុំបានកើតហើយ ៗ" ។

ព្រះបច្ចេកពុទ្ធ, កាលបើនាងមើលឃើញនុ៎ះឯង, ក៏បាននិមន្តទៅកាន់ភ្នំគន្ធមាទន៍ តាមអាកាស បានដាក់ផ្កាឈូកនោះ នៅក្បែរ

ជណ្តើរដែលជាទីសំរាប់ព្រះបច្ចេកពុទ្ធទាំងឡាយជាន់ ទីញកភ្នំឈ្មោះនន្ទមូលកៈ ធ្វើជាគ្រឿងសម្រាប់ជូតជើង ។ ចំណែកនាងបានកើតហើយ ក្នុងទេវលោក ព្រោះផលនៃកម្មនោះ ។ ក៏ចាប់តាំងអំពីពេលដែលនាងកើតហើយ ផ្កាឈូកដ៏ធំ បានផុសឡើងហើយ ដើម្បីនាង គ្រប់ៗជំហាន ។ នាងបានច្យុតចាកទេវលោកនោះហើយ បានមកកើត ក្នុងត្របកនៃផ្កាឈូក ក្នុងស្រះឈូកមួយ ក្បែរជើងភ្នំ ។

តាបសមួយអង្គ នៅអាស្រ័យស្រះនោះ បាននិមន្តទៅកាន់ស្រះដើម្បីប្រយោជន៍ដល់ការលប់លាងមុខ តាំងពីព្រឹកព្រលឹម បានឃើញផ្កា (ឈូក) នោះហើយ ក៏គិត ថា "ផ្កា (ឈូក) នេះ ធំជាងផ្កាទាំងឡាយដ៏សេសសល់, ឯផ្កាដ៏សេសសល់ បានរីកហើយ, ផ្កានេះនៅក្រពុំតែម្តង, ក្នុងផ្កាឈូកនេះ គួរនឹងមានហេតុ !" ដូច្នេះហើយ ក៏ចុះទៅកាច់ផ្កា (ឈូក) នោះមក ។ ផ្កាឈូកនោះ គ្រាន់តែតាបសនោះចាប់ប៉ុណ្ណោះ ក៏រីកឡើងហើយ ។ តាបសបានឃើញក្មេងស្រីដេកខាងក្នុងត្របកផ្កាឈូក ក៏ត្រឡប់បានសេចក្តីស្រឡាញ់ ដូចជាកូនស្រី ទើបនាំទៅកាន់បណ្ណសាលា ព្រមជាមួយនឹងផ្កាឈូកនោះឯង ឲ្យនាងគេងហើយ ក្នុងគ្រែតូច ។ ពេលនោះ ទឹកដោះស្រស់កើតឡើងហើយ ត្រង់ចង្អុលដៃ (របស់តាបស) ដោយបុញ្ញានុភាពរបស់នាង ។ តាបសនោះ, កាលបើផ្កានោះ ស្រពោនហើយ,

ក៏បាននាំយកផ្កាថ្មីដទៃទៀតមកហើយ ឲ្យនាងកុមារិកានោះគេង ។

គ្រានោះ ផ្កាឈូកបានផុសឡើងហើយ ដើម្បីនាងកុមារិកានោះ គ្រប់ ៗ ជំហាន តាំងអំពីពេលដែលនាងអាច ដើម្បីនឹងលេង ដោយការរត់ទៅរត់មកបាន ។ តាបស បានដាក់ឈ្មោះឲ្យ ថា "នាងបទុមវតី" ។ ពណ៌សម្បុរនៃសរីរៈ របស់នាងបទុមវតីនោះ ប្រៀបដូចជាគំនរនៃផ្កាថ្កាន់ ។ នាងមិនបានដល់នូវពណ៌សម្បុរ របស់ទេវតាទេ (តែ) បានកន្លងនូវពណ៌សម្បុររបស់មនុស្ស ។ អ្នកថ្មើរព្រៃ របស់ព្រះរាជាក្រុងពារាណសី បានឃើញនាងហើយ ក៏ទៅកាន់ក្រុងពារាណសីហើយ បានក្រាបទូលដល់ព្រះរាជា ។

ព្រះរាជា ទ្រង់ព្រះសណ្ដាប់ហេតុនោះហើយ ទើបទ្រង់ស្ដេចយាងទៅ ក្នុងអាស្រមបទនោះ ទ្រង់ថ្វាយបង្គំតាបសហើយ ទ្រង់បានគង់នៅ ក្នុងទីដ៏សមគួរ ទ្រង់នាំយកធីតារបស់តាបសមកហើយ ទ្រង់ស្ថាបនានាង ក្នុងគំនរនៃកហាបណៈ ទ្រង់ធ្វើការអភិសេកហើយ ក្នុងទីនោះឯង ស្រេចហើយទ្រង់នាំនាងមកកាន់ព្រះនគរ របស់ព្រះអង្គ តាំងអំពីពេលដែលព្រះអង្គស្ដេចយាងត្រឡប់មកវិញហើយ ទ្រង់មិនបានក្រឡេកមើល នូវស្រ្តីដ៏សេសសល់ទាំងឡាយឡើយ ទ្រង់អភិរម្យជាមួយនឹងនាងបទុមវតីនោះតែប៉ុណ្ណោះ ។ ក៏សត្វដែលកើតក្នុងផ្ទៃ បានកើតឡើងហើយដល់នាង ព្រោះការនៅរួមគ្នានុ៎ះឯង ។

ក៏កាលបើព្រះនាង មានព្រះគភ៌គ្រប់ហើយ, ក៏បានប្រសូតព្រះរាជឱរស ។ ព្រះមហាបទុមកុមារ តែមួយព្រះអង្គគត់ អាស្រ័យនៅក្នុងព្រះគភ៌ ។ ចំណែកព្រះឱរស ៤៩៩ ព្រះអង្គ ដែលសេសសល់ ជាសំសេទជៈ បានប្រសូតហើយ ក្នុងពេលដែលព្រះមហាបទុមកុមារ ប្រសូតចាកព្រះគភ៌នៃព្រះមាតា ទ្រង់បន្ទំហើយ ។ ព្រះរាជកុមារគ្រប់ព្រះអង្គនោះ ក្នុងពេលដែលព្រះអង្គទ្រង់មានព្រះជន្មាយុ ១៦ ព្រះវស្សា ទ្រង់បានព្រមគ្នាតែមួយក្រសាល ក្នុងស្រះមង្គលបោក្ខរណីយ៍ ដែលដេរដាសទៅដោយផ្កាឈូក ក្នុងព្រះឧទ្យាន ទ្រង់ទតព្រះនេត្រឃើញផ្កាឈូកថ្មីរីកស្គុសស្គាយ និងផ្កាឈូកចាស់ជ្រុះធ្លាក់ហើយចាកទង ទើបទ្រង់ព្រះតម្រិះ ថា " សេចក្ដីចាស់ជរាគ្រាំគ្រា យ៉ាងនេះ រមែងមានដល់ផ្កាឈូកនេះ ដែលមិនមានវិញ្ញាណគ្រប់គ្រង ដល់ម្ល៉េះទៅហើយ, ក៏នឹងចាំបាច់ពោលទៅធ្វើអ្វី ដល់សរីរៈរាងកាយ របស់ពួកយើងនោះ, ព្រោះថា សូម្បីសរីរៈរាងកាយ របស់ពួកយើងនេះ ក៏នឹងមានគតិ យ៉ាងនេះ ដូចគ្នាដែរ " ហើយបានកំណត់យកជាអារម្មណ៍ ក៏បានសម្រេចជាព្រះបច្ចេកពុទ្ធ ហោះទៅកាន់ញកភ្នំនន្ទមូលកៈ តាមអាកាស អាស្រ័យនៅក្នុងទីនោះ ក្នុងពេលអស់ព្រះជន្មាយុ ក៏បានបរិនិព្វានហើយ ។

ចំណែកព្រះនាងបទុមវតី ច្យុតចាកភពនោះហើយ កាលទ្រង់

អន្ទោលទៅមក ក្នុងពុទ្ធប្បាទនេះ បានជាព្រះឧប្បលវណ្ណាថេរី ។

រឿង នាងបទុមវតី មកក្នុងអដ្ឋកថាអបទានជាដើម ។

សូម្បីការបូជាព្រះបច្ចេកពុទ្ធក៏រមែងនាំមកនូវប្រយោជន៍សុខដោយប្រការដូច្នេះឯង ។

## ( រឿងស្ត្រី ៤ នាក់ )

(៦៧) ក្នុងអតីតកាល មានស្ត្រី ៤ នាក់ ក្នុងព្រះនគរឈ្មោះបណ្ឌកជៈ ក្នុងរដ្ឋឈ្មោះឯសិកា ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈ ។ បណ្តាស្ត្រីទាំង ៤ នាក់នោះ ស្ត្រីម្នាក់ បានឃើញភិក្ខុ ១ អង្គ ជាអ្នកត្រាច់បិណ្ឌបាត្រជាវត្ត ក៏មានចិត្តជ្រះថ្លាហើយ បានប្រគេននូវផ្ការាជព្រឹក្សមួយបាច់ ដល់ព្រះភិក្ខុរូបនោះ, ស្ត្រីម្នាក់ទៀត បានប្រគេននូវផ្កាឧប្បលខៀវមួយបាច់ ដល់ព្រះភិក្ខុរូបនោះ ដូចគ្នាដែរ, ស្ត្រីម្នាក់ទៀត បានប្រគេននូវផ្កាឧប្បលមួយបាច់ ដល់ព្រះភិក្ខុរូបនោះ ដូចគ្នាដែរ, ស្ត្រីម្នាក់ទៀត បានប្រគេននូវផ្កាម្លិះក្រពុំ ដល់ព្រះភិក្ខុរូបនោះ ដូចគ្នាដែរ ។ បាច់នៃផ្ការាជព្រឹក្ស ឈ្មោះថា ឥន្ទីវរកលាបៈ ។ បាច់នៃផ្កាឧប្បលខៀវ ឈ្មោះថា នីលុប្បលហត្ថកៈ ។ បាច់នៃផ្កាឈូក ឈ្មោះថា បទុមហត្ថកៈ ។ ផ្កាម្លិះក្រពុំ ដែលមានសម្បុរដូចជាភ្លុកដំរី

ឈ្មោះថា សុមនមកុលៈ ។

ស្ត្រីទាំង ៤ នាក់នោះ លុះបានធ្វើបុណ្យមានប្រមាណប៉ុណ្ណោះយ៉ាងដូច្នេះហើយ ក្រោយមក ក៏បានធ្វើកាលកិរិយាហើយ បានទៅកើតក្នុងទេវលោកជាន់តាវត្តឹង្ស ម្នាក់ៗ មានស្រីទេពអប្សរ ១ ពាន់នាក់ជាបរិវារ ។ ទេវតាទាំង ៤ អង្គនោះ សោយនូវទិព្វសម្បត្តិក្នុងភពតាវត្តឹង្សនោះ រហូតអស់កំណត់នៃជន្មាយុហើយ អន្ទោលទៅមកក្នុងភពតាវត្តឹង្សនោះឯង ដោយវិបាកដែលសេសសល់ នៃកម្មនោះឯង សូម្បីក្នុងពុទ្ធុប្បាទនេះ ក៏បានកើតហើយ ក្នុងភពតាវត្តឹង្សនោះ ម្តងទៀត ដូចគ្នាដែរ ។

គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ និមន្តចារិកទៅកាន់ទេវលោក បាននិមន្តទៅកាន់ភពតាវត្តឹង្ស ឃើញនាងទេពធីតាទាំង ៤ អង្គនោះ ក្នុងវិមានទាំង ៤ ដែលស្ថិតនៅតាមលំដាប់គ្នាក្នុងភពតាវត្តឹង្សនោះហើយ ក៏បានសួរនូវបុព្វកម្មរបស់នាងទេពធីតាទាំងនោះ ដោយន័យដែលបានពោលហើយ ក្នុងចតុរិត្ថីវិមាន ។ ចំណែកនាងទេពធីតាទាំងនោះ បានប្រាប់ហើយនូវបុព្វកម្ម របស់ខ្លួនដល់ព្រះថេរៈ ។

គ្រានោះ ព្រះថេរៈ សំដែងនូវអនុបុព្វីកថាហើយ ក៏បានប្រកាសនូវសច្ចៈទាំងឡាយ ដល់នាងទេពធីតាទាំង ៤ អង្គនោះ ។

ក្នុងពេលចប់សច្ចៈ នាងទេពធីតាគ្រប់ទាំង ៤ អង្គនោះ ព្រមទាំងបរិវារ បានសម្រេចជាព្រះសោតាបន្នហើយ ។ ព្រះថេរៈ បានមកអំពីទេវលោកហើយ និមន្តទៅកាន់វត្តជេតពន បានក្រាបទូលហើយនូវរឿងរ៉ាវទាំងអស់នោះ ដល់ព្រះមានព្រះភាគ ។ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនូវសេចក្ដីនោះ ឲ្យជាហេតុកើតឡើងហើយ ទ្រង់សំដែងនូវព្រះធម៌ ដល់បរិស័ទអ្នកប្រជុំគ្នាហើយ ក្នុងវត្តព្រះជេតពននោះ ។ ទេសនានោះ ជាទេសនាប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដល់មហាជន ដូច្នេះឯងហើយ ។

រឿង ស្ត្រី ៤ នាក់ ចប់ ។

## ( រឿង នាងលាជទេពធីតា )

(៦៨) បានឮមកថា ក្នុងទីក្រុងរាជគ្រឹះ ស្ត្រីអ្នករក្សាស្រែស្រូវសាលីម្នាក់ បានកត់ទងស្រូវសាលី ធ្វើលាជហើយ ចិញ្ចឹមជីវិត ។ ក៏ក្បែរទីក្រុងរាជគ្រឹះ មានគុហាមួយ ។ គុហានោះប្រាកដឈ្មោះថា "បិប្ផលិគុហា" ព្រោះមានដើមដីប្លីមួយដើម នៅក្បែរមាត់ទ្វារ ( គុហានោះ ) ។

ព្រះមហាកស្សបៈ ដ៏មានអាយុ ចូលកាន់និរោធសមាបត្តិមួយសប្ដាហ៍ ក្នុងគុហានោះ ចេញ (អំពីសមាបត្តិ) ហើយ

ត្រួតមើលនូវទីកន្លែងដើម្បីត្រាច់បិណ្ឌបាត ដោយទិព្វចក្ខុ ក៏បានឃើញនូវស្ត្រីនោះហើយ បានយកបាត្រនិងចីពរទៅឈរនៅក្បែរស្រែ ។ ស្ត្រីនោះ ឃើញព្រះថេរៈហើយ ក៏មានចិត្តជ្រះថ្លា បានដាក់លាជទៅក្នុងបាត្ររបស់ព្រះថេរៈហើយ ទើបប្រាថ្នា ថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន នាងខ្ញុំគប្បីជាអ្នកមានចំណែកនៃធម៌ដែលព្រះគុណម្ចាស់បានឃើញហើយ" ដូច្នេះ, កាលបើព្រះថេរៈនោះ ពោលថា "សូមឲ្យសេចក្ដីប្រាថ្នាដែលនាងប្រាថ្នាទុកហើយយ៉ាងនេះ ចូរបានសម្រេចចុះ" ដូច្នេះហើយ ក៏បានចៀសចេញទៅ, កាលពិចារណាទានរបស់ខ្លួនត្រឡប់មកវិញ ត្រូវពស់មានពិសដ៏ពន្លឹកលូនចេញអំពីរន្ធមួយមកខាំ ត្រង់ផ្លូវដែលជាទីដើរទៅលើភ្លឺស្រែហើយ ដួលធ្លាក់នៅក្នុងទីនោះឯង ធ្វើកាលៈហើយ ក៏បានទៅកើត ក្នុងវិមានមាសដែលបរិបូណ៌ទៅដោយនាងទេពអប្សរ ១ ពាន់ ក្នុងភពតាវត្តិង្សមានអត្តភាព ៣ គាវុត ប្រដាប់ដោយគ្រឿងអលង្ការសព្វគ្រប់ដូចជាដេកលក់ហើយក្រោកឡើងដូច្នោះ ស្លៀកសំពត់ទិព្វមួយដណ្ដប់សំពត់ទិព្វមួយ មានប្រវែង ១២ យោជន៍ហើយ ឈរនៅត្រង់មាត់ទ្វារនៃវិមាន ដែលប្រដាប់ដោយផ្ទិលមាស ដែលពោរពេញទៅដោយលាជមាស កំពុងតែសំយុងចុះមក ដើម្បីប្រកាសនូវបុព្វកម្មបានត្រួតពិនិត្យមើលសម្បត្តិ របស់ខ្លួនហើយ ក៏ពិចារណាដោយ

ទិព្វចក្ខុ ថា "សម្បត្តិនេះ អាត្មាអញបានហើយ ព្រោះកម្មអ្វី ?" ក៏បានដឹង ថា "ព្រោះការប្រគេនលាជដល់ព្រះមហាកស្សបត្ថេរ" ។ នាងទេពធីតានោះ ប្រាថ្នានឹងធ្វើសម្បត្តិរបស់ខ្លួន ឲ្យបានស្ថិតស្ថេរ ទើបបានយកអំបោស និងកញ្ជើសម្រាប់ចោលសម្រាម ដែលធ្វើដោយមាស មកបោសសំអាតបរិវេណរបស់ព្រះថេរៈហើយ តាំងនូវទឹកសម្រាប់ឆាន់និងទឹកសម្រាប់ប្រើប្រាស់ តាំងអំពីព្រឹកព្រលឹម ។

ព្រះថេរៈបានសម្គាល់ ថា "កិច្ចនេះនឹងជាកិច្ចដែលភិក្ខុកម្លោះនិងសាមណេរអង្គខ្លះបានធ្វើហើយ" ដូច្នេះ ក្នុងថ្ងៃទី ៣ លោកបានបើកទ្វារក្រឡេកមើល ក៏បានឃើញនាងទេពធីតានោះហើយ ទើបពោល ថា "នែនាងទេពធីតា ! ចូរនាងចៀសចេញទៅ, ចូរនាងកុំធ្វើនូវភារៈ នៃអាត្មាដែលព្រះធម្មកថិកទាំងឡាយ ក្នុងអនាគតចាប់ផ្ដិតដ៏វិចិត្រ គប្បីពោល ថា 'បានឮថា នាងទេពធីតាមួយអង្គបានធ្វើវត្តប្រតិបត្តិហើយ ចូលទៅតាំងនូវទឹកសម្រាប់ឆាន់និងទឹកសម្រាប់ប្រើប្រាស់ ប្រគេនដល់ព្រះមហាកស្សបត្ថេរ' ដូច្នេះឡើយ, ចាប់តាំងអំពីថ្ងៃនេះតទៅ ចូរនាងកុំគេចមក ទីនេះឡើយ" ។

នាងទេពធីតានោះ បានសូមអង្វរករ ជាញយៗ ថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន សូមព្រះគុណម្ចាស់ កុំធ្វើឲ្យនាងខ្ញុំវិនាសឡើយ" ។ ព្រះថេរៈ បានទះម្រាមដៃ ដោយពោល ថា

“ នាងមិនចេះស្គាល់នូវប្រមាណ របស់នាងសោះឡើយ ” ។

នាងទេពធីតានោះ មិនអាចដើម្បីនឹងឈរនៅក្នុងទីនោះបាន ទើបបានឈរស្រែកទួញយំ ឰដ៏អាកាស ថា “ បពិត្រព្រះគុណម្ចាស់ដ៏ចំរើន សូមព្រះគុណម្ចាស់ កុំធ្វើនូវសម្បត្តិដែលនាងខ្ញុំបានហើយ ឲ្យវិនាសសាបសូន្យឡើយ, សូមព្រះគុណម្ចាស់មេត្តាឲ្យ ដើម្បីនាងខ្ញុំបានធ្វើនូវសម្បត្តិដែលនាងខ្ញុំបានហើយ ឲ្យបានស្ថិតស្ថេរគង់វង់ផង ” ។

ព្រះសាស្តា ទ្រង់គង់នៅ ក្នុងព្រះគន្ធកុដិ ក្នុងវត្តជេតពន ដែលមានចម្ងាយ ៤៥ យោជន៍ ទ្រង់ព្រះសណ្តាប់សំឡេងស្រែកយំរបស់នាងទេពធីតានោះហើយ ទើបទ្រង់បានផ្សាយព្រះរស្មីទៅ ដូចជាទ្រង់គង់នៅ ចំពោះមុខនាងទេពធីតានោះហើយ ទ្រង់មានព្រះតម្រាស់ ថា “ នែនាងទេពធីតា កិរិយាធ្វើនូវការសង្រួមនុ៎ះឯងជាភារកិច្ច របស់កស្សបៈជាបុត្ររបស់តថាគត, ចំណែកកិរិយាសម្គាល់ ថា ‘ នេះជាប្រយោជន៍ របស់អាត្មាអញ ’ ដូច្នេះហើយបំពេញនូវបុណ្យនុ៎ះឯង ជាភារកិច្ច របស់ជនទាំងឡាយអ្នកត្រូវការបុណ្យ, ព្រោះថា កិរិយាបំពេញបុណ្យ ជាហេតុនាំសេចក្ដីសុខមកប្រគល់ឲ្យ ក្នុងលោកទាំង ២ មែនពិត ” ដូច្នេះហើយ ទ្រង់ត្រាស់នូវគាថានេះ ក្នុងបាបវគ្គ នៃធម្មបទ ថា ៖

" បើបុរសធ្វើបុណ្យ, [១] គួរតែធ្វើបុណ្យនោះ
ឲ្យបានរឿយៗ, គួរធ្វើសេចក្តីពេញចិត្ត
ក្នុងបុណ្យនោះ; ព្រោះថា កិរិយាសន្សំបុណ្យ
រមែងនាំសេចក្តីសុខមកប្រគល់ឲ្យ " ។

បណ្តាបទទាំងនោះ ២ បទ ថា " **បុញ្ញញ្ចេ បុរិសោ** " មានសេចក្តីថា បើបុគ្គលគប្បីធ្វើនូវបុណ្យ មួយដងមួយកាល ។ បទ ថា " **កយិរាថេនំ** " មានសេចក្តីថា បុគ្គលមិនគួរបន្ធូរបន្ថយ ដោយតាំងចិត្ត ថា " អាត្មាអញ បានធ្វើបុណ្យ មួយដងរួចហើយ, គ្រប់គ្រាន់ហើយ ដោយបុណ្យមានប្រមាណប៉ុណ្ណេះ " ដូច្នេះឡើយ ត្រូវតែធ្វើបុណ្យនោះ ឲ្យបានញឹកញយ ។ បទ ថា " **តម្ហិ** " មានសេចក្តីថា បុគ្គលគួរធ្វើនូវសេចក្តីពេញចិត្ត គឺ ការចូលចិត្ត បានដល់ សេចក្តីប្រឹងប្រែង ក្នុងបុណ្យនោះ សូម្បីក្នុងខណៈដែលធ្វើនូវបុណ្យនោះ ឲ្យទាល់តែបាន ។ ព្រោះហេតុអ្វី ? ។ ព្រោះថា កិរិយាសន្សំ គឺ ការចំរើននូវបុណ្យ ឈ្មោះថា រមែងនាំឲ្យបានសេចក្តីសុខ ព្រោះនាំសេចក្តីសុខមកឲ្យ ក្នុងលោកនេះ និងលោកខាងមុខ ។

ក្នុងទីបញ្ចប់នៃព្រះគាថា នាងទេពធីតានោះ បានសម្រេច

---

១ ត្រៃបិដក ភាគទី ៥២ / ទំព័រទី ៤៧ ។

ជាព្រះសោតាបន្នហើយ ក៏បានទៅកាន់ទេវលោក ។

រឿង នាងលាជទេពធីតា ចប់ ។

(៦៩) សូម្បីការបូជាព្រះសាវ័ក ក៏រមែងនាំប្រយោជន៍សុខមកឲ្យ និងព្រះសាស្តា ក៏ទ្រង់បានត្រាស់សរសើរហើយដែរ ដូច្នេះ ។ ក្នុងដំណើរនោះ មានរឿងនេះ ( ជាឧទាហរណ៍ ) ដូចតទៅ ÷

## ( រឿង ព្រាហ្មណ៍ជាឪពុកធំរបស់ព្រះសារីបុត្រ )

បានឮមកថា ព្រាហ្មណ៍ជាឪពុកធំ របស់ព្រះសារីបុត្តត្ថេរម្នាក់ អាស្រ័យនៅ ក្នុងទីក្រុងរាជគ្រឹះ ។ ព្រាហ្មណ៍នោះ បានស្តាប់ចាកលោកគ្រូអាចារ្យ ថា "បុគ្គលឯណា បានធ្វើទាន ដោយការបរិច្ចាគទ្រព្យមួយពាន់ រៀងរាល់ខែ, បុគ្គលនោះ នឹងទៅកាន់ព្រហ្មលោក, ព្រោះថា នេះជាផ្លូវនៃព្រហ្មលោក" ដូច្នេះហើយ ក៏ធ្វើយ៉ាងដូច្នោះ បានធ្វើហើយនូវទាន ដល់ពួកនិគ្រន្ថទាំងឡាយ ។

ព្រះថេរៈ និមន្តទៅកាន់សំណាក់ របស់ព្រាហ្មណ៍នោះហើយស្តាប់រឿងរ៉ាវទាំងនោះ ទើបពោល ថា "ទាំងអ្នក ទាំងអាចារ្យរបស់អ្នក រមែងមិនដឹង នូវផ្លូវទៅកាន់ព្រហ្មលោកទេ, ព្រះសាស្តារបស់ពួកយើង តែមួយព្រះអង្គគត់ប៉ុណ្ណោះ រមែងទ្រង់ជ្រាប, ម្នាលព្រាហ្មណ៍ ចូរអ្នកអញ្ជើញមកចុះ, អាត្មានឹងក្រាបទូលឲ្យព្រះ

សាស្ដាអង្គនោះ ឲ្យត្រាស់សំដែងនូវផ្លូវទៅកាន់ព្រហ្មលោក ដល់អ្នក" ដូច្នេះហើយ ក៏បាននាំព្រាហ្មណ៍នោះ មកកាន់វត្តវេឡុវន ហើយបានក្រាបទូលដល់ព្រះសាស្ដា ។

គ្រានោះ ព្រះសាស្ដា ទ្រង់បានត្រាស់សំដែង ដល់ព្រាហ្មណ៍នោះ ថា "ម្នាលព្រាហ្មណ៍ ! ការក្រឡេកមើល នូវព្រះសាវ័ករបស់តថាគត ដោយចិត្តជ្រះថ្លាហើយ សូម្បីត្រឹមតែមួយស្របក់ក្ដី ការថ្វាយនូវភិក្ខា ប្រមាណ ១ វែកក្ដី រមែងមានផលច្រើនជាងទានដែលអ្នកបានឲ្យហើយ យ៉ាងដូច្នោះ រហូតដល់ ១០០ ឆ្នាំ" ដូច្នេះហើយ កាលទ្រង់ប្រកាសនូវការបូជាដល់ព្រះសាវ័ក ទើបទ្រង់ត្រាស់នូវព្រះគាថានេះ ក្នុងសហស្សវគ្គ នៃធម្មបទ ថា ÷

"បុគ្គលណា បូជា (លោកិយមហាជន) ដោយទ្រព្យមួយពាន់ រាល់ខែៗ អស់ ១ រយឆ្នាំគត់, ចំណែកបុគ្គលណា គប្បីបូជាចំពោះបុគ្គលដែលមានខ្លួនអប់រំហើយ តែ ១ នាក់ សូម្បីតែមួយរំពេច, ការបូជានោះឯង ប្រសើរជាងការបូជារបស់អ្នកដែលបូជា អស់ ១ រយឆ្នាំនោះ, ការបូជា អស់ ១ រយឆ្នាំ មិនប្រសើរឡើយ" ។ (១)

---

១ ត្រៃបិដក ភាគទី ៥២ / ទំព័រទី ៤៤ ។

បណ្ដាបទទាំងនោះ បទ ថា "សហស្សេន" គឺ ដោយការបរិច្ចាគទ្រព្យ ១ ពាន់ ។ បទ ថា "យជេថ" បានដល់ គប្បីឲ្យទានដល់លោកិយមហាជន ។ បទ ថា "សតំ" គឺ ប្រមាណ ១០០ ឆ្នាំ ។ បទ ថា "សមំ" គឺ អស់រដូវភ្លៀង បានដល់ ១ ឆ្នាំ ។ មែនពិត រដូវភ្លៀង (ឆ្នាំ) លោកហៅថា "សមា" ព្រោះអត្ថវិគ្រោះ ថា "ញ៉ាំងបុគ្គលឲ្យគិត គឺ ឲ្យប្រព្រឹត្តទៅ ក្នុងសេចក្ដីនៃបទ" ។ បទ ថា "ឯកញ្ច" បានដល់ ដោយទីបំផុតសូម្បីព្រះសោតាបន្នម្នាក់គត់ ។ បទ ថា "ភាវិតត្តានំ" បានដល់ អ្នកមានខ្លួនដែលចំរើន គឺ មានចិត្តចំរើនឡើងហើយ ដោយអំណាចនៃគុណ ។ បទ ថា "បូជយេ" មានសេចក្ដីថា គប្បីបូជា ដោយអំណាចការឲ្យនូវភិក្ខា ១ វែក ឬ នូវអាហារល្មមតែញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ឬក៏ នូវសំពត់សាដកសាច់គគ្រាត ។ បទ ថា "សេយ្យោ" មានសេចក្ដីថា ការបូជាឯណា ដែលបុគ្គលក្រៅអំពីនោះ បានបូជាហើយ អស់ ១ រយឆ្នាំ, ប្រសើរជាងការបូជារបស់បុគ្គលអ្នកដែលបូជា ១ រយឆ្នាំនោះ ។ មួយ៉ាងទៀត សព្ទ ថា "យញ្ចេ" ជានិបាត ចុះក្នុងសេចក្ដីដែលបដិសេធ ។ អធិប្បាយ ថា "ការបូជានោះ ដែលបុគ្គលនោះ បានបូជាហើយរហូតដល់ ១ រយឆ្នាំ មិនមែនជារបស់ប្រសើរសោះឡើយ" ។

ក្នុងពេលចប់គាថា ព្រាហ្មណ៍ បានសម្រេចព្រះសោតាបន្ន ។ រឿងព្រាហ្មណ៍ដែលជាក្មួយរបស់ព្រះថេរៈក្តី រឿងព្រាហ្មណ៍ដែលជាសំឡាញ់របស់ព្រះថេរៈក្តី អ្នកសិក្សាគប្បីរួបរួមយកមកផងដែរ ។

(៧០) អាមិសបូជា រមែងមានផលច្រើន យ៉ាងដូច្នេះឯង, មិនចាំបាច់ពោលទៅធ្វើអ្វី ដល់បដិបត្តិបូជានោះឡើយ, ព្រោះកុលបុត្រទាំងឡាយណា បូជានូវព្រះដ៏មានព្រះភាគ ដោយគុណទាំងឡាយរបស់ខ្លួន គឺ ការដល់នូវសរណៈ ការទទួលសិក្ខាបទ និងការសមាទានអង្គនៃឧបោសថក្តី គឺចតុប្បារិសុទ្ធិសីលក្តី, អ្នកណាទៅនឹងពណ៌នា នូវផលនៃការបូជា របស់កុលបុត្រទាំងនោះបាន ។ ក៏កុលបុត្រទាំងឡាយនោះ លោកពោល ថា "រមែងបូជានូវព្រះតថាគត ដោយការបូជាយ៉ាងប្រសើរក្រៃលែង" ។

សួរ ថា "អ្នកណា ពោលហើយ ?" ។

ឆ្លើយ ថា "ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ" ។

មែនពិត ព្រះដ៏មានព្រះភាគ ទ្រង់ព្រះបន្ទំ លើគ្រែតូចដែលជាទីមហាបរិនិព្វាន ក្នុងកាលណា, ក្នុងកាលនោះ ពួកទេវតា ក្នុងមួយម៉ឺនចក្រវាល ប្រជុំគ្នាហើយ ក្នុងចក្រវាលនេះ បានបូជាព្រះដ៏មានព្រះភាគហើយ ដោយគ្រឿងបូជាទាំងឡាយមានកម្រងផ្កាទិព្វជាដើម ។

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះបន្ទំហើយ ទ្រង់ទត ព្រះនេត្រឃើញ នូវមហាសក្ការៈ ដែលបរិស័ទបានប្រជុំគ្នា តាំងតែអំពីផ្ទៃនៃប្រឹថពី រហូតដល់ក្របមាត់ទ្វារនៃចក្រវាល និងតាំងតែអំពីក្របមាត់ទ្វារនៃចក្រវាល រហូតដល់ព្រហ្មលោក បានធ្វើហើយដោយសេចក្តីឧស្សាហ៍ដ៏ធំ ទ្រង់សំដែងហើយ នូវសក្ការៈនោះ ដល់ព្រះអានន្ទត្ថេរ ដោយន័យដែលពោលហើយ ក្នុងមហាបរិនិព្វានសូត្រ កាលទ្រង់សំដែង នូវភារៈនៃព្រះអង្គ គឺបរិស័ទនោះ មិនធ្វើសក្ការៈហើយ សូម្បីដោយសក្ការៈនោះឯង ទើបទ្រង់ត្រាស់ ថា "ម្នាលអានន្ទ ! តថាគត ជាអ្នកឈ្មោះថា គឺបរិស័ទធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែងហើយ ដោយគ្រឿងសក្ការៈមានប្រមាណប៉ុណ្ណោះ ក៏ទេដែរ" ។ មានព្រះតម្រាស់ ដែលព្រះមានព្រះភាគ ទ្រង់សំដែងទុក ថា "ម្នាលអានន្ទ ! អភិនីហារ គឺ មិនមែនតថាគតបានក្រាបក្រោមបាទមូល របស់ព្រះពុទ្ធទ្រង់ព្រះនាមទីបង្ករ បានធ្វើហើយ ដើម្បីប្រយោជន៍ ដល់ផ្កាកម្រង គ្រឿងក្រអូប គ្រឿងដូរតន្ត្រី និងគ្រឿងប្រគុំសោះឡើយ, បារមីទាំងឡាយ គឺមិនមែនតថាគត បំពេញហើយ ដើម្បីប្រយោជន៍ ដល់ផ្កាកម្រងជាដើមនោះសោះឡើយ, ព្រោះហេតុនោះ តថាគតទើបមិនឈ្មោះថា ជាអ្នកគឺបរិស័ទ បានបូជាហើយ ដោយគ្រឿង

បូជាមានប្រមាណប៉ុណ្ណោះសោះឡើយ"។

សួរ ថា "ក៏នៅក្នុងបាលីដទៃទៀត ព្រះដ៏មានព្រះភាគ ទ្រង់បានពណ៌នា នូវវិបាកនៃការបូជា ដែលបុគ្គលកាន់យកនូវគ្រឿងសក្ការៈសូម្បីត្រឹមតែផ្កាកប្បាសមួយទងហើយ នឹករលឹកនូវពុទ្ធគុណទាំងឡាយ (ជាអារម្មណ៍) បានធ្វើហើយ ថាជាវិបាក សូម្បីតែព្រះពុទ្ធញ្ញាណ ក៏ទ្រង់កំណត់មិនបានឡើយ ព្រោះហេតុអ្វី បានជាក្នុងបាលីនេះ ទើបទ្រង់បដិសេធនូវការបូជាដ៏ធំ យ៉ាងដូច្នេះ?"។

ឆ្លើយ ថា "ព្រោះទ្រង់អនុគ្រោះ ដល់បរិស័ទផង ទ្រង់មានព្រះបំណង ដើម្បីនឹងឲ្យព្រះសាសនាស្ថិតនៅ បានយូរអង្វែងផង"។

មែនពិត បើព្រះដ៏មានព្រះភាគ មិនទ្រង់បដិសេធ យ៉ាងដូច្នេះទេនោះ, ក្នុងអនាគតកាល ពួកភិក្ខុទាំងឡាយ ក៏នឹងមិននាំគ្នាបំពេញសីលនិងសមាធិជាដើម ឲ្យបានបរិបូណ៌ និងមិនញ៉ាំងវិបស្សនា ឲ្យកាន់យកនូវគតិ បានតែគ្រាច់ទៅបបួលពួកឧបដ្ឋាកឲ្យធ្វើតែការបូជាប៉ុណ្ណោះឯង ។ ក៏ធម្មតាអាមិសបូជានោះ មិនអាច ដើម្បីនឹងទ្រទ្រង់ទុក នូវព្រះពុទ្ធសាសនាបាន អស់កាលសូម្បីត្រឹមតែការហុតនូវបបរមួយគ្រូកឡើយ, ពិតមែនហើយ ព្រះវិហារ ១ ពាន់ខ្ទង់ ដូចជាព្រះមហាវិហារក្ដី ចេតិយ ១ ពាន់អង្គ ដូចជាព្រះមហាចេតិយក្ដី រមែងមិនអាច ដើម្បីនឹងទ្រទ្រង់ នូវព្រះ

សាសនាបានឡើយ, បុគ្គលណាធ្វើ, ផលានិសង្ស នឹងមាន ដល់បុគ្គលនោះតែប៉ុណ្ណោះ ។ ចំណែកសម្មាបដិបត្តិ ជាការបូជាដ៏សមគួរដល់ព្រះសាស្តា ។ ព្រោះថា សម្មាបដិបត្តិនោះ ព្រះអង្គទ្រង់ប្រាថ្នាហើយផង រមែងអាចដើម្បីនឹងទ្រទ្រង់ នូវព្រះសាសនាបានផង ។ ព្រោះហេតុនោះ ព្រះសាស្តា លុះទ្រង់បដិសេធនូវអាមិសបូជាហើយ កាលទ្រង់អនុញ្ញាត នូវបដិបត្តិបូជាក្រៅអំពីនេះ ទើបទ្រង់ត្រាស់ ថា " ម្នាលអានន្ទ ! បុគ្គលណាមួយ ទោះជាភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិដោយត្រឹមត្រូវ ជាអ្នកប្រព្រឹត្តតាមធម៌ជាប្រក្រតី; បុគ្គលនោះ ឈ្មោះថា រមែងធ្វើសក្ការៈ ធ្វើនូវសេចក្តីគោរព រាប់អាន បូជានូវព្រះតថាគត ដោយការបូជាដ៏ប្រសើរ, ម្នាលអានន្ទ ! ព្រោះហេតុនោះ អ្នកទាំងឡាយ ក្នុងព្រះធម្មវិន័យនេះ គប្បីសិក្សា យ៉ាងដូច្នេះ ថា 'អាត្មាអញទាំងឡាយនឹងជាអ្នកប្រតិបត្តិ នូវធម៌ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិដោយត្រឹមត្រូវ ជាអ្នកប្រព្រឹត្តតាមធម៌ជាប្រក្រតី' ដូច្នេះ, ម្នាលអានន្ទ ! អ្នកទាំងឡាយ គប្បីសិក្សា យ៉ាងដូច្នេះឯង " ។

(៧១) ន័យដែលមក ក្នុងអដ្ឋកថាមហាបរិនិព្វានសូត្រ ថា គប្បីជ្រាបវិនិច្ឆ័យ ក្នុងព្រះពុទ្ធវចនៈនោះ ( ដូចតទៅនេះ ) ÷

ការប្រតិបត្តិជាចំណែកខាងដើម ដែលសមគួរដល់ លោកុត្តរធម៌ ៩ ប្រការ ឈ្មោះថា ការប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ។ កិរិយាប្រតិបត្តិជាចំណែកខាងដើមនោះ ដោយសេចក្តី បានដល់ ព្រះបញ្ញត្តិខាងផ្លូវមារយាទ គឺសីល និងការសមាទាននូវធុតង្គ បានដល់សម្មាបដិបត្តិ រហូតដល់គោត្រភូញាណនុ៎ះឯង ។ បុព្វភាគបដិបត្តិនោះឯង ព្រះអង្គត្រាស់ហៅថា "ត្រឹមត្រូវ" ព្រោះជាខប្រតិបត្តិដ៏សមគួរ ។ បុគ្គលណា រមែងប្រតិបត្តិ ប្រព្រឹត្ត បំពេញបុព្វភាគបដិបត្តិនោះ, បុគ្គលនោះ ព្រះអង្គទ្រង់ត្រាស់ ថា "ជាអ្នកប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិដោយត្រឹមត្រូវ ជាអ្នកប្រព្រឹត្តតាមធម៌ជាប្រក្រតី" ។ ព្រោះហេតុនោះ បព្វជិតអ្នកស្ថិតនៅ ក្នុងសេចក្តីមិនគោរព ៦ យ៉ាង ប្រព្រឹត្តល្មើសនូវព្រះបញ្ញត្តិ ចិញ្ចឹមជីវិត ដោយអនេសនា ទើបមិនឈ្មោះថា ជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ទេឡើយ ។ បព្វជិតអ្នកដែលមិនប្រព្រឹត្តល្មើសនូវសិក្ខាបទ ដែលព្រះដ៏មានព្រះភាគ ទ្រង់បានបញ្ញត្តហើយដល់ខ្លួន គ្រប់ទាំងអស់នោះ សូម្បីជាបន្តិចបន្តួច ចិញ្ចឹមជីវិត ដោយធម៌ ទើបបានឈ្មោះថា ជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ។

ចំណែកគ្រហស្ថ អ្នកធ្វើនូវពៀរ ៥ យ៉ាងនិងអកុសលកម្មបថ ១០ ប្រការ មិនបានឈ្មោះថា ជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរ

ដល់ធម៌ ។ តែបុគ្គលណា ជាអ្នកធ្វើឲ្យបានបរិបូណ៌ ក្នុងសរណៈ និងសីលទាំងឡាយ រក្សានូវឧបោសថ ១ ខែ ៨ ដង ឲ្យទាន ធ្វើការបូជាដោយគ្រឿងក្រអូប និងការបូជាដោយផ្កាកម្រង ទំនុកបំរុងនូវមាតាបិតា និងពួកសមណព្រាហ្មណ៍អ្នកតាំងនៅក្នុងធម៌, បុគ្គលនេះ ទើបបានឈ្មោះថា ជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ។ ក៏ព្រះដ៏មានព្រះភាគ កាលទ្រង់ត្រាស់ ថា " ដោយការបូជា យ៉ាងប្រសើរ " ដូច្នេះ ក៏ឈ្មោះថា ទ្រង់សំដែងនូវអត្ថាធិប្បាយនេះ ថា " ធម្មានិរាមិសបូជា រមែងអាចដើម្បីនឹងទ្រទ្រង់ទុក នូវព្រះសាសនា របស់តថាគតបាន, ព្រោះថា បរិស័ទទាំង ៤ នេះ នឹងបូជានូវតថាគត ដោយបដិបត្តិបូជានេះ ដរាបណា, ព្រះសាសនារបស់តថាគត ក៏នឹងរុងរឿង ប្រៀបដូចជាព្រះច័ន្ទពេញបូរមី ត្រង់កណ្តាលនភាល័យ ដរាបនោះ " ។

សូម្បីក្នុងកាលមុន អំពីពេលនេះ ក៏ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សរសើរ នូវបដិបត្តិបូជាដូចគ្នាដែរ ។ ក្នុងដំណើរនោះ មានរឿងទាំងនេះ ( ជាឧទាហរណ៍ ) ÷

## ( រឿងព្រះតិស្សត្ថេរ )

(៧២) ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា " ម្នាលភិក្ខុទាំង

ទាំងឡាយ ! តាំងតែអំពីពេលនេះទៅ ដោយកាលកន្លងទៅ ៤ ខែ តថាគត នឹងបរិនិព្វាន" ដូច្នេះ ក្នុងកាលណា, ក្នុងកាលនោះ ពួកភិក្ខុដែលជាបុថុជ្ជន មិនអាចដើម្បីនឹងទប់ទល់ទឹកភ្នែកបានឡើយ ។ ពួកភិក្ខុទាំងនោះ ជាពួកៗ ប្រឹក្សាគ្នា ថា "តើពួកយើង នឹងធ្វើយ៉ាងដូចម្ដេចទៅហ្ន៎ ?" ហើយ បាននៅក្នុងសំណាក់នៃព្រះសាស្ដា ។

គ្រានោះ ព្រះថេរៈ ១ រូប ឈ្មោះ តិស្សៈ គិត ថា "បានឮថា ដោយកាលកន្លងទៅ ៤ ខែ ព្រះសាស្ដា នឹងទ្រង់បរិនិព្វាន, ក៏អាត្មាអញ ជាអ្នកមានរាគៈមិនទាន់ទៅប្រាសហើយ, កាលបើព្រះសាស្ដា ទ្រង់ធរមាននៅឡើយ, ការដែលអាត្មាអញ ឈោងយកនូវព្រះអរហត្តឲ្យបាន ទើបសមគួរ" ហើយ ក៏មិនបាននិមន្តទៅកាន់សំណាក់របស់ភិក្ខុទាំងនោះ និងមិនធ្វើនូវការសន្ទនាប្រាស្រ័យ ជាមួយនឹងអ្នកណាមួយសោះឡើយ បាននៅតែមួយអង្គឯងប៉ុណ្ណោះ ក្នុងឥរិយាបថទាំង ៤ ។ ពួកភិក្ខុទាំងឡាយ បានក្រាបទូលកិរិយា របស់ព្រះតិស្សត្ថេរនោះ ដល់ព្រះសាស្ដាហើយ ។

ព្រះសាស្ដា ទ្រង់ឲ្យនិមន្តព្រះតិស្សត្ថេរនោះមកហើយ ទ្រង់ត្រាស់សួរ ទ្រង់ព្រះសណ្ដាប់សេចក្ដីនោះហើយ ទើបទ្រង់ប្រទានសាធុការពរ ដល់ព្រះតិស្សត្ថេរនោះហើយ ទ្រង់ត្រាស់ ថា "ម្នាលភិក្ខុទាំងឡាយ ! បុគ្គលណា មានសេចក្ដីស្រឡាញ់ ចំពោះតថាគត,

បុគ្គលនោះ គប្បីដូចជាព្រះតិស្សត្ថេរនុ៎ះឯង, ព្រោះថា ជនទាំងឡាយ សូម្បីធ្វើនូវការបូជា ដោយវត្ថុទាំងឡាយមានគ្រឿងក្រអូប និងផ្កាកម្រងជាដើម រមែងមិនឈ្មោះថា បូជានូវតថាគត ដោយពិតប្រាកដឡើយ, ចំណែកជនទាំងឡាយ ជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌នុ៎ះឯង ទើបឈ្មោះថា រមែងបូជានូវតថាគត" ដូច្នេះហើយ ទើបត្រាស់គាថានេះ ក្នុងសុខវគ្គ នៃធម្មបទ ថា ៖

"ភិក្ខុផឹករសនៃវិវេកផង រសនៃព្រះនិព្វានដែល(១)
ជាទីរម្ងាប់កិលេសផង ផឹករសនៃបីតិ ដែលកើត
អំពីធម៌ផង ទើបជាអ្នកមិនមានសេចក្តីក្រវល់
ក្រវាយ មិនមានសេចក្តីសៅហ្មងឡើយ " ។

បណ្តាបទទាំងនោះ បទ ថា "**បវិវេករសំ**" គឺ រសដែលកើតអំពីសេចក្តីស្ងប់ស្ងាត់, អធិប្បាយ ថា "សេចក្តីសុខដែលកើតអំពីភាវៈនៃបុគ្គលម្នាក់ឯង" ។ បទ ថា "**បិត្វា**" មានសេចក្តីថា ព្រះខីណាស្រព អ្នកធ្វើកិច្ចមានការកំណត់ដឹងនូវទុក្ខជាដើម ផឹកហើយ (នូវរសវិវេក) ដោយអំណាចការធ្វើឲ្យជាក់ច្បាស់ ដោយអារម្មណ៍ ។ បទ ថា "**ឧបសមស្ស**" បានដល់ ព្រះនិព្វាន ដែលជាទីរម្ងាប់កិលេស ។ បទ ថា "**និទ្ទរោ**" មានសេចក្តីថា

១ ត្រៃបិដក ភាគទី ៥២ / ទំព័រទី ៦៤ ។

ឈ្មោះថា ជាអ្នកមិនមានសេចក្ដីក្រវល់ក្រវាយ ព្រោះមិនមានសេចក្ដីក្រវល់ក្រវាយ គឺរាគៈជាដើម ឰដ៏ខាងក្នុង និងឈ្មោះថា ជាអ្នកមិនមានបាប ព្រោះមិនមានបាប គឺរាគៈជាដើម ព្រោះការផឹកនូវរសទាំង ២ យ៉ាងនោះ ។ បទ ថា "**ធម្មប្បីតិរសំ**" បានដល់រសពោលគឺសេចក្ដីឆ្អែតចិត្ត ដែលកើតឡើងហើយ ដោយអំណាចលោកុត្តរធម៌ ៩ ប្រការ ។ បទ ថា "**បិវំ**" ប្រែថា កាលផឹក ។

ក្នុងអវសាននៃគាថា ព្រះតិស្សត្ថេរ ក៏បានសំរេចព្រះអរហត្ត ។

រឿង ព្រះតិស្សត្ថេរ ចប់ ។

## ( រឿង ព្រះអត្តទត្ថត្ថេរ )

(៧៣) ឯព្រះអត្តទត្ថត្ថេរ បានគិតហើយ យ៉ាងដូច្នោះដែរ មិននិមន្តទៅកាន់សំណាក់ នៃភិក្ខុទាំងឡាយឡើយ នៅតែម្នាក់ឯងប៉ុណ្ណោះ ប្រតិបត្តិហើយ ដើម្បីបានសំរេចព្រះអរហត្ត ដោយពិត ។ ភិក្ខុទាំងឡាយ បានក្រាបទូលសេចក្ដីនោះហើយ ដល់ព្រះសាស្ដា ។

ព្រះសាស្ដា ទ្រង់បានប្រទានសាធុការ ដល់ព្រះថេរៈនោះហើយទ្រង់ត្រាស់ ថា "ម្នាលភិក្ខុទាំងឡាយ ! ភិក្ខុណា មានសេចក្ដីស្រឡាញ់ចំពោះតថាគត, ភិក្ខុនោះ គប្បីដូចជាព្រះអត្តទត្ថត្ថេរចុះ, ជនទាំងឡាយ សូម្បីបូជាតថាគត ដោយគ្រឿងបូជាទាំងឡាយ មាន

គ្រឿងក្រអូបជាដើម ក៏មិនឈ្មោះថា បូជាដែរ, ចំណែកជនទាំងឡាយដែលបូជាតថាគត ដោយការប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ទើបបានឈ្មោះថា បូជាតថាគតមែន" ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ក្នុងអត្តវគ្គ នៃធម្មបទ ថា ÷

(១)

" បុគ្គល កុំគប្បីធ្វើប្រយោជន៍ខ្លួនឲ្យវិនាសឡើយ ព្រោះប្រយោជន៍របស់អ្នកដទៃ សូម្បីច្រើន, បើដឹងច្បាស់ នូវប្រយោជន៍ខ្លួនហើយ គប្បីជាអ្នកខ្វល់ខ្វាយ ក្នុងប្រយោជន៍ របស់ខ្លួនឲ្យបាន " ។

បណ្ដាបទទាំងនោះ បទ ថា "**អត្តទត្ថំ**" គឺ ប្រយោជន៍ របស់ខ្លួន សូម្បីមានប្រមាណមួយកាកណិក ។ ២ បទ ថា "**បរត្ថេន ពហុនាបិ**" គឺ ព្រោះប្រយោជន៍ របស់អ្នកដទៃ សូម្បីមានប្រមាណមួយពាន់ ។ បទ ថា "**ន ហាបយេ**" មានសេចក្ដីថា បុគ្គលមិនគួរធ្វើឲ្យវិនាសឡើយ, សម្រាប់គ្រហស្ថ ជាមុនសិន ប្រយោជន៍របស់ខ្លួន សូម្បីមានប្រមាណមួយកាកណិក ក៏រមែងញ៉ាំងរបស់ដែលគួរទំពារស៊ី និងរបស់ដែលគួរបរិភោគប្រើប្រាស់ ឲ្យសម្រេចបាន, ប្រយោជន៍របស់អ្នកដទៃ មិនធ្វើឲ្យសម្រេចបានឡើយ ។

ក៏ពាក្យថា ប្រយោជន៍របស់ខ្លួននេះ ព្រះដ៏មានព្រះភាគ

១ ត្រៃបិដក ភាគទី ៥២ ⁄ ទំព័រទី ៥៧ ។

មិនទ្រង់ត្រាស់ហើយ ដោយព្រះបំណងដូច្នេះឡើយ ទ្រង់ត្រាស់ដោយយកកម្មដ្ឋានជាប្រធាន ។ ព្រោះហេតុនោះ ភិក្ខុមិនគួរធ្វើកិច្ចមានការជួសជុលព្រះចេតិយជាដើម ដែលកើតឡើងហើយ ដល់ព្រះសង្ឃ ឬវត្តមានឧបជ្ឈាយវត្តជាដើម ឲ្យវិនាសសាបសូន្យទៅ ដោយគិតថា "អាត្មាអញ នឹងមិនធ្វើប្រយោជន៍របស់ខ្លួន ឲ្យវិនាសឡើយ" ។ ព្រោះថា ភិក្ខុ កាលបំពេញអភិសមាចារិកវត្តប៉ុណ្ណោះ ទើបធ្វើឲ្យជាក់ច្បាស់នូវអរិយផលជាដើមបាន, ព្រោះហេតុនោះ ប្រយោជន៍នេះឯង ឈ្មោះថា ជាប្រយោជន៍របស់ខ្លួនមែនពិត ។

ក៏ភិក្ខុរូបណា ជាអ្នកប្រារព្ធវិបស្សនាខ្លាំងក្លា ត្រាច់ទៅប្រាថ្នានូវការត្រាស់ដឹង ដោយគិតថា "ក្នុងថ្ងៃនេះឯង ៗ" ដូច្នេះ, ភិក្ខុរូបនោះ គប្បីធ្វើសូម្បីវត្តមានឧបជ្ឈាយវត្តជាដើម ឲ្យវិនាសទៅហើយ ធ្វើកិច្ចរបស់ខ្លួន ដោយពិត" ។

បាទគាថា ថា "**អត្តទត្ថមភិញ្ញាយ**" គឺ សម្គាល់ប្រយោជន៍របស់ខ្លួន យ៉ាងដូច្នេះ ថា "ប្រយោជន៍នេះ គឺជាប្រយោជន៍ របស់ខ្លួនអញ" ។ បាទគាថា ថា "**សទត្ថបសុតោ សិយា**" មានសេចក្តីថា ភិក្ខុគប្បីជាអ្នកខ្វល់ខ្វាយ ខ្នះខ្នែង ក្នុងប្រយោជន៍ដែលជារបស់ខ្លួននោះ ។

ក្នុងទីបញ្ចប់នៃគាថា ចំណោកព្រះអត្តទត្ថត្ថេរ ក៏បានសម្រេច

ហើយ នូវព្រះអរហត្ត ដោយប្រការដូច្នេះឯង ។

រឿង ព្រះអត្តទត្ថត្ថេរ ចប់ ។

សូម្បីរឿងរបស់ព្រះធម្មារាមត្ថេរ ក្នុងភិក្ខុវគ្គ នៃធម្មបទ ក៏គប្បីប្រមូលរួបរួមយកមកផងដែរ ។

(៧៤) បដិបត្តិបូជាប៉ុណ្ណោះ គប្បីឃើញ ថា "ជាការបូជាដែលព្រះសាស្តា ទ្រង់បានត្រាស់សរសើរហើយ និងជាបូជា យ៉ាងប្រសើរខ្ពង់ខ្ពស់" ដោយប្រការដូច្នេះឯង ។

បញ្ជិតអ្នកបូជា ដោយអាមិស មិនឈ្មោះថា ជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ឡើយ យ៉ាងណាមិញ, គ្រហស្ថ មិនមែនជាអ្នកយ៉ាងដូច្នោះឡើយ ។ ព្រោះថា គ្រហស្ថ សូម្បីជាអ្នកបូជាដោយអាមិស ក៏ឈ្មោះថា ជាអ្នកប្រតិបត្តិនូវធម៌សមគួរដល់ធម៌ ។ ព្រោះហេតុនោះ ក្នុងអធិការនៃការប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌របស់គ្រហស្ថ ក្នុងអដ្ឋកថាមហាបរិនិព្វានសូត្រ ទើបលោកពោល ថា "គ្រហស្ថ តែងឲ្យទាន, ធ្វើនូវការបូជា ដោយគ្រឿងក្រអូប និងការបូជាដោយផ្កាកម្រង" ។ ក៏គ្រហស្ថ អ្នកបូជាដោយអាមិស ឈ្មោះថា រមែងធ្វើតាមព្រះឱវាទ ដែលព្រះសាស្តា ទ្រង់បានប្រទានហើយដល់ខ្លួន និងអ្នកដែលធ្វើតាមព្រះឱវាទ ឈ្មោះថា តែងបូជា, ព្រោះហេតុនោះ គ្រហស្ថនោះ ទើបឈ្មោះថា រមែងបូជាព្រះសាស្តា

ដោយគុណរបស់ខ្លួន ពោលគឺការធ្វើអាមិសបូជា ដែលខ្លួនធ្វើឲ្យសមគួរដល់ព្រះឱវាទ របស់ព្រះសាស្ដា ដូច្នេះឯង ។

(៧៥) បុគ្គលឯណា រមែងបូជា ធ្វើសក្ការៈ សរសើរនូវសប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើម ជាអ្នកប្រសើរខ្ពង់ខ្ពស់ចូលដល់ភាពជាអ្នកគួរបូជា តាមលំដាប់ ដោយការមិនសេពគប់នូវជនពាល និងដោយការសេពគប់នូវបណ្ឌិត ដូចបានពោលហើយ, បុគ្គលនោះ រមែងប្រសព្វនូវប្រយោជន៍សុខ ដូចពណ៌នាមកនេះឯង, បុគ្គលណា រមែងបូជានូវពួកអសប្បុរស ដែលខុសផ្សេងគ្នាអំពីពួកសប្បុរសទាំងនោះ, បុគ្គលនោះ រមែងបានជួបប្រទះនូវទុក្ខ ។

ក្នុងដំណើរនោះ មានរឿងទាំងនេះ (ជាឧទាហរណ៍) ÷

## ( ព្រះបាទអជាតសត្រូវបូជាព្រះទេវទត្ត )

(៧៦) បានឮថា ក្នុងគ្រាមួយ ភិក្ខុទេវទត្ត នៅក្នុងទីស្ងាត់គិត ថា “ភិក្ខុទាំងឡាយនេះ យ៉ាងដូច្នេះ គឺ បរិស័ទរបស់ព្រះថេរៈឈ្មោះសារីបុត្រ, បរិស័ទរបស់ព្រះមោគ្គល្លាន ជាអ្នកមានធុរៈផ្សេង ៗ គ្នា, ចំណែកអាត្មាអញ នឹងនាំនូវធុរៈរបស់ពួកគណៈមួយដែរ, តែបើប្រាសចាកលាភហើយ អាត្មាអញ ក៏មិនអាចនឹងញុំាងបរិស័ទ ឲ្យកើតឡើងបានឡើយ, ណ្ហើយចុះ អាត្មាអញ

នឹងរួមជាមួយគ្នា នឹងព្រះបាទអជាតសត្រូវហើយ នឹងញ៉ាំងលាភ ឲ្យកើតឡើង" ដូច្នេះហើយ ក៏បានញ៉ាំងព្រះបាទអជាតសត្រូវ ឲ្យទ្រង់ជ្រះថ្លាហើយ ដោយឥទ្ធិបាដិហារ្យ ដោយន័យដែលមកហើយ ក្នុងសង្ឃភេទក្ខន្ធកៈ ។

ព្រះបាទអជាតសត្រូវនោះ ទ្រង់បានជ្រះថ្លាហើយ ចំពោះព្រះទេវទ័តនោះ ទ្រង់លើកតម្កើងព្រះទេវទ័តនោះ ដែលជាអសប្បុរស ទ្រង់មានព្រះបំណងនឹងធ្វើនូវសក្ការៈ ដល់ព្រះទេវទ័តនោះ ទ្រង់បានបរិច្ចាគព្រះរាជទ្រព្យជាច្រើនហើយ ទ្រង់ត្រាស់ឲ្យកសាងព្រះវិហារក្នុងគយាសីសប្រទេស ទ្រង់បានព្រះរាជទានហើយ នូវថាសភោជន ៥០០ សម្រាប់ ជារៀងរាល់ថ្ងៃ និង ទ្រង់បានស្ដេចយាងទៅកាន់ទីឧបដ្ឋាកនៃព្រះទេវទ័ត ទាំងល្ងាចទាំងព្រឹក ។ ព្រះអង្គទ្រង់ជឿនូវពាក្យ របស់ព្រះទេវទ័ត ទ្រង់បានធ្វើគត់ព្រះរាជបិតា ទ្រង់កាត់ផ្ដាច់នូវឧបនិស្ស័យនៃបឋមមគ្គ របស់ព្រះអង្គហើយ ទ្រង់ប្រសព្វទុក្ខ ដោយន័យដែលបានពោលហើយ ពួដីខាងក្រោយ ។

## ( រឿង សញ្ជីវមាណព )

(៧៧) ព្រះបាទអជាតសត្រូវអង្គនោះឯង ក្នុងអតីតកាលបានជាមាណព ឈ្មោះ សញ្ជីវៈ ដែល ( រាប់បញ្ចូល ) ក្នុងមាណព

៥០០ នាក់ ដែលជាអន្តេវាសិក របស់អាចារ្យទិសាបាមោក្ខ ក្នុងទីក្រុងពារាណសី ។ សញ្ជីវមាណពនោះ បានសិក្សាមន្តសម្រាប់ប្រោសមនុស្សដែលស្លាប់ហើយ ឲ្យក្រោកឡើយវិញតែម្យ៉ាង ក្នុងសំណាក់នៃអាចារ្យ មិនបានសិក្សានូវមន្តសម្រាប់ទុកការពារទេ ។

ក្នុងថ្ងៃមួយ សញ្ជីវមាណពនោះ បានទៅព្រៃ ដើម្បីប្រយោជន៍ដល់ឧស ជាមួយនឹងមាណពទាំងឡាយហើយ បានឃើញសត្វខ្លាស្លាប់ ទើបពោល ថា "ម្នាលអ្នកដ៏ចំរើន ខ្ញុំនឹងញ៉ាំងសត្វខ្លានេះ ឲ្យក្រោកឡើងវិញ" ។ មាណពទាំងនោះ ពោល ថា "បើអ្នកអាច, ចូរអ្នកញ៉ាំងសត្វខ្លានេះ ឲ្យក្រោកឡើងចុះ" ដូច្នេះហើយ ក៏បានឡើងទៅកាន់ដើមឈើ ។ សញ្ជីវមាណពនោះបានរាយមន្តហើយ ក៏បានយកដុំក្រួសមកប្រហារសត្វខ្លានោះ ។ សត្វខ្លា ក្រោកឡើងហើយ ក៏បានបោលទៅ យ៉ាងលឿន មកខាំនូវសញ្ជីវមាណព ត្រង់ដើមក បានញ៉ាំងសញ្ជីវមាណពនោះ ឲ្យដល់នូវការអស់ទៅនៃជីវិតហើយ ក៏បានដួលចុះ ក្នុងទីនោះឯង ។ ចំណែកសញ្ជីវមាណព ក៏បានដួលចុះ ក្នុងទីនោះដូចគ្នាដែរ ។ សត្វនិងមនុស្សទាំង ២ នោះ បានដេកស្លាប់ហើយ ក្នុងទីជាមួយគ្នានុ៎ះឯង ។

មាណពទាំងឡាយ មកហើយ ក៏បានប្រាប់ដល់អាចារ្យ ។

អាចារ្យនោះ ពោល ថា "ម្នាលអ្នកទាំងឡាយ ! ធម្មតាបុគ្គលអ្នកធ្វើការលើកតម្កើងនូវអសប្បុរស កាលធ្វើសក្ការៈនិងការរាប់អានក្នុងឋានៈដែលមិនសមគួរ តែងត្រឡប់បាននូវសេចក្ដីទុក្ខ ដូច្នេះឯង" កាលសំដែងធម៌ ទើបបានពោលហើយ នូវគាថានេះ ថា ÷

"បុគ្គលណា លើកដំកើង នូវជនជាអសប្បុរសផង (១)
ចូលទៅសេពគប់ នូវជនជាអសប្បុរសផង, ជនជា
អសប្បុរសនោះ រមែងធ្វើបុគ្គលនោះឯង ឲ្យទៅ
ជាអាហារ ដូចជាសត្វខ្លា មានជីវិតឡើងវិញ
ធ្វើសញ្ជីវមាណព ឲ្យជាអាហារ ដូច្នោះឯង" ។

បណ្ដាបទទាំងនោះ បទ ថា "**អសន្តំ**" បានដល់ បុគ្គលដែលប្រកបដោយទុច្ចរិត ៣ យ៉ាង ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ។ បទ ថា "**យោ**" គឺ បណ្ដាបុគ្គលទាំងឡាយមានក្សត្រជាដើម បុគ្គលឯណាមួយ ។ បទ ថា "**បគ្គណ្ហាតិ**" មានសេចក្ដីថា រមែងលើកតម្កើង គឺ ធ្វើសក្ការៈនិងការរាប់អាន នូវបព្វជិត ដោយការប្រគេនបច្ច័យមានចីវរជាដើម ឬនូវគ្រហស្ថ ដោយការប្រគល់ឲ្យនូវតំណែង មានឋានន្តរស័ក្ដិជាឧបរាជ និងសេនាបតីជាដើម ។ បទ ថា "**ឧបសេវតិ**" បានដល់ រមែងសេពគប់ ។ ២ បទ ថា

---

១ ត្រៃបិដក ភាគទី ៥៨ / ទំព័រទី ៦៦ ។

"តមេវ ឃាតំ" មានសេចក្ដីថា បុគ្គលអ្នកទ្រុស្ដសីល រមែងធ្វើនូវបុគ្គលអ្នកលើកដំកើងខ្លួននោះឯង ឲ្យទៅជារបស់ដែលគួរទំពារស៊ី, អធិប្បាយ ថា "តែងស៊ី គឺ ទំពារស៊ីនូវជននោះ បានដល់ឲ្យដល់នូវសេចក្ដីវិនាស"។ សួរ ថា "ប្រៀបដូចជាអ្វី?"។ ឆ្លើយ ថា "ប្រៀបដូចជាសត្វខ្លាដែលស្លាប់ហើយ ត្រូវសញ្ជីវមាណព រាយមន្តហើយ លើកដំកើង ដោយការឲ្យនូវជីវិត បានរស់មកវិញ ក៏ត្រឡប់ទៅជាសម្លាប់សញ្ជីវមាណព អ្នកឲ្យជីវិត ដល់ខ្លួននុ៎ះឯង ចាកជីវិតហើយ ឲ្យដល់នូវសេចក្ដីវិនាស ដូច្នោះឯង"។

សូម្បីអ្នកដទៃ ក៏ដូច្នោះដែរ, បុគ្គលណា រមែងលើកដំកើងនូវអសប្បុរសណា, អសប្បុរសនោះ ជាអ្នកទ្រុស្ដសីល រមែងធ្វើនូវបុគ្គលនោះ ដែលជាអ្នកលើកដំកើងខ្លួននុ៎ះឯង ឲ្យវិនាស, អធិប្បាយ ថា "ជនទាំងឡាយ ដែលលើកដំកើង នូវអសប្បុរស រមែងដល់នូវសេចក្ដីវិនាស យ៉ាងដូច្នេះឯង"។

រឿង សញ្ជីវមាណព មកក្នុងសញ្ជីវជាតក ក្នុងឯកនិបាត ។

## ( រឿង បរិព្វាជកអ្នកលើកដំកើងពពែ )

(៧៨) ក្នុងអតីតកាល ក្នុងទីក្រុងពារាណសី មានបរិព្វាជកម្នាក់ ឈ្មោះ ចម្មសាដកៈ ។ បានឮថា ស្បែកតែប៉ុណ្ណោះ

ជាសំពត់សំរាប់ស្លៀក និងដណ្តប់ របស់ចម្មសាដកបរិព្វាជកនោះ ។

ថ្ងៃមួយ បរិព្វាជកនោះ ដើរទៅ ដើម្បីសុំទានគេ ក្នុងក្រុងពារាណសី ក៏ទៅដល់ទីកន្លែងជល់ពពែទាំងឡាយ ។

គ្រានោះ សត្វពពែមួយ ឃើញបរិព្វាជកនោះហើយ ប្រាថ្នានឹងជល់ ទើបបានថយហើយ ។ បរិព្វាជក មិនបានថយចេញហើយ ដោយសម្គាល់ ថា " ពពែនេះ ធ្វើនូវការគោរពកោតក្រែងដល់អញ " ហើយ គិត ថា " ក្នុងចន្លោះនៃមនុស្ស មានប្រមាណប៉ុណ្ណោះនេះ ពពែ តែមួយនេះប៉ុណ្ណោះ ស្គាល់គុណរបស់អញ " ហើយ ក៏បានឈរផ្គងអញ្ជលី ចំពោះពពែនោះ ។ នាយពាណិជជាបណ្ឌិត អង្គុយក្នុងផ្សារ ឃើញហេតុនោះហើយ ទើបហាមឃាត់ថា " ម្នាលព្រាហ្មណ៍ ! ចូរអ្នកកុំជល់នូវការស្និទ្ធស្នាល ចំពោះសត្វជើង ៤ ដោយការឃើញមួយខណៈទៀយ, ព្រោះសត្វពពែនោះប្រាថ្នានូវការជល់ឲ្យធ្ងន់ ទើបថយ " ។

ក្នុងខណៈនោះឯង ពពែបានបោលមក យ៉ាងលឿន ហើយបុះនូវបរិព្វាជកនោះ ត្រង់ដើមទ្រូង ឲ្យដួលហើយ ក្នុងទីនោះឯង ។ បរិព្វាជកនោះ ដល់នូវវេទនា ដេកនៅក្នុងទីនោះឯង ស្រែកទួញ ថា

" ខ្ញុំជាមនុស្សឥតប្រាជ្ញា ត្រូវពពែបុះសម្លាប់[១]

១ ត្រៃបិដក ភាគទី ៥៨ / ទំព័រទី ២១១ ។

ក្នុងថ្ងៃនេះ យ៉ាងណាមិញ, បុគ្គលណាសរសើរ
បុគ្គលដែលមិនគួរបូជា, បុគ្គលនោះត្រូវបុគ្គល
ដែលមិនគួរបូជានោះ សម្លាប់ហើយ ដេកនៅ
(ក្នុងទីនេះ) ក៏យ៉ាងនោះដែរ "

ដូច្នេះ បានធ្វើកាលកិរិយាហើយ ។

បណ្ដាបទទាំងនោះ ច្រើនបទ ថា "**សោ និហតោ សេតិ**" មានសេចក្ដីថា បុគ្គលនោះ គឺ អ្នកដែលលើកតម្កើងនូវបុគ្គលដែលមិនគួរបូជា ត្រូវបុគ្គលដែលមិនគួរបូជានោះ សម្លាប់ហើយ ដេកនៅ ។ បទ ថា "**អបូជិ**" គឺ បុគ្គលដែលគេមិនគួរបូជា ។ ពាក្យ ថា "**យថាហមជ្ជ**" បានដល់ ប្រៀបដូចជាខ្ញុំធ្វើការលើកតម្កើងនូវអសប្បុរស ស្ថិតនៅ ក្នុងថ្ងៃនេះ ។ បទ ថា "**បហដោ**" គឺ ត្រូវពពេបុះ ដោយការបុះយ៉ាងមាំ ។ បទ ថា "**ហតោ**" គឺ ឲ្យស្លាប់ហើយ ។ បទ ថា "**ទុម្មតិ**" គឺ ជាអ្នកឥតប្រាជ្ញា ។ មានពាក្យ ដែលបរិព្វាជកនោះ ពោល ថា "សូម្បីបុគ្គលដទៃទៀតណាមួយ នឹងធ្វើនូវការលើកដំកើងនូវអសប្បុរស, បុគ្គលនោះឯងនឹងបានទទួល នូវសេចក្ដីទុក្ខ ដូចជាខ្ញុំ យ៉ាងដូច្នោះឯង " ។

បរិព្វាជកនោះឯង បានកើតជាបរិព្វាជក អ្នកមានឈ្មោះយ៉ាងដូច្នេះ ក្នុងទីក្រុងសាវត្ថី ក្នុងពុទ្ធុប្បាទនេះ ប្រតិបត្តិ

យ៉ាងដូច្នោះឯង បានត្រូវសត្វពពៃប្រហារហើយ ដូច្នេះឯង ។

រឿង បរិព្វាជក មកក្នុងចម្មសាដកជាតក ក្នុងចតុក្កនិបាត ។

ពណ៌នាអំពីការបូជានូវបុគ្គលដែលគួរបូជាដ៏ខ្ពង់ខ្ពស់ ចប់ ។

(៧៩) ន័យម្យ៉ាងទៀត ក្នុងបទ ថា "**បូជនេយ្យានំ**" នេះ គប្បីជ្រាបបូជនេយ្យបុគ្គលទាំងឡាយ យ៉ាងនេះ ថា "បណ្តាបព្វជិត អាចារ្យនិងព្រះឧបជ្ឈាយ៍ ជាបូជនេយ្យបុគ្គល របស់អន្តេវាសិក ទាំងឡាយជាដើម, ពួកភិក្ខុដែលចាស់ជាង ជាបូជនេយ្យបុគ្គល របស់ពួកភិក្ខុដែលថ្មី , ពួកបព្វជិតទាំងអស់ ជាបូជនេយ្យបុគ្គល របស់ពួកគ្រហស្ថ ។ ចំណែកបណ្តាគ្រហស្ថ បងប្អូនប្រុស-ស្រី ជាបូជនេយ្យបុគ្គល របស់ពួកប្អូនប្រុស-ស្រី, មាតានិងបិតា ជាបូជនេយ្យបុគ្គល របស់បុត្រទាំងឡាយ, ស្វាមី, ឪពុកក្មេក និងម៉ែក្មេក ជាបូជនេយ្យបុគ្គល របស់ស្ត្រីក្រមុំ ក្នុងត្រកូល" ។

ក៏ការបូជា ចំពោះបូជនេយ្យបុគ្គលទាំងនោះឯង ឈ្មោះថា ជាមង្គលទាំងអស់ ព្រោះជាការសមាទាននូវកុសលធម៌ និងព្រោះ ជាហេតុនៃសេចក្តីចំរើន ដោយធម៌មានអាយុជាដើម ។

ព្រោះហេតុនោះ ក្នុងចក្កវត្តិសូត្រ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា "មនុស្សទាំងឡាយនោះ នឹងជាអ្នកប្រតិបត្តិដោយ ប្រពៃចំពោះមាតា ជាអ្នកប្រតិបត្តិដោយប្រពៃចំពោះបិតា ជាអ្នក

ប្រតិបត្តិដោយប្រពៃចំពោះសមណៈ ជាអ្នកប្រតិបត្តិដោយប្រពៃចំពោះព្រាហ្មណ៍ ជាអ្នកប្រព្រឹត្តកោតក្រែងដល់បុគ្គលដែលចំរើនក្នុងត្រកូលជាប្រក្រតី, នឹងសមាទានប្រព្រឹត្តនូវកុសលធម៌នេះ, មនុស្សទាំងឡាយនោះ នឹងចំរើនដោយអាយុខ្លះ នឹងចំរើនដោយពណ៌សម្បុរខ្លះ ព្រោះហេតុសមាទាននូវកុសលធម៌ទាំងឡាយ" ។

បណ្ដាបទទាំងនោះ បទ ថា "**តេ**" មានសេចក្ដីថា ម្នាលភិក្ខុទាំងឡាយ! មនុស្សទាំងឡាយណា ជាបុត្ររបស់មាតានិងបិតាដែលមានអាយុប្រមាណ ២ ម៉ឺន ឆ្នាំ នឹងជាមនុស្សដែលមានអាយុ ៤ ម៉ឺនឆ្នាំ, ពួកមនុស្សដែលកើតមកជាបុត្រទាំងនោះ ។

បទ ថា "**មត្តេយ្យា**" បានដល់ ជាអ្នកទំនុកបម្រុងមាតា គឺ ជាអ្នកប្រតិបត្តិប្រពៃចំពោះមាតា ។ បទ ថា "**បេត្តេយ្យា**" គឺ ជាអ្នកទំនុកបម្រុងចំពោះបិតា ។ បទ ថា "**សាមញ្ញា**" គឺ ជាអ្នកទំនុកបម្រុងចំពោះសមណៈ ។ បទ ថា "**ព្រហ្មញ្ញា**" គឺ ជាអ្នកទំនុកបម្រុងចំពោះព្រាហ្មណ៍ ។

បទថា "**កុលេជេដ្ឋាបចាយិនោ**" មានសេចក្ដីថា ជាអ្នកប្រព្រឹត្តកោតក្រែងជាប្រក្រតី គឺ ប្រព្រឹត្តបន្ទាបខ្លួន ចំពោះជនទាំងឡាយ ដែលជាចម្បង គឺ ជាអ្នកចម្រើន មានឪពុកធំ, ឪពុកមា និងបងប្រុសជាដើម ក្នុងត្រកូលរបស់ខ្លួន ។ បទ ថា

“កុសលានិ” បានដល់ ដែលមិនមានទោសជាលក្ខណៈ ។ បទថា “សមាទានហេតុ” គឺ ព្រោះហេតុនៃការសមាទានហើយប្រព្រឹត្ត ។

ពណ៌នាអំពីការបូជានូវបុគ្គលដែលគួរបូជា ចប់ ។

## ( សរុបសេចក្ដីនៃគាថាទី ១ )

(៨០) ព្រះមានព្រះភាគ ទ្រង់ត្រាស់មង្គល ៣ ប្រការមានការមិនសេពគប់នូវបុគ្គលពាលជាដើម ដោយគាថានេះ, មង្គល ៣ ប្រការទាំងអស់នោះ គប្បីជ្រាបថា “ជាមង្គល” ព្រោះជាហេតុនៃសេចក្ដីចំរើន ដោយសម្បត្តិមានការសរសើរ ក្នុងលោកនេះជាដើម ដោយន័យដែលបានពណ៌នាមកនេះឯង ។

ចំណែកក្នុងអដ្ឋកថា លោកពោលថា “ការមិនសេពគប់នូវជនពាល ឈ្មោះថា ជាមង្គល ព្រោះជាហេតុនៃសេចក្ដីចំរើនក្នុងលោកទាំង ២ ព្រោះការពារនូវហេតុនៃទុក្ខមានភ័យជាដើមដែលមានការសេពគប់នូវជនពាលជាបច្ច័យ, ការសេពគប់បណ្ឌិតនិងការបូជានូវជនដែលគួរបូជា ឈ្មោះថា ជាមង្គល ព្រោះជាហេតុនៃព្រះនិព្វាន និងសុគតិ” ។

សូម្បីពាក្យជាគាថានេះ ក៏ជាបឋ្យាវត្ត ដូច្នេះឯង ។

ពណ៌នាសេចក្ដីនៃគាថាទី ១ ចប់ ។

# ពណ៌នាសេចក្ដីនៃគាថាទី ២

(៨១) គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី ២ ។ ការរស់នៅក្នុងប្រទេសដ៏សមគួរ ឈ្មោះថា **បដិរូបទេសវាសៈ** ។ ក៏ឱកាសជាទីរស់នៅ របស់សត្វទាំងឡាយ ឯណានីមួយ មានស្រុក នគរ និងជនបទជាដើម, ឱកាសនោះ ឈ្មោះថា **ប្រទេស** ។

បទ ថា "**បុព្វេ**" ប្រែថា ក្នុងកាលមុន, អធិប្បាយ ថា "ក្នុងជាតិដែលកន្លងទៅហើយ" ។

ភាពជាអ្នកមានកុសលបានសន្សំទុកមកហើយ ឈ្មោះថា ភាពជាអ្នកមានបុណ្យបានធ្វើទុកហើយ ។

ការតាំងទុក ការប្រាថ្នា ការប្រកបនូវខ្លួន ដោយប្រពៃ ឈ្មោះថា **អត្តសម្មាបណិធិ** ។

បទ ថា "**ឯតំ**" មានសេចក្ដីថា ម្នាលទេវតា! អ្នកចូរប្រកាន់យក ថា "ការនៅក្នុងប្រទេសដ៏សមគួរ ១ ភាពជាអ្នកមានបុណ្យបានធ្វើទុកហើយ ក្នុងកាលមុន ១ ការតាំងខ្លួនទុក ដោយប្រពៃ ១, កម្មទាំង ៣ យ៉ាងនេះឯង ជាមង្គលដ៏ឧត្ដម" ។

សេចក្ដីសង្ខេប ក្នុងគាថាទី ២ នេះ មានតែប៉ុណ្ណោះ ។

❋ ❋ ❋

ចំណែកសេចក្ដីពិស្ដារ ក្នុងគាថាទី ២ នេះ មានដូចតទៅ ÷

(៨២) បរិស័ទ ៤ រមែងត្រាច់ទៅ, បុញ្ញកិរិយាវត្ថុទាំងឡាយ មានទានជាដើម រមែងប្រព្រឹត្តទៅ, ពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា ដែលប្រកបដោយអង្គ ៩ រមែងរុងរឿង ក្នុងប្រទេសឯណា, ប្រទេសនោះ ឈ្មោះថា ប្រទេសដ៏សមគួរ ។ ការរស់នៅ ក្នុងប្រទេសដ៏សមគួរនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា "ជាមង្គល" ព្រោះជាបច្ច័យនៃការបំពេញបុណ្យ របស់សត្វទាំងឡាយ ។ ក្នុងដំណើរនោះ មានរឿងនេះ (ជាឧទាហរណ៍) ÷

## (រឿង ព្រានប្រមង់)

(៨៣) បានឮមកថា ព្រានប្រមង់ម្នាក់ ឈ្មោះ អរិយៈ អាស្រ័យនៅ ក្នុងទីក្រុងសាវត្ថី ។ ថ្ងៃមួយ ព្រានប្រមង់នោះ កំពុងយកសន្ទូចស្ទូចត្រី បានឃើញព្រះសាស្ដា ស្ដេចយាងបិណ្ឌបាត ក្នុងស្រុកក្បែរមាត់ទ្វារទិសខាងជើង នៃទីក្រុងសាវត្ថី មានភិក្ខុសង្ឃចោមរោមហើយ ស្ដេចកំពុងតែយាងមកអំពីស្រុកនោះឯង ទើបបានដាក់ដងសន្ទូច ឈរហើយ ។

ព្រះសាស្ដា ទ្រង់គង់នៅ ក្នុងទីមិនឆ្ងាយ នៃព្រានប្រមង់នោះ ហើយទ្រង់ត្រាស់សួរ នូវពួកព្រះសាវ័កមានព្រះសារីបុត្តត្ថេរ

ជាដើម ថា "តើអ្នកឈ្មោះអ្វី ?"។ ចំណែកព្រះសាវ័កទាំងនោះ បានក្រាបទូល នូវឈ្មោះរបស់ខ្លួនៗ ដោយន័យជាដើម ថា "ខ្ញុំព្រះករុណា ឈ្មោះសារីបុត្រ, ខ្ញុំព្រះករុណា ឈ្មោះមោគ្គល្លានៈ"។

ព្រានប្រមង់ គិត ថា "ព្រះសាស្តាទ្រង់ត្រាស់សួរ នូវឈ្មោះរបស់ពួកសាវ័កទាំងពួង, ព្រះអង្គឃើញថា នឹងទ្រង់ត្រាស់សួរនូវឈ្មោះរបស់អញខ្លះ"។ ព្រះសាស្តា ទ្រង់ជ្រាបចិត្តរបស់ព្រានប្រមង់នោះហើយ ទើបទ្រង់ត្រាស់សួរ ថា "ម្នាលឧបាសក តើអ្នកឈ្មោះអ្វី ?"។ ព្រានប្រមង់ បានក្រាបទូល ថា បពិត្រព្រះអង្គដ៏ចំរើន ទូលព្រះបង្គំ ឈ្មោះអរិយៈ"។

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងព្រានប្រមង់នោះ ថា "ម្នាលឧបាសក បុគ្គលអ្នកសម្លាប់នូវសត្វមានជីវិត ដូចជាអ្នកមិនឈ្មោះថា ជាអរិយៈទេ, ចំណែកព្រះអរិយៈទាំងឡាយស្ថិតនៅហើយ ក្នុងភាវៈ គឺការមិនបៀតបៀន នូវសត្វទាំងឡាយ" ដូច្នេះហើយ កាលទ្រង់ត្រាស់សំដែងនូវធម៌ ទើបត្រាស់គាថានេះ ក្នុងធម្មដ្ឋវគ្គ នៃធម្មបទ ថា ÷

"បុគ្គលបៀតបៀនសត្វទាំងឡាយ ដោយហេតុណា,(១)
មិនបានឈ្មោះថា ជាអរិយៈ ដោយហេតុនោះទេ,

១ ត្រៃបិដក ភាគទី ៥២ / ទំព័រទី ៧៧ ។

បុគ្គលដែលតថាគត ហៅថា ជាព្រះអរិយៈ ព្រោះ
មិនចេះបៀតបៀន នូវសត្វទាំងពួង " ។

បណ្ដាបទទាំងនោះ បទ ថា "**តេន**" គឺ ដោយហេតុនោះ ។ បទ ថា "**ហឹសតិ**" ប្រែថា បៀតបៀន ។ បទ ថា "**អហឹសា**" មានសេចក្ដីថា ព្រោះមិនបៀតបៀននូវសត្វទាំងពួង ដោយគ្រឿងប្រហារមានបាតដៃជាដើម ។ បាទគាថា ថា "**អរិយោតិ បវុច្ចតិ**" មានសេចក្ដីថា បុគ្គលអ្នកដែលស្ថិតនៅឆ្ងាយហើយ ចាកការបៀតបៀនប៉ុណ្ណោះ តថាគតហៅថា 'ជាអរិយៈ' ព្រោះជាអ្នកស្ថិតនៅហើយ ក្នុងភាវនាមានមេត្តាជាដើម ដូច្នេះឯង ។

ក្នុងទីបញ្ចប់នៃគាថា ព្រានប្រមង់ បានជាសោតាបន្ន ។

ការរស់នៅ ក្នុងប្រទេសដ៏សមគួរ របស់ព្រានប្រមង់នោះ ឈ្មោះថា ជាមង្គល ព្រោះជាបច្ច័យនៃបុញ្ញកិរិយាវត្ថុ គឺការស្ដាប់ ។

រឿង ព្រានប្រមង់ ចប់ ។

(៨៤) ម្យ៉ាងទៀត ប្រទេសជាទីផ្ទូរផង់នៃប្រាជ្ញាឈ្មោះពោធិ (ជាគ្រឿងត្រាស់ដឹង) របស់ព្រះសាស្ដា, ប្រទេសដែលព្រះមានព្រះភាគ ទ្រង់ញ៉ាំងព្រះធម្មចក្រ ឲ្យប្រព្រឹត្តទៅ, ប្រទេសគឺគល់នៃឈើឈ្មោះគណ្ឌាម្ពព្រឹក្ស ដែលព្រះមានព្រះភាគ ទ្រង់បាន

សំដែងយមកប្បាដិហារិយ៍ ទំលាយសេចក្តីស្រវឹងរបស់តិរ្ថិយទាំងពួង ត្រង់កណ្តាល នៃបរិស័ទ ប្រមាណ ១២ យោជន៍, ប្រទេសជាទីស្តេចយាងចុះអំពីទេវលោក ឬក៏ ប្រទេសជាទីគង់នៅរបស់ព្រះពុទ្ធ មានទីក្រុងសាវត្ថី និងទីក្រុងរាជគ្រឹះជាដើម ទោះជាឯណានីមួយ, ប្រទេសនោះ ឈ្មោះថា ប្រទេសដ៏សមគួរ ។ ការរស់នៅក្នុងប្រទេសដ៏សមគួរនោះ ឈ្មោះថា ជាមង្គល ព្រោះជាបច្ច័យធ្វើឲ្យបាននូវអនុត្តរិយៈ ៦ របស់សត្វទាំងឡាយ ។

(៨៥) ក៏កិច្ចមានការឃើញរូបជាដើម ដែលវៀរចាកកិច្ចដទៃដែលប្រសើរ គឺ មិនមានកិច្ចដទៃប្រសើរជាង ឈ្មោះថា អនុត្តរិយៈ ។

អនុត្តរិយៈទាំងឡាយនោះ គប្បីជ្រាប ដោយន័យដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ ក្នុងអនុត្តរិយសូត្រ[១] ក្នុងឆក្កនិបាត អង្គុត្តរនិកាយនុ៎ះឯង យ៉ាងដូច្នេះ ថា ÷

## ( ទស្សនានុត្តរិយៈ )

“ ម្នាលភិក្ខុទាំងឡាយ ! បុគ្គលខ្លះ ក្នុងលោកនេះ ទៅមើលដំរីរតន៍ក្តី ទៅមើលសេះរតន៍ក្តី ទៅមើលមណិរតន៍ក្តី ឬក៏ទៅមើលរបស់ធំ-តូចក្តី ទៅមើលសមណៈ ឬព្រាហ្មណ៍ ជាមិច្ឆាទិដ្ឋិ

១ ត្រៃបិដក ភាគទី ៤៦ / ទំព័រទី ៩៣ ។

ជាអ្នកប្រតិបត្តិខុសក្តី, ម្នាលភិក្ខុទាំងឡាយ ! ការឃើញនុ៎ះមាន, តថាគតមិនពោល ថា 'ការឃើញនុ៎ះ មិនមែនមិនមានទេ' ដូច្នេះ, ម្នាលភិក្ខុទាំងឡាយ ! ប៉ុន្តែការឃើញនោះនុ៎ះ ជារបស់ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនប្រសើរ មិនមានប្រយោជន៍ មិនប្រព្រឹត្តទៅ ដើម្បីនឿយណាយទេ ដើម្បីប្រាសចាកតម្រេកទេ ដើម្បីរលត់កិលេសទេ ដើម្បីស្ងប់រម្ងាប់ទេ ដើម្បីដឹងប្រសើរទេ ដើម្បីត្រាស់ដឹងទេ ដើម្បីព្រះនិព្វានទេ, ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណា ទៅឃើញនូវតថាគត ឬសាវ័កនៃតថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង, ម្នាលភិក្ខុទាំងឡាយ ការឃើញនុ៎ះ ទើបប្រសើរបំផុត ជាងការឃើញទាំងឡាយ (ព្រោះប្រព្រឹត្តទៅ) ដើម្បីសេចក្តីបរិសុទ្ធិដល់សត្វទាំងឡាយ ដើម្បីកន្លងបង់ នូវសេចក្តីសោក នឹងខ្សឹកខ្សួល ដើម្បីអស់ទៅ នៃទុក្ខនឹងទោមនស្ស ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន, គឺនៅត្រង់បុគ្គលទៅឃើញតថាគត ឬសាវ័ករបស់តថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន ជាអ្នកមានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង, ម្នាលភិក្ខុទាំងឡាយ ! ការឃើញនេះ ទើបតថាគត ឲ្យឈ្មោះថា ការឃើញដ៏ប្រសើរបំផុត ។

( សវនានុត្តរិយៈ )

ម្នាលភិក្ខុទាំងឡាយ ! បុគ្គលខ្លះ ក្នុងលោកនេះ ទៅស្តាប់សំឡេងស្គរក្តី ទៅស្តាប់សំឡេងពិណក្តី ទៅស្តាប់សំឡេងច្រៀងក្តី ឬក៏ទៅស្តាប់សំឡេងធំ - តូចណាមួយក្តី ទៅស្តាប់ធម៌ របស់សមណៈ ឬព្រាហ្មណ៍ ជាមិច្ឆាទិដ្ឋិ ជាអ្នកប្រតិបត្តិខុសក្តី, ម្នាលភិក្ខុទាំងឡាយ ! ការស្តាប់នុ៎ះមានមែន, តថាគតមិនពោល ថា 'ការស្តាប់នុ៎ះ មិនមែនមិនមានទេ' ដូច្នេះ, ប៉ុន្តែការស្តាប់នោះនុ៎ះឯងជារបស់ថោកទាប ជារបស់អ្នកស្រុក ។ល។ រមែងមិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វានទេ, ម្នាលភិក្ខុទាំងឡាយ ! លុះតែបុគ្គលណា ទៅស្តាប់ធម៌ របស់តថាគត ឬសាវ័កនៃតថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង, ម្នាលភិក្ខុទាំងឡាយ ! ការស្តាប់នុ៎ះ ទើបប្រសើរបំផុតជាងការស្តាប់ទាំងឡាយ ( ព្រោះប្រព្រឹត្តទៅ ) ដើម្បីសេចក្តីបរិសុទ្ធិ ដល់សត្វទាំងឡាយ ។ល។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន, គឺនៅត្រង់បុគ្គល ទៅស្តាប់ធម៌ របស់តថាគត ឬសាវ័កនៃតថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន ។ល។ ជាអ្នកជ្រះថ្លាខ្លាំង, ម្នាលភិក្ខុទាំងឡាយ ! ការស្តាប់នេះ ទើបតថាគត ឲ្យឈ្មោះថា ការស្តាប់យ៉ាងប្រសើរបំផុត ។

( លាភានុត្តរិយៈ )

ម្នាលភិក្ខុទាំងឡាយ ! បុគ្គលខ្លះ ក្នុងលោកនេះ បានលាភគឺកូនក្តី បានលាភគឺប្រពន្ធក្តី បានលាភគឺទ្រព្យក្តី ឬក៏បានលាភធំ-តូចណាមួយក្តី បានសេចក្តីជឿ ក្នុងសមណៈ ឬព្រាហ្មណ៍ជាមិច្ឆាទិដ្ឋិ ជាអ្នកប្រតិបត្តិខុសក្តី, ម្នាលភិក្ខុទាំងឡាយ ! លាភនុ៎ះ មានមែន, តថាគតមិនពោល ថា 'លាភនេះ មិនមែនមិនមានទេ' ដូច្នេះ, តែថាលាភនោះនុ៎ះឯង ជារបស់ដ៏ថោកទាប ជារបស់អ្នកស្រុក ។ល។ រមែងមិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វានទេ, ម្នាលភិក្ខុទាំងឡាយ! លុះតែបុគ្គលណាបានសេចក្តីជឿក្នុងតថាគត ឬសាវ័កនៃតថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន ។ល។ ជ្រះថ្លាខ្លាំង, ម្នាលភិក្ខុទាំងឡាយ ! ការបាននុ៎ះ ជាការបានយ៉ាងប្រសើរបំផុត ជាងការបានទាំងឡាយ (ព្រោះប្រព្រឹត្តទៅ) ដើម្បីសេចក្តីបរិសុទ្ធិ ដល់សត្វទាំងឡាយ ។ល។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន, គឺនៅត្រង់បុគ្គលបាននូវសេចក្តីជឿក្នុងតថាគត ឬព្រះសាវ័ករបស់តថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន ជាអ្នកមានចិត្តស្រឡាញ់មាំ ។ល។ ជាអ្នកជ្រះថ្លាខ្លាំង, ម្នាលភិក្ខុទាំងឡាយ ! ការបាននេះ ទើបតថាគត ឲ្យឈ្មោះថាជាការបានយ៉ាងប្រសើរបំផុត ។

( សិក្ខានុត្តរិយៈ )

ម្នាលភិក្ខុទាំងឡាយ ! បុគ្គលខ្លះ ក្នុងលោកនេះ សិក្សាវិជ្ជាដំរីក្តី សិក្សាវិជ្ជាសេះក្តី សិក្សាវិជ្ជារថក្តី សិក្សាវិជ្ជាធ្នូដាវក្តី ឬក៏សិក្សាវិជ្ជាខ្ពស់-ទាបក្តី សិក្សា (វិជ្ជា) របស់សមណៈ ឬព្រាហ្មណ៍ ជាមិច្ឆាទិដ្ឋិ ជាអ្នកប្រតិបត្តិខុសក្តី, ម្នាលភិក្ខុទាំងឡាយ ការសិក្សានុ៎ះ មានមែន, តថាគតមិនពោល ថា 'ការសិក្សានុ៎ះ មិនមែនមិនមានទេ' ដូច្នេះ, ម្នាលភិក្ខុទាំងឡាយ ! តែថា ការសិក្សានោះនុ៎ះ ជារបស់ថោកទាប សម្រាប់អ្នកស្រុក ។ល។ មិនប្រព្រឹត្តទៅដើម្បីនិព្វានទេ, ម្នាលភិក្ខុទាំងឡាយ ! លុះតែបុគ្គលណាសិក្សាអធិសីលសិក្ខា សិក្សាអធិចិត្តសិក្ខា សិក្សាអធិប្បញ្ញាសិក្ខា ក្នុងធម្មវិន័យ ដែលតថាគតសំដែងហើយ ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន ។ល។ ជាអ្នកជ្រះថ្លាខ្លាំង, ម្នាលភិក្ខុទាំងឡាយ ! ការសិក្សានុ៎ះ ប្រសើរបំផុត ជាងការសិក្សាទាំងឡាយ (ព្រោះប្រព្រឹត្តទៅ) ដើម្បីសេចក្តីបរិសុទ្ធិ ដល់សត្វទាំងឡាយ ។ល។ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន, ម្នាលភិក្ខុទាំងឡាយ ! គឺនៅត្រង់បុគ្គលសិក្សាអធិសីលសិក្ខាក្តី ក្នុងធម្មវិន័យ ដែលតថាគតសំដែងហើយ ។ល។ ជាអ្នកជ្រះថ្លាខ្លាំង, ម្នាលភិក្ខុទាំងឡាយ ! ការសិក្សានេះ ទើបតថាគត ឱ្យឈ្មោះថា ការសិក្សាយ៉ាងប្រសើរបំផុត ។

( បារិចរិយានុត្តរិយៈ )

ម្នាលភិក្ខុទាំងឡាយ ! បុគ្គលខ្លះ ក្នុងលោកនេះ បម្រើក្សត្រិយ៍ក្តី បម្រើព្រាហ្មណ៍ក្តី បម្រើគហបតីក្តី ឬក៏បម្រើបុគ្គលធំ-តូចណាមួយក្តី បម្រើសមណៈ ឬព្រាហ្មណ៍ ជាមិច្ឆាទិដ្ឋិ ជាអ្នកប្រតិបត្តិខុសក្តី, ម្នាលភិក្ខុទាំងឡាយ ! ការបម្រើនុ៎ះមានមែន, តថាគតមិនពោល ថា ' ការបម្រើនុ៎ះ មិនមែនមិនមានទេ ' ដូច្នេះ, ម្នាលភិក្ខុទាំងឡាយ ! តែថា ការបម្រើនោះនុ៎ះ ជារបស់ថោកទាប ជារបស់អ្នកស្រុក ។ ល ។ មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វានទេ, ម្នាលភិក្ខុទាំងឡាយ ! លុះតែបុគ្គលណាបម្រើតថាគត ឬសាវ័កនៃតថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន ជាអ្នកមានចិត្តស្រឡាញ់មាំ ។ ល ។ ជាអ្នកជ្រះថ្លាខ្លាំង, ម្នាលភិក្ខុទាំងឡាយ ! ការបម្រើនុ៎ះ ជាការបម្រើដ៏ប្រសើរបំផុតជាងការបម្រើទាំងឡាយ ( ព្រោះប្រព្រឹត្តទៅ ) ដើម្បីសេចក្តីបរិសុទ្ធិ ដល់សត្វទាំងឡាយ ។ ល ។ ដើម្បីត្រាស់ដឹងមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន, គឺនៅត្រង់បុគ្គល បម្រើតថាគត ឬសាវ័កនៃតថាគត ។ ល ។ ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន ជាអ្នកជ្រះថ្លាខ្លាំង, ម្នាលភិក្ខុទាំងឡាយ ! ការបម្រើនេះ ទើបតថាគត ឲ្យឈ្មោះថា ការបម្រើយ៉ាងប្រសើរបំផុត ។

( អនុស្សតានុត្តរិយៈ )

ម្នាលភិក្ខុទាំងឡាយ ! បុគ្គលខ្លះ ក្នុងលោកនេះ រឭកនូវកូនក្តី រឭកនូវប្រពន្ធក្តី រឭកនូវទ្រព្យក្តី ឬក៏រឭកនូវការបានទ្រព្យធំ - តូចក្តី រឭកនូវសមណៈ ឬព្រាហ្មណ៍ ជាមិច្ឆាទិដ្ឋិ ជាអ្នកប្រតិបត្តិខុសក្តី, ម្នាលភិក្ខុទាំងឡាយ ! ការរឭកនុ៎ះ មានមែន, តថាគត មិនពោល ថា 'ការរឭកនុ៎ះ មិនមែនមិនមានទេ' ដូច្នេះ, ម្នាលភិក្ខុទាំងឡាយ ! តែថា ការរឭកនោះនុ៎ះឯង ជារបស់ថោកទាប ជារបស់អ្នកស្រុក ។ល។ មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វានទេ, ម្នាលភិក្ខុទាំងឡាយ ! លុះតែបុគ្គលណា រឭកតថាគត ឬសាវ័កនៃតថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន ជាអ្នកមានចិត្តស្រឡាញ់មាំ ។ ល ។ ជាអ្នកជ្រះថ្លាខ្លាំង, ម្នាលភិក្ខុទាំងឡាយ ! ការរឭកនុ៎ះ ជាការរឭកដ៏ប្រសើរបំផុត ជាងការរឭកទាំងឡាយ ( ព្រោះប្រព្រឹត្តទៅ) ដើម្បីសេចក្តីបរិសុទ្ធិ ដល់សត្វទាំងឡាយ ។ល។ ដើម្បីត្រាស់ដឹងមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន, គឺនៅត្រង់បុគ្គល រឭកតថាគត ឬសាវ័ករបស់តថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន ។ ល ។ ជាអ្នកជ្រះថ្លាខ្លាំង, ម្នាលភិក្ខុទាំងឡាយ ! ការរឭកនេះ ទើបតថាគត ឲ្យឈ្មោះថា ការរឭកដ៏ប្រសើរបំផុត" ដូច្នេះ ។

(៨៦) ន័យដែលមក ក្នុងអដ្ឋកថាអនុត្តរិយសូត្រនោះ ថា "បណ្ដាបទទាំងនោះ បទ ថា '**ឧច្ចាវចំ**' បានដល់ រូបឯណាមួយ ដែលធំ តូច ឬខ្ពស់ ទាប ។ បទ ថា "**ហីនំ**" គឺ ដ៏ថោកទាប ។ បទ ថា "**គម្មំ**" បានដល់ ដែលជារបស់នៃអ្នកស្រុក ។ បទ ថា "**បោថុជ្ជនិកំ**" គឺ ដែលជារបស់នៃមនុស្សបុថុជ្ជន ។ បទ ថា "**អនរិយំ**" គឺ មិនប្រសើរ មិនខ្ពង់ខ្ពស់ បានដល់ មិនបរិសុទ្ធ ។ បទ ថា "**អនត្ថសញ្ហិតំ**" គឺ មិនប្រកបដោយប្រយោជន៍ ។ បទ ថា "**និព្វិទាយ**" គឺ ដើម្បីនឿយណាយ ក្នុងវដ្ដៈ ។ បទ ថា "**វិរាគាយ**" គឺ ដើម្បីប្រាសចាកនៃកិលេសទាំងឡាយ មានរាគៈជាដើម ។ បទ ថា "**និរោធាយ**" គឺ ដើម្បីរលត់ដោយមិនមានការប្រព្រឹត្តិទៅ នៃកិលេសទាំងនោះ ។ បទ ថា "**ឧបសមាយ**" គឺ ដើម្បីស្ងប់រម្ងាប់នៃកិសេលទាំងនោះ ។ បទ ថា "**អភិញ្ញាយ**" គឺ ដើម្បីត្រាស់ដឹងប្រសើរ ។ បទ ថា "**សម្ពោធាយ**" គឺ ដើម្បីត្រាស់ដឹងនូវមគ្គញាណ ៤ ពោលគឺបញ្ញាគ្រឿងត្រាស់ដឹង ។ បទ ថា "**និព្វានាយ**" គឺ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ បទ ថា "**និវិដ្ឋសទ្ធោ**" គឺ ជាអ្នកមានសទ្ធាឋិតនៅមាំហើយ ។ សូម្បីក្នុងបទទី ២ ក៏ន័យនេះដូចគ្នាដែរ ។ បទ ថា "**ឯកន្តគតោ**" បានដល់ ជាអ្នកដល់ហើយ ដោយចំណែកមួយ, អធិប្បាយ ថា

"ជាអ្នកមានសទ្ធាមិនកម្រើក" ។ បទ ថា "**អភិប្បសន្នោ**" គឺ ជាអ្នកជ្រះថ្លាក្រៃលែង ។ បទ ថា "**ឯតទានុត្តរិយំ**" កាត់បទ ជា **ឯតំ អនុត្តរិយំ** ។ បទ ថា "**វិសុទ្ធិយា**" គឺ ដើម្បីដល់នូវសេចក្ដីបរិសុទ្ធិ ។ បទ ថា "**សោកបរិទេវានំ**" គឺ នូវសេចក្ដីសោក និងសេចក្ដីខ្សឹកខ្សួល ។ បទ ថា "**អដ្ឋង្គមាយ**" គឺ ដើម្បីដល់នូវការតាំងនៅមិនបាន ។ បទ ថា "**ញាយស្ស**" គឺ ដើម្បីមគ្គដែលប្រកបដោយវិបស្សនា ។ បទ ថា "**និព្វានស្ស**" គឺ ដើម្បីព្រះនិព្វានដែលមិនមានបច្ច័យ ។ បទ ថា "**បុត្តលាភំ**" គឺ លាភ ពោលគឺបុត្រ ។ បទ ថា "**ហត្ថិស្មឹ**" មានសេចក្ដីថា តែងសិក្សានូវសិល្បៈ មានដំរីជានិមិត្ត ដែលគួរសិក្សា ឈ្មោះថា សិក្សាព្រោះរឿងដំរី ។ ក្នុងបទទាំងពួង ក៏ន័យនេះដែរ ។ ក៏ក្នុងបទ ថា "**ថរុស្មឹ**" នេះ អាវុធគ្រប់បែបយ៉ាង ឈ្មោះថា **ថរុ** ។ បទ ថា "**ឧច្ចាវចំ**" គឺ សិល្បៈ ធំ-តូច ។ ក្នុងអនុត្តរិយៈទាំង ៦ យ៉ាងនោះ បណ្ដាការឃើញរូបទាំងឡាយ ការឃើញយ៉ាងប្រសើរ ឈ្មោះថា **ទស្សនានុត្តរិយៈ** ។ ក្នុងបទទាំងពួង ក៏ន័យនេះ ។

មែនពិត ការឃើញនូវព្រះសាស្ដា ព្រះភិក្ខុសង្ឃ ឬនូវនិមិត្តមានកសិណ និងអសុភនិមិត្តជាដើម យ៉ាងណានីមួយ នៃបុគ្គលជាអ្នកមានសទ្ធាខ្ជាប់ខ្ជួនហើយ ឈ្មោះថា **ទស្សនានុត្តរិយៈ**,

ការឃើញនូវរតនៈ មានរតនៈ គឺដំរីជាដើម មិនឈ្មោះថា **ទស្សនានុត្តរិយៈ** ឡើយ ។

ការស្តាប់នូវការពណ៌នាគុណព្រះរតនៈត្រៃ និងព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក ឈ្មោះថា **សវនានុត្តរិយៈ**, ការស្តាប់ការពណ៌នាគុណនៃក្សត្រិយ៍ជាដើម មិនឈ្មោះថា **សវនានុត្តរិយៈ** ទេ ។

ការបាននូវអរិយទ្រព្យទាំង ៧ យ៉ាងប៉ុណ្ណោះ ឈ្មោះថា **លាភានុត្តរិយៈ**, ការបាននូវរតនៈ មានមណិរតនៈជាដើម មិនឈ្មោះថា **លាភានុត្តរិយៈ** ឡើយ ។

ការបំពេញត្រៃសិក្ខា ឲ្យបរិបូណ៌ប៉ុណ្ណោះ ទើបឈ្មោះថា **សិក្ខានុត្តរិយៈ**, ការសិក្សាសិល្បៈ មានសិល្បៈគឺដំរីជាដើម មិនឈ្មោះថា **សិក្ខានុត្តរិយៈ** ឡើយ ។

ការប្រតិបត្តិបម្រើនូវព្រះរតនៈត្រៃប៉ុណ្ណោះ ឈ្មោះថា **បារិចរិយានុត្តរិយៈ**, ការប្រតិបត្តិបម្រើក្សត្រិយ៍ជាដើម មិនឈ្មោះថា **បារិចរិយានុត្តរិយៈ** ឡើយ ។

ការនឹករឭកដល់គុណ នៃព្រះរតនៈត្រៃប៉ុណ្ណោះ ឈ្មោះថា **អនុស្សតានុត្តរិយៈ**, ការនឹករឭកដល់គុណរបស់ក្សត្រិយ៍ជាដើម មិនឈ្មោះថា **អនុស្សតានុត្តរិយៈ** ឡើយ" ។

(៨៧) ន័យមកក្នុងអដ្ឋកថាឯកនិបាត អង្គុត្តរនិកាយ

ព្រមទាំងដីកា ថា "ព្រះអានន្ទត្ថេរ បានដើម្បីនឹងឃើញព្រះសាស្តា ដោយចក្ខុវិញ្ញាណ ក្នុងពេលល្ងាច - ព្រឹក, នេះ ឈ្មោះថា **ទស្សនានុត្តរិយៈ** ។ លោកបានដើម្បីស្តាប់នូវព្រះតម្រាស់របស់ព្រះសាស្តារឿយៗ, នេះ ឈ្មោះថា **សវនានុត្តរិយៈ** ។ លោកបាននូវសេចក្តីជឿចំពោះព្រះសាស្តា ថា "ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់បានត្រាស់ដឹង ដោយប្រពៃ" ដូច្នេះ, នេះ ឈ្មោះថា **លាភានុត្តរិយៈ** ។ លោក សិក្សានូវត្រៃសិក្ខា ក្នុងសាសនារបស់ព្រះសាស្តា, នេះឈ្មោះថា **សិក្ខានុត្តរិយៈ** ។ លោកប្រណិបត្តិ ធ្វើនូវការបម្រើ នូវព្រះសាស្តា ជារឿយ ៗ, នេះ ឈ្មោះថា **បារិចរិយានុត្តរិយៈ** ។ លោក នឹករព្ញកដល់គុណដែលជាលោកិយៈ និងលោកុត្តរៈ របស់ព្រះសាស្តា, នេះឈ្មោះថា **អនុស្សតានុត្តរិយៈ** ។

ព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមីបុគ្គលសូម្បីដទៃទៀត ក៏ដូចជាព្រះអានន្ទត្ថេរដែរ បានឃើញនូវព្រះសាស្តា និងបានស្តាប់ព្រះតម្រាស់នៃព្រះសាស្តា, បាននូវសទ្ធា ក្នុងព្រះសាស្តា សិក្សានូវត្រៃសិក្ខា ក្នុងព្រះសាសនា របស់ព្រះសាស្តា ប្រណិបត្តិបម្រើនូវព្រះសាស្តា នឹករព្ញកដល់គុណ នៃព្រះសាស្តា, ទាំងនេះឯង ឈ្មោះថា **ទស្សនានុត្តរិយៈ** ។ល។

**អនុស្សតានុត្តរិយៈ** ។

ចំណែកកល្យាណបុថុជ្ជន ក៏ដូចជាព្រះអានន្ទត្ថេរដែរ បាននូវការឃើញព្រះសាស្តា និងការបានស្តាប់ព្រះតម្រាស់ នៃព្រះសាស្តា បានសទ្ធាចំពោះព្រះសាស្តា សិក្សាត្រៃសិក្ខា ក្នុងព្រះសាសនា នៃព្រះសាស្តា ប្រណិបត្តិបម្រើព្រះសាស្តា នឹករឭកនូវគុណ របស់ព្រះសាស្តា ចំរើនវិបស្សនា មានការឃើញ, ការស្តាប់, ការបានត្រៃសិក្ខា, ការប្រណិបត្តិបម្រើ និងការតាមនឹករឭកនោះ ៗ ( ជាអារម្មណ៍ ) ហើយធ្វើខ្លួន ឲ្យបានសម្រេចព្រះសោតាបត្តិមគ្គ, នេះ ទើបឈ្មោះថា **ទស្សនៈ**, **សវនៈ**, **លាភៈ**, **សិក្ខា**, **បារិចរិយា**, **អនុស្សតិ** ដោយពិតប្រាកដ ។ ចំណែកទស្សនៈដែលជាខាងដើម ឈ្មោះថា **ទស្សនានុត្តរិយៈ**, ការស្តាប់, ការបាន, ការសិក្សា, ការប្រណិបត្តិ និងការតាមនឹករឭក ដែលជាខាងដើម ក៏យ៉ាងដូច្នោះដែល គឺឈ្មោះថា **សវនានុត្តរិយៈ** ។ ល ។ **អនុស្សតានុត្តរិយៈ** ។

(៨៨) ក៏ក្នុងព្រះសូត្រនេះ ព្រះដ៏មានព្រះភាគ មិនទ្រង់ព្រះបំណងត្រឹមតែការឃើញព្រះរូប របស់ព្រះសាស្តា ដែលជាអ្នកប្រសើរខ្ពង់ខ្ពស់ ថា ‘ជាទស្សនានុត្តរិយៈ’ ឡើយ, តាមពិតព្រះអង្គទ្រង់ប្រាថ្នានូវការឃើញឈានចូល ក្នុងព្រះពុទ្ធគុណ ដោយ

សេចក្តីជ្រះថ្លាយ៉ាងក្រៃលែង មានការឃើញព្រះរូប របស់ព្រះអង្គជាប្រធាន ( ថាជាទស្សនានុត្តរិយៈ ) ។ ព្រោះហេតុនោះទើបព្រះអដ្ឋកថាចារ្យ ពោល ថា 'អានន្ទត្ថេរោ' ដូច្នេះជាដើម ។

រូបកាយ របស់ព្រះសាស្តា ឈ្មោះថា **ទស្សនៈ** ក្នុងបទ ថា '**ទស្សនានុត្តរិយំ**' នោះ ព្រោះជាព្រះរូបដែលបុគ្គលគប្បីឃើញ, សូម្បីក្នុងបទ ថា '**ទស្សនានុត្តរិយំ**' នោះ អាយតនៈ គឺរូបក៏ឈ្មោះថា **ទស្សនៈ** ដោយការមិនប្លែកគ្នាឡើយ, ហេតុនោះទើបព្រះអដ្ឋកថាចារ្យ ពោល ថា '**ចក្ខុវិញ្ញាណេន ទដ្ឋុំ**' ដូច្នេះ ។

ទស្សនៈដទៃ ក្រៃលែងជាងទស្សនៈនេះ មិនមាន ហេតុនោះទស្សនៈនេះ ទើបឈ្មោះថា អនុត្តរៈ (មិនមានទស្សនៈដទៃក្រៃលែងជាង), អនុត្តរៈនោះឯង ឈ្មោះថា អនុត្តរិយៈ , ទស្សនៈនោះផង មិនមានទស្សនៈដទៃក្រៃលែងជាងផង ហេតុនោះទើបឈ្មោះថា ទស្សនានុត្តរិយៈ ។ សូម្បីក្នុងអនុត្តរិយៈ ដែលសេសសល់ ក៏ន័យនេះដូចគ្នាដែរ ។ ចំណែកសេចក្តីប្លែកផ្សេងគ្នាមានដូចតទៅនេះ ÷

ដែលឈ្មោះថា **សវនៈ** ព្រោះអត្ថ ថា 'គឺបុគ្គលតែងស្តាប់' គឺ ព្រះតម្រាស់ របស់ព្រះសាស្តា ។ ដែលឈ្មោះថា **លាភៈ** ព្រោះអត្ថ ថា 'គឺបុគ្គលតែងបាន' គឺ ការជឿចំពោះព្រះសាស្តា ។

ដែលឈ្មោះថា **សិក្ខា** ព្រោះអត្ថថា គឺបុគ្គលគប្បីសិក្សា គឺសីល សមាធិ និងបញ្ញា ។ ការប្រណិបត្តិ ឈ្មោះថា បារិចរិយា គឺ ការទំនុកបម្រុង ។ ការតាមរព្ញក ឈ្មោះថា អនុស្សតិ បានដល់ ការរព្ញកនូវគុណ របស់ព្រះសាស្តា ។

ពាក្យ ថា '**ឥទម្បិ**' នេះ ព្រះអដ្ឋកថាចារ្យ ពោលហើយ ព្រោះមិនខុសប្លែកពីពាក្យ ដែលលោកពោលហើយ ក្នុងកាលមុន ។

២ បទ ថា '**សត្ថុ ទស្សនំ**' មានសេចក្តីថា ប្រៀបដូចជា ព្រះអានន្ទត្ថេរ បាននូវការឃើញព្រះសាស្តា ដែលមានការជ្រះថ្លា ការភក្តី និងសេចក្តីមេត្តាជាខាងដើម ។

បទ ថា '**សិក្ខាត្តយំ**' មានសេចក្តីថា សិក្សានូវត្រៃសិក្ខា ដែលជាបុព្វភាគ ។ ២ បទ ថា '**តំ ទស្សនំ**' មានសេចក្តីថា ចំរើនវិបស្សនាដែលប្រព្រឹត្តទៅ ដោយការឃើញជាប្រធាន ។

មែនពិត កល្យាណបុថុជ្ជន ចំរើនវារៈនៃវិបស្សនា រហូត ដល់អនុលោមញាណ ដោយការឃើញជាប្រធានហើយ ឈានចូល ដល់ភូមិនៃអរិយៈទី ៨ ក្នុងលំដាប់នៃអនុលោមញាណនោះ បាន នូវទស្សនៈហើយ ទើបឈ្មោះថា ញ៉ាំងខ្លួន ឲ្យបានសម្រេចមគ្គ ។

ទស្សនៈដែលប្រព្រឹត្តទៅ បន្ទាប់អំពីនេះ ឈ្មោះថា ទស្សនៈ ដ៏ពិតប្រាកដ ។ ទស្សនៈដែលជាខាងដើម ឈ្មោះថា

ទស្សនានុត្តរិយៈ ព្រោះជាហេតុ នៃការឃើញនូវសច្ចៈផងដែរ ។ សូម្បីក្នុងអនុត្តរិយៈ ដ៏សេសសល់ ក៏ន័យនេះ ដូចគ្នាដែរ ។

កល្យាណបុថុជ្ជន ធ្វើញាណដែលមានអនុស្សតិជាអារម្មណ៍ ឲ្យកើតឡើង ដោយអំណាច នៃការរឭកដល់ព្រះពុទ្ធគុណ ដោយន័យជាដើម ថា '**ឥតិបិ សោ ភគវា**' ដូច្នេះហើយ ធ្វើញាណនោះ ឲ្យជាបទដ្ឋាន កាលចំរើនវិបស្សនា ព្រះអដ្ឋកថាចារ្យពោល ថា 'ចំរើនវិបស្សនា មានការរឭក (ជាអារម្មណ៍)" ដូច្នេះ ។

## ( រឿង វក្កលិព្រាហ្មណ៍ )

(៨៩) បានឮថា ព្រាហ្មណ៍ម្នាក់ ឈ្មោះវក្កលិ អាស្រ័យនៅក្នុងទីក្រុងសាវត្ថី ។ ថ្ងៃមួយ ព្រាហ្មណ៍នោះ ឃើញព្រះសាស្តា ស្តេចកំពុងយាងបិណ្ឌបាត ក្នុងទីក្រុងសាវត្ថី មិនបានឆ្អែតឆ្អន់ហើយ ដោយការឃើញព្រះរូប របស់ព្រះសាស្តា បានទៅកាន់វត្តជេតពន ជាមួយនឹងព្រះសាស្តានុ៎ះឯង បានស្តាប់នូវទេសនារបស់ព្រះសាស្តា ក៏បានសទ្ធាហើយ បួសក្នុងសំណាក់ នៃព្រះសាស្តា ដោយតាំងចិត្ត ថា "អញនឹងបានឃើញ នូវព្រះសាស្តា ជាប់ជានិច្ច ដោយឧបាយយ៉ាងនេះ" ដូច្នេះហើយ, ក្នុងកាលដទៃក្រៅអំពីកាលឆាន់អាហារ ខ្លួនបានឈរនៅ ក្នុងទីស្ថានណា ហើយឃើញ

នូវព្រះសាស្តា, ក៏បានឈរនៅក្នុងទីស្ថាននោះ បានលះបង់ចោលនូវកិច្ចទាំងឡាយ មានការស្វាធ្យាយ និងការធ្វើទុកក្នុងចិត្ត ដោយឧបាយ ក្នុងកម្មដ្ឋានជាដើម ហើយបាននៅចាំមើលព្រះសាស្តា ។

ព្រះសាស្តា ទ្រង់រង់ចាំនូវការចាស់ក្លា នៃញាណ របស់ព្រះវក្កលិនោះ មិនទ្រង់ត្រាស់ព្រះតម្រាស់អ្វីឡើយ អស់កាលដ៏យូរ, កាលបើព្រះវក្កលិនោះ មានញាណចាស់ក្លាហើយ, ទើបទ្រង់ត្រាស់ ថា "ម្នាលវក្កលិ នឹងមានប្រយោជន៍អ្វីដល់អ្នក ដោយកាយដែលស្អុយ គឺអ្នកបានឃើញហើយនេះ, ម្នាលវក្កលិ បុគ្គលណាឃើញនូវធម៌, បុគ្គលនោះរមែងឃើញនូវតថាគត, បុគ្គលណាឃើញតថាគត, បុគ្គលនោះ រមែងឃើញនូវធម៌, ម្នាលវក្កលិ ក៏បុគ្គលអ្នកឃើញនូវធម៌ ឈ្មោះថា ឃើញនូវតថាគត, បុគ្គលអ្នកឃើញនូវតថាគត ឈ្មោះថា ឃើញនូវធម៌" ដូច្នេះហើយ , កាលបើថ្ងៃចូលព្រះវស្សា ជិតចូលមកដល់ហើយ, ទើបស្តេចយាងទៅកាន់ព្រះនគររាជគ្រឹះ ក្នុងថ្ងៃចូលព្រះវស្សា ទ្រង់បានត្រាស់បណ្តេញព្រះវក្កលិនោះ ថា "ម្នាលវក្កលិ ចូរអ្នកគេចចេញទៅ" ។

ព្រះវក្កលិនោះ កាលមិនអាចដើម្បីស្ថិតនៅបាន ទើបនឹកគិតថា " នឹងមានប្រយោជន៍អ្វី ដោយជីវិត របស់អាត្មាអញនោះ ដែលជាអ្នកមិនបានឃើញ នូវព្រះសាស្តា " ហើយ ក៏បានឡើងទៅ

កាន់ភ្នំគិជ្ឈកូដ ដើម្បីនឹងទម្លាក់ខ្លួនអំពីភ្នំ ។

ព្រះសាស្តា ទ្រង់ជ្រាបសេចក្តីនោះហើយ ទើបទ្រង់ព្រះតម្រិះ ថា "ព្រះវក្កលិនេះ កាលមិនបាននូវសេចក្តីសប្បាយចិត្ត អំពីសំណាក់តថាគតទេ នឹងគប្បីញ៉ាំងឧបនិស្ស័យនៃមគ្គផល ឲ្យវិនាស" ដូច្នេះហើយ ទ្រង់គង់នៅ ក្នុងវត្តវេឡុវនន៍ះឯង ទ្រង់បញ្ចេញនូវព្រះរស្មីហើយ សំដែងព្រះអង្គ កាលទ្រង់ញ៉ាំងបីតិដ៏មានកម្លាំងឲ្យកើតឡើង ដល់ព្រះវក្កលិនោះ ទ្រង់បានត្រាស់ហើយ នូវព្រះគាថានេះ ក្នុងភិក្ខុវគ្គ នៃធម្មបទ ថា ÷

"ភិក្ខុអ្នកក្រាស់ដោយសេចក្តីរីករាយ ជ្រះថ្លា[១]
ហើយ ក្នុងព្រះពុទ្ធសាសនា គប្បីបានសម្រេច
នូវបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ ជាសុខ" ។

បណ្តាបទទាំងនោះ បទ ថា "**បាមោជ្ជពហុលោ**" មានសេចក្តីថា ជាអ្នកច្រើនដោយសេចក្តីរីករាយ សូម្បីដោយប្រក្រតី ។ បទ ថា "**បសន្នោ**" បានដល់ ជាអ្នកបណ្តុះសេចក្តីជ្រះថ្លា ។

បាទគាថា ថា "**អធិគច្ឆេ បទំ សន្តំ**" មានសេចក្តីថា គប្បីបានសម្រេច នូវចំណែកដែលស្ងប់ ពោលគឺព្រះនិព្វាន ។

បាទគាថា ថា "**សង្ខារូបសមំ សុខំ**" មានសេចក្តីថា

---

១ ត្រៃបិដក ភាគទី ៥២ / ភាគទី ១០១ ។

ជាធម៌ជាទីរម្ងាប់ នូវសង្ខារទាំងពួង ជាសុខយ៉ាងក្រៃលែង ។

ក៏ព្រះសាស្តា លុះទ្រង់ត្រាស់ព្រះតម្រាស់នេះហើយ ទើបទ្រង់លាតព្រះហស្តហើយ ទ្រង់ត្រាស់ ថា "ម្នាលវក្កលិ ចូរអ្នកមកចុះ, ចូរអ្នកកុំភ័យខ្លាចឡើយ" ។

ព្រះវក្កលិនោះ គិត ថា "អាត្មាអញ បានឃើញព្រះសាស្តាហើយ, សូម្បីព្រះតម្រាស់ ថា 'ចូរអ្នកមកចុះ' ដូច្នេះ ក៏អាត្មាអញបានហើយ" ដូច្នេះហើយ ក៏បានញ៉ាំងបីតិដ៏មានកម្លាំងឲ្យកើតឡើង មិនទាន់បានដឹងនូវភាវៈ គឺការទៅ របស់ខ្លួនផង ថា "អាត្មាអញនឹងទៅខាងណា" ដូច្នេះ ក៏ហោះទៅឰដ៏អាកាស នៅទីចំពោះព្រះភក្ត្រនៃព្រះសាស្តា បានឈរនៅលើភ្នំ ដោយជើងទីមួយនុ៎ះឯង ហើយរព្ញកនូវគាថា ដែលព្រះសាស្តាទ្រង់ត្រាស់ហើយ ទើបបានរម្ងាប់នូវបីតិ លើអាកាសនុ៎ះឯង ហើយសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយហើយ ចុះមកថ្វាយបង្គំព្រះសាស្តា ។

រឿង ព្រះវក្កលិ មកក្នុងអដ្ឋកថាធម្មបទជាដើម ។

(៩០) ការនៅក្នុងប្រទេស ដែលជាទីគង់នៅ នៃព្រះពុទ្ធរបស់ព្រះវក្កលិនោះ រមែងជាបច្ច័យនៃការបានចំពោះ នូវអនុត្តរិយៈ ៦ យ៉ាង គឺ ការឃើញព្រះរូបរបស់ព្រះសាស្តា ជាទស្សនានុត្តរិយៈ,

ការបានស្តាប់នូវទេសនា របស់ព្រះសាស្តា ជាសវនានុត្តរិយៈ, ការបានសទ្ធា ចំពោះព្រះសាស្តា ជាលាភានុត្តរិយៈ, ការបំពេញត្រៃសិក្ខា ជាសិក្ខានុត្តរិយៈ, ការប្រណិបត្តិនូវព្រះសាស្តា ជាបារិចរិយានុត្តរិយៈ, ការតាមរឭកព្រះគុណ របស់ព្រះសាស្តា ជាអនុស្សតានុត្តរិយៈ ដោយប្រការដូច្នេះឯង ។

## ( មជ្ឈិមប្រទេស ជាប្រទេសដ៏សមគួរ )

(៩១) ម្យ៉ាងវិញទៀត ជនបទដែលមានឈ្មោះថា មជ្ឈិមប្រទេស ដែលលោកបានកំណត់ទុកហើយ ក្នុងចម្មក្ខន្ធកៈ យ៉ាងដូច្នេះ ថា "ក្នុងទិសបូព៌ា មាននិគម ឈ្មោះកជង្គលៈ, តអំពីនិគមនោះទៅ មាននគរ ឈ្មោះមហាសាល, តអំពីមហាសាលនគរនោះទៅ ជាបច្ចន្តជនបទ រួមខាងក្នុង ជាមជ្ឈិមជនបទ,

ក្នុងទិសអាគ្នេយ៍ មានស្ទឹង ឈ្មោះសល្លវតី, តអំពីស្ទឹងសល្លវតីនោះទៅ ជាបច្ចន្តជនបទ រួមខាងក្នុង ជាមជ្ឈិមជនបទ,

ក្នុងទិសទក្សិណ មាននិគម ឈ្មោះសេតកណ្ណិកៈ, តអំពីសេតកណ្ណិកនិគមនោះទៅ ជាបច្ចន្តជនបទ រួមក្នុង ជាមជ្ឈិមជនបទ,

ក្នុងទិសបស្ចិម មានស្រុកព្រាហ្មណ៍ ឈ្មោះថូនៈ, តអំពីស្រុកព្រាហ្មណ៍នោះទៅ ជាបច្ចន្តជនបទ រួមខាងក្នុង ជាមជ្ឈិមជនបទ,

ក្នុងទិសឧត្តរ មានភ្នំ ឈ្មោះឧសីរទ្ធជៈ, តអំពីភ្នំនោះទៅ ជាបច្ចន្តជនបទ រួមខាងក្នុង ជាមជ្ឈិមជនបទ ឈ្មោះថា ប្រទេសដ៏សមគួរ ។

សូម្បីក្នុងអដ្ឋកថាឯកនិបាត អង្គុត្តរនិកាយ លុះលោកសំដែងបាលីក្នុងខន្ធកៈ យ៉ាងដូច្នោះឯងហើយ ទើបបានពោល ថា "ក៏ជនបទនេះ មានទ្រង់ទ្រាយដូចជាស្គរសំភោរ ដោយត្រង់កន្លែងខ្លះ (វាស់) បាន ៨០ យោជន៍, កន្លែងខ្លះ បាន ១០០ យោជន៍, កន្លែងខ្លះ បាន ២០០ យោជន៍, តែត្រង់កណ្តាល បាន ៣០០ យោជន៍, ដោយជុំវិញ (វាស់) បាន ៩០០ យោជន៍" ។

## (មនុស្សល្អកើតក្នុងប្រទេសដ៏សមគួរ)

ព្រះពុទ្ធ, ព្រះបច្ចេកពុទ្ធ, ព្រះមហាសាវ័កទាំងឡាយ មានព្រះសារីបុត្រនិងព្រះមោគ្គល្លានជាដើម, អ្នកបម្រើព្រះពុទ្ធ, ព្រះពុទ្ធមាតា, ព្រះពុទ្ធបិតា និងស្តេចចក្រពត្តិ រមែងកើតឡើងក្នុងមជ្ឈិមប្រទេសនោះ ។

បណ្តាសប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើមនោះ សត្វទាំងឡាយ បានទទួលឱវាទ របស់ស្តេចចក្រពត្តិហើយ តាំងនៅក្នុងសីល ៥ ជាអ្នកមានស្ថានសួគ៌នៅខាងមុខ, តាំងនៅក្នុង

ឱវាទរបស់ព្រះបច្ចេកពុទ្ធ ក៏យ៉ាងដូច្នោះដែរ ។ តែកាលតាំងនៅក្នុងឱវាទ របស់ព្រះពុទ្ធ និងព្រះសាវ័ករបស់ព្រះពុទ្ធ ជាអ្នកមានព្រះនិព្វាននិងសុគតិនៅខាងមុខ ។ ព្រោះហេតុនោះ ការនៅក្នុងប្រទេសដ៏សមគួរនោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅថា "ជាមង្គល" ព្រោះជាបច្ច័យនៃសម្បត្តិទាំងឡាយនេះ ។

(៩២) ចំណែកក្នុងអដ្ឋកថាឯកនិបាត អង្គុត្តរនិកាយ លោកពោល ថា "ន័យមួយទៀត សូម្បីព្រោះការប្រៀបធៀប ក៏តែងបានមជ្ឈិមប្រទេស, មែនពិត ជម្ពូទ្វីបទាំងមូល ឈ្មោះថាមជ្ឈិមប្រទេស, ទ្វីបទាំងឡាយដែលសេសសល់ ចាត់ជាបច្ចន្តជនបទ ។ ក្នុងតម្ពបណ្ណិទ្វីប អនុរាធបុរី ឈ្មោះថាមជ្ឈិមប្រទេស, ក្រៅអំពីនោះ ជាបច្ចន្តជនបទ ដូច្នេះឯង ។ សូម្បីពាក្យនោះ ក៏ត្រឹមត្រូវដែរ ។

## ( តំណនៃខត្តិយវង្ស ក្នុងអនុរាធបុរី )

ក៏ក្នុងអនុរាធបុរី ព្រះរាជឱរសទី ២ នៃព្រះបាទមុដសីវៈ ទ្រង់ព្រះនាមថា ទេវានម្បិយតិស្សៈ ទ្រង់តាំងនៅ ក្នុងឱវាទ របស់ព្រះមហាមហិន្ទត្ថេរ ទ្រង់បានបំពេញបុណ្យជាច្រើន ទ្រង់គ្រប់គ្រងរាជសម្បត្តិបាន ៤០ ព្រះវស្សា ហើយទ្រង់សោយទិវង្គត

ទ្រង់បានកើតឡើងហើយ ក្នុងទេវលោកជាន់តាវត្តិង្ស ។

តអំពីនោះមក ព្រះរាជឱរសទី ៤ នៃព្រះបាទមុដសីវៈ ទ្រង់ព្រះនាមឧត្តិយៈ គ្រប់គ្រងរាជសម្បត្តិបាន ១០ ព្រះវស្សា ។ ព្រះរាជឱរសទី ៥ ទ្រង់ព្រះនាម មហាសីវៈ, ព្រះរាជឱរសទី ៧ ទ្រង់ព្រះនាម សូរតិស្សៈ របស់ព្រះបាទមុដសីវៈនោះឯង ក៏យ៉ាងដូច្នោះដែរ គឺគ្រងរាជសម្បត្តិបាន ១០ ព្រះវស្សាដែរ ។

ក្នុងកាលនោះ ព្រះរាជបុត្រនៃព្រះរាជាទមិឡ ២ ព្រះអង្គ គឺ ព្រះសេនៈ ១ ព្រះគុត្តៈ ១ ទ្រង់បានបណ្ដេញព្រះរាជាព្រះនាម សូរតិស្សៈ ហើយគ្រងរាជសម្បត្តិ ក្នុងអនុរាធបុរី បាន ១២ ឆ្នាំ ។

ក្នុងកាលនោះ ព្រះរាជឱរសទី ៩ នៃព្រះបាទមុដសីវៈ ទ្រង់ព្រះនាមអសេលៈ ទ្រង់បានបណ្ដេញព្រះបាទសេនៈ និងព្រះបាទគុត្តៈ ហើយ ឡើងគ្រប់គ្រងរាជសម្បត្តិ បាន ១០ ព្រះវស្សា ។

ក្នុងកាលនោះ ព្រះរាជាទមិឡ ព្រះនាមឯឡារៈ ទ្រង់បានបណ្ដេញព្រះបាទអសេលៈ ហើយគ្រងរាជសម្បត្តិ បាន ៤៤ ឆ្នាំ ។

ក្នុងកាលនោះ ព្រះរាជបុត្រនៃព្រះបាទកាកវណ្ណតិស្សៈ ជាព្រះរាជនត្តា នៃព្រះបាទទេវានម្បិយតិស្សៈ ព្រះនាម ទុដ្ឋគាមណីអភ័យ ទ្រង់បានធ្វើគត់ព្រះបាទឯឡារៈ ហើយបានជាព្រះរាជាមួយព្រះអង្គ ក្នុងអនុរាធបុរី ក្នុងលង្កាទ្វីប ។

ព្រះបាទទុដ្ឋគាមណីអភ័យអង្គនោះ ទ្រង់បានឡើងគ្រប់គ្រងរាជសម្បត្តិ ក្នុងទីបំផុតនៃឆ្នាំ ៩៦ ក្រោយពីឆ្នាំទ្រង់សោយទិវង្គតនៃព្រះបាទទេវានម្បិយតិស្សៈមក ដោយប្រការដូច្នេះឯង ។

ក្នុងកាលនោះ ទេវានម្បិយតិស្សទេវបុត្រ ឃើញថា សង្ខារទាំងឡាយ ជារបស់មិនទៀងទាត់ ទើបបានច្យុតចាកភពតាវត្តិង្ស ដោយការធ្វើកាលកិរិយា គឺការបង្អោនចិត្តទៅ ហើយបានទៅកើតក្នុងត្រកូលសេដ្ឋី ក្នុងលង្កាទ្វីប ក្នុងពេលមានអាយុបាន ៧ ឆ្នាំ ក៏បានបួសហើយ បានសម្រេចជាព្រះអរហន្ត ។

សូម្បីជនទាំងឡាយឯទៀត អ្នកនៅក្នុងលង្កាទ្វីបនោះ បានសម្រេចមគ្គផល ពណ៌នាត្រារាប់មិនបានឡើយ ដូច្នេះឯង ។

ពណ៌នាអំពីការរស់នៅក្នុងប្រទេសដ៏សមគួរ ចប់ ។

⁂

ប្រែចប់ ថ្ងៃសៅរ៍ ៤ រោច ខែមិគសិរ ព.ស.២៥៣៦
ថ្ងៃទី ១ មករា ១៩៩៤
(វេលាយប់)

## ពណ៌នាភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន

---

(៩៣) បុគ្គលអ្នកមានកុសលបានសន្សំទុកហើយ គឺមានអធិការបានធ្វើទុកហើយ ប្រារព្ធនូវព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រព ក្នុងជាតិដែលកន្លងទៅហើយ ឈ្មោះថា ជាអ្នកមានបុណ្យបានធ្វើទុកហើយ ក្នុងកាលមុន ។ មែនពិត បុគ្គលដូច្នេះ ជាអ្នកមានកុសលមូលដុះឡើងហើយ បានស្តាប់នូវទេសនារបស់ព្រះពុទ្ធ ឬព្រះសាវ័ក របស់ព្រះពុទ្ធហើយ រមែងបានសម្រេចព្រះអរហត្ត ដោយកុសលមូលនោះឯង ដូចជាព្រះបាទមហាកប្បិនៈជាដើម ។ ព្រោះហេតុនោះ ភាវៈនៃបុគ្គលដូច្នោះ ជាអ្នកមានបុណ្យបានធ្វើទុកហើយ ក្នុងកាលមុន ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា "ជាមង្គល" ។

ក្នុងដំណើរនោះ មានរឿងនេះ ( ជាឧទាហរណ៍ ) ÷

### ( រឿង ព្រះមហាកប្បិនត្ថេរ )

(៩៤) ក្នុងអតីតកាល មានជាងតម្បាញចំនួន ១ ពាន់នាក់ អាស្រ័យនៅ ក្នុងស្រុកមួយ ក្បែរទីក្រុងពារាណសី ។

ក្នុងកាលនោះ ព្រះបច្ចេកពុទ្ធទាំងឡាយ ចំនួន ១ ពាន់ រូប

អាស្រ័យនៅ ក្នុងហិមវន្តប្រទេស អស់ ៨ ខែ ហើយប្រាថ្នាចង់នៅក្នុងជនបទ ៤ ខែ ដែលជារដូវភ្លៀង ទើបចុះនៅក្បែរព្រះនគរហើយ បានបញ្ជូនព្រះបច្ចេកពុទ្ធ ៨ រូបទៅ ដើម្បីសុំនូវហត្ថកម្មយកមកកសាងសេនាសនៈ ។

ក្នុងកាលនោះ ភរិយារបស់ជាងតម្បាញជាចម្បង ដើរទៅកាន់ព្រះនគរ ដោយករណីយកិច្ចបន្តិចបន្តួច បានជួបនឹងព្រះបច្ចេកពុទ្ធទាំងនោះ ក៏សួរ ស្តាប់រឿងនោះហើយ ទើបពោល ថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន យើងខ្ញុំទាំងឡាយ មានគ្នា ១ ពាន់នាក់ នៅក្នុងស្រុកនេះ បណ្តាពួកនាងខ្ញុំទាំងឡាយ ម្នាក់ៗ នឹងប្រគេនភិក្ខាដល់ព្រះគុណម្ចាស់ ១ រូបៗ, ក្នុងថ្ងៃស្អែកនេះ សូមព្រះគុណម្ចាស់ទាំងឡាយ ទទួលនូវភិក្ខា របស់ពួកនាងខ្ញុំ, ពួកនាងខ្ញុំនឹងឲ្យគេកសាងសេនាសនៈប្រគេនព្រះគុណម្ចាស់ទាំងឡាយ" ហើយក៏បានចូលទៅកាន់ស្រុក បានប្រាប់ហើយ ដល់មនុស្សទាំងឡាយ ។

ថ្ងៃស្អែកឡើង ឯព្រះបច្ចេកពុទ្ធទាំងឡាយ ក៏បាននិមន្តចូលទៅកាន់ស្រុកនោះហើយ ។ មនុស្សទាំងឡាយ មានឆន្ទៈតែមួយ បានប្រគេនភិក្ខា ដល់ព្រះបច្ចេកពុទ្ធទាំងនោះ ហើយនាំគ្នាកសាងនូវបណ្ណសាលា ១ ពាន់ខ្នង បានប្រគេនហើយ ដល់ព្រះបច្ចេកពុទ្ធទាំងឡាយនោះ ក្នុងពេលរួចភត្តកិច្ច ។ ពួកមនុស្សទាំងនោះ

បានទំនុកបម្រុង នូវព្រះបច្ចេកពុទ្ធទាំងឡាយ ដែលចាំព្រះវស្សា ក្នុងបណ្ណសាលារបស់ខ្លួន ដោយគោរពហើយ ក៏បានប្រគេនចីវរទាំងឡាយ ដល់ព្រះបច្ចេកពុទ្ធទាំងនោះ ដែលបានចាំវស្សាហើយ ។ ព្រះបច្ចេកពុទ្ធទាំងឡាយ អនុមោទនាហើយ ទើបចៀសចេញទៅ ។

ជាងតម្បាញទាំងនោះ ច្យុតចាកអត្តភាពនោះហើយ កើតមានឈ្មោះថាគណៈទេវបុត្រ ក្នុងភពតាវត្តិង្ស សោយទិព្វសម្បត្តិក្នុងភពតាវត្តិង្សនោះហើយ បានច្យុតចាកភពនោះ មកកើតក្នុងត្រកូលកុដុម្ពី ក្នុងទីក្រុងពារាណសី ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈ ។ បណ្តាជាងតម្បាញទាំងនោះ ជាងតម្បាញដែលជាចម្បង បានជាកូនរបស់កុដុម្ពីដែលជាចម្បង ។ ចំណែកភរិយារបស់គាត់ ក៏បានជាធីតារបស់កុដុម្ពីដែលជាចម្បងដូចគ្នា ។ ជាងតម្បាញដទៃទៀតក្រៅពីនោះ បានជាបុត្រធីតា របស់កុដុម្ពីដទៃក្រៅពីនោះ ។ ជនទាំងអស់នោះឯង ចំរើនវ័យហើយ បានជាភរិយាស្វាមីដល់គ្នានឹងគ្នា រួបរួមទ្រព្យបានហើយ ទើបឲ្យគេធ្វើបរិវេណប្រដាប់ដោយបន្ទប់ ១ ពាន់ កាលធ្វើការឆ្លងបរិវេណ បានប្រគេនមហាទាន អស់មួយសប្តាហ៍ ដល់ភិក្ខុ ២ ហ្មឺនអង្គ មានព្រះពុទ្ធជាប្រធាន ក្នុងថ្ងៃបញ្ចប់ ក៏បានប្រគេនហើយនូវចីវរ ។

ចំណែកភរិយា របស់កុដុម្ពីដែលជាចម្បង ប្រាថ្នានឹងធ្វើឲ្យ

ឱទ្បារិក ទើបបានបូជាព្រះសាស្តា ដោយសំពត់សាដក មានពណ៌ដូចជាផ្កាននោង មានតម្លៃ ១ ពាន់ និងដោយផ្កានោងទាំងឡាយ ហើយប្រាថ្នា ថា "បពិត្រព្រះអង្គដ៏ចំរើន សូមឱ្យនាងខ្ញុំ មានឈ្មោះថា អនោជា មានសរីរៈ មានពណ៌ដូចជាផ្កានោង ក្នុងទីស្ថានដែលនាងខ្ញុំបានកើតហើយ ៗ" ។

ព្រះសាស្តា ទ្រង់បានអនុមោទនា ថា "ចូរសេចក្តីប្រាថ្នារបស់នាង បានសម្រេច យ៉ាងដូច្នោះចុះ" ។ ជនទាំងអស់នោះឯង អន្ទោលទៅមក ក្នុងទេវតានិងមនុស្សលោក អស់មួយពុទ្ធន្តរហើយ ក៏ច្យុតចាកទេវលោក មុនពេលព្រះសាស្តា របស់យើង ស្តេចកើតឡើងហើយតែម្តង ។ បណ្តាជនទាំងនោះ កុដុម្ពីដែលជាចម្បង បានកើត ក្នុងត្រកូលនៃព្រះរាជា ក្នុងកុក្កុដវតីនគរ បានជាព្រះរាជាទ្រង់ព្រះនាម មហាកប្បិនៈ ។ ចំណែកបុរសទាំងឡាយក្រៅពីនោះ ក៏បានកើតហើយ ក្នុងត្រកូលនៃអមាត្យ ក្នុងនគរឈ្មោះកុក្កុដវតីនោះ ដូចគ្នាដែរ ។ ឯភរិយារបស់កុដុម្ពីដែលជាចម្បង កើតជាធីតារបស់ព្រះរាជា ក្នុងសាគលនគរ ក្នុងមទ្ទរដ្ឋ ទ្រង់មានព្រះនាមថា អនោជា ព្រោះមានព្រះសរីរៈ មានពណ៌ដូចជាផ្កានោង ។ ឯស្ត្រីទាំងឡាយ ក្រៅពីនោះ ក៏បានជាធីតារបស់អមាត្យ ក្នុងសាគលនគរនោះ ដូចគ្នាដែរ ។ ជនទាំងអស់នោះ

ចំរើនវ័យហើយ ក៏បានជាភរិយាស្វាមី ដល់គ្នានឹងគ្នាហើយ ។ កាលបើជនទាំងនោះ នៅរួមសាមគ្គីគ្នា យ៉ាងដូច្នេះ, ព្រះសាស្ដា របស់យើង ទ្រង់បានស្ដេចកើតឡើងហើយ ក្នុងលោក ទ្រង់គង់នៅក្នុងទីក្រុងសាវត្ថី ។

ក្រោយមក ថ្ងៃមួយ ព្រះរាជាព្រះនាមមហាកប្បិនៈ ទ្រង់ព្រះសណ្ដាប់ (ពត៌មាន) ចាកសំណាក់ពួកពាណិជ ដែលធ្វើដំណើរមកអំពីទីក្រុងសាវត្ថី ថា "ព្រះពុទ្ធ ទ្រង់កើតឡើងហើយ, ព្រះធម៌ បានកើតឡើងហើយ, ព្រះសង្ឃ បានកើតឡើងហើយ" ដូច្នេះ ទ្រង់កើតបីតិនិងសោមនស្សហើយ ទ្រង់បានបូជានូវពាក្យ របស់ពាណិជទាំងនោះ ដោយទ្រព្យ ៣ សែន ហើយទ្រង់ត្រាស់ ថា "ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយ ចូរទៅកាន់សំណាក់នៃព្រះនាងទេវីហើយ ទទួលយកទ្រព្យ ៣ សែនចុះ" ដូច្នេះហើយ ទើបទ្រង់ស្ដេចយាងចេញទៅ ដោយយានដែលទឹមដោយសេះ ឧទ្ទិសចំពោះព្រះសាស្ដា មួយអន្លើដោយអមាត្យ ១ ពាន់នាក់ ។

ក្នុងថ្ងៃនោះ ចំណែកព្រះសាស្ដា ទ្រង់ត្រួតមើលសត្វលោក ក្នុងវេលាទៀបភ្លឺ ទ្រង់ទតព្រះនេត្រឃើញហើយ នូវឧបនិស្ស័យនៃព្រះអរហត្ត របស់រាជាព្រមទាំងបរិវារ កាលទ្រង់ស្ដេចយាងទៅទទួលព្រះបាទមហាកប្បិនៈនោះ ទ្រង់បានយកបាត្រ និងចីពរ

ដោយព្រះអង្គឯងហើយ ស្តេចយាងទៅចាកទីក្រុងសាវត្ថី ១២០ យោជន៍ ទ្រង់គង់ បញ្ចេញព្រះឆព្វណ្ណរង្សី ក្រោមគល់និគ្រោធ ក្បែរមាត់ស្ទឹងចន្ទភាគា ។

ក៏ត្រង់ផ្លូវដែលព្រះរាជាស្តេចយាងទៅ មានស្ទឹង ៣ គឺ ស្ទឹងទី ១ ឈ្មោះគង្គា, ទី ២ ឈ្មោះនីលពាហា ជាស្ទឹងដ៏ធំមួយ មានបណ្តោយកន្លះយោជន៍, ទី ៣ ឈ្មោះ ចន្ទភាគា ។

ព្រះរាជាព្រមទាំងបរិវារ ទ្រង់ស្តេចយាងទៅដល់មាត់ស្ទឹង ទាំង ៣ នោះ ដោយលំដាប់ហើយ ទ្រង់ត្រាស់ ថា "ធម្មតាព្រះ គុណរបស់ព្រះសាស្តាអង្គនោះ បានផ្សាយទៅ ឰដ៏ខាងក្រោម តាំង អំពីអវីចិនរក ខាងលើ រហូតទល់គ្នានឹងភវគ្គព្រហ្ម, បើព្រះ សាស្តាអង្គនេះ ជាព្រះសម្មាសម្ពុទ្ធមែននោះ, សូមអានទាំងឡាយ (កែប) នៃសេះទាំងឡាយនេះ កុំទទឹកឡើយ" ដូច្នេះហើយ ទ្រង់ធ្វើ នូវសច្ចកិរិយាហើយ ទ្រង់បានបរសេះទៅ តាមខ្នងទឹក ។ ត្រឹមតែអាន នៃសេះមួយ ក៏មិនទទឹកឡើយ ។ ព្រះរាជាអង្គ នោះ ព្រមទាំងបរិវារ ទ្រង់បានឆ្លងនូវស្ទឹងទី ៣ ដោយអាការៈ ដូច្នោះឯង ទ្រង់ទតព្រះនេត្រឃើញនូវព្រះឆព្វណ្ណរង្សីហើយ ទ្រង់ ស្តេចចុះអំពីខ្នងសេះ ទ្រង់បានឱនព្រះកាយហើយ ទើបស្តេចយាង ទៅកាន់សំណាក់ នៃព្រះសាស្តា ទ្រង់ថ្វាយបង្គំហើយ ទ្រង់គង់

ព្រះសណ្ដាប់នូវអនុបុព្វីកថាហើយ ទ្រង់បានសម្រេចព្រះសោតាបន្ន ទ្រង់បានផ្នួស ដោយភាពជាឯហិភិក្ខុ ទ្រង់ប្រៀបបាននឹងព្រះថេរៈ ដែលមានវស្សា ១០០ ជាអ្នកទ្រទ្រង់នូវបរិក្ខារ ៨ ។

ចំណែកព្រះនាងអនោជាទេវី ទ្រង់ព្រះសណ្ដាប់នូវការកើតឡើងនៃព្រះពុទ្ធជាដើមហើយ ទ្រង់បានបូជានូវពាក្យរបស់ពាណិជទាំងឡាយ ដោយទ្រព្យ ៩ សែន ទ្រង់បញ្ជូនពួកពាណិជទាំងនោះទៅ ដោយព្រះតម្រាស់ ថា "ម្នាលអ្នកទាំងឡាយ ចូរអ្នកទាំងឡាយអញ្ជើញទៅចុះ" ដូច្នេះហើយ មានពួកភរិយា របស់ពួកអមាត្យដែលទៅហើយ ជាមួយនឹងព្រះរាជា ចោមរោមហើយ ស្ដេចយាងចេញទៅ ដោយយានគឺរថ ឧទ្ទិសចំពោះព្រះសាស្ដា ទ្រង់បានឆ្លងហើយ នូវស្ទឹងទាំងឡាយនោះ ដោយន័យមុននុ៎ះឯង ។

ព្រះសាស្ដា ទ្រង់ព្រះតម្រិះ ថា "កាលបើស្ត្រីទាំងឡាយនេះឃើញពួកស្វាមី របស់ខ្លួន, ឆន្ទរាគៈ ក៏គប្បីកើតឡើងហើយធ្វើនូវសេចក្ដីអន្តរាយដល់មគ្គ, ឆន្ទរាគៈនោះ នឹងមិនអាចដើម្បីធ្វើ យ៉ាងដូច្នេះបានឡើយ" ហើយ ទ្រង់បានធ្វើហើយ ដោយប្រការដែលជនទាំងឡាយនោះ នឹងមើលគ្នានឹងគ្នាមិនឃើញ ។

ស្ត្រីទាំងអស់នោះ បានឆ្លងស្ទឹងទី ៣ ហើយទៅកាន់សំណាក់នៃព្រះសាស្ដា ថ្វាយបង្គំហើយ អង្គុយស្ដាប់នូវអនុបុព្វីកថា ហើយ

ក៏បានសម្រេចជាព្រះសោតាបន្ន ។ ភិក្ខុទាំងឡាយនោះ កាល ស្ដាប់នូវព្រះធម៌ ដែលព្រះសាស្ដាទ្រង់សំដែងហើយ ដល់ស្ត្រីទាំង ឡាយនោះ ក៏បានសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំង ឡាយ ។ ព្រះសាស្ដា ទ្រង់បានរម្ងាប់នូវឫទ្ធាភិសង្ខារហើយ ។

លំដាប់នោះ ស្ត្រីទាំងឡាយនោះ បានឃើញស្វាមីរបស់ខ្លួន ទាំងនោះ បួសហើយ ទើបបានក្រាបទូលសុំបព្វជ្ជានឹងព្រះសាស្ដា ។

ព្រះសាស្ដា ទ្រង់ព្រះតម្រិះ ថា " នាងឧប្បលវណ្ណាភិក្ខុនី ចូរមក " ។ ព្រះថេរី និមន្តមកហើយ បានញ៉ាំងឲ្យស្ត្រីទាំងនោះ បួសហើយ បាននាំទៅកាន់សំណាក់នៃនាងភិក្ខុនី ក្នុងក្រុងសាវត្ថី ។ នាងភិក្ខុនីទាំងអស់នោះ បានសម្រេចហើយ នូវព្រះអរហត្ត ។

ចំណែកព្រះសាស្ដា ទ្រង់បាននាំភិក្ខុ ១ ពាន់អង្គ ទៅកាន់ វត្តព្រះជេតពន តាមអាកាសហើយ ។

រឿង ព្រះមហាកប្បិនត្ថេរ មកក្នុងអដ្ឋកថាទាំងឡាយ មានអដ្ឋកថា- ឯកនិបាត អង្គុត្តរនិកាយជាដើម ។

## ( សិរីតែងស្ថិតនៅនឹងអ្នកមានបុណ្យ )

(៩៥) ម្យ៉ាងទៀត ព្រោះបុគ្គលអ្នកមានបុណ្យដែលមិន បានធ្វើទុកហើយ សូម្បីបាននូវវត្ថុ ដែលដល់ព្រមដោយអានុភាព

ក៏រមែងជួបប្រទះនូវសេចក្ដីទុក្ខ, បុគ្គលអ្នកមានបុណ្យបានធ្វើទុកហើយ (កាលបានវត្ថុយ៉ាងដូច្នោះ) រមែងបានទទួលនូវសេចក្ដីសុខ, មួយទៀត ព្រោះបុគ្គលអ្នកមានបុណ្យមិនបានធ្វើទុកហើយ រមែងមិនអាច ដើម្បីនឹងទទួលយកនូវសិរី សួម្បីដែលបុគ្គលដទៃឲ្យហើយបានឡើយ, សិរីនោះរមែងចូលដល់បុគ្គលអ្នកមានបុណ្យតែប៉ុណ្ណោះ ព្រោះហេតុដូច្នោះឯង ភាពនៃបុគ្គលអ្នកមានបុណ្យបានធ្វើទុកហើយក្នុងកាលមុន បុគ្គលគប្បីឃើញ ថា "ជាមង្គល" ។

ក្នុងដំណើរនោះ មានរឿងទាំងនេះ (ជាឧទាហរណ៍) ÷

## (រឿង បុរសអ្នកមានវាសនា)

(៩៦) ក្នុងអតីតកាល ព្រាហ្មណ៍ដែលជាបងប្អូនគ្នា ៤ នាក់ ក្នុងទីក្រុងពារាណសី បួសជាតាបសឥសី ធ្វើបណ្ណសាលាតាមលំដាប់គ្នាហើយ នៅក្នុងហិមវន្តប្រទេស ។

បណ្ដាតាបសទាំងនោះ តាបសដែលជាចម្បង ធ្វើកាលៈហើយ ក៏បានទៅកើតជាស្ដេចសក្កទេវរាជ ។ ស្ដេចសក្កទេវរាជនោះ ជ្រាបហេតុនោះហើយ ថ្ងៃមួយ ក៏បានចូលទៅរកតាបសដែលជាប្រធាន ថ្វាយបង្គំហើយសួរ ថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន

តើព្រះគុណម្ចាស់ មានសេចក្តីត្រូវការ ដោយវត្ថុអ្វីខ្លះ ? ” ។

ឯតាបសនោះ ជាអ្នកមានរោគលឿង ព្រោះហេតុនោះ ទើបបានពោល ថា “ អាត្មាភាព មានសេចក្តីត្រូវការ ដោយភ្លើង ” ។

ស្តេចសក្កទេវរាជ ទ្រង់ត្រាស់ ថា “ បពិតព្រះគុណម្ចាស់ដ៏ចំរើន បើព្រះគុណម្ចាស់ត្រូវការភ្លើង, សូមព្រះគុណម្ចាស់ គប្បីយកដៃគោះនូវកាំបិតព្រានេះ ហើយពោល ថា ‘ ចូរអ្នកទៅរកឧសមកហើយ បង្កាត់ភ្លើង ’ ដូច្នេះ, កាំបិតព្រានេះ ក៏នឹងធ្វើតាមយ៉ាងដូច្នោះ ” ដូច្នេះហើយ ទើបទ្រង់បានប្រទាន នូវកាំបិតព្រាដល់តាបសនោះហើយ ។ កាំបិតក្តី ប៉ូវថៅក្តី ឈ្មោះថាវាសីផរសុកៈ ដោយអំណាចញាត់បញ្ចូលទៅក្នុងដងបាន ។

ស្តេចសក្កទេវរាជ ទ្រង់ស្តេចយាងទៅរកតាបសទី ២ ហើយទ្រង់បានត្រាស់សួរ យ៉ាងដូច្នោះដែរ ។ ផ្លូវនៃដំរី មាននៅក្បែរបណ្ណសាលា របស់តាបសនោះ ។ តាបសនោះ ត្រូវដំរីទាំងឡាយបៀតបៀនហើយ ទើបពោល ថា “ សេចក្តីទុក្ខ រមែងកើតឡើងដល់អាត្មាភាព ដោយអំណាច នៃដំរីទាំងឡាយ, សូមព្រះអង្គញុំាងដំរីទាំងនោះ ឲ្យចៀសចេញទៅ ” ។

ស្តេចសក្កទេវរាជ ទ្រង់ត្រាស់ ថា “ បពិត្រព្រះគុណម្ចាស់ដ៏ចំរើន កាលបើព្រះគុណម្ចាស់ទះផ្ទៃនៃស្គរនេះ, ពួកបច្ចាមិត្រ

របស់ព្រះគុណម្ចាស់ ក៏នឹងរត់ចេញទៅ, កាលបើព្រះគុណម្ចាស់ទះផ្ទៃនៃស្គរនេះហើយ, សេនា ដែលមានអង្គ ៤ ក៏នឹងមានចិត្តប្រកបដោយមេត្តាហើយ មកចោមរោម" ដូច្នេះហើយ ទើបទ្រង់បានប្រទាននូវស្គរមួយ ដល់តាបសនោះ ស្រេចហើយទ្រង់ស្ដេចយាងទៅរកតាបសទី ៣ ទៀត ទ្រង់ត្រាស់សួរហើយ ដូច្នោះដែរ ។

តាបសនោះ មានរោគល្មើង ព្រោះហេតុនោះ ទើបពោលថា "អាត្មាភព មានសេចក្ដីត្រូវការ ដោយទឹកដោះជូរ" ។

ស្ដេចសក្កទេវរាជ ទ្រង់បានប្រទាន នូវក្រឡនៃទឹកដោះជូរមួយ ដល់តាបសនោះហើយ ទ្រង់ត្រាស់ ថា "បើព្រះគុណម្ចាស់ប្រាថ្នា សូមផ្កាប់ក្រឡនៃទឹកដោះជូរនេះ, ទឹកដោះជូរនេះ ក៏នឹងក្លាយទៅជាស្ទឹងដ៏ធំ ញ៉ាំងអន្លង់ដ៏ធំ ឲ្យហូរទៅបាន ហើយអាចដណ្ដើមយកនូវរាជសម្បត្តិ មកប្រគេន ដល់ព្រះគុណម្ចាស់បាន" ដូច្នេះហើយ ទើបស្ដេចយាងចេញទៅ ។

ចាប់ដើមអំពីពេលនោះមក កាំបិតព្រា ក៏បង្កាត់ភ្លើង ដល់តាបសដែលជាប្រធាន ។ កាលបើតាបសទី ២ ទះផ្ទៃនៃស្គរហើយ, ដំរីទាំងឡាយ ក៏បោលរត់ទៅ ។ តាបសទី ៣ ក៏ឆាន់នូវទឹកដោះជូរ ។

ក្នុងកាលនោះ ជ្រូកមួយ កាលបោលទៅ ក្នុងទីស្ថាននៃស្រុក

ចាស់ ក៏ឃើញដុំនៃកែវមណី ដែលដល់ព្រមដោយអានុភាព ទើបពាំដោយមាត់ហើយ ហោះទៅកាន់អាកាស ដោយអានុភាព នៃកែវមណីនោះ ឃើញកោះមួយ ត្រង់កណ្តាលសមុទ្រ ក៏ចុះមកហើយដេកនៅក្រោមដើមឧទុម្ពរមួយដើម ។ ថ្ងៃមួយ ជ្រូកនោះបានដាក់ដុំកែវមណីទុក ខាងមុខ ហើយក៏ដេកលក់ក្បែរគល់ឈើ ។

គ្រានោះ បុរសអ្នកនៅក្នុងដែនកាសីម្នាក់ ត្រូវម្តាយឪពុកបណ្តេញចេញពីផ្ទះ ជាកម្មកររបស់អ្នកនាវាទាំងឡាយ ឡើងទូកហើយ, កាលបើទូកបែកធ្លាយហើយ ត្រង់កណ្តាលសមុទ្រ, ក៏ដេកបណ្តែតលើបន្ទះក្តារ បានទៅដល់កោះនោះ កាលស្វះស្វែងរកផលាផល ទើបឃើញជ្រូកនោះ កំពុងតែដេកលក់ ហើយក៏ដើរទៅលបៗ យកដុំកែវមណី ហោះទៅកាន់អាកាស ដោយអានុភាពនៃកែវមណីនោះ អង្គុយលើមែកឧទុម្ពរហើយ គិត ថា "ជ្រូកនេះដូចជាហោះទៅលើអាកាស ដោយអានុភាពនៃកែវមណីនេះ ទើបបាននៅក្នុងទីនេះ, ការដែលអញសម្លាប់ជ្រូកនេះ ស៊ីសាច់ហើយចាំធ្វើដំណើរទៅ ទើបគួរ" ដូច្នេះហើយ ក៏បានកាច់មែកឈើមួយមែក ទម្លាក់លើក្បាលជ្រូកនោះ ។

ជ្រូកភ្ញាក់ឡើង កាលមិនឃើញកែវមណី ក៏ បោលចលាចល់ទៅខាងនេះផង ខាងនោះផង ។ បុរសនោះ បានសើចហើយ ។

ជ្រូកអើតមើលខាងលើ ឃើញបុរសនោះ ក៏យកក្បាលជល់នឹងដើមឈើនោះ ហើយស្លាប់ក្នុងទីនោះភ្លាម ។

បុរសនោះ ចុះមក បង្កាត់ភ្លើង អាំងសាច់ជ្រូកនោះស៊ីហើយ ហោះទៅកាន់អាកាស កាលទៅតាមទីបំផុតនៃប្រទេសហេមពាន្ត ឃើញអាស្រមបទ ក៏នៅក្នុងអាស្រមបទ នៃតាបសជាចម្បង ២-៣ ថ្ងៃ បានឃើញអានុភាពនៃកាំបិតព្រា ទើបសំដែងអានុភាព នៃកែវមណីរបស់ខ្លួន ហើយពោល ថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន សូមព្រះគុណម្ចាស់យកកែវមណីនេះ ហើយឲ្យកាំបិតព្រា ដល់ខ្ញុំចុះ" ។

តាឥសី ប្រាថ្នានឹងហោះទៅលើអាកាស ទើបទទួលយកកែវមណីហើយ បានឲ្យកាំបិតព្រាមួយនេះ ដល់បុរសនោះហើយ ។ បុរសនោះ ទទួលយកកាំបិតព្រាហើយ ដើរទៅបានបន្តិច ក៏គោះនូវកាំបិតព្រា ហើយពោល ថា "ចូរអ្នកកាត់ក្បាលតាបសនេះហើយនាំយកកែវមណីមក" ។ កាំបិតព្រា បានធ្វើហើយ យ៉ាងដូច្នោះ ។ បុរសនោះ បានលាក់កាំបិតព្រា ក្នុងទីកំបាំង ហើយចូលទៅរកតាបសទី ២ នៅបាន ពីរ -បី ថ្ងៃ ក៏ឃើញអានុភាពនៃស្គរ ទើបឲ្យកែវមណីហើយ ទទួលយកស្គរ បានបញ្ជាឲ្យកាំបិតព្រាទៅកាត់ក្បាលតាបសទី ២ នោះ ដោយន័យមុននុ៎ះឯង ហើយចូលទៅរក

តាបសទី ៣ ឃើញអានុភាពក្រឡនៃទឹកដោះជូរហើយ ទើបបានឲ្យកែវមណីហើយ ទទួលយកក្រឡនៃទឹកដោះជូរ បានបញ្ជាឲ្យកាំបិតព្រាទៅកាត់ក្បាលតាបសទី ៣ នោះ យ៉ាងដូច្នោះដែរ ហើយនាំយករបស់ទាំងពួង ហោះទៅកាន់អាកាស ចុះក្នុងទីមិនឆ្ងាយ អំពីទីក្រុងពារាណសី ហើយបានបញ្ជូនសំបុត្រ ក្នុងដៃនៃបុរសម្នាក់ទៅថ្វាយព្រះបាទក្រុងពារាណសី ថា "ព្រះរាជាក្រុងពារាណសីនឹងឲ្យនូវការធ្វើសង្គ្រាម ឬក៏ឲ្យនូវរាជសម្បត្តិ ដល់យើង" ។

ព្រះរាជា ទ្រង់ព្រះសណ្ដាប់ពត៌មានហើយ ទ្រង់ស្ដេចយាងចេញមក ដោយតាំងព្រះទ័យ ថា "អញនឹងចាប់នូវចោរ" ។ បុរសនោះ បានវាយស្គរហើយ ។ សេនាប្រកបដោយអង្គ ៤ បានចោមរោម បុរសនោះហើយ ។ បុរសនោះ ដឹងថា ព្រះរាជាទ្រង់បានលើកពលមក ទើបបានចាក់ក្រឡនៃទឹកដោះជូរហើយ ។ ស្ទឹងដ៏ធំ បានហូរទៅហើយ ។ មហាជន បានលង់ក្នុងទឹកដោះជូរហើយ មិនអាចដើម្បីនឹងឆ្លងបានឡើយ ។ បុរសនោះ បានគោះកាំបិតព្រា ហើយពោល ថា "ចូរអ្នកនាំយកព្រះសិរសីរបស់ព្រះរាជាមកចុះ" ។ កាំបិតព្រានោះ បានទៅនាំយកព្រះសិរសី មកដាក់ក្បែរជើងហើយ ។ ទាហានម្នាក់ៗ មិនអាចដើម្បីនឹងលើកអាវុធបានឡើយ ។ បុរសនោះ ត្រូវពួកពល

ដ៏ច្រើន ចោមរោមហើយ ចូលទៅកាន់នគរ បានឲ្យគេធ្វើការអភិសេកហើយ ក៏បានឡើងជាព្រះរាជា ព្រះនាមទធិវាហនៈ ។

រឿង ជ្រូកបានកែវមណី មកក្នុងទធិវាហនជាតក ក្នុងទុកនិបាត ។

## ( រឿង ព្រាហ្មណ៍លួចសិរី )

(៩៧) បានឮមកថា ព្រាហ្មណ៍អ្នកដឹងនូវលក្ខណៈសិរីម្នាក់ អាស្រ័យនៅ ក្នុងក្រុងសាវត្ថី ។ ថ្ងៃមួយ ព្រាហ្មណ៍នោះគិតថា "អនាថបិណ្ឌិកសេដ្ឋីនេះ ជាអ្នកក្រីក្រលំបាកហើយ ត្រឡប់ជាឥស្សរៈម្តងវិញទៀត, ធ្វើដូចម្តេចហ្ន៎ អាត្មាអញ នឹងគប្បីលួចនូវសិរី របស់សេដ្ឋីនោះ យកមកបាន" ដូច្នេះហើយ ក៏បានទៅផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋី ។

ក៏សេដ្ឋី មានមាន់សសុទ្ធ ប្រៀបបាននឹងស័ង្ខ ដែលគេខាត់ហើយ ក្រុងទុកក្នុងទ្រុងមាស, សិរីតាំងនៅលើសិរមាន់នោះ ។

ព្រាហ្មណ៍ បានទៅក្នុងផ្ទះនៃសេដ្ឋីនោះ ត្រូវសេដ្ឋីធ្វើសក្ការៈនិងការរាប់អានហើយ សួរថា "តើអ្នកមក ដើម្បីប្រយោជន៍អ្វី ?" ដូច្នេះ កាលគ្រួតមើលថា "តើសិរី ស្ថិតនៅ ក្នុងទីណាហ្ន៎ ?" ទើបដឹង ថា "នៅលើសិរមាន់" ហើយពោល ថា "បពិត្រលោកសេដ្ឋី ខ្ញុំនឹងប្រាប់នូវមន្ត នឹងមាណព ៥០០ នាក់, មាណពទាំង

៥០០ នាក់នោះ និងយើងខ្ញុំ អាស្រ័យមាន់ដែលរងាវមិនត្រូវកាល រមែងលំបាក, បានឮមកថា មាន់មួយនេះ រងាវត្រូវពេលវេលា, ខ្ញុំមកហើយ ដើម្បីត្រូវការមាន់នេះ, សូមលោកសេដ្ឋី ឲ្យនូវមាន់នោះ ដល់ខ្ញុំផង ” ។

សេដ្ឋីនោះ ពោល ថា “ ម្នាលព្រាហ្មណ៍ ចូរអ្នកចាប់យកចុះ, ខ្ញុំឲ្យនូវមាន់ ដល់អ្នក ” ។ ក៏ក្នុងពេលដែលលោកសេដ្ឋីពោល ថា “ ខ្ញុំនឹងឲ្យ ” ដូច្នេះឯង សិរី ក៏បានរត់ចេញបាត់អំពីសិរមាន់នោះ ហើយទៅស្ថិតនៅ លើកែវមណី ដែលលោកសេដ្ឋីតាំងទុក ឮដ៏ក្បាលដំណេក ។ ព្រាហ្មណ៍ ដឹងរឿងនោះហើយ ទើបបានសុំនូវកែវមណីទៀត ។ ក្នុងពេលដែលលោកសេដ្ឋីពោល ថា “ ខ្ញុំនឹងឲ្យនូវកែវមណី ” ប៉ុណ្ណោះឯង សិរី ក៏បានរត់ចេញបាត់អំពីកែវមណី ហើយទៅស្ថិតនៅលើចុងឈើច្រត់ ដែលលោកសេដ្ឋីបានតាំងទុក លើក្បាលដំណេក ។ ព្រាហ្មណ៍ ដឹងរឿងនោះហើយ ទើបបានសុំនូវឈើច្រត់នោះទៀត ។ ក្នុងពេលដែលលោកសេដ្ឋីពោល ថា “ ខ្ញុំនឹងឲ្យ ” នុ៎ះឯង សិរី ក៏បានរត់ចេញបាត់អំពីឈើច្រត់នោះ ហើយទៅស្ថិតនៅ លើសិរសី នៃអគ្គមហេសីរបស់សេដ្ឋី ឈ្មោះនាងបុញ្ញលក្ខណាទេវី ។

ព្រាហ្មណ៍ ដឹងរឿងនោះហើយ ទើបគិត ថា “ ភ័ណ្ឌៈនោះ

គឺភរិយារបស់លោកសេដ្ឋី មិនព្រមលះបង់, អញមិនអាចដើម្បីនឹងសូម (នូវភ័ណ្ឌៈនុ៎ះ) បានឡើយ” ដូច្នេះហើយ ក៏បានប្រាប់តាមសេចក្តីពិត ដល់សេដ្ឋី ហើយពោល ថា “ខ្ញុំមិនអាចដើម្បីនឹងលួចនូវសិរី របស់លោកសេដ្ឋីបានឡើយ, របស់ដែលមាននៅ នៃលោកសេដ្ឋី ចូរជារបស់ នៃលោកសេដ្ឋីដដែលចុះ” ដូច្នេះហើយ ក៏បានចៀសចេញទៅហើយ ។

ភាពជាឥស្សរៈ ដែលព្រះដ៏មានព្រះភាគ ទ្រង់បានត្រាស់សំដៅយកហើយ ក្នុងទេវតាសំយុត្ត ថា “**សិរីសួស្តី ជាលំនៅនៃភោគៈទាំងឡាយ**” ដូច្នេះ ឈ្មោះថា **សិរី** ។

ក្នុងអដ្ឋកថាទេវតាសំយុត្តនោះ លោកពោល ថា “ភាពជាឥស្សរៈ ឈ្មោះថា **សិរី** ។ បទ ថា ‘**អាសយោ**’ បានដល់ជាទីសម្រាប់នៅ ។ មែនពិត កាលបើភាពជាឥស្សរៈ មាននៅចំពោះមុខ, ភោគៈទាំងឡាយ រមែងមកតាមផ្លូវគោកខ្លះ តាមផ្លូវទឹកខ្លះ តែម្តង ។ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់បានត្រាស់ព្រះតម្រាស់នោះហើយ” ។

ព្រោះហេតុនោះ សិរីនោះ រមែងសម្រេចបាន ដោយអានុភាពនៃបុណ្យ ។ សិរីនោះឯង ដោយសេចក្តី គឺ ការដល់ព្រមនៃបុណ្យ កម្លាំងនៃបុណ្យនុ៎ះឯង, ព្រោះហេតុនោះ

បុគ្គលអ្នកមានបុណ្យតិច ក៏មិនអាចដើម្បីនឹងទទួលយក នូវសិរីសួម្បីដែលពួកជនដទៃឲ្យហើយ បានឡើយ ដោយប្រការដូច្នេះ ។

រឿង ចោរលួចសិរី ចប់ ។

(៩៨) ក៏កាលបើព្រាហ្មណ៍នោះ ចៀសចេញទៅហើយ, សេដ្ឋីបានទៅកាន់វត្តជេតពនហើយ ក្រាបទូលរឿងរ៉ាវទាំងអស់ដល់ព្រះសាស្តា ។

ព្រះសាស្តា ទ្រង់ត្រាស់ ថា "ម្នាលគហបតី សិរីរបស់ពួកជនដទៃ រមែងទៅក្នុងទីដទៃ ក្នុងពេលឥឡូវនេះ តែប៉ុណ្ណោះ ក៏ទេ, សូម្បីក្នុងពេលមុន សិរី ដែលពួកជនអ្នកមានបុណ្យតិច បានធ្វើឲ្យកើតឡើងហើយ ក៏បានទៅដល់ហើយក្បែរជើង របស់ពួកជនអ្នកមានបុណ្យប៉ុណ្ណោះ" ដូច្នេះហើយ ត្រូវលោកសេដ្ឋីក្រាបទូលសុំហើយ ទើបទ្រង់បាននាំនូវអតីតនិទានមក (សំដែង) ថា ÷

## ( រឿង បុរសអ្នករកឧស )

ក្នុងអតីតកាល មានបុរសអ្នករកឧសម្នាក់ ក្នុងទីក្រុងពារាណសី ។ ថ្ងៃមួយ បុរសនោះ ដឹកឧសចេញមកអំពីព្រៃមិនអាច (ទៅទាន់) ទ្វារនគរ ក្នុងវេលាបាន ក៏បានដេក ក្នុងខ្ទមនៃទេវតាមួយ ក្នុងវេលាល្ងាច ។

មាន់ជាច្រើន ដែលគេលែងចោល ក្នុងខ្ទមទេវតា ដេកនៅលើដើមឈើមួយដើម ក្នុងទីមិនឆ្ងាយអំពីខ្ទមទេវតានោះ ។ ក្នុងចំណោមហ្វូងមាន់ទាំងនោះ មាន់ដែលដេកនៅខាងលើមួយ បានជុះអាចម៍ដាក់ លើខ្លួនមាន់ដែលដេកនៅខាងក្រោម ក្នុងពេលជិតភ្លឺ, កាលបើមាន់ខាងក្រោម ស្រែក ថា "អ្នកណា ជុះអាចម៍ដាក់ខ្លួនរបស់ខ្ញុំ ?" ដូច្នេះ, ទើបស្រែក ថា "ខ្ញុំមិនបានពិចារណា ទើបបានជាជុះដាក់" ហើយ ក៏បានជុះដាក់មក ម្តងទៀត ។

បន្ទាប់មក មាន់ទាំង ២ នោះ ក៏បានធ្វើការឈ្លោះប្រកែកគ្នា ថា "អ្វីជាកម្លាំង របស់អ្នក ?, អ្វីជាកម្លាំង របស់អ្នក ?" ។ គ្រានោះ មាន់ដែលនៅខាងក្រោម អួតអាង ថា "អ្នកណា សម្លាប់ខ្ញុំហើយ អាំងលើរងើកភ្លើង ស៊ីសាច់ដែលឆ្អិនហើយ នឹងបានទ្រព្យ ១ ពាន់កហាបណៈ តាំងអំពីព្រឹកព្រលឹម" ។

ចំណែកមាន់ដែលនៅខាងលើ បានអួតអាង ថា "នែអ្នកដ៏ចំរើន ! អ្នកគម្រាម ដោយពាក្យមានប្រមាណប៉ុណ្ណេះ, ក៏អ្នកដែលស៊ីសាច់ដុំ របស់ខ្ញុំ នឹងបានជាព្រះរាជា, អ្នកដែលស៊ីសាច់ខាងក្រៅ បើបុរស ក៏នឹងបានតំណែងសេនាបតី, បើជាស្ត្រីវិញ ក៏នឹងបានតំណែងជាអគ្គមហេសី, ចំណែកអ្នកដែលស៊ីសាច់ជាប់ឆ្អឹង បើជាគ្រហស្ថ នឹងបានតំណែងជាអ្នកថែរក្សា

ឃ្លាំង, បើបព្វជិតវិញ ក៏នឹងបានជាអ្នកចូលកាន់រាជត្រកូល ” ។

បុរសអ្នករកឧស បានឮពាក្យ របស់មាន់ទាំងគូនោះហើយ ទើបបានលបៗ ឡើងទៅ ចាប់មាន់ដែលនៅខាងលើ យកមក សម្លាប់ហើយ គិត ថា “អញនឹងបានជាព្រះរាជា” ហើយ ក៏បានទៅ កាន់ផ្ទះ បានឲ្យហើយ ដល់ភរិយា ដោយប្រាប់ ថា “ចូរនាងចាត់ ចែងនូវសាច់មាន់នេះ ឲ្យបានល្អ ” ។

ភរិយានោះ បានធ្វើ ដូចជាស្វាមីបញ្ជា ហើយពោល ថា “បពិត្រអ្នកប្តី ចូរបងពិសាចុះ” ហើយ ក៏បានបង្អោនចូលទៅ ។

ស្វាមីនោះ ពោល ថា “នែនាងដ៏ចំរើន ! សាច់នេះ មាន អានុភាពច្រើន, បងបរិភោគសាច់នោះហើយ នឹងបានជាព្រះ រាជា, អូនឯង នឹងបានជាព្រះអគ្គមហេសី, ចូរអូន នាំយកភត្ត និងសាច់មកចុះ, ពួកយើង នឹងទៅងូតទឹក ក្នុងទន្លេគង្គាហើយ បរិភោគ ” ។ ស្វាមី និងភរិយាទាំង ២ នាក់នោះ បាននាំគ្នា ទៅហើយ ដាក់ថាសនៃភត្ត ក្បែរមាត់ច្រាំងទន្លេគង្គា បានចុះ ទៅហើយ ដើម្បីនឹងងូតទឹក ។ ក្នុងខណៈនោះ ទឹកបាន ត្រូវខ្យល់ធ្វើឲ្យកម្រើកហើយ ក៏បាននាំយកភាជនៈភត្តទៅហើយ ។

គ្រានោះ មហាអមាត្យម្នាក់ ជាអ្នកហ្វឹកដំរី កាលលាងដំរី ក្នុងទន្លេ ខាងក្រោម ក៏ឃើញនូវភាជនៈនៃភត្តនោះ ត្រូវខ្សែទឹក

កំពុងផាត់ ទើបបានឱ្យគេស្រង់ឡើងយកមក ឃើញនូវអាហារទាំងអស់នោះ ក៏បានបញ្ជាឱ្យបិតភាជនៈភ័ត្តនោះ ហើយបញ្ជូនទៅដល់ភរិយា ។ ចំណែកបុរសអ្នករកឧសនោះឯង មានពោះឡើងប៉ោងហើយ ព្រោះទឹកលាយដោយជីខ្សាច់ ហូរចូលទៅ ក្នុងមាត់ បានរត់ចេញទៅហើយ ។

លំដាប់នោះ តាបសភ្នែកទិព្វ ដែលជាកុលុបកៈ របស់អ្នកហ៊ឹកដំរី ១ រូប អាស្រ័យនៅ ក្នុងព្រះរាជឧទ្យាន ពិចារណាដោយទិព្វចក្ខុ ថា "ឧបដ្ឋាករបស់អាត្មាអញ មិនព្រមលះបង់នូវតំណែងនៃអ្នកហ៊ឹកដំរី, តើពេលណាទៅហ្ន៎ គេនឹងបានទទួលនូវសម្បត្តិ ?" ដូច្នេះ បានដឹងនូវហេតុនោះហើយ ទើបបាននិមន្តទៅគង់នៅ លើរោងនៃអ្នកហ៊ឹកដំរីជាមុន ។

ចំណែកអ្នកហ៊ឹកដំរី បានមកអង្គុយហើយ ឱ្យបុគ្គលនាំយកភាជនៈភ័ត្តមក បានប្រគេនហើយ ដល់តាបស ។ តាបសបានឱ្យបុគ្គលចែកសាច់ជុំជាដើម ជាចំណែកមួយៗ ឱ្យបុគ្គលឱ្យហើយនូវសាច់ជុំដល់អ្នកហ៊ឹកដំរី សាច់ខាងក្រៅ ដល់ភរិយារបស់គាត់ ខ្លួនឯង បានឆាន់សាច់ជាប់ឆ្អឹង ស្រេចហើយ ពោល ថា "ក្នុងថ្ងៃទី ៣ បន្ទាប់អំពីថ្ងៃនេះទៅ លោកនឹងបានជាព្រះរាជា, សូមលោក កុំបីប្រមាទ" ដូច្នេះហើយ ក៏បាននិមន្តចេញទៅហើយ ។

ក៏ក្នុងថ្ងៃទី ៣ ព្រះរាជាជិតខាង មួយព្រះអង្គ ទ្រង់ស្តេចយាងមក លោមព័ទ្ធក្រុងពារាណសី ។ គ្រានោះ ព្រះរាជាទ្រង់បានត្រាស់បញ្ជា ឲ្យមហាអមាត្យអ្នកហ៊ឹកដំរី ទទួលភេទជាព្រះរាជាហើយ ទ្រង់ត្រាស់ ថា "ចូរអ្នកឡើងជិះដំរី ធ្វើសង្គ្រាមចុះ" ដូច្នេះហើយ ព្រះអង្គឯង ទ្រង់បានបន្លំភេទ យាងត្រួតកងទ័ព ត្រូវកូនសរដែលមានកម្លាំងខ្លាំងក្លាមួយ ចាក់ទំលុះ ទ្រង់បានសោយទិវង្គតហើយ ក្នុងខណៈនោះឯង ។

អ្នកហ៊ឹកដំរី ដឹងថា ព្រះរាជាអង្គនោះ សោយទិវង្គតហើយ ទើបឲ្យគេនាំយកកហាបណៈជាច្រើនចេញមក បានឲ្យវាយស្គរប្រកាស ថា "ជនទាំងឡាយ អ្នកត្រូវការទ្រព្យ ចូរធ្វើសង្គ្រាម" ។ ពួកពល បានញុាំងព្រះរាជាដែលជាសត្រូវ ឲ្យដល់ហើយនូវការអស់ទៅនៃព្រះជន្មាយុ ដោយកាលមួយភ្លែតប៉ុណ្ណោះឯង ។

ពួកអមាត្យ បានថ្វាយព្រះភ្លើងព្រះសរីរកិច្ច របស់ព្រះរាជានៃខ្លួនហើយ ទើបប្រឹក្សាគ្នា ថា "ព្រះរាជា កាលទ្រង់មានព្រះជន្មាយុនៅឡើយ ទ្រង់បានព្រះរាជទានហើយ នូវភេទរបស់ព្រះអង្គដល់អ្នកហ៊ឹកដំរីនេះ, បុរសអ្នកហ៊ឹកដំរីនេះឯង បានធ្វើសង្គ្រាមហើយ ដណ្តើមយករាជសម្បត្តិមកបាន, ពួកយើង នឹងប្រគល់រាជសម្បត្តិ ដល់បុរសអ្នកហ៊ឹកដំរីនេះ" ដូច្នេះហើយ ទើបបាន

អភិសេកបុរសអ្នកហ៊ឹកដំរី ក្នុងរាជសម្បត្តិហើយ និងបានតែងតាំងនូវភរិយា របស់អ្នកហ៊ឹកដំរីនោះ ជាព្រះអគ្គមហេសី ។ ចំណែកតាបស បានឡើងជារាជកុលុបកៈហើយ ។

រឿង បុរសអ្នករកខុស ចប់ ។

(៩៩) ព្រះសាស្តា លុះទ្រង់នាំអតីតនិទាននេះមកហើយ កាលទ្រង់សំដែងធម៌ ដល់អនាថបិណ្ឌិកសេដ្ឋីនោះ ទើបទ្រង់បានត្រាស់ព្រះគាថាទាំងនេះ ក្នុងសិរិចោរជាតក ក្នុងតិកនិបាត ថា ÷

" ពួកបុគ្គលអ្នកឥតបុណ្យ មានសេចក្តីខ្វល់ខ្វាយ(១) ទោះមានសិល្បៈក្តី មិនមានសិល្បៈក្តី ប្រមូលទ្រព្យណាមកបានដ៏ច្រើន, ឯអ្នកមានបុណ្យប៉ុណ្ណោះ រមែងបរិភោគទ្រព្យទាំងឡាយនោះ, ភោគៈទាំងឡាយជាច្រើន រមែងកន្លងនូវសត្វដទៃ (អ្នកឥតបុណ្យ) ហើយកើតឡើង ដល់បុគ្គលអ្នកមានបុណ្យបានធ្វើទុកហើយ ក្នុងទីទាំងពួងប៉ុណ្ណោះ, មួយទៀត ភោគៈទាំងឡាយដ៏ច្រើន រមែងកើតឡើង សូម្បីក្នុងទីមិនមែនជាកន្លែង សម្រាប់កើតឡើងទាំងឡាយ " ។

---

១ ត្រៃបិដក ភាគទី ៥៨ / ទំព័រទី ១៦៩ ។

បណ្ដាបទទាំងនោះ បទ ថា "**យំ**" ប្រែថា ទ្រព្យឯណា ។ បាឋៈ ថា "**យេ**" ដូច្នេះក៏មាន ។ សេចក្ដីថា "បុរសទាំងឡាយឯណាមួយ" ។ បទ ថា "**ឧស្សុក្កា**" បានដល់ ជាអ្នកដល់នូវការខ្វល់ខ្វាយ គឺ កើតសេចក្ដីពេញចិត្តក្នុងការរួបរួមទ្រព្យ ។ បុគ្គលអ្នកមិនមានបុណ្យ ឈ្មោះថា **អលក្ខិកា** ។ បុគ្គលអ្នកមិនមានបុណ្យទាំងនោះ មានសិល្បៈក្ដី មិនមានសិល្បៈក្ដី ដោយអំណាចនៃសិល្បៈ មានសិល្បៈគឺដំរីជាដើម ដោយហោចទៅ សូម្បីធ្វើនូវការងារ ដោយថ្លៃឈ្នួល រួបរួម គឺ ប្រមូលទ្រព្យជាច្រើន ដោយសេចក្ដីលំបាក ។ បទ ថា "**លក្ខីវ**" មានសេចក្ដីថា បុរសដទៃទៀត អ្នកមានបុណ្យប៉ុណ្ណោះ សូម្បីមិនបានធ្វើការងារអ្វីមួយ ក៏រមែងបរិភោគទ្រព្យទាំងឡាយ គឺ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ ថា "ទ្រព្យជាច្រើន" ដោយផលបុណ្យរបស់ខ្លួន ។

បទ ថា "**អតិច្ចា**" ប្រែថា កន្លងហើយ ។ **ឯវ** ស័ព្ទក្នុងពាក្យ ថា "**អញ្ញេវ**" គប្បីប្រកប ដោយបទ ថា "**សព្ពេ**" នុ៎ះថា "ភោគៈទាំងឡាយដ៏ច្រើន រមែងកន្លងនូវសត្វទាំងឡាយដទៃអ្នកមិនបានធ្វើបុណ្យទុកហើយ កើតឡើង ដល់បុគ្គលអ្នកបានធ្វើបុណ្យទុកហើយ ក្នុងទីទាំងពួងប៉ុណ្ណោះ" ។

បាទគាថា ថា "**អបិ នាយតនេសុបិ**" មានសេចក្ដីថា

មួយ៉ាងទៀត ភោគៈទាំងឡាយជាច្រើន ទាំងមានវិញ្ញាណ និងទាំងមិនមានវិញ្ញាណ រមែងកើតឡើង សូម្បីក្នុងទីមិនមែនជាកន្លែងសម្រាប់កើតទាំងឡាយ គឺ រតនៈទាំងឡាយ រមែងកើតឡើង ក្នុងទីមិនមែនជាកន្លែងសម្រាប់កើតនៃរតនៈទាំងឡាយ, វត្ថុទាំងឡាយមានមាសជាដើម រមែងកើតឡើង ក្នុងទីមិនមែនជាកន្លែងសម្រាប់កើតនៃមាសជាដើម, សត្វទាំងឡាយ មានដំរីជាដើម រមែងកើតឡើង ក្នុងទីមិនមែនជាកន្លែងសម្រាប់កើតនៃដំរីជាដើម ។ បណ្ដាភោគៈ ដែលមានវិញ្ញាណ និងមិនមានវិញ្ញាណទាំងនោះ ក្នុងការកើតឡើង ក្នុងទីមិនមែនជាកន្លែងសម្រាប់កើតឡើង នៃភោគៈដែលមិនមានវិញ្ញាណទាំងឡាយ មានកែវមុក្តា និងកែវមណីជាដើម គប្បីសំដែងរឿងនៃព្រះបាទទុដ្ឋគាមណីអភ័យ ។

## ( រឿង ព្រះបាទទុដ្ឋគាមណីអភ័យ )

(១០០) បានឮថា មានព្រះរាជបុត្រ នៃព្រះរាជាព្រះនាមកាកវណ្ណតិស្សៈ ព្រះអង្គទ្រង់គ្រប់គ្រងរាជសម្បត្តិ ក្នុងមហាគ្រាមក្នុងរោហណជនបទ ទ្រង់ព្រះនាមថា ទុដ្ឋគាមណីអភ័យ ។ ដោយកាលដែលព្រះបិតាសោយទិវង្គតទៅ ព្រះបាទទុដ្ឋគាមណីអភ័យអង្គនោះ ទ្រង់បានឡើងគ្រងរាជសម្បត្តិ ក្នុងមហាគ្រាមនោះឯង

ទ្រង់ស្តេចយាងអំពីមហាគ្រាមនោះហើយ ទ្រង់បានធ្វើគត់ព្រះរាជាទមិឡ ទ្រង់ព្រះនាមថា ឯឡារៈ ហើយទ្រង់បានជាព្រះរាជាមួយព្រះអង្គ ក្នុងអនុរាធបុរី ក្នុងលង្កាទ្វីប ។

ក្នុងឆ្នាំទី ៧២ រាប់តាំងអំពីឆ្នាំដែលព្រះសាស្តាទ្រង់បានព្រះបរិនិព្វានទៅបាន ៣០០ ឆ្នាំ រតនៈទាំងឡាយ មានរ៉ែនៃមាសជាដើម កើតឡើងហើយ ជុំវិញនៃអនុរាធបុរី ដោយបុញ្ញានុភាពរបស់ព្រះអង្គ ។ ពិតមែនដូច្នោះ រ៉ែនៃមាសច្រើនជាអនេកមានប្រមាណមួយចំអាមខ្លះ មានប្រមាណមួយធ្នាប់ខ្លះ បានដុះឡើងហើយ លើផែនដីប្រមាណ ១៦ករីស ក្នុងអាវរវិរដ្ឋិគ្រាមចម្ងាយដល់ទៅ ៣ យោជន៍ ក្នុងទិសភ្លិសានអំពីទីក្រុង ។

ក្នុងទិសខាងកើត អំពីទីក្រុងនោះទៅ ចម្ងាយដល់ទៅ ៧ យោជន៍ រ៉ែនៃមាសពណ៌ក្រហម ដុះឡើងហើយ ក្នុងជនបទដែលមានឈ្មោះថា តម្ពបិដ្ឋិ ឮដីត្រើយខាងនាយ នៃទន្លេគង្គា ។

ក្នុងទិសអាគ្នេយ៍ អំពីទីក្រុងនោះទៅ ចម្ងាយដល់ទៅ ៤ យោជន៍ កែវមណីទាំងឡាយ ដុះឡើង ក្នុងសុមនវាបីគ្រាម ។

ក្នុងទិសទក្សិណ អំពីទីក្រុងនោះទៅ ចម្ងាយដល់ទៅ ៨ យោជន៍ ប្រាក់ បានកើតឡើងហើយ ក្នុងគុហាមួយ ក្នុងជនបទឈ្មោះថា អម្ពដ្ឋកោលៈ ។

ក្នុងទិសបស្ចឹម អំពីទីក្រុងនោះទៅ ចម្ងាយដល់ទៅ ៥ យោជន៍ កែវមុក្តាទាំងឡាយ ដោយសណ្ឋានប្រមាណស្មើនឹងផ្លែកន្ទួតព្រៃខ្នាតធំ ផ្ទុកបានពេញ ៦០ រទេះ ព្រមទាំងកែវប្រពាឡទាំងឡាយ ឡើងមកលើគោក ត្រង់កំពង់ ឈ្មោះឱរុវេលៈ ។

ក្នុងទិសឧត្តរ អំពីទីក្រុងនោះទៅ ចម្ងាយដល់ទៅ ៧ យោជន៍ កែវមណីទាំងឡាយ ៤ បែប យ៉ាងល្អប្រសើរ មានពណ៌សម្បុរស្មើនឹងផ្កាកប្បាស ដោយវែង ប្រវែង ១ ចំអាម ៤ ធ្នាប់ ដោយមូល មានទំហំប៉ុនជុំថ្មតូចដែលគេកិនកំទេច បានផុសឡើងហើយ លើខ្នងនៃដីខ្សាច់ ក្បែរជ្រោះភ្នំ ដែលហូរទៅកាន់បឹង នៃបេឡិវាបិកគ្រាម ។

មនុស្សទាំងឡាយ ឃើញរតនៈទាំងឡាយ មានរ៉ែនៃមាសជាដើមនោះហើយ ក៏បានក្រាបទូល ដល់ព្រះរាជា ។ ព្រះរាជាទ្រង់ត្រាស់បញ្ជា ឲ្យជញ្ជូនយករ៉ែមាសទាំងអស់នោះ មកហើយ ។

រឿង ព្រះបាទទុដ្ឋគាមណីអភ័យ មកក្នុងបរិច្ឆេទទី ២៨ ក្នុងគម្ពីរមហាវង្ស ។

(១០១) ក៏ព្រះសាស្តា លុះទ្រង់ត្រាស់ ២ គាថានេះហើយ ទើបត្រាស់ទៀត ថា “ម្នាលគហបតី ! ឈ្មោះថា ទីជាទីកើតដទៃ ដូចជាបុណ្យ នៃសត្វទាំងឡាយនេះ មិនមានសោះឡើយ,

ព្រោះថា រតនៈទាំងឡាយ រមែងកើតឡើង សូម្បីក្នុងទីមិនមែនជាទីកើត ដល់ពួកបុគ្គលអ្នកមានបុណ្យ តែប៉ុណ្ណោះ” ដូច្នេះហើយ កាលទ្រង់សំដែងធម៌ ដោយន័យដែលទ្រង់បានត្រាស់ទុកហើយ ក្នុងនិធិកណ្ឌ ទើបទ្រង់ត្រាស់ នូវព្រះគាថាទាំងនេះ ថា ÷

“ កំណប់ទ្រព្យ គឺបុណ្យនុ៎ះ ឲ្យនូវសេចក្តីប្រាថ្នា(១)
គ្រប់យ៉ាង ដល់ទេវតា និង មនុស្សទាំងឡាយ,
ទេវតា និង មនុស្សទាំងឡាយ ប្រាថ្នាណាស់
នូវផលណា ៗ, ផលទាំងពួងនោះ ៗ រមែង
បាន ដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះ ។

ភាពជាអ្នកមានសម្បុរផូរផង់ មានសំឡេង
ពីរោះ មានទ្រង់ទ្រាយល្អ មានរូបល្អ ភាពជា
អធិបតី មានយសបរិវារ, ផលទាំងអស់
រមែងបាន ដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះ ។

ភាពជាស្តេចប្រទេសរាជ ឥស្សរិយយស
សេចក្តីសុខរបស់ស្តេចចក្រពត្តិ ជាទីស្រឡាញ់
ភាពជាស្តេច នៃទេវតា ក្នុងទេពនិកាយទាំង
ឡាយ, ផលទាំងអស់ រមែងបាន ដោយកំណប់

១ ត្រៃបិដក ភាគទី ៥២ / ទំព័រទី ១៧ ។

ទ្រព្យ គឺបុណ្យនុ៎ះ ។

សម្បត្តិជារបស់មនុស្សណាផង សេចក្ដីត្រេកអរ ក្នុងទេវលោកណាផង សម្បត្តិគឺព្រះនិព្វានណាផង, សម្បត្តិទាំងអស់ រមែងបាន ដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។

ភាពនៃបុគ្គលកាលអាស្រ័យ នូវមិត្តសម្បទា បើប្រកបសេចក្ដីព្យាយាម ដោយឧបាយដែលត្រឹមត្រូវ ជាអ្នកស្ទាត់ជំនាញ ក្នុងវិជ្ជានិងវិមុត្តិ, ឥដ្ឋផលទាំងអស់ រមែងបាន ដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។

បដិសម្ភិទា វិមោក្ខ សាវកបារមីញាណ បច្ចេកពោធិញ្ញាណ និងពុទ្ធភូមិណាៗ, ឥដ្ឋផលទាំងអស់ រមែងបាន ដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។

បុញ្ញសម្បទានេះ ឲ្យសម្រេចប្រយោជន៍ដ៏ធំ ដោយប្រការដូច្នេះឯង, ព្រោះហេតុនោះ បណ្ឌិតទាំងឡាយ ជាធីរជន ទើបសរសើរនូវភាពនៃបុគ្គល ជាអ្នកមានបុណ្យធ្វើទុកហើយ” ។

ន័យមកក្នុងអដ្ឋកថានិធិកណ្ឌ ថា " ក្នុងគាថានោះ កំណប់ទ្រព្យ គឺបុណ្យ ឈ្មោះថា **និធិ** ។ មែនពិត បុណ្យនុ៎ះឯង ឈ្មោះថា **និធិ** ព្រោះអត្ថ ថា បុគ្គលគួរកប់ទុក ។

ព្រះដ៏មានព្រះភាគ លុះទ្រង់ត្រាស់សំដែងផលដែលបុញ្ញនិធិនោះ ឲ្យដល់ទេវតានិងមនុស្សទាំងឡាយនោះ ដោយសេចក្ដីសង្ខេប ថា " **កំណប់ទ្រព្យ គឺបុណ្យ ឲ្យនូវសេចក្ដីប្រាថ្នាគ្រប់យ៉ាង ដល់ទេវតានិងមនុស្សទាំងឡាយ** " ដោយប្រការដូច្នេះហើយ ក្នុងពេលឥឡូវនេះ កាលនឹងទ្រង់សំដែង នូវសេចក្ដីប្រាថ្នានោះ ថា ជាហេតុ ក្នុងភារៈនៃបុញ្ញនិធិនោះ ឲ្យនូវសេចក្ដីប្រាថ្នាគ្រប់យ៉ាង ព្រោះបុញ្ញនិធិនោះ នឹងឲ្យនូវសេចក្ដីប្រាថ្នាគ្រប់យ៉ាងបាន ក៏ដោយសេចក្ដីប្រាថ្នា ប្រាសចាកអំពីសេចក្ដីប្រាថ្នាហើយ មិនអាចឲ្យនូវសេចក្ដីប្រាថ្នាគ្រប់យ៉ាងបានឡើយ ទើបទ្រង់ត្រាស់កន្លះគាថា មានជាអាទិ៍ ថា " **យំ យំ** " ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងកន្លះគាថា ថា " **យំ យំ** " ជាដើមនោះ (ដូចតទៅ)÷ ពាក្យ ថា " **យំ យំ** " ប្រែថា ផលណាៗ ។ ពាក្យ ថា " **ទេវា** " បានដល់ ទេវតានិងមនុស្សទាំងឡាយ ។ ផលទាំងអសនោះ រមែងបាន ដោយបុញ្ញនិធិនុ៎ះ ។

ឥឡូវនេះ ព្រះដ៏មានព្រះភាគ កាលទ្រង់សំដែងនូវផលទាំង

ពួកនោះ ដែលបានដោយបុញ្ញនិធិនុ៎ះ ដោយផ្នែក ៗ ទើបទ្រង់ត្រាស់ ៥ គាថា មានជាអាទិ៍ ថា 'សុវណ្ណតា សុស្សរតា' ។

(១០២) ក្នុង ៥ គាថានោះ គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី ១ (ដូចតទៅ) ÷ ភាពជាអ្នកមានសម្បុរល្អប្រសើរ ភាពជាអ្នកមានសាច់ស្បែកភ្លឺថ្លាប្រៀបដូចជាមាស ឈ្មោះថា ភាពជាអ្នកមានសម្បុរផូរផង់ ។ ភាពជាអ្នកមានសំឡេងដូចជាសំឡេងនៃព្រហ្ម ភាពជាអ្នកមានប្រក្រតីស្រដី ដូចជាសត្វករវិក ឈ្មោះថា ភាពជាអ្នកមានសំឡេងពីរោះ ។ ភាពជាអ្នកមានអវយវៈស្ថិតនៅដោយល្អ, មានពាក្យដែលលោកពោល ថា 'ការតាំងនៅព្រមនៃអវយវៈតូច-ធំទាំងឡាយ ក្នុងទីសមគួរ ស្មើ ពេញ និងមូល ដោយភាពជារបស់ស្មើ ពេញ និងមូល' ឈ្មោះថា ភាពជាអ្នកមានទ្រង់ទ្រាយល្អ ។ ភាវៈនៃរូប ពោលគឺសរីរៈទាំងមូលល្អ, មានពាក្យដែលលោកពោលទុកហើយ ថា 'ភាពនៃបុគ្គលជាអ្នកមិនខ្ពស់ពេក មិនទាបពេក មិនស្គមពេក មិនធាត់ពេក មិនខ្មៅពេក និងមិនសពេក' ដូច្នេះ ឈ្មោះថា ភាពជាអ្នកមានរូបល្អ ។ ភាពជាអធិបតី, អធិប្បាយ ថា 'ភាពជាធំ ដោយភាពជាស្តេចមហាសាលជាដើម' ឈ្មោះថា ភាពជាអធិបតី ។ ភាពជាអ្នកមានពួកបរិវារ ឈ្មោះថា ភាពជាអ្នកមានយសបរិវារ ។

បទ ថា 'សព្វំ' គឺ ផល ៦ យ៉ាង មានភាពជាអ្នកមានសម្បុរល្អ ជាដើម ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ដោយផ្នែកៗ ឈ្មោះថា ផលទាំងពួង ។

(១០៣) ព្រះដ៏មានព្រះភាគ លុះទ្រង់សំដែងនូវសម្បត្តិ ក្នុងទេវតានិងមនុស្ស ដែលទាបជាងរាជសម្បត្តិ ដែលបុគ្គលគប្បីបាន ដោយអានុភាពនៃបុណ្យ ដោយគាថានេះ ដូចពណ៌នាមកហើយឥឡូវនេះ កាលនឹងទ្រង់សំដែងរាជសម្បត្តិទាំង ២ យ៉ាងនោះ ទើបទ្រង់ត្រាស់ហើយ នូវគាថាទី ២ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី ២ នោះ ( ដូចតទៅនេះ ) ÷ ភាពជាព្រះរាជា ក្នុងប្រទេសមួយ ៗ លើផែនដី មិនដល់នូវទ្វីប ១ ទាំងមូលឡើយ ឈ្មោះថា ភាពជាស្តេចប្រទេសរាជ ។ ភាពជាធំ ឈ្មោះថា ឥស្សរិយយស ។ ព្រះដ៏មានព្រះភាគ ទ្រង់សំដែងនូវភាពជាស្តេចចក្រពត្តិចំពោះទ្វីប ដោយបទនេះ ។ សេចក្តីសុខរបស់ស្តេចចក្រពត្តិ ឈ្មោះថា សេចក្តីសុខនៃស្តេចចក្រពត្តិ ។ បទ ថា 'បិយំ' បានដល់ ជាទីប្រាថ្នា គួរចង់បាន ជាទីពេញចិត្ត ។ ព្រះដ៏មានព្រះភាគ ទ្រង់សំដែង នូវភាពជាស្តេចចក្រពត្តិ ដែលជាឥស្សរៈ លើផែនដី មានសមុទ្រសាគរទាំង ៤ ជាទីបំផុត ដោយបទនេះ ។ ភាពជាព្រះរាជា ក្នុងពួកទេវតាទាំងឡាយ

ឈ្មោះថា ភាពជាស្តេចនៃទេវតា ។ ព្រះមានព្រះភាគទ្រង់សំដែងនូវភាពជាស្តេចក្នុងទេវតា សូម្បីរបស់មនុស្សទាំងឡាយ មានព្រះបាទមន្ធាតជាដើម ដោយបទនេះ ។

ពាក្យ ថា '**អបិ ទិព្វេសុ**' បានដល់ ភាពជាព្រះរាជានៃទេវតា សូម្បីក្នុងទេពនិកាយទាំងឡាយ ។ ទេវតាទាំងឡាយណានោះ ដែលលោកហៅថា 'ទិព្វ' ព្រោះកើតក្នុងពពួកដែលជាទិព្វ, ព្រះដ៏មានព្រះភាគ ទ្រង់សំដែង នូវភាពនៃទេវតា ដែលជាស្តេចសូម្បីនៃទេវតាទាំងឡាយ ដែលកើតហើយ ក្នុងពួកទិព្វនិកាយទាំងឡាយនោះ ដោយបទនេះ ។ ផលមាន ភាពជាស្តេចប្រទេសរាជជាដើម ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកហើយដោយផ្នែក ៗ ឈ្មោះថា ផលទាំងពួង ។

(១០៤) ព្រះដ៏មានព្រះភាគ លុះទ្រង់សំដែងនូវរាជសម្បត្តិក្នុងទេវតានិងមនុស្ស ដែលបុគ្គលគប្បីបាន ដោយបញ្ញានុភាពដោយគាថានេះ ដូចបានពណ៌នាមកហើយនេះ ឥឡូវនេះ កាលនឹងទ្រង់រួបរួមសម្បត្តិដែលទ្រង់ត្រាស់ហើយ ដោយ ២ គាថា ដោយសង្ខេប សំដែងសម្បត្តិគឺព្រះនិព្វាន ទើបទ្រង់ត្រាស់គាថាទី ៣ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី ៣ នោះ ( ដូចតទៅនេះ ) ÷ សម្បត្តិនេះ ជារបស់មនុស្សទាំងឡាយ ព្រោះហេតុ ទើបឈ្មោះថា

មានុសី, មានុសីនុ៎ះឯង ឈ្មោះថា មានុសិកា ។ ការដល់ព្រម ឈ្មោះថា សម្បត្តិ ។ ទេវតានិងមនុស្សទាំងឡាយ រមែងត្រេកអរ ដោយសម្បត្តិនុ៎ះ ដែលកើតឡើង ខាងក្នុងក្តី ដែលជាឧបករណ៍ ខាងក្រៅក្តី ព្រោះហេតុនោះ សម្បត្តិនោះ ទើបឈ្មោះថា រតិ (ជាហេតុត្រេកអរនៃទេវតានិងមនុស្សទាំងឡាយ) បានដល់ សេចក្តីសុខ និងហេតុជាទីតាំងនៃសេចក្តីសុខ ។ ព្រះនិព្វាននុ៎ះឯង ឈ្មោះថា និព្វានសម្បត្តិ ។ ផលមានសម្បត្តិដែលជារបស់មនុស្សជាដើម ដែលព្រះអង្គត្រាស់ហើយ ដោយផ្នែក ៗ ឈ្មោះថា ផលទាំងពួង ។

(១០៥) ព្រះដ៏មានព្រះភាគ លុះទ្រង់សំដែងសូម្បីនូវសម្បត្តិ គឺព្រះនិព្វាន ដែលគប្បីសម្រេច ដោយអំណាចភាវៈនៃព្រះអរិយ-បុគ្គលដែលជាសទ្ធានុសារីជាដើម ដែលគប្បីបានដោយបុញ្ញានុភាព ដោយគាថានេះ ដូចបានពណ៌នាមកហើយនេះ ឥឡូវនេះ កាលនឹងទ្រង់សំដែងនូវព្រះនិព្វាននោះឯង ដែលគប្បីសម្រេច សូម្បីដោយអំណាចភាវៈនៃព្រះអរិយបុគ្គល ដែលជាតេវិជ្ជៈ និងឧភតោភាគ-វិមុត្តិ និងឧបាយនៃព្រះនិព្វាននោះ ទើបត្រាស់គាថាទី ៤ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី ៤ នោះ (ដូចតទៅនេះ) ÷ បុគ្គល រមែងដល់ព្រម គឺបានសម្រេច នូវសេចក្តីចំរើននៃគុណ

ដោយសម្បត្តិនុ៎ះ ព្រោះហេតុនោះ សម្បត្តិនុ៎ះ ទើបឈ្មោះថា សម្បទា (ធម្មជាតិជាហេតុដល់ព្រម)។ សម្បទាគឺមិត្រ ឈ្មោះថា មិត្តសម្បទា ។ នូវសម្បទា គឺមិត្រនោះ ។

បទ ថា '**អាគម្ម**' មានសេចក្តីថា អាស្រ័យនូវព្រះសាស្តា ឬ សព្រហ្មចារីបុគ្គល ណាមួយ ដែលជាអ្នកគួរដល់នូវឋានៈគួរគោរព ហើយ ទទួលយកនូវឱវាទានុសាសនី អំពីព្រះសាស្តា ឬ សព្រហ្មចារីបុគ្គល ដែលជាអ្នកគួរនូវឋានៈគួរគោរពនោះ ។

បទ ថា '**យោនិសោ**' គឺ ដោយឧបាយ ។ បទ ថា '**បយុញ្ជតោ**' គឺ ធ្វើនូវសេចក្តីប្រឹងប្រែង ជាហេតុព្យាយាម ។ ភាពជាអ្នកឈ្មោះថាស្ទាត់ជំនាញ ព្រោះអត្ថ ថា មិនប្រព្រឹត្តយឺតយូរ ដោយប្រការនោះ ។ ក្នុងវិជ្ជា ៣ មានបុព្វេនិវាសានុស្សតិញាណ ជាដើម និងវិមុត្តិ ដែលផ្សេងដោយសមាបត្តិ ៨ និងព្រះនិព្វាន ឈ្មោះថា ភាពជាអ្នកស្ទាត់ជំនាញ ក្នុងវិជ្ជានិងវិមុត្តិ ។ ភាពជាអ្នកស្ទាត់ជំនាញ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ ដោយផ្នែកៗ ឈ្មោះថា ផលទាំងពួង ។

(១០៦) ព្រះដ៏មានព្រះភាគ លុះទ្រង់សំដែងនិព្វានសម្បត្តិ ដែលគប្បីសម្រេច សូម្បីដោយអំណាចភាវៈ នៃព្រះអរិយបុគ្គល ដែលជាតេវិជ្ជៈជាដើម ដែលគប្បីបាន ដោយបុញ្ញានុភាព ដែល

ជាចំណែកនៃភាពជាអ្នកស្ទាត់ជំនាញ ក្នុងវិជ្ជានិងវិមុត្តិ ដែលខ្លួនបានធ្វើទុកហើយ ក្នុងកាលមុន ដោយគាថានេះ ដូចបានពណ៌នាមកហើយនេះ ..., ព្រះអរិយបុគ្គលទាំងឡាយទាំងពួង ជាអ្នកសម្រេចនូវភាពជាអ្នកស្ទាត់ជំនាញ ក្នុងវិជ្ជានិងវិមុត្តិនោះ សូម្បីជាព្រះអរិយបុគ្គលដែលជាតេវិជ្ជៈ និងឧភតោភាគវិមុត្តិ រមែងបានសេចក្តីចំរើនដោយគុណ មានបដិសម្ភិទាជាដើម, មួយទៀត រមែងបានសូម្បីសេចក្តីចំរើនដោយគុណ មានបដិសម្ភិទាជាដើមនោះ ដោយបុញ្ញសម្បទានេះ ដែលខ្លួនបានធ្វើទុកហើយ ដោយប្រការនោះ ៗ ដោយអំណាចជាបទដ្ឋាន នៃសេចក្តីចំរើននោះ ព្រោះហេតុណា, ព្រោះហេតុនោះ ឥឡូវនេះ កាលទ្រង់សំដែងសូម្បីនូវសេចក្តីចំរើនដោយគុណនោះ ទើបទ្រង់ត្រាស់ នូវគាថាទី ៥ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី ៥ នោះ (ដូចតទៅនេះ) ÷ បញ្ញាដែលដល់នូវការចាក់ធ្លុះ ក្នុងធម៌ អត្ថ និរុត្តិ និងបដិភាណ ឈ្មោះថា បដិសម្ភិទា ។ វិមោក្ខ ដែលជាលោកិយ ៨ ប្រការ ឈ្មោះថា វិមោក្ខ ។ បារមី ដែលញុំាងសាវកសម្បត្តិ ឲ្យសម្រេច ឈ្មោះថា សាវកបារមី ។ បារមី ដែលញុំាងភាពជាព្រះសយម្ភូ ឲ្យបានសម្រេច ឈ្មោះថា បច្ចេកពោធិ ។ បារមីដែលញុំាងភាពជាអ្នកប្រសើរបំផុតនៃសត្វទាំងពួង ឲ្យបានសម្រេច ឈ្មោះថា

ពុទ្ធភូមិ ។ ផលមានបដិសម្ភិទាជាដើម ដែលព្រះអង្គទ្រង់ត្រាស់ទុកហើយ ដោយផ្នែក ៗ ឈ្មោះថា ផលទាំងពួង ។

ព្រះដ៏មានព្រះភាគ លុះទ្រង់សំដែងនូវផលដែលព្រះអង្គទ្រង់បានត្រាស់ទុកហើយ ក្នុងកន្លះគាថានោះ ថា '**ទេវតានិងមនុស្សទាំងឡាយ ប្រាថ្នាណាស់នូវផលណា ៗ, ផលទាំងពួងនោះ ៗ រមែងបាន ដោយបុញ្ញនិធិនុ៎ះ**' ដូច្នេះ ដោយផ្នែក ៗ ដោយគាថាទាំងឡាយ ៥ នេះ ដូចបានពណ៌នាមកហើយនេះ ឥឡូវនេះ កាលទ្រង់ត្រាស់សរសើរ នូវបុញ្ញសម្បទា ដែលយល់បានថា ឲ្យនូវសេចក្ដីប្រាថ្នាគ្រប់យ៉ាងនោះឯង ទើបទ្រង់ត្រាស់គាថាទីបញ្ចប់ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទីបញ្ចប់នោះ (ដូចតទៅនេះ)÷ ពាក្យ ថា '**ឯវំ**' ជាពាក្យសំដែងនូវសេចក្ដីដែលកន្លងទៅហើយ ។ ប្រយោជន៍ជាច្រើន មានដល់បុញ្ញសម្បទានុ៎ះ ព្រោះហេតុនោះ បុញ្ញសម្បទានោះ ទើបឈ្មោះថា មានប្រយោជន៍ច្រើន ។ អធិប្បាយ ថា 'រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដ៏ច្រើន' ។ បាឋៈ ថា '**មហិទ្ធិយា**' ដូច្នេះក៏មាន ។

ពាក្យ ថា '**ឯសា**' ជាពាក្យសំដែងឡើង ។ ព្រះដ៏មានព្រះភាគ ទ្រង់សំដែងនូវបុញ្ញសម្បទា ដែលព្រះអង្គទ្រង់ត្រាស់ហើយ ដោយបទនោះ ។

សព្ទ ថា 'យទិទំ' ជានិបាត ចុះក្នុងអត្ថ ថា ធ្វើបទឲ្យត្រង់ ។ ដោយបទ ថា 'យទិទំ' នោះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើបទ ឲ្យត្រង់នឹងគ្នា ថា 'យា ឯសា' ដូច្នេះ ដើម្បីនឹងទ្រង់សំដែង បង្ហាញនូវបទដែលទ្រង់សំដែងឡើងហើយ ថា 'ឯសា' ដូច្នេះ ។ ការដល់ព្រម នៃបុណ្យទាំងឡាយ ឈ្មោះថា បុញ្ញសម្បទា ។

បទ ថា 'បសំសន្តិ' មានសេចក្ដីថា រមែងសរសើរ ដោយព្រះតម្រាស់ដែលព្រះអង្គត្រាស់ទុកហើយ ក្នុងនិធិកណ្ឌ (១) ថា ÷

> 'កំណាប់ទ្រព្យ គឺបុណ្យ មិនទូទៅ ដល់ពួកជនដទៃ ជារបស់ដែលចោរលួចយកទៅមិនបាន, កំណាប់ទ្រព្យ គឺបុណ្យណា ជាប់តាមខ្លួនទៅបាន, អ្នកមានប្រាជ្ញា គួរធ្វើនូវកំណាប់ទ្រព្យគឺបុណ្យនោះ'

និង ដោយព្រះតម្រាស់ដែលព្រះអង្គត្រាស់ទុកហើយ ក្នុងសត្តកនិបាត អង្គុត្តរនិកាយ ថា 'ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយ កុំខ្លាចបុណ្យឡើយ, ម្នាលភិក្ខុទាំងឡាយ ពាក្យថា បុណ្យ ៗ នេះ គឺជាជាឈ្មោះ នៃសេចក្ដីសុខ' ដូច្នេះជាដើម ។

បទ ថា 'កតបុញ្ញតំ' ប្រែថា ភាពជាអ្នកបានធ្វើបុណ្យទុកមកហើយ ក្នុងកាលមុន" ដូច្នេះ ។

---

១ ត្រៃបិដក ភាគទី ៥២ / ទំព័រទី ១៧ ។

ក៏គាថាទាំង ៧ នេះ ព្រះធម្មសង្គាហកាចារ្យ បានលើកឡើង ហើយកាន់បាលី ក្នុងនិធិកណ្ឌសូត្រ ក្នុងខុទ្ទកបាឋៈ ព្រោះហេតុណា, ព្រោះហេតុនោះ ទើបលោក មិនបានលើកឡើងកាន់បាលី ក្នុងសិរីចោរជាតក, លើកឡើងកាន់បាឋៈ ក្នុងអដ្ឋកថា តែប៉ុណ្ណោះ ។

ពណ៌នាអំពីភាពនៃបុគ្គលជាអ្នកមានបុណ្យបានធ្វើទុកក្នុងកាលមុន ចប់ ។

៚ ៚ ៚

ប្រែចប់ ថ្ងៃព្រហស្បតិ៍ ៩ រោច ខែមិគសិរ ឆ្នាំច ឆស័ក ព.ស.២៥៣៧
ថ្ងៃទី ៦ មករា ១៩៩៤

( វេលាយប់ )

# ពណ៌នាការដំកល់ខ្លួនដោយប្រពៃ

(១០៧) ចិត្ត ឈ្មោះថា ខ្លួន,ម្យ៉ាងទៀត អត្តភាពទាំងមូល ឈ្មោះថា ខ្លួន ។ មែនពិត ចិត្តនិងអត្តភាពទាំង ២ យ៉ាងនោះ លោកហៅថា "**ខ្លួន**" ព្រោះអត្ថថា "ត្រាច់ទៅ បានដល់ស្ទុះទៅកាន់ភពតូចនិងភពធំ ជួបប្រសព្វ គឺ ជួបប្រទះនូវសេចក្តីទុក្ខក្នុងសង្សារ ផ្សេងដោយជាតិនិងជរាជាដើម ជាប់តគ្នា ។ **អត្ត** ធាតុ ប្រព្រឹត្តទៅ ក្នុងកិរិយាទៅជារឿយ ៗ, កិរិយាប្រព្រឹត្តិទៅមិនខាតរយៈ ឈ្មោះថា កិរិយាប្រព្រឹត្តិទៅរឿយ ៗ ។

ម្យ៉ាងទៀត ដោយអំណាចសេចក្តីផ្សេងពីនេះ ចិត្តនិងអត្តភាពទាំង ២ យ៉ាងនោះ លោកហៅថា "ខ្លួន" ព្រោះអត្ថថា "ការប្រកាន់ ថា 'អញ' តាំងនៅស៊ប់ហើយ ក្នុងអត្តភាពនេះ និង ព្រោះអត្ថ ថា "រមែងទំពាស៊ី បានដល់ រមែងសោយនូវសេចក្តីសុខនិងសេចក្តីទុក្ខ" ។

នឹងពណ៌នាអំពីការដំកល់ខ្លួនទុកដោយប្រពៃ (ដូចតទៅ) ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងញុំាងខ្លួន ដែលទ្រុស្តសីល ឲ្យតាំងនៅក្នុងសីល ញុំាងខ្លួនដែលមិនមានសទ្ធា ឲ្យតាំងនៅក្នុងការដល់ព្រមដោយសទ្ធា ញុំាងខ្លួនដែលកំណាញ់ស្វិតស្វាញ ឲ្យតាំងនៅ

ក្នុងការដល់ព្រមដោយការបរិច្ចាគ, នេះ ហៅថា ការដំកល់ខ្លួនទុកដោយប្រពៃ ។

(១០៨) បណ្ដាពាក្យទាំងនោះ ក្នុងពាក្យ ថា “ញ៉ាំងខ្លួនដែលទ្រុស្ដសីល ឲ្យតាំងនៅក្នុងសីល” នេះ នឹងពោលរឿង (តទៅ)÷

## ( រឿង ចោរ ៥០០ នាក់ )

ក្នុងអតីតកាល ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈ មានចោរ ៥០០ នាក់ ធ្វើកម្មទាំងឡាយមានការសម្លាប់អ្នកស្រុកជាដើម ហើយចិញ្ចឹមជីវិត ដោយចោរកម្ម ។

ថ្ងៃមួយ ពួកចោរទាំងនោះ ត្រូវពួកមនុស្សដេញតាមមកកាលរត់គេចចូលទៅព្រៃ ក៏ជួបនឹងភិក្ខុដែលនៅក្នុងព្រៃជាវត្ត ១ រូបក្នុងទីនោះ ទើបថ្វាយបង្គំហើយ ពោល ថា “បពិត្រព្រះគុណម្ចាស់ដ៏ចំរើន សូមព្រះគុណម្ចាស់ ជាទីពឹង របស់ពួកយើងខ្ញុំផង” ។

ភិក្ខុរូបនោះ ពោល ថា “ឈ្មោះថា ទីពឹងស្មើដោយសីល មិនមានឡើយ, ពួកអ្នកទាំងអស់គ្នា ចូរសមាទាននូវសីល ៥ ចុះ” ដូច្នេះហើយ ក៏បានឲ្យសីល ដល់ពួកចោរទាំង ៥០០ នោះ ហើយទូន្មាននូវចោរទាំង ៥០០ នោះ ថា “ឥឡូវនេះ ពួកអ្នកទាំងឡាយជាអ្នកមានសីល, ពួកអ្នកទាំងឡាយ មិនគួរប្រព្រឹត្តកន្លងសីល

សូម្បីព្រោះហេតុនៃជីវិតឡើយ, មិនគួរធ្វើការប្រទូសរ៉ាយនៃចិត្តឡើយ" ។ ចោរទាំងនោះ ទទួលព្រម ថា "ប្រពៃហើយ" ។

គ្រានោះ មនុស្សទាំងឡាយ ដល់ទីនោះហើយ ក៏បានសម្លាប់ពួកចោរទាំងអស់នោះហើយ ។ ពួកចោរទាំងនោះ មានសីលមិនខាត បានធ្វើកាលកិរិយាទៅកើត ក្នុងទេវលោកហើយ ។ បណ្ដាចោរទាំងនោះ មេចោរ បានជាប្រធាននៃទេវបុត្រ ។ ទេវបុត្រទាំងឡាយនោះ អន្ទោលទៅមក ក្នុងទេវលោក អស់ ១ ពុទ្ធន្តរ ដោយអំណាចអនុលោមនិងបដិលោម ឥឡូវនេះ បានច្យុតចាកអំពីអត្តភាពនោះហើយ ក៏បានមកកើត ក្នុងស្រុកអ្នកព្រានប្រមង់ ដែលមាន ៥០០ ត្រកូល ក្បែរមាត់ទ្វារក្រុងសាវត្ថី ។ បណ្ដាទេវបុត្រទាំងនោះ ទេវបុត្រជាប្រធាន កើតក្នុងត្រកូលនៃព្រានប្រមង់ដែលជាប្រធាន បានជាកុលបុត្រ ឈ្មោះថា យសោជៈ ជាបុរសប្រសើរបំផុតជាងបុរសទាំងឡាយនោះ ។ ពួកកុលបុត្រដទៃទៀត បានកើតហើយ ក្នុងត្រកូលផ្សេងពីនេះ ។

ថ្ងៃមួយ កុលបុត្រទាំងឡាយនោះ បង់សំណាញ់ ក្នុងស្ទឹងអចិរវតី ចាប់បានត្រីមួយ មានសម្បុរដូចជាមាស ទើបប្រឹក្សាគ្នា ថា "ត្រីនេះ មានសម្បុរដូចមាស, ពួកយើង នឹងបង្ហាញត្រីនោះ ថ្វាយដល់ព្រះរាជា" ហើយ ដាក់ត្រីនោះលើទូក លើកទូកហើយ ទើប

សំដែងដល់ព្រះបាទកោសលរាជ ។ ព្រះរាជា ទ្រង់បានត្រាស់ឲ្យពួកកុលបុត្រទាំងនោះឯង នាំយកត្រីនោះ ហើយស្តេចយាងទៅកាន់វត្តជេតពន ទ្រង់សំដែងហើយ ដល់ព្រះសាស្តា ។

ព្រះសាស្តា កាលទ្រង់សំដែងនូវធម៌ ដែលសមគួរដល់ខណៈនោះ ទ្រង់បានធ្វើត្រីនោះ ឲ្យជាហេតុកើតឡើងនៃរឿង ទើបទ្រង់សំដែងកបិលសូត្រ ក្នុងសុត្តនិបាត ហើយទ្រង់បានត្រាស់នូវគាថាទាំងឡាយ ៤ ថា "**មនុជស្ស បមត្តចារិនោ**" ដូច្នេះជាដើម ក្នុងតណ្ហាវគ្គ នៃធម្មបទ ម្តងទៀត ។

ក្នុងពេលចប់គាថា ពួកព្រានប្រមង់ទាំងនោះ កើតសេចក្តីសង្វេគតក់ស្លុតហើយ បួសក្នុងសំណាក់នៃព្រះសាស្តា ក្រោយមកក៏បានសម្រេចព្រះអរហត្ត ដោយន័យដែលព្រះអង្គទ្រង់ត្រាស់ទុកហើយ ក្នុងយសោជសូត្រ ក្នុងតតិយវគ្គ នៃឧទាន ជាអ្នកមានបរិក្ខារជាមួយគ្នានឹងព្រះសាស្តា ដោយធម្មបរិភោគ គឺសមាបត្តិជាគ្រឿងនៅមិនញាប់ញ័រ ។

រឿង ចោរ ៥០០ ក្នុងអដ្ឋកថាកបិលសូត្រជាដើម ចប់ ។

សូម្បីរឿងចោរដែលជ្រះថ្លាហើយ ក្នុងសង្កិច្ចសាមណេរនិងអធិមុត្តកសាមណេរ ក្នុងគាថាវណ្ណនាជាដើម ថា "**យោ ច វស្សសតំ ជីវេ ទុស្សីលោ**" ដូច្នេះ ក្នុងសហស្សវគ្គ ក៏គួរសំដែងផងដែរ ។

(១០៩) ចំណែកក្នុងពាក្យ ថា "ញុំាងខ្លួន ដែលមិនមានសទ្ធា ឲ្យតាំងនៅ ក្នុងសទ្ធាសម្បទា" នេះ នឹងពោលរឿង (ដូចតទៅ) ÷

## ( រឿងព្រះភារទ្វាជត្ថេរ )

ព្រាហ្មណ៍ ឈ្មោះថា ភារទ្វាជគោត្រ ជាមិច្ឆាទិដ្ឋិក៍ អាស្រ័យនៅក្នុងទីក្រុងរាជគ្រឹះ ។ ព្រាហ្មណ៍នោះ ជាអ្នកមិនមានសទ្ធា ជាអ្នកមិនជ្រះថ្លាហើយ, កាលបើបុគ្គលពោល ថា "**ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ**" ដូច្នេះ, តែងបិទនូវត្រចៀកទាំង ២ ជាអ្នករឹងត្អឹង ប្រៀបដូចជាដង្គត់នៃឈើសង្កែ ។ ចំណែកនាងព្រាហ្មណី ឈ្មោះ ធនញ្ជានី របស់ព្រាហ្មណ៍នោះ ជាសោតាបន្ន ជាអ្នកមានសទ្ធា ជ្រះថ្លាហើយ ។ តាមប្រក្រតី នាងព្រាហ្មណីនោះ ទោះជាឈរក្តី អង្គុយក្តី ក្អកក្តី កណ្តាស់ក្តី តែងធ្វើការនមស្សការ ថា "**នមោ ពុទ្ធស្ស**" ដូច្នេះជាដើម ។

ក្រោយមក ថ្ងៃមួយ ព្រាហ្មណ៍ប្រាថ្នានឹងឲ្យបាយបាយាសដែលមានទឹកតិច ដល់ព្រាហ្មណ៍ ៥០០ នាក់ ទើបអញ្ជើញព្រាហ្មណ៍ទាំងឡាយ ដើម្បីបរិភោគអាហារក្នុងថ្ងៃស្អែក ហើយបានប្រាប់នឹងនាងព្រាហ្មណី ថា "ម្នាលនាងដ៏ចំរើន ក្នុងថ្ងៃស្អែក ពួកព្រាហ្មណ៍ចំនួន ៥០០ នាក់ នឹងបរិភោគ ក្នុងផ្ទះរបស់យើង, នាងធ្វើ

នូវការនមស្សការណា ដល់សមណៈត្រង៉ោលនោះ, ក្នុងថ្ងៃស្អែក ត្រឹមតែមួយថ្ងៃ ចូរនាងកុំធ្វើ នូវការនមស្សការនោះឡើយ, ព្រោះថា ព្រាហ្មណ៍ទាំងឡាយ បានឮពាក្យនោះហើយ នឹងមិនពេញចិត្ត, ចូរនាងកុំបំបែកបង អំពីព្រាហ្មណ៍ទាំងឡាយឡើយ"។

នាងព្រាហ្មណី ពោល ថា "ចូរអ្នកបែកអំពីពួកព្រាហ្មណ៍ ឬក៏ពួកទេវតាក៏ដោយ, នាងខ្ញុំរឭកនូវព្រះសាស្ដាអង្គនោះ កាលមិនបាននមស្សការ នឹងមិនអាច ដើម្បីនឹងស្ថិតនៅបានឡើយ"។

ព្រាហ្មណ៍នោះ ទាញយកដាវមកហើយ ពោលថា "នែនាងដ៏ចំរើន បើថ្ងៃស្អែក កាលបើពួកព្រាហ្មណ៍ទាំងនោះអង្គុយហើយ, នាងនមស្សការ នូវសមណៈត្រង៉ោលនោះ, ខ្ញុំនឹងកាត់នាងឯងដោយដាវនេះ"។

ធម្មតាព្រះអរិយសាវ័កទាំងឡាយ ជាអ្នកដែលបុគ្គលធ្វើឲ្យកម្រើកញាប់ញ័របាន ដោយលំបាក ដូចជាផែនដី និងជាអ្នកដែលគេបង្វិលត្រឡប់បាន ដោយលំបាក ដូចជាភ្នំព្រះសុមេរុ, ព្រោះហេតុនោះ នាងព្រាហ្មណីនោះ ទើបពោលហើយ យ៉ាងដូច្នេះ ថា

"ម្នាលព្រាហ្មណ៍ បើអ្នកកាត់ នូវនាងខ្ញុំ ទៅជា
កំណាត់តូច-ធំ ពិតមែន, នាងខ្ញុំនឹងមិនវៀរចាក
សាសនា នៃព្រះពុទ្ធជាអ្នកប្រសើរបានឡើយ"។

ព្រាហ្មណ៍នោះ កាលមិនអាចដើម្បីនឹងប៉ះពាល់ឬក៏ប្រហារនូវនាងព្រាហ្មណីនោះបាន ទើបពោល ថា “ចូរនាងធ្វើនូវរបស់ដែលនាងចូលចិត្តចុះ” ហើយ ក៏បានបោះដាវទៅលើទីដេក ។

ក្នុងថ្ងៃស្អែកឡើង ព្រាហ្មណ៍បានចាត់ចែងហើយនូវបាយបាយាស ដើម្បីព្រាហ្មណ៍ទាំងឡាយ ឲ្យគេប្រាប់ពេលវេលាហើយ ។ ព្រាហ្មណ៍ទាំងនោះ បានមកអង្គុយហើយ ។ ចំណែកព្រាហ្មណ៍ក៏បានអង្គុយលើជួរជាមួយគ្នានឹងព្រាហ្មណ៍ទាំងនោះ ។

គ្រានោះ នាងព្រាហ្មណីចាប់នូវវែកមាស អង្គាសព្រាហ្មណ៍ទាំងឡាយ ក្នុងរោងភត្ត កាលបង្អោនភត្តទៅ ដើម្បីព្រាហ្មណ៍នោះក៏បានរអិលដួលលើបន្ទះក្តារដែលក្រាលហើយមិនល្អ ។ ទុក្ខវេទនាបានកើតឡើងហើយ ។ ក្នុងខណៈនោះឯង នាងព្រាហ្មណីរឭកដល់ព្រះសាស្តា ផ្គងអញ្ជលីលើក្បាល, វត្តវេឡុវន ស្ថិតនៅដោយទិសណា, ក៏បានប្រណម្យអញ្ជលី ដោយទិសនោះ ហើយបានបន្លឺឧទាន ៣ ដង ថា “**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**” ដូច្នេះ ។

ក៏ក្នុងខណៈនោះ បណ្តាព្រាហ្មណ៍ទាំងនោះ ពួកព្រាហ្មណ៍ខ្លះបរិភោគហើយ, ពួកខ្លះ កំពុងតែបរិភោគ, ពួកខ្លះ គ្រាន់តែផ្តើមដាក់ដៃចុះ, ពួកខ្លះ គ្រាន់តែគេដាក់ភោជន នៅខាងមុខ ។

ព្រាហ្មណ៍ទាំងឡាយនោះ គ្រាន់តែឮសំឡេងនោះ ប្រៀបដូចជាត្រូវញញួរទំហំប៉ុនភ្នំសុមេរុប្រហារហើយ ចំលើក្បាល ប្រៀបដូចជាត្រូវលំពែងចាក់ទម្លុះ ត្រង់ត្រចៀកទាំង ២ ដល់នូវទុក្ខទោមនស្សហើយ ក្រោធខឹង ថា "ពួកយើង ត្រូវមនុស្សអ្នកកាន់លទ្ធិដទៃនេះ ឲ្យចូលមកកាន់ផ្ទះហើយ" ដូច្នេះ បានចោលដុំបាយក្នុងដៃ ខ្លះដុំបាយដែលបៀមនឹងមាត់ហើយ ដេរប្រទេចព្រាហ្មណ៍ ចៀសចេញទៅហើយ ។

ចំណែកព្រាហ្មណ៍ ក៏បានដេរប្រទេច នូវនាងព្រាហ្មណីដោយប្រការផ្សេងៗ កាលមិនអាចដើម្បីនឹងធ្វើអ្វីបាន ទើបពោលថា "ក៏វាយ៉ាងដូច្នេះឯង នាងថោកទាបនេះ ទើបសរសើរគុណរបស់សមណៈត្រងោលនោះ ក្នុងទីគ្រប់កន្លែង, នែនាងថោកទាបអញនឹងលើកវាទៈនៃសាស្តារបស់នាងនោះ ឥឡូវនេះ" ហើយបានក្រោធខឹងមិនពេញចិត្ត ដើរទៅវត្តវេឡុវន មិនថ្វាយបង្គំព្រះសាស្តាឡើយ បានអង្គុយក្នុងទីដ៏សមគួរ ហើយក្រាបទូលសួរបញ្ហា ថា ÷

"បុគ្គលសម្លាប់នូវអ្វីហ្ន៎ ? ទើបនៅជាសុខ,
បុគ្គលសម្លាប់នូវអ្វីហ្ន៎ ? ទើបមិនសោកសៅ,
បពិត្រព្រះគោតម ព្រះអង្គទ្រង់ពេញព្រះទ័យ
នូវការសម្លាប់ធម៌ឯកអ្វី ?" ។

គ្រានោះ ព្រះសាស្ដា កាលនឹងទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបញ្ហា ដល់ព្រាហ្មណ៍នោះ ទើបទ្រង់ត្រាស់ ថា ៖

"បុគ្គលសម្លាប់សេចក្ដីក្រោធបានហើយ រមែងនៅជាសុខ, បុគ្គលសម្លាប់សេចក្ដីក្រោធបានហើយ រមែងមិនសោកសៅ, ម្នាលព្រាហ្មណ៍ ព្រះអរិយៈទាំងឡាយ រមែងសរសើរនូវការសម្លាប់នូវសេចក្ដីក្រោធ ដែលមានឫសជាពិស មានរសផ្អែមឆ្ងាញ់ជាទីបំផុត, ព្រោះថា បុគ្គលសម្លាប់ នូវសេចក្ដីក្រោធនោះ បានហើយ រមែងមិនសោកសៅ " ។

បណ្ដាបទទាំងនោះ បទ ថា "**ឃត្វា**" ប្រែថា សម្លាប់បានហើយ ។ សូម្បីក្នុងគម្ពីរសទ្ទនីតិ ក៏លោកពោលន័យទុកហើយ ថា "**ហន** ធាតុ ប្រព្រឹត្តទៅ ក្នុងការបៀតបៀន សម្រេចរូប ថា **ឃត្វា** ប្រែថា សម្លាប់ហើយ" ។ ២ បទ ថា "**សុខំ សេតិ**" មានសេចក្ដីថា បុគ្គលឈ្មោះថា រមែងនៅជាសុខ ព្រោះភាវៈជាអ្នកដែលសេចក្ដីក្ដៅក្រហាយ គឺសេចក្ដីក្រោធ ដុតរោលមិនបាន ។ ឈ្មោះថា រមែងមិនសោកសៅ ព្រោះជាអ្នកមានទោមនស្ស

សាបសូន្យហើយ ព្រោះការសាបសូន្យទៅនៃសេចក្តីក្រោធ ។ បទ ថា "**វិសមូលស្ស**" បានដល់ មានទុក្ខជាផល ។ បទ ថា "**មធុរគ្គស្ស**" គឺ មានសេចក្តីសុខជាទីបំផុត ។ មែនពិត សេចក្តីសុខ រមែងកើតឡើង ព្រោះជេរតប ដល់បុគ្គលដែលជេរហើយ និងព្រោះប្រហារតប ដល់បុគ្គលដែលប្រហារហើយ ; ព្រោះហេតុនោះ ពាក្យ ថា "**មធុរំ**" ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដៅយកសេចក្តីសុខនោះ ។ ក៏ **អគ្គ** ស័ព្ទ ក្នុងបទ ថា "**អគ្គស្ស**" នេះ ជាស័ព្ទសំដែងនូវទីបំផុត ។ បណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើម ឈ្មោះថា ព្រះអរិយៈ ។

ព្រាហ្មណ៍ បានស្តាប់ទេសនា របស់ព្រះសាស្តា ត្រឡប់ជាមានសទ្ធា បានបួសហើយ ឧបសម្បទ ក្នុងសំណាក់ព្រះសាស្តាហើយ ក៏បានសម្រេចជាព្រះអរហន្ត អស់កាលមិនយូរឡើយ ។

រឿង ព្រះភារទ្វាជត្ថេរ មកក្នុងអដ្ឋកថាព្រាហ្មណសំយុត្ត ។

សូម្បីរឿងកាឡកសេដ្ឋី ក្នុងអដ្ឋកថាកាឡការាមសូត្រ ក្នុងចតុកនិបាត អង្គុត្តរនិកាយ ក៏គប្បីសំដែងផងដែរ ។

(១១០) ក៏ក្នុងពាក្យ ថា "ញ៉ាំងខ្លួនដែលកំណាញ់ស្វិតស្វាញឲ្យតាំងនៅក្នុងចាគសម្បទា" នេះ នឹងសំដែងរឿង (ដូចតទៅនេះ)

# ( រឿង កោសិយសេដ្ឋី )

ក្នុងទីក្រុងពារាណសី សេដ្ឋីម្នាក់ មានទ្រព្យ ៨០ កោដិ បានឱ្យបុគ្គលកសាងរោងទាន ៦ ខ្នង គឺ ក្បែរទ្វារព្រះនគរ ៤ ខ្នង ត្រង់កណ្ដាលព្រះនគរ ១ ខ្នង និងក្បែរទ្វារនៃទីលំនៅ ១ ខ្នង បានលះបង់ទ្រព្យ ៦ សែន ឱ្យមហាទាន រៀងរាល់ថ្ងៃ ។ សេដ្ឋីនោះ ឱ្យទានហើយ ទូន្មានកូន រហូតអស់ជីវិត ថា " ចូរកូន កុំកាត់ផ្ដាច់នូវតំណនៃទាន របស់ឪពុកនេះឡើយ " ហើយ បានកើតជាស្ដេចសក្កទេវរាជ ក្នុងទីបំផុតនៃជីវិត ។

ចំណែកកូនរបស់សេដ្ឋីនោះ ក៏បានឱ្យទាន យ៉ាងដូច្នោះដែរ ហើយកើតជាចន្ទទេវបុត្រ ។ បុត្ររបស់ចន្ទទេវបុត្រនោះ កើតជាសុរិយទេវបុត្រ , បុត្ររបស់សុរិយទេវបុត្រនោះ កើតជាមាតលីទេវបុត្រ, បុត្ររបស់មាតលីទេវបុត្រនោះ កើតជាបញ្ចសិខទេវបុត្រ ។ ក៏បុត្ររបស់បញ្ចសិខទេវបុត្រនោះ កើតជាសេដ្ឋី ឈ្មោះថា កោសិយៈ ជាអ្នកមានទ្រព្យ ៨០ កោដិដូចគ្នា ។

កោសិយសេដ្ឋីនោះ គិត ថា " ឪពុកនិងជីតា របស់អញ ជាមនុស្សល្ងង់ខ្លៅ បានលះបង់ចោលនូវទ្រព្យ ដែលកើតមានមក ដោយលំបាក, អញនឹងថែរក្សាទ្រព្យនោះ, នឹងមិនឱ្យទ្រព្យអ្វីមួយ ដល់អ្នកណាមួយឡើយ " ដូច្នេះហើយ ទើបឱ្យបុគ្គលរុះរើរោងទាន

ទាំងឡាយហើយ ឲ្យយកភ្លើងដុត ជាអ្នករឹងត្អឹងនិងកំណាញ់ស្អិតស្អាញ ប្រមូលទ្រព្យទុកតែម្យ៉ាង មិនបរិភោគ ដោយខ្លួនឯង មិនចែកឲ្យ ដល់បុគ្គលដែលគួរឲ្យ មានកូននិងប្រពន្ធជាដើម ។

ក៏សេដ្ឋីនោះ បរិភោគនូវភ័ត្តព្រមទាំងកន្ទក ដែលមានទឹកបាយជាគម្រប់ ២ ស្លៀកសំពត់សាច់គ្រើម បាំងឆ័ត្រដែលធ្វើដោយស្លឹកឈើ លើក្បាល ធ្វើដំណើរ ដោយរថចាស់ដែលទឹមដោយគោចាស់ ។ ទ្រព្យមានចំនួនប៉ុណ្ណោះ របស់សេដ្ឋីជាអសប្បុរសនោះ កើតប្រៀបដូចជាផ្លែដូង ដែលសុនខបានហើយ ដូច្នោះឯង ។

ថ្ងៃមួយ សេដ្ឋីនោះ កាលទៅកាន់ព្រះរាជសំណាក់ ទើបគិត ថា "អញនឹងនាំយកអនុសេដ្ឋីទៅផង" ដូច្នេះហើយ ក៏បានទៅកាន់ផ្ទះរបស់អនុសេដ្ឋីនោះហើយ ។

ក្នុងខណៈនោះ អនុសេដ្ឋីនោះ កំពុងតែបរិភោគនូវបាយបាយាស ដែលផ្សំហើយ ដោយទឹកដោះខាប់ ទឹកដោះថ្លា ទឹកឃ្មុំដែលរម្ងាស់ហើយ និងផង់នៃស្ករក្រួស ឃើញសេដ្ឋីនោះដើរមក ក៏ក្រោកចាកអាសនៈហើយ ពោល ថា "ម្នាលមហាសេដ្ឋី សូមលោកអញ្ជើញមកចុះ, សូមអញ្ជើញអង្គុយ ក្នុងទីនេះ, ពួកយើង នឹងបរិភោគ" ។

សេដ្ឋីនោះ គ្រាន់តែឃើញនូវបាយបាយាសប៉ុណ្ណោះ ក៏កើត

ទឹកមាត់ច្រោកក្នុងមាត់ ជាអ្នកប្រាថ្នាដើម្បីនឹងបរិភោគ ក៏ពិតមែន ទោះជាដូច្នោះក៏ដោយ គាត់គិតថា "បើអញបរិភោគ, ក្នុងពេលដែលអនុសេដ្ឋីនេះ មកផ្ទះរបស់អញ អញនឹងត្រូវតែធ្វើសក្ការៈតបវិញ, កាលបើដូច្នោះ, ទ្រព្យរបស់អញ ក៏នឹងវិនាសសាបសូន្យ" ដូច្នេះហើយ គ្រាន់តែអង្គុយប៉ុណ្ណោះ សូម្បីអនុសេដ្ឋីនោះ ដណ្ដឹងសួរញយៗ ក៏ពោលថា "ខ្ញុំទើបតែបរិភោគមកអម្បាញ់មិញនេះឯង, ខ្ញុំបរិភោគឆ្អែតគ្រប់គ្រាន់ហើយ" ហើយ មិនបរិភោគឡើយ ។

ក្នុងពេលដែលអនុសេដ្ឋីបរិភោគរួចហើយ មហាសេដ្ឋីនោះ ក៏នាំអនុសេដ្ឋីនោះ ទៅកាន់ព្រះរាជសំណាក់ ត្រឡប់មកកាន់ផ្ទះរបស់ខ្លួនវិញហើយ សូម្បីត្រូវសេចក្ដីចំណង់ក្នុងបាយបាយាស បៀតបៀនហើយ ក៏មិនប្រាប់ដល់អ្នកណាមួយឡើយ ព្រោះភ័យតែអស់ទ្រព្យ កាលអត់ទ្រាំនឹងសេចក្ដីស្រេកឃ្លាន ក៏កើតជាមនុស្សមានរោគលឿងៗ ហើយ ដោយលំដាប់ ។ កាលបើដូច្នោះ, មហាសេដ្ឋីនោះ ក៏មិនប្រាប់ ព្រោះខ្លាចតែអស់ទ្រព្យ ក្រោយមកទើបមានកម្លាំងខ្សោយ ចូលទៅដេកឱបនូវទីដេក ត្រូវភរិយាសួរញយៗ ទើបប្រាប់ហើយ នូវហេតុនោះ ។

ភរិយានោះ ស្ដាប់ហេតុនោះហើយ ទើបពោលថា "តើបងជាមនុស្សក្រីក្រឬ ?, នាងខ្ញុំ នឹងដាំបាយបាយាស ធ្វើឲ្យគ្រប់គ្រាន់

ដល់ជនទាំងឡាយ ដែលរស់នៅក្នុងទីក្រុងពារាណសីទាំងមូល ” ។

សេដ្ឋីនោះ ក្រោធខឹង ដូចជាគេយកដំបងមកវាយចំក្បាល ហើយពោល ថា “បងដឹងថា នាងជាអ្នកមានទ្រព្យច្រើន, បើទ្រព្យដែលនាងនាំមកហើយ អំពីផ្ទះនៃត្រកូលរបស់នាងមាន, ចូរនាងចម្អិនបាយបាយាស ឲ្យដល់ពួកអ្នកនគរទាំងឡាយចុះ ” ។

ភរិយា. បើដូច្នោះ នាងខ្ញុំ នឹងចម្អិនបាយបាយាស ឲ្យបានគ្រប់គ្រាន់ ដល់ពួកជនដែលនៅលើថ្នល់ជាមួយគ្នា ។

មហាសេដ្ឋី. នឹងមានប្រយោជន៍អ្វី ដោយជនទាំងនោះ ។

ភរិយា. បើដូច្នោះ នាងខ្ញុំ នឹងចម្អិនបាយបាយាស ឲ្យបានគ្រប់គ្រាន់ ដល់ពួកជនដែលនៅក្នុងផ្ទះមួយ ៗ ៧ ៗ គ្រួសារ ខាងនេះផង ខាងនោះផង, បើដូច្នោះ នាងខ្ញុំ នឹងចម្អិន ឲ្យគ្រប់គ្រាន់ដល់ជនអ្នកនៅជិតខាង ក្នុងផ្ទះនេះ, បើដូច្នោះ នាងខ្ញុំ នឹងចម្អិន ឲ្យគ្រប់គ្រាន់ ដល់ជនដែលជាផៅពង្សប៉ុណ្ណោះ ។

មហាសេដ្ឋី. នឹងមានប្រយោជន៍អ្វី ដោយជនទាំងនោះ ។

ភរិយា. បើដូច្នោះ នាងខ្ញុំ នឹងចម្អិន ឲ្យគ្រប់គ្រាន់ ដល់បងផង ដល់នាងខ្ញុំផង ។

មហាសេដ្ឋី. នាងឯង ជាអ្នកណាទៅ ?, បាយបាយាសរមែងមិនគួរ ដល់នាងឡើយ ។

ភរិយា. បើដូច្នោះ នាងខ្ញុំនឹងចម្អិន ឲ្យគ្រប់គ្រាន់ ដល់បងតែម្នាក់ឯងប៉ុណ្ណោះ ។

មហាសេដ្ឋីនោះ ពោល ថា "ត្រូវហើយ ! ទោះបីជានាងចម្អិន ដើម្បីបង ចូរនាងកុំចម្អិន ក្នុងទីនេះឡើយ, ជនជាច្រើននឹងប្រាថ្នាប៉ុនប៉ង, ចូរនាងឲ្យនូវអង្ករ ១ កំបង់, ទឹកដោះស្រស់ ៤ ភាគ, ស្ករក្រួសត្រឹមតែមួយចឹប, ទឹកដោះថ្លា ពេញ ១ ដប, ទឹកឃ្មុំប្រមាណប៉ុណ្ណោះដែរ និងភាជនៈសម្រាប់ចម្អិន ១ ផងដែរ, បងនឹងចូលទៅព្រៃហើយ ចម្អិនបរិភោគ ក្នុងទីនោះ" ។

ភរិយានោះ បានធ្វើហើយ យ៉ាងដូច្នោះឯង ។

មហាសេដ្ឋីនោះ ប្រើឲ្យអ្នកបម្រើយករបស់របរទាំងអស់នោះទៅព្រៃហើយ ឲ្យធ្វើជើងក្រាន ក្បែរគុម្ពឈើមួយ ជិតមាត់ស្ទឹង ឲ្យនាំយកឧសនិងទឹកមកហើយ បញ្ជូនអ្នកបម្រើនោះទៅ ដោយប្រាប់ ថា "ចូរអ្នកទៅឈរនៅត្រង់ផ្លូវមួយ ឃើញអ្នកណាមួយភ្លាមហើយ ចូរឲ្យសញ្ញាដល់អញ, ក្នុងពេលដែលអញហៅអ្នកមកហើយ អ្នកគប្បីមក" ហើយ ទើបបង្កាត់ភ្លើងចម្អិនបាយបាយាសតែម្នាក់ឯង ។

ក្នុងខណៈនោះ ស្តេចសក្កទេវរាជ កាលទ្រង់ត្រួតមើលនូវដំណើរនៃទាន របស់ព្រះអង្គ ទ្រង់ជ្រាបនូវហេតុទាំងអស់នោះ

ហើយ ទើបទ្រង់ព្រះតម្រិះ ថា "មហាសេដ្ឋីនេះ ជាមនុស្សកំណាញ់ កាត់ផ្តាច់នូវវង្សរបស់អញហើយ នឹងកើតក្នុងនរក, អញនឹងឲ្យនូវឱវាទ ដល់មហាសេដ្ឋីនោះហើយ ធ្វើឲ្យគួរដល់ការកើតឡើង ក្នុងទីនេះ" ដូច្នេះហើយ ទ្រង់ត្រាស់ហៅ នូវចន្ទទេវបុត្រជាដើមមក ត្រាស់ប្រាប់រឿងរ៉ាវទាំងអស់ហើយ ទ្រង់ត្រាស់ ថា "ខ្ញុំនឹងទៅមុន, ក្នុងពេលដែលខ្ញុំ សុំនូវបាយបាយាសហើយអង្គុយ ពួកអ្នកទាំងឡាយ គប្បីមក តាមលំដាប់លំដោយចុះ" ហើយ ទ្រង់បានបន្លំភេទជាព្រាហ្មណ៍ ស្តេចយាងទៅរកមហាសេដ្ឋីនោះ ទ្រង់ត្រាស់សួរ ថា "ម្នាលអ្នកដ៏ចំរើន ! ផ្លូវទៅកាន់ក្រុងពារាណសី គឺផ្លូវខាងណា ?"។

សេដ្ឋី ពោល ថា "តើអ្នកជាមនុស្សឆ្កួតឬ ? មិនស្គាល់ទាំងផ្លូវទៅកាន់ទីក្រុងពារាណសីសោះឡើយ, ចូរអ្នក កុំមកខាងផ្លូវនេះ សូមអញ្ជើញទៅខាងផ្លូវនុ៎ះចុះ" ។

ស្តេចសក្កទេវរាជ ទ្រង់ធ្វើដូចជាស្តាប់មិនឮ ទ្រង់ត្រាស់សួរ ថា "តើអ្នកនិយាយថាដូចម្តេច ?" ហើយ ទ្រង់ស្តេចយាងទៅរកមហាសេដ្ឋីនោះភ្លាម ។

មហាសេដ្ឋីនោះ ស្រែក ថា "នែវើយ ! ព្រាហ្មណ៍អ្នកមានធាតុថ្លង់ តើអ្នកមក ខាងផ្លូវនេះធ្វើអ្វី ? ចូរទៅខាងផ្លូវនុ៎ះចុះ" ។

ស្តេចសក្កទេវរាជ ទ្រង់ត្រាស់សួរ ថា "ម្នាលអ្នកដ៏ចំរើន !

អ្នកស្រែក ព្រោះហេតុអ្វី ?, ផ្សែងនិងភ្លើង រមែងប្រាកដ, អ្នកកំពុងតែចម្អិនបាយបាយាស, ទីជាទីអញ្ជើញព្រាហ្មណ៍ គប្បីមាន, ក្នុងពេលដែលពួកព្រាហ្មណ៍បរិភោគ សូម្បីខ្ញុំ ក៏នឹងបានបន្តិចបន្តួចផងដែរ " ។

មហាសេដ្ឋី . ក្នុងទីនេះ មិនមានការអញ្ជើញព្រាហ្មណ៍ទេ, ចូរអ្នកអញ្ជើញទៅខាងផ្លូវផ្សេងទៀតចុះ ។

ស្ដេចសក្កទេវរាជ . បើដូច្នោះ ក្នុងពេលដែលអ្នកបរិភោគ ខ្ញុំនឹងបានបន្តិចបន្តួចដែរ ។

មហាសេដ្ឋី . សូម្បីតែមួយគ្រាប់ ក៏ខ្ញុំមិនឲ្យដល់អ្នកដែរ, បាយបាយាសបន្តិចបន្តួចនេះ ល្មមគ្រាន់តែញ៉ាំងអត្តភាព របស់ខ្ញុំឲ្យប្រព្រឹត្តទៅបាន ។

ស្ដេចសក្កទេវរាជ ទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ទើបទ្រង់ត្រាស់គាថា ថា ÷

" បុគ្គលគប្បីឲ្យនូវវត្ថុតិច អំពីវត្ថុតិច គប្បីឲ្យវត្ថុពាក់កណ្ដាល អំពីវត្ថុពាក់កណ្ដាល គប្បីឲ្យវត្ថុច្រើន អំពីវត្ថុច្រើន, ការមិនឲ្យ មិនសមគួរទេ, ម្នាលកោសិយសេដ្ឋី ព្រោះហេតុនោះ ខ្ញុំសូម (១)

១ ត្រៃបិដក ភាគទី ៥៩ / ទំព័រទី ៥៣ ។ ភាគទី ៦១ / ទំព័រទី ១៣១ ។

និយាយនឹងអ្នក ចូរអ្នកឲ្យទានទាំងឡាយផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គផង, បុគ្គលបរិភោគម្នាក់ឯង មិនបានសេចក្ដីសុខឡើយ" ។

បណ្ដាបទទាំងនោះ បាទគាថា ថា "**អនុមជ្ឈតោ មជ្ឈកំ**" មានសេចក្ដីថា គប្បីបែងចែកសូម្បីវត្ថុតិច ត្រង់ពាក់កណ្ដាល ធ្វើទៅជា ២ ចំណែកហើយ ឲ្យមួយចំណែក ទើបបែងចែក ត្រង់ពាក់កណ្ដាល សូម្បីចាកវត្ថុពាក់កណ្ដាល ដែលសេសសល់ អំពីវត្ថុតិចនោះម្ដងទៀត ហើយឲ្យមួយចំណែកតែម្ដង ។

បាទគាថា ថា "**អទានំ នុបបជ្ជតិ**" មានសេចក្ដីថា បុគ្គលនឹងឲ្យវត្ថុតិច ឬច្រើន ក៏ដោយចុះ, ធម្មតាការមិនឲ្យ រមែងមិនសមគួរទេ, ការឲ្យនោះឯង រមែងមានផលច្រើន ដោយពិត ។

ពាក្យ ថា "**តំ តំ**" មានសេចក្ដីថា ព្រោះហេតុនោះ ខ្ញុំនឹងនិយាយនឹងអ្នក គឺ អ្នកដ៏ចំរើន ។ បទ ថា "**ភុញ្ជ ច**" មានសេចក្ដីថា ចូរអ្នកឲ្យទានទាំងឡាយផង ចូរបរិភោគខ្លួនឯងផង ។

បាទគាថា ថា "**អរិយមគ្គំ សមារុហ**" មានសេចក្ដីថា ចូរអ្នកឡើងកាន់មាគ៌ា នៃព្រះអរិយៈទាំងឡាយ បានដល់ សប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើម ជាអ្នកត្រេកអរក្រៃលែងក្នុងទាន ។

បទ ថា " ឯកាសី " បានដល់ អ្នកបរិភោគតែម្នាក់ឯង ។ បទ ថា "លភតេ" ប្រែថា រមែងបាន ។

សេដ្ឋី ស្ដាប់ពាក្យនោះហើយ ក៏ពោល ថា " ម្នាលព្រាហ្មណ៍ អ្នកនិយាយត្រូវចិត្ត (ខ្ញុំ), អ្នកនឹងបានបន្តិច, អញ្ជើញអ្នកអង្គុយសិនចុះ " ។ ស្ដេចសក្កទេវរាជ ទ្រង់គង់ហើយ ។

បន្ទាប់ពីនោះមក ចន្ទទេវបុត្រ ក៏បានមក ដោយន័យនោះឯង ហើយ បានពោលគាថា ថា ៖

"បុគ្គលណា កាលភ្ញៀវអង្គុយហើយ បរិភោគ(១) ភោជនតែម្នាក់ឯង, ការបូជា របស់បុគ្គល នោះ ឈ្មោះថា ឥតអំពើផង, ការព្យាយាមញ៉ាំង ទ្រព្យឲ្យកើតឡើង របស់បុគ្គលនោះ ឈ្មោះថា ឥតអំពើផង, ម្នាលកោសិយសេដ្ឋី ព្រោះ ហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក ។ ល ។ បុគ្គលបរិភោគម្នាក់ឯង មិនបានសេចក្ដីសុខទេ" ។

ការធ្វើពលិកម្ម ក្នុងស្ថានទីទាំងឡាយ មានស្រះនិងទន្លេ ជាដើម ដើម្បីឲ្យកើតទ្រព្យ ឈ្មោះថា ការបូជា ក្នុងគាថានោះ ។ សេចក្ដីព្យាយាមដែលតាំងទុក ដោយអំណាចការញ៉ាំងទ្រព្យឲ្យកើត

---

១ ត្រៃបិដក ភាគទី ៥៩ / ទំព័រទី ២៥៣ ។

ឡើង ឈ្មោះថា សេចក្តីព្យាយាមញ៉ាំងទ្រព្យឲ្យកើតឡើង ។

សេដ្ឋី ពោល ថា “បើដូច្នោះ ចូរអ្នកអង្គុយសិនចុះ, អ្នកនឹងបានបន្តិច” ។ ចន្ទទេវបុត្រនោះឯង បានអង្គុយហើយ ។

បន្ទាប់ពីនោះមក សុរិយទេវបុត្រ ក៏បានមក ដោយន័យនោះដូចគ្នាដែរ ហើយពោលគាថា ថា ៖

“បុគ្គលណា កាលភ្ញៀវអង្គុយហើយ មិនបរិភោគ(១)
ភោជនតែម្នាក់ឯង, ការបូជា របស់បុគ្គលនោះ
ឈ្មោះថា រមែងមានផលពិតផង ការព្យាយាម
ញ៉ាំងទ្រព្យឲ្យកើត របស់បុគ្គលនោះ ឈ្មោះថា
រមែងមានផលពិតផង, ម្នាលកោសិយសេដ្ឋី
ព្រោះហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក ។ល។
បុគ្គលបរិភោគម្នាក់ឯង មិនបានសេចក្តីសុខទេ”។

ពាក្យដែលសេសសល់ ដូចគ្នានឹងពាក្យមុន ។

បន្ទាប់ពីនោះមក មាតលិទេវបុត្រ មកហើយ បានពោល ថា ៖

“បុគ្គលណា ចូលទៅរកស្រះទាំងពួងហើយ បូជា
ក្នុងទន្លេផង ក្នុងស្រះបោក្ខរណីផង ក្នុងកំពង់

---

១ ត្រៃបិដក ភាគទី ៥៩ / ទំព័រទី ២៥៤ ។

ឈ្មោះ ទោណៈផង ក្នុងកំពង់ ឈ្មោះតិម្ពរុផង ក្នុងស្ទឹងធំដែលមានខ្សែទឹករហ័សផង, ប្រសិនបើការបូជា របស់បុគ្គលនោះ ក្នុងទីនោះ មានផល និង ការព្យាយាមញ៉ាំងទ្រព្យឲ្យកើត របស់បុគ្គលនោះ ក្នុងទីនោះ មានផលមែន, បុគ្គលណា កាលដែលភ្ញៀវអង្គុយហើយ មិនបរិភោគភោជនតែម្នាក់ឯង, ពាក្យដែលគួរពោលក្នុងបុគ្គលនោះ រមែងមិនមាន, ម្នាលកោសិយសេដ្ឋី ព្រោះហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក ។ល។ បុគ្គលបរិភោគម្នាក់ឯង មិនបានសេចក្ដីសុខទេ" ។

បណ្ដាបទទាំងនោះ ២ បទ ថា "**សរំ សពិ្ភ**" មានសេចក្ដីថា បុរសណា កាលធ្វើនូវពលិកម្ម ដល់អមនុស្សទាំងឡាយ មាននាគនិងយក្សជាដើម ចូលទៅក្នុងទីទាំងឡាយមានសមុទ្រ ត្រពាំង និងស្រះបោក្ខរណីជាដើម ស្រះណាមួយ ហើយបូជា គឺ ធ្វើពលិកម្មក្នុងទីនោះ ។ បទ ថា "**ពហុកាយ**" បានដល់ ក្នុងស្ទឹង ។ បទ ថា "**គយាយ**" បានដល់ ក្នុងស្រះបោក្ខរណី ។ បទ ថា "**ទោណេ**" បានដល់ ក្នុងកំពង់ ឈ្មោះថា ទោណៈ ។ បទ ថា

“**តិម្ពរុតិត្ថស្មឹ**” បានដល់ ក្នុងកំពង់ ឈ្មោះ តិម្ពរុផង ។ បទ ថា “**មហាវហេ**” បានដល់ ក្នុងស្ទឹងធំ ដែលមានខ្សែរហ័សផង ។

បទ ថា “**អត្រ**” បានដល់ ក្នុងទីទាំងឡាយ មានស្រះជាដើម នោះ ។ ស័ព្ទ ថា “**ចេ**” ប្រែថា ប្រសិនបើ ។ បទ ថា “**អស្ស**” មានសេចក្តីថា ការបូជា និងសេចក្តីព្យាយាមញ៉ាំងទ្រព្យ ឲ្យកើតឡើង របស់បុគ្គលនោះ រមែងមាន គឺ រមែងមានផល មាន សេចក្តីសុខជាកម្រៃ រមែងសម្រេច, បុគ្គលណា កាលដែលភ្ញៀវ គឺ អាគន្តុកៈ អង្គុយហើយ មិនបរិភោគភោជនតែម្នាក់ឯង, ពាក្យ ដែលគួរនិយាយ ក្នុងបុគ្គលនោះ នឹងមិនមានឡើយ ។

ពាក្យដែលសេសសល់ ដូចគ្នានឹងពាក្យមុនដែរ ។

បន្ទាប់ពីនោះមក បញ្ចសិខទេវបុត្រ មកហើយ ពោល ថា÷

“ បុគ្គលណា កាលដែលភ្ញៀវអង្គុយហើយ[១] បរិភោគនូវភោជនតែម្នាក់ឯង, បុគ្គលនោះ ឈ្មោះថា រមែងលេបនូវសន្ទូច ដែលមានខ្សែ វែង ព្រមទាំងរនង ។ ម្នាលកោសិយសេដ្ឋី ព្រោះហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក ។ល។ បុគ្គលបរិភោគម្នាក់ឯង មិនបានសេចក្តីសុខទេ” ។

---

១ ត្រៃបិដក ភាគទី ៥៩ / ទំព័រទី ២៥៥ ។

សេដ្ឋី ស្តាប់ពាក្យនោះហើយ ក៏ដកដង្ហើមធំ ព្រោះការជួបប្រទះនឹងសេចក្តីទុក្ខ ទើបពោល ថា “បើដូច្នោះ សូមអ្នកអញ្ជើញអង្គុយចុះ, អ្នកនឹងបានបន្តិច” ។ ឯបញ្ចសិខទេវបុត្រនោះក៏បានអង្គុយហើយ ។ កាលបើព្រាហ្មណ៍ទាំង ៥ នាក់នោះអង្គុយហើយ យ៉ាងដូច្នេះឯង, សេដ្ឋី ក៏បានចម្អិនបាយបាយាសឆ្អិនហើយ ។ សេដ្ឋី លើកចុះអំពីជើងក្រានហើយ ពោល ថា “ចូរអ្នកទាំងឡាយ បេះស្លឹកឈើមក” ។

ព្រាហ្មណ៍ទាំងនោះ អង្គុយក្នុងទីនោះឯងហើយ លាតដៃទៅបេះស្លឹកជ្រៃ អំពីហិមវន្តប្រទេស ។

សេដ្ឋី ពោល ថា “បាយបាយាសដែលខ្ញុំគប្បីដាក់ឲ្យ ក្នុងស្លឹកឈើទាំងឡាយនេះ មិនមានទេ, ចូរអ្នកទាំងឡាយ នាំយកស្លឹកសង្កែមកចុះ” ។

ព្រាហ្មណ៍ទាំងនោះ នាំយកស្លឹកសង្កែទាំងឡាយនោះមកហើយ ។ បណ្តាស្លឹកសង្កែទាំងនោះ សន្លឹកមួយ ៗ មានទំហំប៉ុនក្រម៉ែលទាហាន ។ សេដ្ឋីនោះ បានយកវែកដួសបាយបាយាសឲ្យដល់ព្រាហ្មណ៍ទាំងអស់គ្នាហើយ ។

ក្នុងពេលដែលសេដ្ឋី ឲ្យបាយបាយាស ដល់ព្រាហ្មណ៍ចុងក្រោយគេបង្អស់ ការខ្វះខាត ក្នុងឆ្នាំង មិនមានប្រាកដឡើយ ។

សេដ្ឋីនោះ លុះឲ្យ (បាយបាយាស) ដល់ព្រាហ្មណ៍ទាំងនោះហើយ ក៏បានអង្គុយកាន់ផ្ទាំងហើយ ។

ក្នុងខណៈនោះ បញ្ចសិខទេវបុត្រ បានប្រែក្រឡាជាសត្វសុនខ ដើរបន្ទោបង់បស្សាវៈ ខាងមុខព្រាហ្មណ៍ទាំងឡាយនោះ ។ ព្រាហ្មណ៍ទាំងឡាយ បានយកដៃគ្របបាយបាយាស របស់ខ្លួន ។ ចំណែកសេដ្ឋី ក៏បានគ្របហើយ យ៉ាងដូច្នោះដែរ ។ ក៏ដំណក់ទឹកបស្សាវៈ ធ្លាក់លើខ្នងដៃ របស់សេដ្ឋីនោះហើយ ។ សេដ្ឋីនោះ ប្រាថ្នានឹងលាងដៃ ទើបពោល ថា "ចូរអ្នកទាំងឡាយ មើលនូវផ្ទាំងបាយ របស់ខ្ញុំផង" ហើយ ក៏បានចុះទៅកាន់ស្ទឹង ។

ក្នុងខណៈនោះឯង សត្វសុនខ ក៏បានបន្ទោបង់បស្សាវៈដាក់លើផ្ទាំងបាយ ។ សេដ្ឋីនោះ ឃើញសត្វសុនខនោះ កំពុងបន្ទោបង់បស្សាវៈ បានចាប់ដំបងយ៉ាងធំ គំរាមមកហើយ ។ សត្វសុនខក្លាយជាសត្វមានទំហំប៉ុនសេះអាជានេយ្យ បានដេញតាមសេដ្ឋីនោះ ដែលទៅហើយ ក្នុងទីនោះ ៗ ។ សេដ្ឋីនោះ ភ័យហើយព្រោះមរណភ័យ ទើបចូលទៅរកពួកព្រាហ្មណ៍ទាំងឡាយ ។ ព្រាហ្មណ៍ទាំងនោះឯង ក៏បានហោះទៅស្ថិតនៅលើអាកាសហើយ ។

សេដ្ឋីនោះ ឃើញនូវឫទ្ធិ របស់ព្រាហ្មណ៍ទាំងនោះហើយ ទើបសួរ ថា "តើពួកអ្នកទាំងឡាយ ជាអ្នកណាទៅ ?" ។

លំដាប់នោះ ស្ដេចសក្កទេវរាជ ទ្រង់ត្រាស់ ថា "អ្នកនេះ ជាចន្ទទេវបុត្រ, អ្នកនេះ ជាសុរិយទេវបុត្រ, អ្នកនេះ ជាមាតលិទេវបុត្រ, ខ្ញុំ ជាស្ដេចសក្កទេវរាជ, សត្វសុនខនេះ ជាបញ្ចសិខទេវបុត្រ" ហើយ ទ្រង់ត្រាស់ ថា "ពួកយើង មិនមែនមកហើយ ដើម្បីត្រូវការបាយបាយាស របស់អ្នកឡើយ, តែអ្នកជាញាតិ របស់ពួកយើង, ឥឡូវនេះ អ្នកជាបុគ្គលកំណាញ់ស្វិតស្វាញ, ក៏ធម្មតាពួកមនុស្សកំណាញ់ រមែងទៅកើតក្នុងនរក, ពួកមនុស្សដែលមិនកំណាញ់ រមែងទៅកើតក្នុងស្ថានសួគ៌, ព្រោះហេតុនោះ យើងទាំងឡាយ មកហើយ ព្រោះសេចក្ដីអាណិតអាសូរ ចំពោះអ្នកតែម្យ៉ាងប៉ុណ្ណោះ" ។

សេដ្ឋីនោះ ស្ដាប់ពាក្យនោះហើយ មានចិត្តត្រេកអរ ថា "បានឮថា ពួកទេវតាទាំងឡាយនេះ ជាអ្នកប្រាថ្នាប្រយោជន៍ ចំពោះអញ ជាអ្នកប្រាថ្នានឹងលើកអញ ឲ្យរួចផុតអំពីនរកហើយ ឲ្យស្ថិតនៅក្នុងស្ថានសួគ៌" ដូច្នេះហើយ ទើបពោល ថា "ចាប់ផ្ដើមអំពីពេលនេះតទៅ សូម្បីវត្ថុពាក់កណ្ដាល ៗ ចាកដុំបាយរបស់អញ ឈ្មោះថាអញមិនគប្បីឲ្យ មិនមានឡើយ, មួយទៀត អញបាននូវទឹក សូម្បីត្រឹមតែមួយទូកដៃ មិនបានឲ្យ (ដល់អ្នកណា) ហើយ ក៏នឹងមិនផឹកឡើយ" ហើយ បានទទួលពរ ក្នុងសំណាក់នៃស្ដេចសក្កទេវរាជ ។

ស្ដេចសក្កទេវរាជ ទ្រង់អប់រំទូន្មានសេដ្ឋីនោះហើយ ទ្រង់ញ៉ាំងសេដ្ឋីនោះ ឱ្យស្គាល់នូវផលនៃទាន ទ្រង់បានប្រទានបញ្ចសីលហើយ ទ្រង់ស្ដេចយាងទៅកាន់ទេវលោក ព្រមទាំងទេវបុត្រទាំងឡាយ មានចន្ទទេវបុត្រជាដើម ។

ចំណែកសេដ្ឋីនោះ ចូលទៅកាន់ព្រះនគរ បានញ៉ាំងព្រះរាជាឱ្យទ្រង់ត្រាស់អនុញ្ញាតឱ្យហើយ ទើបប្រកាស ថា "សូមពួកជនទាំងឡាយ ញ៉ាំងភាជនៈ ដែលខ្លួនកាន់ហើយៗ ឱ្យពេញបរិបូណ៌ហើយនាំយកទៅចុះ" ដូច្នេះហើយ បានឱ្យទ្រព្យ ដល់ពួកយាចកទាំងឡាយចេញហើយ ក្នុងខណៈនោះឯង បានកសាងបណ្ណសាលា ក្នុងចន្លោះនៃទន្លេគង្គា និងស្រះដែលកើតឯងមួយ ខាងទិសទក្សិណ អំពីហិមវន្តប្រទេស បួសហើយអាស្រ័យនៅក្នុងទីនោះ អស់កាលដ៏យូរធ្វើកាលកិរិយាហើយ ក៏បានកើតជាឧបបាតិកទេវបុត្រ បានឡើងជិះរថវេជយន្ត ដែលស្ដេចសក្កទេវរាជទ្រង់បានបញ្ជូនទៅ ហើយបានទៅកាន់សំណាក់ស្ដេចសក្កទេវរាជ មួយអន្លើនឹងមាតលិទេវបុត្រ ។

ស្ដេចសក្កទេវរាជ ទ្រង់ទតព្រះនេត្រឃើញទេវបុត្រនោះហើយ ទ្រង់មានព្រះទ័យត្រេកអរ ទ្រង់បានប្រទានហើយ នូវព្រះធីតា ព្រះនាមហិរីទេវី ដល់ទេវបុត្រនោះ ។ ឥស្សរិយយសដែលរកប្រមាណមិនបាន កើតមានហើយ ដល់ទេវបុត្រនោះ ។

ក្នុងពុទ្ធុប្បាទនេះ ទេវបុត្រនោះ កើតជាកុលបុត្រ ក្នុងទីក្រុងសាវត្ថី ស្តាប់ទេសនារបស់ព្រះសាស្តាហើយ ក៏បានបួស មានប្រក្រតីធ្វើឲ្យបរិបូណ៌ក្នុងសីល ដល់ព្រមដោយគុណគឺធុតង្គ មានអធ្យាស្រ័យក្នុងទាន ត្រេកអរខ្លាំងក្នុងទាន ជាអ្នកបំពេញសារាណិយធម៌ កាលបើបដិគ្គាហកៈមាន សូម្បីជាអ្នកអត់អាហារ ក៏ឲ្យនូវវត្ថុដែលខ្លួនបាន ហើយទាល់តែបាន ។

ព្រះសាស្តា ទ្រង់ធ្វើនូវការត្រេកអរដ៏ក្រៃលែង ក្នុងទាននោះ របស់ភិក្ខុរូបនោះ ឲ្យជាហេតុកើតឡើងហើយ ទើបទ្រង់ត្រាស់ ថា "ម្នាលភិក្ខុទាំងឡាយ ក្នុងកាលមុន ភិក្ខុរូបនេះ ជាអ្នកមិនឲ្យទានជាប្រក្រតី ជាមនុស្សកំណាញ់ មិនឲ្យសូម្បីទាំងប្រេងមួយដំណក់ដោយចុងស្មៅ, កាលបើដូច្នោះ តថាគតបានអប់រំទូន្មានភិក្ខុរូបនោះហើយ ពណ៌នាផលនៃទាន បានឲ្យស្ថិតនៅស៊ប់ក្នុងទានហើយ, ភិក្ខុរូបនោះ បានតាំងចិត្ត ថា 'អាត្មាអញ បានទឹកសូម្បីមួយទូកដៃ មិនបានឲ្យ (ដល់អ្នកណាមួយ) ហើយ នឹងមិនផឹកឡើយ' ហើយ បានទទួលពរ ក្នុងសំណាក់នៃតថាគត ព្រោះផលនៃទាននោះ ភិក្ខុរូបនោះទើបជាអ្នកមានអធ្យាស្រ័យក្នុងទាន ជាអ្នកត្រេកអរខ្លាំងក្នុងទាន" ហើយ ទើបត្រាស់សុធាភោជនជាតក ក្នុងអសីតិនិបាត ។

រឿងមច្ឆរិកោសិយៈ មកក្នុងអដ្ឋកថាសុធាភោជនជាតក ។

(១១១) រឿងរបស់ឥល្លីសសេដ្ឋី អ្នកផឹកសុរាក្បែរគុម្ពឈើមួយដើម ជាអ្នកដែលស្ដេចសក្កជាស្ដេចនៃទេវតា បានទូន្មានហើយ ស្គាល់ផលនៃទាន បានធ្វើបុណ្យហើយ ក៏បានទៅកើត ក្នុងឋានសួគ៌ ក្នុងអដ្ឋកថាឥល្លីសជាតក ថា "**ឧភោ ខញ្ជា ឧភោ កុណី**" ដូច្នេះជាដើម ក្នុងអដ្ឋមវគ្គនៃឯកនិបាតក្ដី , រឿងសេដ្ឋីកំណាញ់ដែលព្រះមហាមោគ្គល្លានត្ថេរ ដឹងថា សេដ្ឋីនោះ បានអង្គុយលើផ្ទៃខាងលើនៃប្រាសាទ ទី ៧ ដើម្បីបរិភោគនំអំបែងហើយ និមន្តទៅទូន្មានក្នុងទីនោះហើយ ប្រគេននំ ក្រោយមក បានទៅវត្តជេតពន ស្ដាប់ទេសនា របស់ព្រះសាស្ដាហើយ ក៏បានសម្រេចសោតបត្តិផល ក្នុងអដ្ឋកថានៃគាថា ថា "**យថាបិ ភមរោ បុប្ផំ**" ដូច្នេះជាដើម ក្នុងបុប្ផវគ្គ នៃធម្មបទក្ដី ក៏គប្បីសំដែងផងដែរ ។

ជនទាំងអស់នោះ តាំងខ្លួនដែលទ្រុស្ដសីល មិនមានសទ្ធា កំណាញ់ស្អិតស្អាញ ក្នុងគុណមានសីលជាដើមហើយ ក៏បានសម្រេចអានិសង្សផ្សេង ៗ គ្នា ដោយប្រការដូច្នេះ ។

មួយទៀត ពៀរឯណា មានការទ្រុស្ដសីលជាដើមជាហេតុ ដែលជនទាំងឡាយនោះគប្បីបាន ក្នុងបច្ចុប្បន្ននិងសម្បរាយភព, ពៀរនោះ គឺជនទាំងនោះ រមែងលះបង់បាន ខាងក្រោយអំពីពេលដែលខ្លួនតាំងនៅក្នុងគុណមានសីលជាដើម , ព្រោះហេតុនោះ

ការតាំងខ្លួនទុកដោយប្រពៃ គប្បីជ្រាប ថា "ជាមង្គល" ។

ព្រោះហេតុនោះ ក្នុងអដ្ឋកថា ទើបលោកពោល ថា "ការតាំងខ្លួនទុកដោយប្រពៃនោះឯង ជាមង្គល ។ ព្រោះហេតុអ្វី ? ។ ព្រោះជាហេតុលះបង់ពៀរដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្ន និងក្នុងសម្បរាយភព និងសម្រេចអានិសង្សផ្សេង ៗ គ្នា" ដូច្នេះឯង ។

(១១២) មែនពិត ចិត្តដែលបុគ្គលបានតាំងទុកប្រពៃហើយ រមែងអាចដើម្បីនឹងឲ្យនូវសម្បត្តិគ្រប់យ៉ាងបាន ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ត្រាស់ ថា "បិយជនទាំងឡាយ មានមាតាជាដើម រមែងមិនអាចដើម្បីនឹងឲ្យ នូវសម្បត្តិណាមួយបានឡើយ, ចិត្តដែលបុគ្គលដំកល់ទុកប្រពៃហើយ ដែលប្រព្រឹត្តទៅពួដខាងក្នុង នៃសត្វទាំងឡាយនេះប៉ុណ្ណោះឯង រមែងឲ្យនូវសម្បត្តិនោះបាន" ដូច្នេះហើយ ទើបទ្រង់ត្រាស់គាថានេះ ក្នុងចិត្តវគ្គនៃធម្មបទ(១) ថា ÷

"មាតាបិតា មិនគប្បីធ្វើហេតុនោះបាន, ឬជនទាំងឡាយដទៃជាញាតិ ក៏មិនគប្បីធ្វើនូវហេតុនោះបាន, ចំណែកខាងចិត្ត ដែលបុគ្គលដំកល់ទុកត្រូវហើយ តែងធ្វើបុគ្គលនោះ ឲ្យប្រសើរជាងហេតុនោះបាន"។

---

១ ត្រៃបិដក ភាគទី ៥២ ⁄ ទំព័រទី ៣០ ។

បណ្ដាបទទាំងនោះបទ ថា "**ន តំ**" មានសេចក្ដីថា ម្នាលភិក្ខុទាំងឡាយ មាតាគប្បីធ្វើនូវហេតុនោះមិនបានឡើយ, បិតាក៏មិនបាន, ជនទាំងឡាយដទៃជាញាតិក៏មិនបានដែរ ។

បទ ថា "**សម្មាបណិហិតំ**" បានដល់ ដែលបុគ្គលតាំងទុកហើយ ក្នុងកុសលកម្មបថ ១០ ប្រការ ។ បាទគាថា ថា "**សេយ្យសោ នំ តតោករេ**" មានសេចក្ដីថា រមែងធ្វើបុគ្គលឲ្យប្រសើរជាង គឺ ឲ្យខ្ពង់ខ្ពស់ជាងហេតុនោះ ។ មែនពិតមាតានិងបិតា កាលនឹងឲ្យនូវទ្រព្យ ដល់កូនទាំងឡាយ រមែងអាចដើម្បីឲ្យកូនមិនចាំបាច់ធ្វើការងារ ចិញ្ចឹមជីវិតរស់នៅ ដោយស្រួលបាន ក្នុងអត្តភាពនេះតែប៉ុណ្ណោះ, តែឈ្មោះថាមាតាបិតា ជាអ្នកអាចដើម្បីឲ្យនូវសិរីគឺចក្រពត្តិ ដល់កូនទាំងឡាយ មិនមានឡើយ, នឹងពោលធ្វើអ្វី ដល់មាតាបិតា ជាអ្នកអាចដើម្បីឲ្យនូវទិព្វសម្បត្តិ ឬសម្បត្តិមានបឋមឈានជាដើមបាននោះ, មិនចាំបាច់និយាយក្នុងការឲ្យនូវលោកុត្តរសម្បត្តិឡើយ ។ ចំណែកខាងចិត្តដែលបុគ្គលតាំងទុកត្រូវហើយ រមែងអាចដើម្បីឲ្យនូវសម្បត្តិទាំងពួងនោះបាន, ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ព្រះតម្រាស់នោះទុកហើយ ។

ព្រោះហេតុនោះ ចិត្ត សូម្បីបុគ្គលណាមួយក៏ដោយ ត្រូវតែ

តាំងទុកដោយប្រពៃ ទើបឲ្យនូវសេចក្ដីសុខគ្រប់បែបយ៉ាងបាន ។

(១១៣) មែនពិត ចិត្តដែលបុគ្គលតាំងទុកខុសហើយ រមែងឲ្យនូវសេចក្ដីទុក្ខគ្រប់បែបយ៉ាងបាន, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ ថា "ពួកចោរ ពួកជនអ្នកមានពៀរ រមែងមិនអាចដើម្បីធ្វើនូវសេចក្ដីវិនាសណាមួយបានឡើយ, ចិត្តដែលបុគ្គលដំកល់ទុកខុសហើយ ឮដ៏ខាងក្នុង នៃសត្វទាំងឡាយនេះតែប៉ុណ្ណោះ រមែងធ្វើ នូវសេចក្ដីវិនាសនោះបាន" ដូច្នេះហើយ ទើបទ្រង់ត្រាស់គាថានេះ ក្នុងចិត្តវគ្គ(១) នៃធម្មបទនោះឯង ថា ÷

> "ចោរក្រឡេកឃើញចោរផងគ្នា ឬក៏ បុគ្គលមានពៀរ ក្រឡេកឃើញបុគ្គលមានពៀរផងគ្នា គប្បីធ្វើនូវសេចក្ដីវិនាសណាមួយ (ដល់គ្នា), ចិត្តដែលបុគ្គលដំកល់ទុកខុសហើយ រមែងធ្វើបុគ្គលនោះ ឲ្យអាក្រក់ក្រៃលែងជាងសេចក្ដីវិនាសនោះទៅទៀត"។

ចោរ ឈ្មោះថា **ទិសោ** ក្នុងគាថានោះ ។ បទ ថា "**ទិសំ**" ប្រែថា នូវចោរ ។ គប្បីបន្ថែមបាលីដែលសេសសល់ ថា "**ទិស្វា**" ប្រែថា ឃើញហើយ ។ ២ បទ ថា "**យន្តំ កយិរា**" មាន សេចក្ដីថា គប្បីធ្វើនូវសេចក្ដីវិនាសណាមួយ ដល់ចោរដែលខ្លួនបាន

១ ត្រៃបិដក ភាគទី ៥២ / ទំព័រទី ៣០ ។

ឃើញហើយនោះ ដោយអំណាចការបៀតបៀនបុត្រនិងភរិយា ការញាំងអសង្ខារិមទ្រព្យមានស្រែជាដើម ឱ្យវិនាសសាបសូន្យ និងការផ្តាច់បង់ចាកជីវិត ។ បុគ្គលអ្នកចងពៀរទុក ដោយហេតុណាមួយប៉ុណ្ណោះ ឈ្មោះថា អ្នកមានពៀរ ។

បទ ថា " **វេរិនំ** " ប្រែថា ឃើញបុគ្គលអ្នកមានពៀរនោះ ។ បទ ថា " **មិច្ឆាបណិហិតំ** " មានសេចក្តីថា ដែលបុគ្គលតាំងទុកហើយ ក្នុងអកុសលកម្មបថ ១០ ប្រការ ។ បទ ថា " **បាបិយោ** " ប្រែថា ឱ្យអាក្រក់ក្រៃលែងជាង ។ បទ ថា " **នំ** " បានដល់នូវបុគ្គលដែលដំកល់ចិត្តទុកខុសហើយនោះ ។ បទ ថា " **តតោ** " មានសេចក្តីថា ជាងបុគ្គលដែលជាចោរ និងបុគ្គលដែលមានពៀរ គឺចោរនិងបុគ្គលមានពៀរទាំងឡាយឃើញហើយនោះ, មួយទៀតជាងសេចក្តីវិនាសនោះ ។ បទ ថា " **ករេ** " ប្រែថា គប្បីធ្វើ ។

ដូចព្រះតម្រាស់ ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុកហើយថា " ចោរ ឬ បុគ្គលមានពៀរ កាលប្រព្រឹត្តខុសក្នុងបុត្រ ភរិយា ស្រែ ចំការ គោ និងក្របីជាដើម, ខ្លួនប្រព្រឹត្តខុសចំពោះចោរនិងបុគ្គលអ្នកមានពៀរណាមួយ, ឃើញសូម្បីនូវចោរនិងបុគ្គលអ្នកមានពៀរនោះ ដែលប្រព្រឹត្តខុសចំពោះខ្លួន ដូច្នោះដែរ រមែងធ្វើនូវសេចក្តីវិនាសណាមួយ ដល់ចោរនិងបុគ្គលអ្នកមានពៀរនោះ, ចិត្តដែល

បុគ្គលដំកល់ទុកខុសហើយ គប្បីធ្វើនូវបុគ្គលនោះ ឲ្យអាក្រក់ក្រៃលែង ជាងចោរ ឬបុគ្គលអ្នកមានពៀរគប្បីធ្វើដល់គ្នា ឬជាងសេចក្តីវិនាស នោះទៅទៀត ។ មែនពិត ពួកចោរ និងបុគ្គលអ្នកមានពៀរទាំងឡាយ គប្បីធ្វើសេចក្តីទុក្ខឲ្យកើតឡើង ឬគប្បីធ្វើនូវការអស់ទៅនៃជីវិត ក្នុងអត្តភាពនេះតែប៉ុណ្ណោះឯង, ចំណែកខាងចិត្តដែលបុគ្គលដំកល់ទុកខុសហើយ ឲ្យដល់សេចក្តីវិនាស ក្នុងបច្ចុប្បន្ននេះហើយ បានទំលាក់ចោលទៅ ក្នុងអបាយទាំង ៤ មិនឲ្យងើបក្បាលឡើងរួចអស់មួយសែនអត្តភាពថែមទៀត ។ ព្រោះហេតុនោះ អ្នកណាក៏ដោយ មិនគួរដំកល់ចិត្តខុសសោះឡើយ ។

(១១៤) ក៏បុគ្គលណា ដំកល់ចិត្តដែលប្រតិបត្តិខុស ក្នុងកាលមុន ដោយប្រពៃ ក្នុងកាលជាខាងក្រោយ, បុគ្គលនោះ លោកឲ្យឈ្មោះថា " ជាអ្នកមានខ្លួនបានអប់រំហើយ " ។ ក៏ធម្មតាបុគ្គលដែលមានខ្លួនបានអប់រំហើយ រមែងទៅកាន់ទិសដែលខ្លួនមិនធ្លាប់បានទៅដល់, ហេតុនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់ទូន្មាននូវភិក្ខុ ១ រូប ដែលធ្លាប់ជាអ្នកហ្វឹកដំរី ទើបទ្រង់ត្រាស់គាថានេះ ក្នុងនាគវគ្គ នៃធម្មបទ[(១)] ថា ÷

" បុគ្គលទូន្មានខ្លួនបានបទហើយ ទូន្មានខ្លួនល្អហើយ

---

១ ត្រៃបិដក ភាគទី ៥២ / ទំព័រទី ៨៩ ។

ឈ្មោះថាទូន្មានហើយ រមែងទៅកាន់ទិសដែលខ្លួន
មិនធ្លាប់ទៅ គឺព្រះនិព្វានបាន ពុំមែនដូចជាបុគ្គល
ទៅកាន់ទិស ដែលខ្លួនមិនធ្លាប់ទៅ ដោយសារ
យានទាំងឡាយនោះឡើយ " ។

បណ្ដាបទទាំងនោះ បទ ថា "**អគតំ**" បានដល់ ដែលខ្លួនមិនធ្លាប់បានទៅ សូម្បីដោយការយល់សប្តិ ។ បទ ថា "**ទិសំ**" បានដល់ ព្រះនិព្វាន ។ បទ ថា "**អត្តនា**" បានដល់ ចិត្ត ។ បទ ថា "**សុទន្តេន**" មានសេចក្ដីថា ដែលបានទូន្មានហើយ ដោយល្អ ដោយភាវនាដែលសម្បយុត្តដោយអរិយមគ្គ ។ បទ ថា "**ទន្តោ**" បានដល់ ជាអ្នកមានការសេពគប់ខុសអស់ហើយ ។ បទ ថា "**ទន្តេន**" បានដល់ ដែលខ្លួនទូន្មានហើយ ដោយការទូន្មាននូវឥន្ទ្រីយ៍ ។ ដូចព្រះតម្រាស់ ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុក ថា "បុគ្គលអ្នកមានប្រាជ្ញា ទូន្មានខ្លួនហើយ មានខ្លួនបានទូន្មានហើយ ក្នុងចំណែកខាងដើម ក្នុងកាលក្រោយមក ទូន្មានបានល្អហើយ រមែងទៅកាន់ទិសដែលខ្លួនមិនធ្លាប់បានទៅ គឺ ទៅដល់ភូមិដែលអប់រំហើយ យ៉ាងណាមិញ, បុគ្គលពួកខ្លះ គប្បីទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅដល់ ដោយយានទាំងឡាយ មានយានដែលទឹម

ដោយដំរីជាដើមនោះ យ៉ាងដូច្នោះមិនបានឡើយ, ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ការទូន្មានខ្លួនប៉ុណ្ណោះ ជាធម្មជាតប្រសើរសម្រាប់អ្នក ដោយប្រការដូច្នេះឯង " ។

ពណ៌នាអំពីការតម្កល់ខ្លួនទុកដោយប្រពៃ ចប់ ។

(១១៥) មង្គល ៣ ប្រការ គឺ ការរស់នៅក្នុងប្រទេសដ៏សមគួរ ១ ភាពជាអ្នកមានបុណ្យបានធ្វើទុកហើយ ក្នុងកាលមុន ១ ការដំកល់ខ្លួនទុកដោយប្រពៃ ១ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយគាថានេះឯង ដោយប្រការដូច្នេះ ។

បាទទី ១ ក្នុងគាថាទី ២ នេះ មាន ៩ អក្សរ ដូចគ្នានឹងគាថាទី ៥ ថា "**ការឲ្យទាន ១ ការប្រព្រឹត្តធម៌ ១ តបៈ ១ កិរិយាប្រព្រឹត្តិប្រសើរ ១**" យ៉ាងដូច្នេះដែរ ។ បាទទី ២ ប្រកបដោយលក្ខណៈនៃបាទទី ២ នៃបថ្យាវត្ត ។ កន្លះគាថាទី ២ ជាបថ្យាវត្ត ដូច្នេះឯង ។

ពណ៌នាសេចក្តីនៃគាថាទី ២ ចប់ ។

* * *

ប្រែចប់ថ្ងៃអង្គារ ១៣ រោច ខែបុស្ស ឆ្នាំច ឆស័ក ព.ស. ២៥៣៧
ទី ៨ ខែកុម្ភៈ ៩៤

## ពណ៌នាសេចក្តីនៃគាថាទី ៣

(១១៦) គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី ៣ ។ ភាវៈនៃបុគ្គលអ្នកមានកិរិយាស្តាប់ច្រើន ឈ្មោះថា **ពាហុសច្ចៈ** ។ ភាពជាអ្នកឆ្លាតវាងវៃ ក្នុងហត្ថកម្មណាមួយ ឈ្មោះថា **សិល្បៈ** ។ សូម្បីក្នុងដីកាវារសេដ្ឋសូត្រ ក្នុងមជ្ឈិមបណ្ណាសកៈ ក៏លោកពោលហើយ ថា "ភាពជាអ្នកឆ្លាតវាងវៃ ក្នុងហត្ថកម្ម ឈ្មោះថា **សិល្បៈ** ព្រោះអត្ថ ថា គឺបុគ្គលគប្បីសិក្សា ដោយឧបាយនោះ ៗ " ។

ច្បាប់សម្រាប់ទូន្មាននូវកាយ វាចា និង ចិត្ត អធិប្បាយ ថា "គ្រឿងហាមឃាត់ គ្រឿងហាមប្រាម នូវកាយ វាចា និងចិត្តទាំងឡាយនោះ ចាកអាបត្តិខ្លះ ចាកទោសគ្រឿងទ្រុស្តសីលខ្លះ ចាកអកុសលកម្មបថខ្លះ តាមសមគួរ" ឈ្មោះថា **វិន័យ** ។

ចំណែកក្នុងអដ្ឋកថាទាំងឡាយ មានអដ្ឋកថាសាមន្តបាសាទិកាជាដើម លោកបានពោលសំដៅយកព្រះវិន័យបិដកតែម្យ៉ាង ថា "ឧបាយនុ៎ះ រមែងទូន្មាននូវកាយផង វាចាផង ព្រោះហាមឃាត់នូវអជ្ឈាចារដែលប្រព្រឹត្តទៅតាមផ្លូវកាយនិងវាចា ព្រោះហេតុនោះ ឧបាយនោះ ទើបឈ្មោះថា **វិន័យ** " ។

ក្នុងអដ្ឋកថា លោកពោលហើយ ថា "បទ ថា '**សុសិក្ខិតោ**'

គឺ ដែលបុគ្គលសិក្សាហើយ ដោយល្អ ។ បទ ថា " **សុភាសិតា** " គឺ ដែលបុគ្គលពោលហើយ ដោយល្អ ។ សព្ទ ថា ' **យា** ' ជាសព្ទសំដែងនូវសេចក្តីដែលមិនមានកំណត់ ។ វាចាដែលបុគ្គលគប្បីពោល គឺ វាចាដែលជាផ្លូវ ឈ្មោះថា **វាចា** " ។

អដ្ឋកថានៃរូបកណ្ឌ ថា " សទ្ទជាតិណា ដែលបុគ្គលពោល ហេតុនោះ សទ្ទជាតិនោះ ឈ្មោះថា **វាចា** ។ សទ្ទជាតិណា ដែលបុគ្គលនិយាយ ហេតុនោះ សទ្ទជាតិនោះ ឈ្មោះថា **គិរា** ។ ការបញ្ចេញវាចា ឈ្មោះថា វាចាដែលជាផ្លូវ ។ វាចានោះផង ជាផ្លូវផង នៃពួកជនដែលប្រាថ្នាចង់ដឹងខ្លួនឯង និងប្រាថ្នាចង់ឲ្យអ្នកដទៃដឹងនូវសេចក្តី ហេតុនោះឯង វាចានោះ ទើបឈ្មោះថា វាចាដែលជាផ្លូវ " ដូច្នេះ ។

អដ្ឋកថាមុសាវាទសិក្ខាបទ ថា " ពាក្យដែលជាផ្លូវ ឈ្មោះថា **ព្យបថោ** ។ មែនពិត វាចានុ៎ះឯង ជាផ្លូវរបស់ជនទាំងឡាយ អ្នកដល់នូវទិដ្ឋានុគតិ សូម្បីនៃពួកជនដទៃ ទើបលោកហៅថា ' **ព្យបថោ** " ។

ផ្លាស់វាចាសព្ទ ទៅជា **ព្យ**ៈ ព្រោះបថសព្ទខាងដើម ដោយសូត្រក្នុងសទ្ទនីតិ ដែលសំដែងអំពីសន្ធិកប្បៈ ថា " ផ្លាស់វាចាសព្ទទៅជា **ព្យ**ៈ ព្រោះបថសព្ទ " ក៏បាន ដោយមហាព្រឹទ្ធិក៏បាន ។

បទ ថា " ឯតំ " មានសេចក្ដីថា ម្នាលទេវតា អ្នកចូរប្រកាន់យក ថា " **ភាវៈនៃបុគ្គលជាអ្នកមានកិរិយាស្ដាប់មកច្រើន ១ សិល្បៈ ១ វិន័យដែលបុគ្គលបានសិក្សាល្អហើយ ១ វាចាដែលបុគ្គលពោលល្អហើយ ១, កម្មទាំង ៤ យ៉ាងនេះ ជាមង្គលដ៏ឧត្ដម** " ។

សេចក្ដីសង្ខេប ក្នុងគាថាទី ៣ នេះ មានត្រឹមតែប៉ុណ្ណោះ ។ ចំណែកសេចក្ដីពិស្ដារ ក្នុងគាថាទី ៣ នេះ មានដូចតទៅនេះ ÷

❀

❀ ❀

## ពណ៌នាអំពីភាពជាអ្នកបានស្តាប់ច្រើន

(១១៧) ភាវៈនៃបុគ្គលជាអ្នកមានកិរិយាស្តាប់មកច្រើន ឈ្មោះថា **ពាហុសច្ចៈ** ។ ដោយសេចក្តី ពាហុសច្ចៈ បានដល់ភាពជាអ្នកឆ្លាតវាងវៃ ក្នុងកិច្ចការនោះៗ ដែលកើតឡើង ព្រោះសិក្សាខ្លះ ព្រោះស្តាប់ខ្លះ នូវព្រះពុទ្ធវចនៈ ឬសិល្បៈខាងក្រៅ លើកលែងនូវភាពជាអ្នកឈ្លាសវៃក្នុងហត្ថកម្ម ដែលព្រះមានព្រះភាគទ្រង់ប្រកាន់យកហើយ ដោយសិប្បស័ព្ទដែលបំរុងនឹងពោលចេញ ។ ពាហុសច្ចៈនោះ មាន ២ យ៉ាង ដោយអំណាចពាហុសច្ចៈ របស់បព្វជិតនិងគ្រហស្ថ ។ បណ្តាពាហុសច្ចៈទាំង ២ យ៉ាងនោះ ភាពជាអ្នកទ្រង់ចាំ នូវពាក្យប្រៀនប្រដៅ របស់ព្រះសាស្តា ដែលព្រះមានព្រះភាគទ្រង់សំដែងទុកហើយ ក្នុងព្រះសូត្រទាំងឡាយមានឧរុវេលសូត្រជាដើម ដោយន័យជាអាទិ៍ យ៉ាងនេះ ថា "ភិក្ខុជាអ្នកមានកិរិយាស្តាប់មកច្រើន ជាអ្នកទ្រទ្រង់ព្រះសូត្រ ជាអ្នកមានព្រះសូត្រជាទីសន្សំទុក" ដូច្នេះ ឈ្មោះថា ពាហុសច្ចៈ របស់បព្វជិត ។

ឧរុវេលសូត្រ មកក្នុងបឋមបណ្ណាសកៈ ចតុក្កនិបាត អង្គុត្តរនិកាយ ។

(១១៨) អដ្ឋកថា នៃឧរុវេលសូត្រនោះ ថា "សុតៈ គឺពាក្យប្រៀនប្រដៅ របស់ព្រះសាស្តាប្រកបដោយអង្គ ៩ របស់ភិក្ខុ

នោះច្រើន អធិប្បាយ ថា 'ជាព្រះសូត្រដែលភិក្ខុរូបនោះ សិក្សាហើយ ដោយអំណាចនៃអក្ខរៈ ខាងដើម និងខាងចុង នៃបាលីនិងអនុសន្ធិ' ដូច្នេះ, ភិក្ខុនោះ ឈ្មោះថា ពហុស្សុត ។ បទ ថា '**សុតធរោ**' គឺ ជាអ្នកទ្រទ្រង់នូវព្រះសូត្រ ។ មែនពិត ព្រះព្រះពុទ្ធវចនៈ គឺភិក្ខុរូបណា រៀនហើយ អំពីបាលីនេះ រមែងបាត់សូន្យទៅ ចាកបាលីនេះ មិនស្ថិតនៅ ដូចជាទឹកក្នុងឆ្នាំងដែលធ្លុះ, ភិក្ខុរូបនោះ រមែងមិនអាច ដើម្បីនឹងសំដែង ឬប្រាប់នូវព្រះសូត្រ ឬជាគកមួយ ក្នុងកណ្តាលបរិស័ទបានឡើយ, ភិក្ខុរូបនេះ មិនបានឈ្មោះថា ជាអ្នកទ្រទ្រង់ព្រះសូត្រទេ ។ ចំណែកព្រះពុទ្ធវចនៈដែលភិក្ខុរូបណា រៀនហើយ រមែងដូចជាពេលដែលខ្លួនបានរៀនមកហើយនុ៎ះឯង, កាលបើភិក្ខុរូបនោះ មិនធ្វើការស្វាធ្យាយ រហូតដល់ ១០ ឆ្នាំក្តី ២០ ឆ្នាំក្តី, ក៏រមែងមិនវិនាសបាត់ទៅ, ភិក្ខុរូបនេះ ទើបឈ្មោះថា ជាអ្នកទ្រទ្រង់នូវព្រះសូត្រ ។ បទ ថា "**សុតសន្និចយោ**" គឺ ជាអ្នកសន្សំនូវព្រះសូត្រ ។ មែនពិត ព្រះសូត្រ គឺភិក្ខុរូបណា សន្សំទុកហើយ ក្នុងទូ គឺហឫទ័យ រមែងស្ថិតនៅ ដូចជាស្នាមចារិកលើសីលា និងដូចជាខ្លាញ់រាជសីហ៍ដែលគេចាក់ទុកហើយ ក្នុងឆ្នាំងមាស, ភិក្ខុរូបនោះ ទើបឈ្មោះថា ជាអ្នកសន្សំនូវព្រះសូត្រ" ដូច្នេះឯង ។

ដីកានៃឱរុវេលសូត្រនោះ ថា "ព្រះបរិយត្តិធម៌ ឈ្មោះថា សុតៈ ព្រោះជាធម៌ដែលបុគ្គលអ្នកមានសេចក្តីត្រូវការ ដោយការចៀសចេញចាកសេចក្តីទុក្ខក្នុងវដ្ដៈ គប្បីស្តាប់, ភិក្ខុរូបណាទ្រទ្រង់នូវសុតៈនោះ ហេតុនោះ ភិក្ខុរូបនោះ ឈ្មោះថា ជាអ្នកទ្រទ្រង់នូវសុតៈ ។ សុតៈមានបទតែមួយ មិនវិនាសបាត់ទៅ សូម្បីតែអក្ខរៈ ១ រមែងសន្សំទុក ហេតុនោះ សុតៈនោះ ទើបឈ្មោះថា របស់ដែលសន្សំទុក, សុតៈជារបស់សន្សំទុក មាននៅក្នុងភិក្ខុរូបនោះ ហេតុនោះ ភិក្ខុរូបនោះ ឈ្មោះថា ជាអ្នកមានសុតៈជាទីសន្សំទុក" ។

(១១៩) ក៏បុគ្គលណា ជាពហុស្សូត ជាអ្នកប្រកបដោយសុតៈ, បុគ្គលនោះ ព្រះសាស្តាទ្រង់បានត្រាស់សរសើរហើយ ។ មែនពិត ព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយ ក្នុងអប្បស្សុតសូត្រក្នុងបឋមបណ្ណាសកៈ ចតុក្កនិបាត អង្គុត្តរនិកាយ[១] ថា ÷

" ម្នាលភិក្ខុទាំងឡាយ ! បុគ្គល ៤ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ? ។ គឺបុគ្គលមានសេចក្តីចេះដឹងតិច មិនបានប្រកបដោយការចេះដឹង ១ មានសេចក្តីចេះដឹងតិច បានប្រកបដោយការចេះដឹង ១ មានសេចក្តីចេះដឹងច្រើន មិនបានប្រកប ដោយការចេះដឹង ១ មានសេចក្តីចេះដឹង

១ ត្រៃបិដក ភាគទី ៤២ ⁄ ទំព័រទី ១៣ ។

ច្រើន ហើយបានប្រកបដោយការចេះដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ ! ចុះបុគ្គលអ្នកមានសេចក្តីចេះដឹងតិច មិនបានប្រកបដោយការចេះដឹង តើដូចម្តេច ? ។ ម្នាលភិក្ខុទាំងឡាយ ! ព្រះពុទ្ធវចនៈ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ មានតិច ដល់បុគ្គលពួកខ្លះ ក្នុងលោកនេះ, បុគ្គលនោះ មិនចេះអដ្ឋកថា មិនចេះបាលីនៃពុទ្ធវចនៈ ដែលមានប្រមាណតិចនោះ ជាអ្នកមិនប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌, ម្នាលភិក្ខុទាំងឡាយ ! បុគ្គលអ្នកមានសេចក្តីចេះដឹងតិច ហើយមិនបានប្រកប ដោយការចេះដឹង យ៉ាងដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ! ចុះបុគ្គលអ្នកមានសេចក្តីចេះដឹងតិច បានប្រកបដោយការចេះដឹងតិច តើដូចម្តេច ? ។ ម្នាលភិក្ខុទាំងឡាយ ! ព្រះពុទ្ធវចនៈ គឺ សុត្តៈ ។ល។ វេទល្លៈ មានតិចដល់បុគ្គលពួកខ្លះ ក្នុងលោកនេះ, បុគ្គលនោះ ចេះអដ្ឋកថា ចេះបាលីនៃពុទ្ធវចនៈ ដែលមានប្រមាណតិចនោះ ជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ។ ម្នាលភិក្ខុទាំងឡាយ ! យ៉ាងនេះឯងឈ្មោះថា បុគ្គលអ្នកមានសេចក្តីចេះដឹងតិច បានប្រកបដោយការចេះដឹង ។ ម្នាលភិក្ខុទាំងឡាយ ! ចុះបុគ្គលអ្នកមានសេចក្តីចេះដឹងច្រើន តែមិនបានប្រកបដោយការចេះដឹង តើដូចម្តេច ? ។

ម្នាលភិក្ខុទាំងឡាយ ! ព្រះពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ ។ ល ។ វេទល្លៈ មានច្រើនដល់បុគ្គលពួកខ្លះ ក្នុងលោកនេះ, បុគ្គលនោះ មិនចេះអដ្ឋកថា មិនចេះបាលីនៃពុទ្ធវចនៈ ដែលមានប្រមាណច្រើន នោះ ជាអ្នកមិនប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ។ ម្នាលភិក្ខុទាំង ឡាយ ! យ៉ាងនេះឯង ឈ្មោះថា បុគ្គលអ្នកមានសេចក្តីចេះដឹង ច្រើន តែមិនបានប្រកបដោយការចេះដឹង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលអ្នកមានសេចក្តីចេះដឹងច្រើន បានប្រកបដោយការចេះដឹង តើដូចម្តេចខ្លះ ? ។ ម្នាលភិក្ខុទាំងឡាយ ! ព្រះពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ ។ ល ។ វេទល្លៈ មានច្រើនដល់បុគ្គលពួកខ្លះ ក្នុងលោកនេះ, បុគ្គលនោះ ចេះអដ្ឋកថា ចេះបាលីនៃពុទ្ធវចនៈ ដែលមានប្រមាណច្រើននោះ ជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ ធម៌ ។ ម្នាលភិក្ខុទាំងឡាយ ! យ៉ាងនេះឯង ឈ្មោះថា បុគ្គលអ្នកមានសេចក្តីចេះដឹងច្រើន បានប្រកបដោយការចេះដឹង ។ ម្នាលភិក្ខុទាំងឡាយ ! បុគ្គលទាំងឡាយ ៤ ពួកនេះឯង រមែងមាននៅក្នុងលោក" ។

( ព្រះដ៏មានព្រះភាគ បានត្រាស់ព្រះសូត្រនេះហើយ លុះព្រះ សុគតជាសាស្តា ទ្រង់ត្រាស់ព្រះសូត្រនេះរួចហើយ ទើបទ្រង់ត្រាស់ នូវគាថាពន្ធនេះ តទៅទៀត ថា ÷ )

(១២០) "បើបុគ្គលមានសេចក្តីចេះដឹងតិច ទាំងមិនបាន[1] ឋិតនៅក្នុងសីលទាំងឡាយ, អ្នកប្រាជ្ញទាំងឡាយ រមែងតិះដៀលបុគ្គលនោះ ដោយហេតុទាំង ២ គឺសីល ១ សេចក្តីចេះដឹង ១ ។ បើបុគ្គលមានសេចក្តីចេះដឹងតិច តែឋិតនៅខ្ជាប់ខ្ជួន ក្នុងសីលទាំងឡាយ, អ្នកប្រាជ្ញទាំងឡាយ រមែងសរសើរនូវបុគ្គលនោះ តែដោយសីល, ប៉ុន្តែសេចក្តីចេះដឹង មិនបានសម្រេចដល់បុគ្គលនោះទេ ។ បើបុគ្គលមានសេចក្តីចេះដឹងច្រើន តែមិនឋិតនៅខ្ជាប់ខ្ជួន ក្នុងសីលទាំងឡាយទេ, អ្នកប្រាជ្ញទាំងឡាយ រមែងតិះដៀលបុគ្គលនោះ ដោយសីល, ប៉ុន្តែសេចក្តីចេះដឹង រមែងសម្រេច ដល់បុគ្គលនោះ ។ បើបុគ្គលមានសេចក្តីចេះដឹងច្រើន ទាំងឋិតនៅខ្ជាប់ខ្ជួន ក្នុងសីលទាំងឡាយ, អ្នកប្រាជ្ញទាំងឡាយ តែងសរសើរបុគ្គលនោះ ដោយហេតុទាំង ២ គឺសីល ១ សេចក្តីចេះដឹង ១ ។

១ ត្រៃបិដក ភាគទី ៤២ / ទំព័រទី ១៦ ។

អ្នកណា គួរនិន្ទាបុគ្គលអ្នកមានសេចក្ដីចេះដឹងច្រើន ទ្រទ្រង់នូវព្រះធម៌ មានបញ្ញា ជាពុទ្ធសាវ័កនោះ ដែលដូចជាដុំនៃមាសជម្ពូនទបាន, សូម្បីទេវតានិងមនុស្សទាំងឡាយ ក៏រមែងសរសើរនូវបុគ្គលនោះ, សូម្បីព្រហ្ម ក៏សរសើរដែរ ”។

អដ្ឋកថា នៃអប្បស្សុតសូត្រនោះ ថា “ បណ្ដាបទទាំងនោះ បទ ថា ‘**អនុបបន្នោ**’ ប្រែថា មិនចូលទៅជិតហើយ ” ។

ដីកានៃអប្បស្សុតសូត្រនោះ ថា “២ បទថា ‘**អប្បកំ សុតំ**’ មានសេចក្ដីថា បណ្ដាពាក្យប្រៀនប្រដៅ របស់ព្រះសាស្ដា ដែលប្រកបដោយអង្គ ៩ អង្គណាមួយក៏ដោយ ចាត់ជាសុតៈ(ទាំងអស់), ដើម្បីនឹងទ្រង់សំដែងនូវអង្គ ៩ នេះនោះ ទើបព្រះអង្គទ្រង់ត្រាស់ ថា ‘សុត្តៈ គេយ្យៈ’ ដូច្នេះជាដើម ” ។

ន័យដែលមកក្នុងអដ្ឋកថា នៃសូត្រនោះ ថា “ ច្រើនបទ ថា ‘**អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ**’ មានសេចក្ដីថា ជាអ្នកចេះដឹងអដ្ឋកថា និងបាលីហើយ ប្រតិបត្តិនូវបដិបទាដែលជាចំណែកខាងដើម ព្រមទាំងសីលដែលសមគួរដល់លោកុត្តរធម៌ ៩ ប្រការ ។ បណ្ដាបុគ្គល ៤ ពួកនោះ បុគ្គលពួកទី ១ គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ (សំដៅយក) អ្នកមានកិរិយាស្ដាប់តិចនិង

ជាអ្នកទ្រុស្តសីល, ពួកទី ២ ជាអ្នកមានកិរិយាស្តាប់តិច (តែ) ជាព្រះខីណាស្រព, ពួកទី ៣ ជាអ្នកមានកិរិយាស្តាប់ច្រើន ( តែ ) ជាអ្នកទ្រុស្តសីល, ពួកទី ៤ ជាអ្នកមានកិរិយាស្តាប់ច្រើនផង ជាព្រះខីណាស្រពផង " ។

អដ្ឋកថានៃសូត្រនោះ ថា "បទ ថា '**អសមាហិតោ**' គឺ ជាអ្នកមិនធ្វើឲ្យបរិបូណ៌ ។ បាទគាថា ថា '**សីលតោ ច សុតេន ច**' គឺ ទាំងផ្នែកសីល ទាំងផ្នែកសុតៈ ។ អធិប្បាយ ថា 'បណ្ឌិតទាំងឡាយ តែងតិះដៀលបុគ្គលនោះ យ៉ាងនេះ ថា 'បុគ្គលនេះ ជាអ្នកទ្រុស្តសីល (និង) មានការស្តាប់តិច' ។ បាទគាថា ថា '**តស្ស សម្បជ្ជតេ សុតំ**' មានសេចក្តីថា កិច្ចគឺសុតៈ គឺបុគ្គលនោះ ធ្វើហើយ ដោយសុតៈនេះ ព្រោះហេតុណា, ព្រោះហេតុនោះ សុតៈ ឈ្មោះថា រមែងសម្រេច ដល់បុគ្គលនោះ ។ ២ បទ ថា '**នាស្ស សម្បជ្ជតេ**' មានសេចក្តីថា ព្រោះបុគ្គលនោះ មិនបានធ្វើកិច្ចគឺសុតៈ ទើបសុតៈមិនបានសម្រេច ។ បទ ថា '**ធម្មធរំ**' បានដល់ ជាអ្នកទ្រទ្រង់នូវព្រះធម៌ គឺសុតៈ ។ បទ ថា '**សប្បញ្ញំ**' គឺ អ្នកមានបញ្ញាល្អ ។ បាទគាថា ថា '**និក្ខំ ជម្ពូនទស្សេវ**' មានសេចក្តីថា មាសតាមធម្មជាតិ លោកហៅថា មាសជម្ពូនទ, ប្រៀបដូចជាដុំ នៃមាសជម្ពូនទនោះ, អធិប្បាយ ថា ដូចជាផែន

នៃមាស ដែលមានប្រមាណបញ្ចសុវណ្ណ (១ និក្ខៈ)' ដូច្នេះ" ។

(១២១) សូម្បីព្រះអានន្ទត្ថេរ អាស្រ័យនូវភាវៈ នៃខ្លួនជាអ្នកមានកិរិយាស្តាប់ច្រើន ទើបដល់នូវភាពជាអ្នក គឺព្រះសាស្តាទ្រង់ត្រាស់សរសើរ ថា "ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុអ្នកមានកិរិយាស្តាប់ច្រើន ដែលជាសាវ័ក របស់តថាគត ស្រេចតែនឹងព្រះអានន្ទ ជាអ្នកប្រសើរជាងគេ" ។ មួយទៀត ភិក្ខុដែលជាពហុស្សូត រមែងជាអ្នកមានលាភកើតឡើង ដោយមិនលំបាក ។

ក្នុងដំណើរនោះ មានរឿងនេះ (ជាឧទាហរណ៍) ÷

## ( រឿងព្រាហ្មណ៍បូជាភិក្ខុជាពហុស្សូត )

បានឮថា ព្រាហ្មណ៍ម្នាក់គិត ថា "ការបូជាព្រះពុទ្ធរតនៈនិងព្រះសង្ឃរតនៈ រមែងប្រាកដ, ព្រះធម្មរតនៈ នឹងបានឈ្មោះថា គឺអាត្មាអញបូជាហើយ យ៉ាងដូចម្តេចទៅហ្ន៎ ?" ហើយ ទើបចូលទៅគាល់ព្រះសាស្តា ក្រាបទូលសួរហើយ នូវសេចក្តីនោះ ។

ព្រះសាស្តា ម្នាលព្រាហ្មណ៍ បើអ្នកប្រាថ្នាដើម្បីនឹងបូជាព្រះធម្មរតនៈ ចូរអ្នកបូជានូវភិក្ខុជាពហុស្សូត ១ រូបចុះ ។

ព្រាហ្មណ៍ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គទ្រង់ត្រាស់ប្រាប់នូវភិក្ខុជាពហុស្សូតឲ្យទានផង ។

ព្រះសាស្ដា . ចូរអ្នកសួរនូវព្រះភិក្ខុសង្ឃចុះ ។

ព្រាហ្មណ៍នោះ បានចូលទៅរកព្រះភិក្ខុសង្ឃហើយ សួរ ថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើនទាំងឡាយ សូមព្រះគុណម្ចាស់មេត្តាប្រាប់នូវភិក្ខុដែលជាពហុស្សូតផង " ។

ភិក្ខុទាំងឡាយ. នែព្រាហ្មណ៍ ព្រះអានន្ទត្ថេរជាពហុស្សូត ។

ព្រាហ្មណ៍ បានបូជាព្រះថេរៈដោយពីវរដែលមានតម្លៃ ១ ពាន់ ។

រឿងនេះ មកក្នុងអដ្ឋកថាមហាគោសិង្គសាលសូត្រ ។

(១២២) ពាហុសច្ចៈ របស់ពហុស្សុតបុគ្គល ឈ្មោះថា ជាមង្គល ព្រោះជាហេតុនៃឥទ្ធផលមានការសរសើរជាដើម និងបានឈ្មោះថា ជាមង្គល សូម្បីព្រោះហេតុនៃការលះអកុសល និងបានសម្រេចនូវកុសល ដោយប្រការដូច្នេះឯង ។ សមដូចជាព្រះគម្រាស់ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ទុក ក្នុងនគរោបមសូត្រ ក្នុងទុតិយវគ្គ នៃទុតិយបណ្ណាសកៈ ក្នុងសត្តកនិបាត អង្គុត្តរនិកាយ យ៉ាងដូច្នេះ ថា "ម្នាលភិក្ខុទាំងឡាយ ក៏ព្រះអរិយសាវ័ក អ្នកបានស្ដាប់ហើយនុ៎ះឯង រមែងលះបង់នូវអកុសលបាន ចំរើនកុសលឲ្យកើតមានឡើង, រមែងលះបង់នូវកម្មដែលមានទោស ចំរើនកម្មដែលគ្មានទោសឲ្យកើតឡើង រមែងបរិហារខ្លួនឲ្យបានបរិសុទ្ធ " ។

(១២៣) អដ្ឋកថានៃសូត្រទីមួយ នៃសូត្រទាំងពួង ក្នុងទុក្កនិបាត អង្គុត្តរនិកាយ ថា "បណ្ដាពាក្យទាំងនោះ ក្នុងពាក្យ ថា '**សុទ្ធមត្តានំ បរិហរតិ**' នេះ សេចក្ដីបរិសុទ្ធិ មាន ២ យ៉ាង គឺ ដោយបរិយាយ ១ ដោយនិប្បរិយាយ ១ ។ ក៏ព្រះអរិយសាវ័កបរិហារខ្លួន ដោយសរណគមន៍ ឈ្មោះថា បរិហារខ្លួន ឲ្យបរិសុទ្ធ ដោយបរិយាយ ។ សូម្បីបរិហារខ្លួន ដោយសីល ៥ សីល ១០ ចតុប្បារិសុទ្ធិសីល បឋមជ្ឈាន ។ល។ នេវសញ្ញា-នាសញ្ញាយតនៈ សោតាបត្តិមគ្គ សោតាបត្តិផល ។ល។ អរហត្តមគ្គ ក៏ឈ្មោះថា បរិហារខ្លួន ឲ្យបរិសុទ្ធ ដោយបរិយាយ ដូចគ្នាដែរ ។ ចំណែកខាងព្រះអរិយបុគ្គល ដែលឋិតនៅក្នុង អរហត្តផល ជាព្រះខីណាស្រព កាលញុំាងបញ្ចក្ខន្ធ ដែលមានមូល កាត់ផ្ដាច់ហើយ ឲ្យដូតក្ដី ឲ្យទំពាស៊ីក្ដី ឲ្យបរិភោគក្ដី ឲ្យអង្គុយក្ដី ឲ្យដេកក្ដី បណ្ឌិតគប្បីជ្រាប ថា 'រមែងបរិហារ គឺ ប្រតិបត្តិខ្លួន ឲ្យបរិសុទ្ធ គឺ ឲ្យអស់មន្ទិល ដោយនិប្បរិយាយ មែនពិត' ដូច្នេះ" ។

ដីកានៃបឋមសូត្រនោះ ថា "បទ ថា '**ឆិន្នមូលកេ**' បានដល់ ឈ្មោះថា មានមូលបានកាត់ផ្ដាច់ហើយ ព្រោះមូលគឺតណ្ហា គឺលោក បានជីករំលើងអស់ហើយ" ។

អដ្ឋកថានៃអធិប្បតេយ្យសូត្រ ក្នុងចតុត្ថវគ្គ បឋមបណ្ណាសកៈ

ក្នុងតិកនិបាត អង្គុត្តរនិកាយ ថា “អធិប្បាយថា ‘ភិក្ខុបរិហារ គឺប្រតិបត្តិ គ្រប់គ្រងខ្លួន ធ្វើឲ្យបរិសុទ្ធ គឺឲ្យអស់មន្ទិល’។ ក៏ភិក្ខុរូបនេះ បរិហារខ្លួន ឲ្យបរិសុទ្ធ ដោយអរហត្តមគ្គ ឈ្មោះថា រមែងបរិហារខ្លួន ឲ្យបរិសុទ្ធ ដោយបរិយាយ, ចំណែកព្រះអរិយបុគ្គលដែលបានសម្រេចផលហើយ ទើបឈ្មោះថា រមែងបរិហារខ្លួន ឲ្យបរិសុទ្ធ ដោយនិប្បរិយាយ” ។

ដីកានៃអធិប្បាយគេយ្យសូត្រនោះ ថា “២ បទ ថា ‘**និម្មលំកត្វា**’ មានសេចក្តីថា ធ្វើឲ្យប្រាសចាកមន្ទិល ព្រោះកំចាត់បង់នូវមន្ទិលទាំងឡាយមានរាគៈជាដើម ។ បទ ថា ‘**គោបយតិ**’ ប្រែថា រមែងរក្សា ចាកអនត្ថៈគឺសង្កិលេស ។ បទ ថា ‘**អយំ**’ ជាដើម មានសេចក្តីថា ភិក្ខុអ្នកប្រតិបត្តិបានយ៉ាងដូច្នេះ ឈ្មោះថា បរិហារខ្លួន ឲ្យបរិសុទ្ធ ព្រោះមិនមានសូម្បីកិលេសដែលជាហេតុមិនបរិសុទ្ធ” ។

លោកមិនបានពណ៌នាពាក្យអ្វីមួយឡើយ ក្នុងអដ្ឋកថានិងដីកានៃនគរោបមសូត្រ ព្រោះលោកបានពណ៌នាទុកហើយ ឰដ៏ខាងដើមយ៉ាងដូច្នេះឯង ។

(១២៤) មួយទៀត ពាហុសច្ចៈ ឈ្មោះថា ជាមង្គល ព្រោះជាហេតុនៃការធ្វើឲ្យជាក់ច្បាស់បរមត្ថសច្ចៈ ដោយលំដាប់មែនពិត ។

សមដូចជាព្រះតម្រាស់ ដែលព្រះមានព្រះភាគ កាលនឹងទ្រង់សំដែងនូវធម៌ ដល់ព្រាហ្មណ៍ឈ្មោះថា ភារទ្វាជៈ ទ្រង់ត្រាស់ទុកហើយ ថា "កុលបុត្រដែលកើតសេចក្ដីជ្រះថ្លាហើយ រមែងចូលទៅរក, លុះចូលទៅរកហើយ រមែងអង្គុយជិត, កាលអង្គុយជិត រមែងផ្ទៀងនូវត្រចៀកចុះ, ផ្ទៀងត្រចៀកចុះហើយ រមែងស្ដាប់នូវធម៌, លុះស្ដាប់ហើយ រមែងទ្រទ្រង់ចាំធម៌ទុក, រមែងពិចារណានូវសេចក្ដីនៃធម៌ទាំងឡាយ ដែលបានទ្រទ្រង់ទុកហើយ, កាលបើកុលបុត្រនោះ ពិចារណានូវសេចក្ដី, ធម៌ទាំងឡាយ រមែងអត់ធន់នូវការសំឡឹងរំពៃ, កាលបើមានការអត់ធន់នូវការសំឡឹងរំពៃនូវធម៌, សេចក្ដីពេញចិត្ត រមែងកើតឡើង, កុលបុត្រនោះ កើតសេចក្ដីពេញចិត្តហើយ រមែងព្យាយាម, លុះព្យាយាមហើយ រមែងត្រិះរិះ, លុះត្រិះរិះហើយ រមែងតាំងសេចក្ដីព្យាយាម, កុលបុត្រនោះមានខ្លួនតាំងព្យាយាមហើយ រមែងធ្វើឲ្យជាក់ច្បាស់ នូវបរមត្ថសច្ចៈដោយកាយ និងរមែងឃើញ នូវការចាក់ធ្លុះ នូវបរមត្ថសច្ចៈនោះដោយបញ្ញា" ។

បាលីក្នុងចង្កីសូត្រ ក្នុងបញ្ចមវគ្គ នៃមជ្ឈិមបណ្ណាសកៈ ។

(១២៥) អដ្ឋកថានៃចង្កីសូត្រនោះ ថា "បទ ថា 'បយិរុបាសតិ' គឺ អង្គុយក្នុងសំណាក់ ។ បទ ថា 'សោតំ' បានដល់

សោតប្រសាទ ។ បទ ថា 'ធម្មំ' បានដល់ ទេសនាធម៌ ។ បទ ថា 'ធារេតិ' គឺ ទ្រទ្រង់ទុកធ្វើឲ្យស្ទាត់ជំនាញ ។ បទ ថា 'ឧបបរិក្ខតិ' បានដល់ រមែងពិចារណា ដោយអត្ថ និងដោយហេតុការណ៍ ។ បទ ថា 'និជ្ឈានំ' គឺ រមែងអត់ធន់នូវការត្រួតពិនិត្យមើល, អធិប្បាយ ថា 'ធម៌ទាំងឡាយ រមែងប្រាកដ យ៉ាងដូច្នេះ ថា 'សីល គឺព្រះមានព្រះភាគ ទ្រង់សំដែងហើយ ក្នុងទីនេះ, សមាធិ គឺព្រះអង្គទ្រង់សំដែងហើយ ក្នុងទីនេះ' ដូច្នេះជាដើម ។ សេចក្តីពេញចិត្ត គឺភាពជាអ្នកប្រាថ្នាដើម្បីនឹងធ្វើ ឈ្មោះថា ឆន្ទៈ ។ បទ ថា 'ឧស្សហតិ' ប្រែថា រមែងព្យាយាម ។ បទ ថា 'តុលយតិ' ប្រែថា រមែងពិចារណា ដោយអំណាចត្រៃលក្ខណ៍ មានអនិច្ចលក្ខណៈជាដើម ។ បទ ថា 'បទហតិ' ប្រែថា រមែងចាប់ផ្តើម នូវសេចក្តីព្យាយាម ដែលរាប់បញ្ចូលក្នុងមគ្គ ។ ពាក្យ ថា 'កាយេន ចេវ បរមត្ថសច្ចំ' មានសេចក្តីថា រមែងធ្វើឲ្យជាក់ច្បាស់ នូវព្រះនិព្វាន ដោយសហជាតនាមកាយ និងកំចាត់ចោលហើយ នូវកិលេសទាំងឡាយ រមែងឃើញព្រះនិព្វាននោះឯងច្បាស់លាស់ គឺពិតប្រាកដ ដោយបញ្ញា" ។

ដីកានៃចង្កឹសូត្រនោះ ថា "បទ ថា 'បយិរូបាសតិ' គឺ ចូលទៅអង្គុយជិត ដោយអំណាចនៃការឧបដ្ឋាក ។ ព្រះអដ្ឋកថាចារ្យ

ពោល ថា 'បទ ថា **សោតំ** បានដល់ សោតប្រសាទ' ដូច្នេះ ដោយប្រាថ្នា ថា 'ក៏សោតប្រសាទនោះ គឺបុគ្គលគប្បីផ្ទៀងចុះ ដើម្បីស្តាប់'។ បទ ថា '**ធារេតិ**' គឺ ទ្រទ្រង់ទុក ដោយហឫទ័យ បានដល់ រមែងតាំងធម៌នោះទុក ក្នុងហឫទ័យនោះ ។ បទ ថា '**អត្ថតោ**' គឺ ដោយសេចក្តី នៃធម៌តាមដែលបានទ្រទ្រង់ហើយ ។ បទ ថា '**ការណតោ**' បានដល់ ដោយសមគួរ គឺ ដោយហេតុ ឧទាហរណ៍ ដោយគួរ ។ បទ ថា '**និលោកនំ**' មានសេចក្តីថា ធម៌ទាំងឡាយ រមែងអត់ធន់ គឺអត់ទ្រាំបាន នូវភាវៈជាធម៌ ដែលបុគ្គលគប្បីយល់បាន ដោយបញ្ញាចក្ខុ តាមសេចក្តីពិត ថា 'ខនេះ យ៉ាងដូច្នេះឯង'។ កិរិយាអត់ធន់នោះ ក៏គឺកិរិយាដែលសេចក្តីប្រាកដក្នុងចិត្ត ព្រោះបានសម្រេច ដូចជាព្រុយនៃត្រីក្រាយដូច្នោះ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលពាក្យ ថា '**ឥធ**' ដូច្នេះជាដើម ។ សេចក្តីពេញចិត្តក្នុងកុសល ពោលគឺភាពជាអ្នកប្រាថ្នាដើម្បីធ្វើ ឈ្មោះថា ឆន្ទៈ គឺភាពជាអ្នកប្រាថ្នានឹងធ្វើ ។ បទ ថា '**វាយមតិ**' គឺ រមែងធ្វើនូវសេចក្តីព្យាយាម គឺ សេចក្តីប្រឹងប្រែង ដោយអំណាចញ៉ាំងសេចក្តីបរិសុទ្ធិទាំងឡាយ ៤ យ៉ាងខាងដើម ឲ្យបានដល់ព្រម ។ បទ ថា '**មគ្គប្បធានំ**' មានសេចក្តីថា រមែងតាំងសេចក្តីព្យាយាមត្រូវ ៤ យ៉ាង ដែលនាំមកនូវមគ្គ គឺ

ដែលរាប់បញ្ចូលក្នុងមគ្គ បានដល់ រមែងញ៉ាំងសេចក្ដីព្យាយាមត្រូវ ៤ យ៉ាងនោះ ឲ្យបរិបូណ៌ ដោយអំណាចការតាំងសេចក្ដីព្យាយាម ។ បទ ថា **'បរមត្ថសច្ចំ'** បានដល់ សច្ចៈ ឈ្មោះថា បរមត្ថ ព្រោះជាធម៌ដែលមិនទទេ ។ បទ ថា **'សហជាតនាមកាយេន'** មានសេចក្ដីថា បញ្ញាណា ញ៉ាំងព្រះនិព្វាន ឲ្យដល់ព្រម ដោយសហជាត-នាមកាយ, បញ្ញានោះ កាលធ្វើនូវព្រះនិព្វានដែលខ្លួនកំពុងធ្វើ ដោយសហជាតនាមកាយនោះឯង ឲ្យជាក់ច្បាស់ គឺ ឲ្យប្រាកដច្បាស់ ឈ្មោះថា ឃើញ គឺ ធ្វើឲ្យប្រត្យក្ស ដោយសច្ឆិកិរិយាភិសម័យ " ។

(១២៦) ភាពជាអ្នកឈ្លាសវៃ នៃពួកគ្រហស្ថ ដែលកើតឡើង ព្រោះស្ដាប់ ឬក៏រៀននូវសិល្បៈខាងក្រៅ ឈ្មោះថា ពាហុសច្ចៈ របស់គ្រហស្ថ ។ សូម្បីក្នុងពាហុសច្ចៈ របស់គ្រហស្ថនោះ ពាហុសច្ចៈណា មិនមានទោស, ពាហុសច្ចៈនោះ ឈ្មោះថា ជាមង្គល ព្រោះជាហេតុនាំប្រយោជន៍សុខមកឲ្យ ក្នុងលោកទាំង ២ ។ ក្នុងដំណើរនោះ មានរឿងនេះ (ជាឧទាហរណ៍) ÷

## ( រឿង សេនកបណ្ឌិត )

ក្នុងអតីតកាល ព្រះពោធិសត្វ កើតជាព្រាហ្មណ៍ ឈ្មោះថា សេនកៈ ក្នុងទីក្រុងពារាណសី បានរៀនសិល្បសាស្ត្រគ្រប់បែប

យ៉ាង ក្នុងទីក្រុងតក្កសីលា ចប់ស្រេចហើយ ក៏បានវិលត្រឡប់មកទីក្រុងពារាណសីវិញ ។

ក្នុងកាលនោះ ព្រះរាជាក្រុងពារាណសី ទ្រង់ព្រះនាម ជនកៈ ទ្រង់បានព្រះរាជទានដំណែងជាអមាត្យ ព្រមទាំងយសស័ក្តិដ៏ធំ ដល់ព្រះពោធិសត្វនោះ ។ ព្រះពោធិសត្វនោះ ជាអមាត្យអ្នកបង្រៀនអត្ថៈនិងធម៌ របស់ព្រះរាជា ក្នុងថ្ងៃនៃបក្សទាំងឡាយ បានអង្គុយសំដែងធម៌ ដោយពុទ្ធលីលា លើធម្មាសនៈដែលបុគ្គលតាក់តែងទុកហើយ លើធម្មសភា ដែលព្រះរាជាជាដើមទ្រង់ត្រៀមទុកហើយ ។

គ្រានោះ ព្រាហ្មណ៍ចាស់ម្នាក់ ដើរសុំទ្រព្យគេ បាន ១ ពាន់កហាបណៈ យកទៅផ្ញើរទុក ក្នុងត្រកូលព្រាហ្មណ៍មួយហើយ ក៏បានដើរទៅរកសុំគេទៀត ។ ត្រកូលព្រាហ្មណ៍នោះ បានប្រើប្រាស់កហាបណៈអស់ហើយ, កាលបើព្រាហ្មណ៍ចាស់នោះ ត្រឡប់មកវិញ, ក៏មិនអាចសងវិញបាន ទើបបានលើកកូនក្រមុំ របស់ខ្លួន ធ្វើជាបាទបរិចារិកា ដល់ព្រាហ្មណ៍ចាស់នោះ ។ គាត់ក៏បាននាំយកនាងទៅអាស្រ័យនៅ ក្នុងស្រុកព្រាហ្មណ៍ ក្បែរក្រុងពារាណសី ។ ចំណែកនាងព្រាហ្មណីនោះ មិនឆ្អែតឆ្អន់ ដោយមេថុនធម្ម ព្រោះនាងនៅវ័យក្មេងខ្ចី ទើបប្រព្រឹត្តមិច្ឆាចារ ជាមួយនឹងព្រាហ្មណ៍កម្លោះម្នាក់ គិតថា "ដោយឧបាយយ៉ាងនេះ អញនឹងជាអ្នកមិនមានភ័យ ធ្វើ

(អ្វីមួយស្រេចតែនឹងចិត្ត)" ដូច្នេះហើយ ថ្ងៃមួយ បាននិយាយនឹងព្រាហ្មណ៍ដូច្នេះ ថា "ម្នាលព្រាហ្មណ៍ នាងខ្ញុំមិនអាចធ្វើកិច្ចការងារក្នុងផ្ទះ របស់អ្នកបានឡើយ, ចូរអ្នកយកទ្រព្យដែលសុំគេបានមកនាំយកទាសា ឬទាសី មកឱ្យនាងខ្ញុំចុះ" ។ ព្រាហ្មណ៍នោះធ្លាក់ក្នុងអំណាច របស់នាងព្រាហ្មណីនោះ ទើបពោល ថា "ប្រពៃហើយ" ដូច្នេះហើយ បានស្ពាយស្បោងស្បែក ដែលពេញដោយសដូវ ត្រាច់ទៅក្នុងទីទាំងឡាយ មានស្រុកនិងនិគមជាដើម បាននូវទ្រព្យ ៧៧ កហាបណៈហើយ ទើបត្រឡប់មកវិញ អង្គុយបរិភោគសដូវ ក្រោមដើមឈើដែលមានប្រហោងមួយដើម ត្រង់ចន្លោះផ្លូវមិនបានចងមាត់ស្បោង ស្រាប់តែចុះទៅផឹកទឹក ។

គ្រានោះ ពស់វែកដំបូក ក្នុងដើមឈើដែលមានរន្ធមួយ បានវារមកចូលស្បោង ដោយក្លិននៃសដូវហើយ បានដេកវៀនស៊ីនូវសដូវ ។ ព្រាហ្មណ៍មកហើយ មិនទាន់បានក្រួតមើលខាងក្នុងផង ក៏បានចងមាត់ស្បោងស្ពាយដើរចេញទៅ បានស្តាប់ពាក្យរបស់រុក្ខទេវតា ១ អង្គ ប្រាប់ ថា "ម្នាលព្រាហ្មណ៍ ថ្ងៃនេះ បើអ្នកនឹងសំណាក់នៅតាមផ្លូវ, ខ្លួនអ្នកឯង នឹងត្រូវស្លាប់, តែថ្ងៃនេះបើអ្នកនឹងទៅដល់ផ្ទះ, ភរិយារបស់អ្នក ក៏នឹងត្រូវស្លាប់" ដូច្នេះហើយ ទើបតក់ស្លុតចំពោះមរណភ័យ ស្រែកទ្ទូញយំ បានធ្វើដំណើរ

ទៅដល់មាត់ទ្វារក្រុងពារាណសីហើយ ។ ក្នុងពេលនោះ ជាថ្ងៃឧបោសថ ទី ១៥ ។ មនុស្សទាំងឡាយ បានកាន់គ្រឿងក្រអូបនិងផ្កាកម្រងជាដើម ទៅស្តាប់ធម៌ព្រះពោធិសត្វ ។ ព្រាហ្មណ៍នោះ ឃើញមនុស្សទាំងនោះហើយ ក៏សួរ បានដឹងសេចក្តីនោះហើយ ទើបគិត ថា " បានឮថា សេនកបណ្ឌិត ជាអ្នកសំដែងធម៌, លោកនឹងសំដែងធម៌ណាមួយ កំចាត់ចេញនូវសេចក្តីសោក របស់អញបាន, ការដែលអញទៅ ក្នុងទីនោះ ស្តាប់ធម៌ ទើបសមគួរណាស់ " ដូច្នេះហើយ ក៏បានទៅជាមួយនឹងមនុស្សទាំងនោះ បានឈរស្រេកឃ្លាំនៅត្រង់ទីបំផុតនៃបរិស័ទ មានស្បោងសដូវដែលជាប់នៅលើ-ក ។

ព្រះពោធិសត្វ ឃើញព្រាហ្មណ៍នោះហើយ គិត ថា " សេចក្តីសោកសៅ ដែលអាចឲ្យកើតទឹកភ្នែក ឮដ៏ខាងក្នុងព្រាហ្មណ៍នោះ គង់នឹងមានពិត " ហើយ ក៏បានសួរនូវហេតុនៃសេចក្តីសោកនោះ ។

ព្រាហ្មណ៍នោះ បានប្រាប់ពាក្យដែលទេវតាប្រាប់ហើយ សួរ ថា " ខ្ញុំបាទ បានឮពាក្យនេះហើយ ទើបសោកសៅ, ម្នាលបណ្ឌិត អ្វីទៅហ្ន៎ ជាហេតុនៃសេចក្តីស្លាប់ របស់ខ្ញុំបាទ និងភរិយា ? " ។

ព្រះពោធិសត្វ កាលពិចារណាមើល ក៏បានដឹងហេតុការណ៍ទាំងអស់ ដោយញាណ គឺភាពជាអ្នកឈ្លាសវៃ ក្នុងឧបាយ របស់ខ្លួនបានតែម្តង ដូចជាឃើញដោយភ្នែកទិព្វ ហើយក៏បានសួរ ថា

“ម្នាលព្រាហ្មណ៍ ក្នុងស្បៀងរបស់អ្នកនុ៎ះ មានសដូវខ្លះឬទេ ?”។

ព្រាហ្មណ៍ . បពិត្រលោកបណ្ឌិត មាន ។

សេនកៈ . ក្នុងពេលបរិភោគអាហារព្រឹក ថ្ងៃនេះ តើអ្នកបរិភោគសដូវ នៅទីណា ? ។

ព្រាហ្មណ៍ . ក្រោមគល់ឈើ ក្នុងព្រៃ ។

សេនកៈ . អ្នកបរិភោគសដូវហើយ កាលទៅផឹកទឹក តើបានចងមាត់ស្បៀងដែរឬទេ ? ។

ព្រាហ្មណ៍ . ខ្ញុំមិនបានចងទេ ។

សេនកបណ្ឌិត ប្រាប់ ថា “បើដូច្នោះ ខ្ញុំយល់ ថា ‘ក្នុងពេលដែលអ្នកទៅផឹកទឹក ពស់វែកដំបូកមួយ បានវារចូលស្បៀង ព្រោះក្លិននៃសដូវ’ ដូច្នេះ, បើថ្ងៃនេះ អ្នកនឹងឈប់សម្រាកនៅតាមផ្លូវ, អ្នកកាលបរិភោគសដូវ ក្នុងពេលល្ងាច នឹងលូកដៃចូល ក្នុងស្បៀង, កាលបើដូច្នោះ អ្នកនឹងត្រូវពស់ខាំដៃស្លាប់, នេះគឺជាហេតុនៃសេចក្ដីស្លាប់របស់អ្នក, បើអ្នកនឹងទៅដល់ផ្ទះ ក្នុងថ្ងៃនេះ, ប្រពន្ធរបស់អ្នក នឹងលូកដៃចូលទៅ ក្នុងស្បៀង ដើម្បីយកទ្រព្យ, កាលបើដូច្នោះ ប្រពន្ធរបស់អ្នកនោះ នឹងត្រូវពស់ខាំដៃស្លាប់, នេះគឺជាហេតុនៃសេចក្ដីស្លាប់ របស់ប្រពន្ធរបស់អ្នកនោះ, ទេវតាបានពោលយ៉ាងដូច្នោះ សំដៅយកហេតុនៃសេចក្ដីស្លាប់នេះ, ព្រោះហេតុនោះ

ចូរអ្នកទម្លាក់ស្បោងនោះ ដាក់ត្រង់កណ្ដាលបរិស័ទ ស្រាយមាត់ស្បោងចេញហើយ ចៀសចេញទៅឈរ យកដំបងគោះស្បោង" ។ ព្រាហ្មណ៍ បានធ្វើហើយ យ៉ាងដូច្នោះ ។ ពស់ដកពពារ ឲ្យសំឡេង "សុ ៗ" បានវារចេញមកហើយ ។

គ្រានោះ គ្រូពស់ម្នាក់ បានចាប់ពស់នោះ យកទៅលែងចោលក្នុងព្រៃហើយ ។ មនុស្សទាំងឡាយ រីករាយសប្បាយចិត្ត ថា "សេនកបណ្ឌិតនេះ រមែងព្យាករ ដូចជាព្រះសព្វញ្ញុពុទ្ធ" ហើយនាំគ្នាញ៉ាំងសែននៃការលើកផ្ទាំងបដា សែននៃការទះដៃ និងសែននៃការឲ្យសាធុការ ឲ្យប្រព្រឹត្តទៅហើយ ។ សំឡេងឲ្យសាធុការកើតដូចជាសំឡេងនៃការរបើកមហាប្រឹថពី, ភ្លៀងរតនៈ ៧ ប្រការ ក៏បានធ្លាក់មក ដូចជាភ្លៀងធ្លាក់ព្រិល ដើម្បីបូជាចំពោះព្រះពោធិសត្វ ។ ចំណែកព្រាហ្មណ៍ ក៏បានបូជាព្រះពោធិសត្វនោះដោយកហាបណៈ ដែលខ្លួនបានមកហើយ ។ ព្រះពោធិសត្វមិនបានទទួលយកកហាបណៈទាំងនោះទេ ត្រឡប់ជាបន្ថែមឲ្យ ៣០០ កហាបណៈទៀត ដល់ព្រាហ្មណ៍ ដើម្បីគម្រប់ ១ ពាន់ ហើយសួរ ថា "តើអ្នកណា បញ្ជូនអ្នកទៅ ដើម្បីសុំទ្រព្យ ?" ។

ព្រាហ្មណ៍ . បពិត្រលោកបណ្ឌិត ភរិយារបស់ខ្ញុំបាទ ។

សេនកៈ . ភរិយារបស់អ្នកនោះ តើចាស់ ឬក្មេង ? ។

ព្រាហ្មណ៍ . បពិត្រលោកបណ្ឌិត នាងជាស្រីក្មេង ។

ព្រះពោធិសត្វ បានពន្យល់ ថា “បើដូច្នោះ ភរិយារបស់អ្នកនោះ គង់ធ្វើនូវមិច្ឆាចារជាមួយនឹងបុរសដទៃ ទើបបានបញ្ជូនអ្នកទៅ, ក៏បើអ្នក នឹងនាំយកកហាបណៈទាំងនេះ ទៅផ្ទះ, ភរិយារបស់អ្នកនោះ នឹងឲ្យដល់ប្រុសសហាយ, ព្រោះហេតុនោះ អ្នកគប្បីលាក់ទុកនៅកន្លែងណាមួយ ខាងក្រៅផ្ទះសិនហើយ ទើបចូលទៅផ្ទះ” ហើយ ក៏បានបញ្ជូនព្រាហ្មណ៍នោះទៅ ។ ព្រាហ្មណ៍នោះ បានធ្វើយ៉ាងដូច្នោះហើយ បានឈរនៅក្បែរមាត់ទ្វារផ្ទះ ស្រែកហៅ ថា “នែនាងដ៏ចំរើន!” ។

ក្នុងខណៈនោះ ចំណែកភរិយានោះ អង្គុយជាមួយនឹងប្រុសសហាយ បានឮសំឡេងស្វាមីនោះហើយ ទើបពន្លត់ប្រទីប បិទទ្វារ, កាលបើស្វាមីនោះ ចូលទៅក្នុង (ផ្ទះ) ហើយ, ក៏នាំប្រុសសហាយចេញទៅឈរនៅក្បែរទ្វារហើយ បានចូលទៅកាន់ផ្ទះ សួរ ថា “តើបងបានអ្វីមកខ្លះ ?” ។ ព្រាហ្មណ៍នោះ ប្រាប់ ថា “បងបានទ្រព្យ ១ ពាន់ បងដាក់ទុក ក្នុងទីឯណោះ” ។ ភរិយានោះបានទៅប្រាប់ ដល់ប្រុសសហាយហើយ ។ ប្រុសសហាយនោះក៏បានទៅយកទ្រព្យនោះ រត់ចេញទៅហើយ ។

លុះថ្ងៃស្អែកឡើង ព្រាហ្មណ៍ មិនឃើញទ្រព្យនោះ ទើបចូល

ទៅរកព្រះពោធិសត្វ ប្រាប់(រឿងរ៉ាវ) ហើយ ។ ព្រះពោធិសត្វ ដឹងសេចក្តីនោះហើយ ទើបបានឲ្យស្បៀង ដល់ព្រាហ្មណ៍នោះ ល្មមនឹងគ្រប់ ៧ ថ្ងៃ ហើយបានប្រាប់ ថា "ក្នុងថ្ងៃដំបូង ចូរអ្នកអញ្ជើញព្រាហ្មណ៍ ១៤ នាក់ មកជប់លៀង គឺ ព្រាហ្មណ៍ជាកុលុបកៈ របស់អ្នក ៧ នាក់, ព្រាហ្មណ៍របស់ភរិយានៃអ្នក ៧ នាក់ ចាប់តាំងអំពីថ្ងៃស្អែកឡើងទៅ ចូរដកចេញម្នាក់មួយៗ ក្នុងថ្ងៃទី ៧ ចូរអ្នកអញ្ជើញតែព្រាហ្មណ៍ ២ នាក់ គឺ ព្រាហ្មណ៍ របស់អ្នកម្នាក់ របស់ភរិយានៃអ្នកម្នាក់, បណ្តាព្រាហ្មណ៍ទាំង ២ នាក់នោះ កុលុបកៈ របស់ភរិយានៃអ្នករូបណា មកជាប់ជានិច្ច រហូត ៧ ថ្ងៃ, ចូរអ្នកប្រាប់កុលុបកៈរូបនោះ ដល់យើងចុះ" ។ ព្រាហ្មណ៍នោះ បានធ្វើហើយ យ៉ាងដូច្នោះ ប្រាប់ហើយ ដល់ព្រះពោធិសត្វ ។

ព្រះពោធិសត្វ បានញ៉ាំងបុរសទាំងឡាយ ឲ្យនាំយកព្រាហ្មណ៍នោះមកហើយ សួរ ថា "តើអ្នកបានយកទ្រព្យ ១ ពាន់កហាបណៈ របស់ព្រាហ្មណ៍នេះ អំពីគល់ឈើឯណោះឬទេ ?" ។

ព្រាហ្មណ៍ បពិត្រលោកបណ្ឌិត ខ្ញុំមិនបានយកទេ ។

សេនកៈ ខ្ញុំឈ្មោះសេនកបណ្ឌិត, អ្នកមិនស្គាល់ទេឬ ? ។

ព្រាហ្មណ៍នោះ ភ័យហើយ ទើបប្រាប់ ថា "ខ្ញុំបាទបាននាំយកទៅកប់ទុក ក្នុងទីឈ្មោះនោះ" ។

ព្រះពោធិសត្វ បានប្រើពួកបុរស ឲ្យនាំយកទ្រព្យនោះមកហើយ ឲ្យដាក់រាជអាជ្ញា ដល់ព្រាហ្មណ៍ជាចោរ ឲ្យនិរទេសចេញពីព្រះនគរ ហើយ ឲ្យទ្រព្យ ១ ពាន់នោះ ព្រមទាំងយសស័ក្តិដ៏ធំ ដល់ព្រាហ្មណ៍ ក្រៅពីនេះ បានឲ្យព្រាហ្មណ៍នោះ ព្រមទាំងភរិយា អាស្រ័យនៅ ក្នុងសំណាក់របស់ខ្លួនហើយ ។ ព្រះពោធិសត្វនោះ បំពេញបរមត្ថបារមី ឲ្យបរិបូណ៌ ដោយការរំដោះព្រាហ្មណ៍ ឲ្យរួចចេញអំពីសេចក្តីទុក្ខ ដោយប្រការដូច្នេះឯង ។

ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ក្នុងចរិយាបិដក ថា ៖

**(១២៧) "តថាគត កាលពិចារណា ដោយបញ្ញា ទើបបានរំដោះព្រាហ្មណ៍ ឲ្យរួចចាកសេចក្តីទុក្ខ, គុណជាតដទៃស្មើនឹងបញ្ញា របស់តថាគត មិនមានឡើយ, នេះជាបញ្ញាបារមី របស់តថាគត" ។**

សូម្បីក្នុងអដ្ឋកថាអដ្ឋសាលិនី ក៏លោកពោលទុកហើយ ថា "ភាវៈជាបញ្ញាបារមី របស់ព្រះពោធិសត្វ អ្នកសំដែងពស់ ដែលនៅខាងក្នុងស្បោង ឈ្មោះថា ជាបរមត្ថបារមី" ។

ក៏កិរិយាពោល (ដោះស្រាយ) នូវបញ្ហាប្រាកដដូច្នេះ ដោយ

ពុទ្ធលីលា, មិនមែនជាកម្លាំងនៃជាតិឡើយ, មិនមែនជាកម្លាំងនៃគោត្រ ត្រកូល ប្រទេស យកស័ក្តិ និងទ្រព្យឡើយ, តាមពិតហើយគឺជាកម្លាំងនៃបញ្ញា ។ ព្រោះថា បុរសអ្នកមានបញ្ញា ចំរើនវិបស្សនាហើយ រមែងបើកទ្វារ គឺអរិយមគ្គ ចូលទៅកាន់នគរ គឺព្រះនិព្វាន, រមែងចាក់ធ្លុះនូវសាវកបារមីខ្លះ បច្ចេកពោធិញាណខ្លះ សម្មាសម្ពោធិញាណខ្លះ ។ មែនពិត បណ្តាធម៌ដែលញុំាងបុគ្គលអ្នកប្រតិបត្តិ ឲ្យបានសម្រេចព្រះនិព្វាន បញ្ញាប៉ុណ្ណោះឯងជាគុណជាតិប្រសើរបំផុត, ធម៌ទាំងឡាយដែលសេសសល់ សុទ្ធតែជាបរិវារ របស់បញ្ញានោះ ។

ដោយហេតុនោះ សរភង្គសាស្តា ត្រូវស្តេចសក្កៈ ដែលជាស្តេចនៃទេវតា ត្រាស់សួរហើយ យ៉ាងដូច្នេះ ថា ៖

(១២៨) "បណ្ឌិតទាំងឡាយ ពោលនូវសីលផង[១] សិរីផង ធម៌របស់សប្បុរសផង ប្រាជ្ញាផង (ថា) តើគុណជាតិណា ប្រសើរជាងគេបំផុត" ។

ដូច្នេះហើយ ទើបបានពោល ថា ៖

"អ្នកឈ្លាសវៃទាំងឡាយ រមែងពោល ថា ប្រាជ្ញានុ៎ះឯង ជាគុណជាតិដ៏ប្រសើរបំផុត ដូចជាស្តេច

---

១ ត្រៃបិដក ភាគទី ៦០ / ទំព័រទី ២៣៩ ។

នៃផ្កាយ (ព្រះច័ន្ទ) ដ៏ប្រសើរជាងផ្កាយទាំងឡាយ, ទុកជាសីលក្តី សិរីក្តី ធម៌របស់សប្បុរសក្តី ក៏រមែងប្រព្រឹត្តទៅតាមបុគ្គលអ្នកមានប្រាជ្ញា" ។

បណ្តាបទទាំងនោះ បទ ថា "**សីលំ**" បានដល់ សីល គឺមារយាទ ។ បទ ថា "**សិរី**" បានដល់ ភាពជាឥស្សរៈ ។ ពាក្យ ថា "**បញ្ញា ហិ**" មានសេចក្តីថា បពិត្រស្តេចសក្កទេវរាជ បុគ្គលអ្នកឈ្លាសវៃទាំងឡាយ មានព្រះពុទ្ធជាដើម រមែងពោល ថា "បណ្តាធម៌ ៤ ប្រការនេះ គុណជាតិដែលឈ្មោះថា បញ្ញានុ៎ះឯងប្រសើរបំផុត" ។ បទ ថា "**នក្ខត្តរាជារិវ**" បានដល់ ដូចជាព្រះច័ន្ទ ដ៏ប្រសើរជាងតារាទាំងឡាយ ។ បទ ថា "**អន្វាយិកា**" មានសេចក្តីថា ធម៌ទាំង ៣ យ៉ាងនេះ រមែងប្រព្រឹត្តទៅតាមបុគ្គលអ្នកមានប្រាជ្ញាតែប៉ុណ្ណោះ, អធិប្បាយ ថា "ជាបរិវាររបស់បញ្ញាប៉ុណ្ណោះឯង" ។

សេនកបណ្ឌិត បានសម្រេចនូវប្រយោជន៍ ក្នុងលោកនេះ ពោលគឺដំណែងនៃអមាត្យជាដើមហើយ បានធ្វើកម្មដែលជាហេតុនាំមកនូវប្រយោជន៍ ក្នុងលោកខាងមុខ ព្រោះការសំដែងធម៌ ដល់មនុស្សទាំងឡាយ និងព្រោះការរំដោះព្រាហ្មណ៍ ឲ្យរួចផុតអំពី

សេចក្តីទុក្ខ ព្រោះភាពនៃខ្លួនជាពហុស្សូត ដោយប្រការដូច្នេះឯង ។

រឿង សេនកបណ្ឌិត មកក្នុងអដ្ឋកថាសត្តុភស្តជាតក ក្នុងសត្តកនិបាត ។

សូម្បីរឿង របស់ព្រះរាជឱរសនៃព្រះបាទព្រហ្មទត្ត ដែលទ្រង់សិក្សានូវសិល្បសាស្ត្រគ្រប់យ៉ាង និងមន្តដែលជាហេតុដឹងនូវសំឡេងសត្វយំទាំងពួង ក្នុងក្រុងតក្កសីលាហើយ ទ្រង់ស្តេចយាងមកវិញ ត្រូវព្រះរាជបិតាតែងតាំងហើយ ក្នុងដំណែងជាឧបរាជ ក្រោយមកទ្រង់បានឡើងគ្រងរាជសម្បត្តិ ទ្រង់បានបំពេញបុណ្យ មានទានជាដើមហើយ ទ្រង់មានស្ថានសួគ៌ប្រព្រឹត្តទៅខាងមុខ ដែលមកហើយ ក្នុងអដ្ឋកថាបរន្តបជាតក ក្នុងសត្តកនិបាតនោះឯង ក៏គប្បីប្រមូលយកមកផងដែរ ។

ពណ៌នាអំពីភាពជាអ្នកមានការស្តាប់ច្រើន ចប់ ។

⁂

ប្រែចប់ថ្ងៃអាទិត្យ ៣ កើត ខែមាឃ ឆ្នាំច ឆស័ក ព.ស.២៥៣៧
ថ្ងៃទី ១៣ ខែកុម្ភៈ ១៩៩៤

## ពណ៌នាអំពីសិល្បៈ

(១២៩) ភាពជាអ្នកឈ្លាសវាងវៃ ក្នុងហត្ថកម្ម មាន ២ យ៉ាង ដោយអំណាចនៃសិល្បៈ របស់បព្វជិត និងគ្រហស្ថ ឈ្មោះថា សិល្បៈ ។

### ( សិប្បៈរបស់បព្វជិត )

បណ្ដាសិល្បៈទាំង ២ យ៉ាងនោះ ការចាត់ចែងសមណបរិក្ខារ មានការពិចារណា និងការដេរចីពរជាដើម ដែលព្រះដ៏មានព្រះភាគ ទ្រង់បានត្រាស់សំដែងហើយ ក្នុងសត្តមសូត្រ ក្នុងទុតិយវគ្គ នៃទសកនិបាត អង្គុត្តរនិកាយ យ៉ាងដូច្នេះ ថា "ម្នាលភិក្ខុទាំងឡាយ ! ក្នុងសាសនានេះ អំពើទាំងឡាយណា ដែលខ្ពស់និងទាប ដែលពួកសព្រហ្មចារីបុគ្គលត្រូវស្នួរគ្នីគ្នា ហើយទើបធ្វើ, ភិក្ខុជាអ្នកឈ្លាសវៃ មិនខ្ជិលច្រអូស ក្នុងអំពើនោះ ប្រកបព្រមដោយបញ្ញាជាគ្រឿងពិចារណា ដោយឧបាយ ក្នុងអំពើនោះថា គួរធ្វើ គួរចាត់ចែងបាន, ម្នាលភិក្ខុទាំងឡាយ អំពើទាំងឡាយណា ដែលខ្ពស់និងទាប ដែលពួកសព្រហ្មចារីបុគ្គលត្រូវស្នួរគ្នីគ្នា ហើយទើបធ្វើ, ភិក្ខុជាអ្នកឈ្លាសវៃ ។ល។ គួរធ្វើ គួរចាត់ចែងបាន, ធម៌នេះឯង ឈ្មោះថា នាថករណធម៌ " ដូច្នេះ ឈ្មោះថា សិល្បៈនៃបព្វជិត ។

(១៣០) អដ្ឋកថាសត្តមសូត្រនោះ ថា "បណ្ដាបទទាំងនោះ បទ ថា '**ឧច្ចាវចានិ**' ប្រែថា ខ្ពស់និងទាប ។ កិច្ចការងារ ដែលបុគ្គលគប្បីពោល យ៉ាងដូច្នេះថា 'ខ្ញុំនឹងធ្វើនូវកិច្ចការអ្វី ?' ដូច្នេះហើយ ទើបធ្វើ ឈ្មោះថា ការងារដែលបុគ្គលគប្បីសួរគ្នីគ្នា ហើយទើបធ្វើ ។ បណ្ដាការងារខ្ពស់និងទាបទាំង ២ យ៉ាងនោះ ការងារជាអាទិ៍ យ៉ាងនេះ គឺ ការធ្វើ ការជ្រលក់នូវចីពរ កម្មគឺ ការលាបកំបោរ លើព្រះចេតិយ ការងារដែលបុគ្គលត្រូវធ្វើ ក្នុង រោងឧបោសថ រោងព្រះចេតិយ និងរោងដើមពោធិ ឈ្មោះថា ការងារខ្ពង់ខ្ពស់' ។ ការងារតិចតួច មានការលាងនិងការ លាបជើងជាដើម ឈ្មោះថា ការងារទាប ។ បទ ថា '**តត្រុបាយាយ**' ប្រែថា ប្រព្រឹត្តចូលទៅ ក្នុងការងារដែលគប្បី សួរគ្នីគ្នាធ្វើនោះ ។ បទ ថា '**អលំ កាតុំ**' គឺ ជាអ្នកអាចដើម្បី ធ្វើបាន ។ បទ ថា '**អលំ សំវិធាតុំ**' គឺ ជាអ្នកអាចដើម្បីចាត់ ចែងបាន ។ បទ ថា '**នាថករណោ**' បានដល់ ធ្វើភារៈជាទីពឹង របស់ខ្លួន, អធិប្បាយ ថា 'ធ្វើនូវទីពឹងពំនាក់' ដូច្នេះ" ។

ដីកាសត្តមសូត្រនោះ ថា "បទ ថា '**ឧច្ចនីចានិ**' គឺ ធំនិង តូច ។ បទ ថា '**តត្រុបគមនិយា**' មានសេចក្ដីថា ដំណើរការ ចូលទៅ ក្នុងការងារធំនិងតូចនោះ ៗ ដោយអំណាចធ្វើឲ្យបាន

សម្រេច គឺ អាចក្នុងការញ៉ាំងកិច្ចការងារនោះ ៗ ឲ្យបានសម្រេច ។ បទ ថា 'តត្រុបាយាយ' បានដល់ ជាឧបាយក្នុងកិច្ចការនោះ ៗ ដែលគប្បីធ្វើឲ្យសម្រេច ។ ភិក្ខុ លោកហៅថា 'នាថៈ' ព្រោះអត្ថ ថា 'រមែងរក្សា ថែទាំ គ្រប់គ្រង (នូវខ្លួន) ដោយធម៌ទុំះឯង ព្រោះមានធម៌ជាទីពឹងពាក់, ធម៌ដែលធ្វើនូវភាពជាទីពឹង របស់ភិក្ខុនោះ លោកហៅថា 'នាថករណធម៌' ដូច្នេះ " ។

ក៏សេចក្ដីនេះ បណ្ឌិតគប្បីត្រួតពិនិត្យ សូម្បីក្នុងសង្គីតិសូត្រ ព្រមទាំងអដ្ឋកថា និង ដីកា ។

(១៣១) សិល្បៈរបស់បព្វជិតនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ ថា " ជាមង្គល " ព្រោះនាំមកនូវប្រយោជន៍សុខ ក្នុងលោកទាំង ២ ដល់ខ្លួនឯងផង ដល់ពួកជនដទៃផង ។

ក្នុងដំណើរនោះ មានរឿងទាំងនេះ (ជាឧទាហរណ៍) ÷

## ( រឿង ព្រះអានន្ទត្ថេរ )

សម័យមួយ ព្រះមានព្រះភាគ កាលស្ដេចយាងចារិកទៅ[(១)] ក្នុងទក្ខិណាគិរីជនបទ ទ្រង់ទតព្រះនេត្រឃើញស្រែអ្នកដែនមគធៈ ទើបទ្រង់ត្រាស់ ថា "ម្នាលអានន្ទ តើអ្នកអាច ដើម្បីនឹងចាត់ចែងធ្វើចីពរបែបនេះ ដល់ភិក្ខុទាំងឡាយ បានដែរឬទេ ? " ដូច្នេះ

---

១ ត្រៃបិដក ភាគទី ៨ / ទំព័រទី ១១៧ ។

ហើយ ទើបបានស្តេចយាងទៅកាន់ទីក្រុងរាជគ្រឹះ ។ ព្រះថេរៈ ព្រោះខ្លួនជាអ្នកឈ្លាសវៃ ក្នុងហត្ថកម្ម ទើបក្រាបទូល ថា "បពិត្រ ព្រះអង្គដ៏ចំរើន ទូលព្រះបង្គំអាច ចាត់ចែងបាន" ដូច្នេះហើយ ទើប បានចាត់ចែងនូវចីពរមានរូបដូច្នោះ សំដែងថ្វាយដល់ព្រះសាស្តា ។

ព្រះសាស្តា កាលទ្រង់សរសើរនូវព្រះថេរៈនោះ ទើបទ្រង់ត្រាស់ ហៅភិក្ខុទាំងឡាយមក ថា "ម្នាលភិក្ខុទាំងឡាយ អានន្ទ ជាបណ្ឌិត ម្នាលភិក្ខុទាំងឡាយ អានន្ទ មានប្រាជ្ញាច្រើន, ព្រោះថា អានន្ទ អាចដឹងច្បាស់នូវសេចក្តី នៃពាក្យដែលតថាគតសំដែងហើយ ដោយ សង្ខេប បានដោយពិស្តារ ហើយចេះធ្វើសំពត់ឈ្មោះកុសិផង ឈ្មោះ អឌ្ឍកុសិផង ឈ្មោះមណ្ឌលផង ឈ្មោះអឌ្ឍមណ្ឌលផង ឈ្មោះវិវដ្ដៈ ផង ឈ្មោះអនុវិវដ្ដៈផង ឈ្មោះគីវេយ្យកៈផង ឈ្មោះជង្ឃេយ្យកៈផង ឈ្មោះពាហន្តៈផង, ហើយសំពត់នោះ ក៏អានន្ទបានកាត់ដាច់ ឲ្យសៅ ហ្មងដោយមុខកាំបិត ឲ្យសមគួរដល់សមណៈ ឲ្យជារបស់មិនគួរប្រាថ្នា ដល់ពួកចោរជាសឹកសត្រូវ ។ ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតសង្ឃាដីកាត់ ឧត្តរាសង្គៈកាត់ អន្តរវាសកៈកាត់" ។

(១៣២) បណ្តាបទទាំងនោះ បទ ថា "**យត្រ ហិ**" គឺ **យោ** ប្រែថា ព្រះអានន្ទណា ។ ផ្ទាំងសំពត់វែង មានអនុវាត ជាដើម ទាំងបណ្តោយ ទាំងទទឹង ឈ្មោះថា កុសិ ។ ផ្ទាំងសំពត់

ដែលខ្លី ក្នុងចន្លោះៗ ឈ្មោះថា អឌ្ឍកុសិ ។ មណ្ឌលធំ ក្នុងខ្ទង់នីមួយៗ ឈ្មោះថា មណ្ឌល ។ មណ្ឌលតូច ឈ្មោះថា អឌ្ឍមណ្ឌល ។ ខ្ទង់ត្រង់កណ្តាល ដែលគេដេរនូវមណ្ឌលនិងអឌ្ឍមណ្ឌលបញ្ចូលជាមួយគ្នា ឈ្មោះថា វិវដ្ដៈ ។ ២ ខ្ទង់ គឺខាងមួយ ៗ នៃវិវដ្ដៈ មានមួយខ្ទង់ ៗ ក្នុងចីពរដែលមានខ្ទង់ ៥ (និង) ៤ ខ្ទង់ គឺ ក្នុងខាងទាំង ២ នៃវិវដ្ដៈ ក្នុងចីពរដែលមានខ្ទង់ ៧ មានខ្ទង់ ២ ៗ ឈ្មោះថា អនុវិវដ្ដៈ ។ ផ្ទាំងសំពត់ដែលបន្ថែមចូលមក ដែលគេដេរភ្ជាប់នឹងអំបោះផ្សេងទៀត ដើម្បីធ្វើឲ្យណែន ត្រង់ទីកន្លែងដែលឃ្លុំ-ក ឈ្មោះថា គីវេយ្យកៈ ។ ផ្ទាំងសំពត់ដែលគេដេរភ្ជាប់ យ៉ាងដូច្នោះដែរ ត្រង់ទីកន្លែងដែលគ្របជង្គង់ ឈ្មោះថា ជង្ឃេយ្យកៈ ។ អាចារ្យពួកខ្លះ ពោល ថា "ផ្ទាំងសំពត់ដែលនៅ ត្រង់កន្លែង-ក (ឈ្មោះថា គីវេយ្យកៈ) និងត្រង់កន្លែងជង្គង់ (ឈ្មោះថា ជង្ឃេយកៈ)" ដូច្នេះក៏មាន ។ ខ្ទង់មួយ ៗ ខាងក្រៅអនុវិវដ្ដៈ ឈ្មោះថា ពាហន្តៈ ។

ចំណែកក្នុងមហាអដ្ឋកថា លោកពោល ថា "ជាយទាំងឡាយពីរ ដែលភិក្ខុកាលគ្រងចីពរដែលត្រូវខ្នាត មូលមកពាក់លើដើមដៃមានមុខស្ថិតនៅខាងក្រៅ, ពាក្យ ថា 'ពាហន្តៈ' នុ៎ះ ជាឈ្មោះនៃជាយទាំង ២ នោះ " ។

ព្រះដ៏មានព្រះភាគ លុះទ្រង់សំដែងនូវចីពរ ៤ យ៉ាង ដោយអំណាចកុសិជាដើម យ៉ាងដូច្នេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់សំដែង ថា "ចីពរទាំងអស់នុ៎ះ គឺភិក្ខុត្រូវតែកាត់" ដូច្នេះ ទើបទ្រង់ត្រាស់ ថា "**ឆិន្នកញ្ច**" ដូច្នេះជាដើម ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យទាំងនោះ ។ បទ ថា "**ឆិន្នកញ្ច**" គឺ ឈ្មោះថា ចីពរដែលកាត់ហើយ ដោយប្រការមានកុសិជាដើម ។ បទ ថា "**បច្ចត្ថិកានំ**" បានដល់ ពួកចោរដែលជាសឹកសត្រូវ ដល់ព្រះសាសនា ។ បទ ថា "**អនភិជ្ឈាកតំ**" គឺ មិនធ្វើការសំឡឹងរំពៃហើយ, អធិប្បាយថា "មិនចង់បានហើយ" ។ ហេតុនោះចីពរទាំង ៣ នោះឯង ភិក្ខុត្រូវតែកាត់ ។ បើភិក្ខុកាត់ចីពរ ៣, សំពត់មិនគ្រប់គ្រាន់, ភិក្ខុត្រូវកាត់តែចីពរ ២ ។ សូម្បីកាលបើភិក្ខុកាត់ចីពរ ២, សំពត់ក៏មិនគ្រប់គ្រាន់, ភិក្ខុត្រូវកាត់ចីពរ ១, សូម្បីកាលបើភិក្ខុកាត់ចីពរ ១, សំពត់ក៏មិនគ្រប់គ្រាន់ដែរ, ភិក្ខុត្រូវតែបន្ថែមសំពត់អាគន្តុកៈ (សំពត់ថ្មី) ទៀត ។

ក្នុងដំណើរនោះ មានបាលីនេះ (ជាឧទាហរណ៍) ÷

( បាលីក្នុងចីវរក្ខន្ធកៈ )

(១៣៣) ក៏សម័យនោះឯង ពួកភិក្ខុកំពុងធ្វើចីពរ[១] (ឲ្យ) ភិក្ខុ ១ រូប, លុះភិក្ខុកាត់ចីពរទាំងអស់ទៅហើយ សំពត់មិនគ្រប់គ្រាន់ ។

១ ត្រៃបិដក ភាគទី ៨ / ទំព័រទី ១៤៤ ។

( ពួកភិក្ខុ ក្រាបបង្គំទូលនូវសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ឲ្យហៅភិក្ខុទាំងឡាយមក ហើយ ទ្រង់ត្រាស់អនុញ្ញាត ថា ) "ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឲ្យកាត់ចីពរ ២ (ឯ) ចីពរ ១ មិនបាច់កាត់ក៏បានដែរ" ។ ពួកភិក្ខុនោះ បានកាត់ចីពរ ២, មិនបានកាត់ ១, សំពត់ក៏នៅតែមិនគ្រប់គ្រាន់ទៀត ។ ( បន្ថែមសេចក្តីដូចមុន ) ។ "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតចីពរ ២ មិនបាច់កាត់ទេ, ឲ្យកាត់តែចីពរ ១ បាន" ។ ពួកភិក្ខុទាំងនោះ មិនបានកាត់ចីពរ ២, បានកាត់តែចីពរ ១, សំពត់ក៏នៅតែមិនគ្រប់គ្រាន់ទៀត ។ ( បន្ថែមសេចក្តីដូចមុន ) ។ "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឲ្យភិក្ខុលើកឡើង (ប៉ះ) សូម្បីនូវសំពត់អាគន្តុកៈ (សំពត់ថ្មី ) ទៀត ។ ម្នាលភិក្ខុទាំងឡាយ ក៏ភិក្ខុមិនត្រូវទ្រទ្រង់ចីពរដែលមិនបានកាត់ទាំងអស់ឡើយ, ភិក្ខុណា ទ្រទ្រង់, ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ" ។

អដ្ឋកថានៃចីវរក្ខន្ធកៈនោះ ថា "ក្នុងពាក្យ ថា '**អន្វាធិកំបិ អារោបេតុំ**' គឺ ដើម្បីបន្ថែមនូវសំពត់អាគន្តុកៈ ។ តែសំពត់អាគន្តុកៈនេះ, បើសំពត់មិនគ្រប់គ្រាន់, ភិក្ខុគប្បីប៉ះបាន ។ បើសំពត់គ្រប់គ្រាន់, ការដែលភិក្ខុប៉ះនូវសំពត់អាគន្តុកៈ មិនគួរទេ,

ចីពរទាំងអស់ ភិក្ខុត្រូវតែកាត់ឲ្យទាល់តែបាន " ។

អនុដីកានៃវិមតិវិនោទនីដែលសំដែងអំពីគណភោជនសិក្ខាបទថា "បទ ថា 'អាគន្តុកបដំ' ព្រះអដ្ឋកថាចារ្យ ពោលសំដៅយកចីពរដែលមិនកាត់ហើយលើកឡើង (ប៉ះ) នូវសំពត់អាគន្តុកៈធ្វើ "។

រឿង ព្រះអានន្ទត្ថេរ ចប់ ។

## ( រឿង ភិក្ខុមួយរូប )

(១៣៤) ក្នុងគ្រានោះ ភិក្ខុ ១ រូបមានស្បង់ធ្លុះហើយ ។ ភិក្ខុនោះ គិត ថា "ចីពរ ៣ គឺ សង្ឃាដី ២ ជាន់ ឧត្តរាសង្គៈ ១ ជាន់ អន្តរវាសកៈ ១ ជាន់ ព្រះដ៏មានព្រះភាគ ទ្រង់បានអនុញ្ញាតហើយ, ឯអន្តរវាសកៈ របស់អាត្មាអញនេះ ធ្លុះហើយ, បើដូច្នោះគួរតែអាត្មាអញប៉ះនូវបំណះ, (កាលបើដូច្នោះ) អន្តរវាសកៈនោះ នឹងទៅជា ២ ជាន់ ដោយជុំវិញ, កណ្តាល ១ ជាន់ " ដូច្នេះហើយ ទើបបានប៉ះនូវបំណះ ។

ព្រះសាស្តា ទ្រង់ជ្រាបនូវរឿងនោះហើយ[១] ទ្រង់ធ្វើដូចជាស្តេចយាងចារិកទៅ ក្នុងវិហារ ទ្រង់ស្តេចយាងចូលទៅរកភិក្ខុរូបនោះហើយ ទ្រង់ត្រាស់សួរ ថា "នែភិក្ខុ តើអ្នកធ្វើអ្វី ? " ។

ភិក្ខុនោះ ក្រាបទូល ថា "បពិត្រព្រះមានព្រះភាគ ទូលព្រះបង្គំ

១ ត្រៃបិដក ភាគទី ៨ / ទំព័រទី ១២៣ ។

ប៉ះនូវបំណះ” ។

ព្រះសាស្តា ទ្រង់ត្រាស់ ថា “ម្នាលភិក្ខុ ប្រពៃហើយ ៗ, ម្នាលភិក្ខុ ប្រពៃហើយ អ្នកបានប៉ះនូវបំណះ” ដូច្នេះហើយ ទើបទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក ថា “ម្នាលភិក្ខុទាំងឡាយ កាលបើសំពត់នៅថ្មោង ឬក៏សំពត់ដែលគេបោកលាងម្តងហើយ, តថាគតអនុញ្ញាត (ឲ្យអ្នកទាំងឡាយធ្វើ) សង្ឃាដី ២ ជាន់ ឧត្តរាសង្គៈ ១ ជាន់ អន្តរវាសកៈ ១ ជាន់, (បើ) សំពត់ដែលគេរើឡើងពីរដូវ (សំពត់ចាស់), តថាគត អនុញ្ញាតឲ្យអ្នកទាំងឡាយធ្វើនូវសង្ឃាដី ៤ ជាន់ ឧត្តរាសង្គៈ ២ ជាន់ អន្តរវាសកៈ ២ ជាន់, អ្នកទាំងឡាយ គប្បីធ្វើសេចក្តីប្រឹងប្រែង ក្នុងសំពត់បង្សុកូល ក្នុងសំពត់ដែលធ្លាក់ចុះ ក្នុងទីផ្សារ តាមសេចក្តីត្រូវការ, ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវបំណះ នូវការជុល នូវក្រវិលកណ្តុំ នូវកណ្តុំ នូវការធ្វើឲ្យមាំទាំ” ។

(១៣៥) បណ្តាបទទាំងនោះ បទ ថា “**អហតកប្បានំ**” បានដល់ សំពត់ដែលគេបោកម្តងហើយ ។ បទ ថា “**ឧតុទ្ធតានំ**” បានដល់ សំពត់ដែលគេរើឡើង អំពីរដូវ គឺ អំពីកាលដ៏យូរ ។ មានព្រះតម្រាស់ដែលព្រះអដ្ឋ ទ្រង់ត្រាស់ទុក ថា “បើសំពត់ចាស់ដែលមានពណ៌សាកអស់ហើយ” ។ បទ ថា “**បាបណិកេ**”

បានដល់ ក្នុងសំពត់ចាស់ដែលធ្លាក់ចុះ អំពីចន្លោះនៃទីផ្សារ ។ ការស្វែងរក ឈ្មោះថា សេចក្ដីឧស្សាហៈ ។ តែសំពត់បង្សុកូល និងសំពត់ដែលធ្លាក់ចុះ ក្នុងទីផ្សារនោះ មិនមានកំណត់ទេ, សូម្បី ១០០ ជាន់ ក៏គួរដែរ ។ ពាក្យទាំងអស់នេះ លោកពោលទុកហើយ សម្រាប់ភិក្ខុដែលត្រេកអរ ។ បទ ថា "**អគ្គឡំ**" បានដល់ កំណាត់សំពត់ (ថ្មី) ដែលគេរើ (សំពត់ចាស់) ចេញហើយប៉ះ ។ បទ ថា "**តុន្នំ**" គឺ សំពត់ដែលគេដេរ ដោយចេស ។ បទ ថា "**ឱវដ្ដិកំ**" គឺ ការចោះ ហើយធ្វើ (ជាប្រហោង) ។ បទ ថា "**កណ្ឌុសកំ**" គឺ កណ្ដុំ ។ បទ ថា "**ទឡ្ហីកម្មំ**" បានដល់ កំណាត់សំពត់ដែលមិនបានរើ ធ្វើសម្រាប់ទ្រ ហើយប៉ះចូលគ្នា ។

រឿងភិក្ខុមួយរូប ចប់ ។

(១៣៦) ភាពនៃបុគ្គលជាអ្នកឈ្លាសវៃ ក្នុងហត្ថកម្ម របស់បុគ្គលទាំងឡាយនេះ ដែលប្រកបហើយ ក្នុងឋានៈ រមែងនាំមកនូវសេចក្ដីសរសើរ ដែលរាប់ចូលក្នុងប្រយោជន៍សុខ ក្នុងលោកនេះ ដោយប្រការដូច្នេះឯង ព្រោះហេតុនោះ ទើបចាត់ថា ជាមង្គល ។ តែដែលប្រកបហើយ ក្នុងទីមិនមែនជាឋានៈ មិនចាត់ថា ជាមង្គលឡើយ ព្រោះជាហេតុនាំមកនូវសេចក្ដីនិន្ទា ។

ក្នុងដំណើរនោះ មានរឿងនេះ (ជាឧទាហរណ៍)៖

( រឿង ព្រះលោលុទាយី )

បានឮថា ព្រះលោលុទាយី ជាអ្នកល្អិត ជាអ្នកអាចធ្វើនូវចីវរកម្មបាន ។ ព្រះលោលុទាយីនោះ ដេរចីពរ ដើម្បីនាងភិក្ខុនីដែលជាភរិយាចាស់របស់ខ្លួន ជ្រលក់ហើយ ធ្វើរូបភាពដ៏វិចិត្រដែលសម្រេចដោយការឈ្លាសវៃ ត្រង់កណ្ដាល បត់ស្រេចហើយពោលថា "នែប្អូនស្រី បើដូច្នោះ ចូរនាងយកចីពរដែលបងបានបត់ហើយនេះ ទៅទុកដាក់, ក្នុងពេលណា នាងភិក្ខុនីសង្ឃ មកដើម្បីទទួលឱវាទ, ចូរគ្រងចីពរនេះហើយ និមន្តមក ខាងក្រោយ ៗ ក្នុងពេលនោះចុះ" ។ នាងភិក្ខុនីនោះ បានធ្វើយ៉ាងដូច្នោះហើយ ។ ពួកមនុស្ស ឃើញភិក្ខុនីនោះហើយ ក៏បានលើកទោស ។ នាងភិក្ខុនីនោះ បានប្រាប់ ដល់ពួកនាងភិក្ខុនី ។ ពួកនាងភិក្ខុនី បានប្រាប់ ដល់ពួកភិក្ខុ ។ ពួកភិក្ខុ បានក្រាបទូលសេចក្ដីនោះ ដល់ព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគ ទ្រង់បានតិះដៀល ភិក្ខុឧទាយី ដោយអនេកបរិយាយ ហើយទ្រង់បញ្ញត្តចីវរសិព្វនសិក្ខាបទក្នុងភិក្ខុនីវគ្គ ថា "ក៏ភិក្ខុណា ដេរខ្លួនឯងក្ដី ប្រើគេឲ្យដេរក្ដី នូវចីវរដើម្បីនាងភិក្ខុនីដែលមិនមែនជាញាតិ, ភិក្ខុនោះ ត្រូវបាចិត្តិយៈ"។

បទ ថា "បដិភានចិត្តំ" បានដល់ ចិត្រកម្មដែលធ្វើហើយដោយបដិភាណរបស់ខ្លួន, អធិប្បាយ ថា "រូបភាពរបស់ស្ត្រីនិងបុរស ដែលសេពនូវមេថុនធម្មពុំទាន់រួច ដែលខ្លួនធ្វើហើយ ដោយពណ៌ផ្សេងៗ" ។

រឿង ព្រះលោឡុទាយី ចប់ ។

## ( អាគារិយសិប្បៈ )

(១៣៧) ឈ្មោះថា សិប្បៈរបស់គ្រហស្ថ មាន ២ យ៉ាង ។ បណ្ដាសិប្បៈទាំង ២ យ៉ាងនោះ កិច្ចការណា ដែលវៀរចាកការបៀតបៀនជីវិតនៃសត្វដទៃ វៀរចាកអកុសលកម្ម មានកិច្ចការងាររបស់ជាងកែវមណីនិងជាងមាសជាដើម, កិច្ចការងារនោះឈ្មោះថា ជាមង្គល ព្រោះនាំប្រយោជន៍ ក្នុងលោកនេះ មកឲ្យ ។

ក្នុងដំណើរនោះ មានរឿងនេះ (ជាឧទាហរណ៍) ÷

## ( រឿង ជាងកែវមណី )

ក្នុងអតីតកាល ក្នុងស្រុកមួយ ក្នុងទីក្រុងពារាណសី ក្នុងដែនកាសី មានសេដ្ឋីម្នាក់ ជាអ្នកមានទ្រព្យសម្បត្តិច្រើន ។ ក៏ទ្រព្យដែលគាត់កប់ទុក មានដល់ទៅ ៤០ កោដិ ។ ចំណែកភរិយារបស់សេដ្ឋីនោះ ធ្វើកាលៈហើយ ក៏បានទៅកើតជាសត្វកណ្ដុរញី

លើខ្លួននៃទ្រព្យ ព្រោះសេចក្តីស្រឡាញ់ ក្នុងទ្រព្យ ។ ត្រកូលទាំងអស់នោះ ដល់ហើយនូវសេចក្តីវិនាស ដោយលំដាប់ ។ ឯផ្ទះនោះត្រូវគេបោះបង់ចោលហើយ ក៏ដល់នូវសេចក្តីសាបសូន្យផងដែរ ។

គ្រានោះ ជាងកែវមណីម្នាក់ ប្រាថ្នាចង់ដំថ្មហើយ យកនូវកែវមណី ទើបរើយកថ្ម ក្នុងទីនៃផ្ទះចាស់នោះមកដំ ។ សត្វកណ្ដុរញីនោះ កាលបោលរកស៊ី ក៏ឃើញជាងកែវមណីនោះញឹកញាប់ ទើបកើតសេចក្តីស្រឡាញ់ហើយ គិត ថា "ទ្រព្យជាច្រើន របស់អញនឹងវិនាសបាត់ទៅ ដោយមិនសមហេតុ, អញនឹងរួមជាមួយនឹងជាងកែវមណីនេះ ហើយប្រើប្រាស់ទ្រព្យនោះ" ដូច្នេះហើយ បានពាំទ្រព្យ ១ កហាបណៈ បោលទៅកាន់សំណាក់ជាងកែវមណីនោះ ។ ជាងកែវមណីនោះ ឃើញសត្វកណ្ដុរញីនោះហើយ កាលនិយាយរាក់ទាក់នឹងសត្វកណ្ដុរញីនោះ ដោយវាចាដ៏ពិរោះ ទើបពោល ថា "នែនាង តើនាងពាំកហាបណៈ មកធ្វើអ្វី ?" ។ សត្វកណ្ដុរញីប្រាប់ ថា "ម្នាលអ្នក ចូរអ្នកនាំយកកហាបណៈនេះ ទៅប្រើប្រាស់ដោយខ្លួនឯងចុះ, ចូរអ្នកនាំយកសាច់មកឲ្យនាងខ្ញុំផងណា" ។ ជាងកែវមណីនោះ បាននាំយកកហាបណៈ ទៅកាន់ផ្ទះហើយ ទិញយកសាច់នាំទៅឲ្យ ដល់សត្វកណ្ដុរញីនោះ ។ សត្វកណ្ដុរញីនោះ បានពាំយកសាច់ទៅកាន់ទីលំនៅ របស់ខ្លួនហើយស៊ី ។ កណ្ដុរញី

នោះ បានពាំទ្រព្យមកឲ្យដល់ជាងកែវមណីនោះឯង ហើយទទួលយកសាច់ ដោយន័យនេះ ជារៀងរាល់ថ្ងៃ ។ សត្វកណ្ដុរញីនោះ បានពាំទ្រព្យទាំងអស់នោះ យកទៅឲ្យដល់ជាងកែវមណីនោះឯង ដោយលំដាប់ ដោយប្រការដូច្នេះឯង ។

រឿង ជាងកែវមណី មកក្នុងអដ្ឋកថាពច្ចជាតក ក្នុងវគ្គទី ១៤ នៃឯកនិបាត ។

(១៣៨) ក៏ព្រោះលោកពោលហើយ ដោយមិនខុសប្លែកអំពីគ្នា ថា "ភាពជាអ្នកឈ្លាសវៃ ក្នុងហត្ថកម្មឯណាមួយ ឈ្មោះថាសិប្បៈ" ដូច្នេះហើយ សិប្បៈរបស់ជាងត្បាញផែងជាដើមក្ដី សិប្បៈរបស់អ្នកផ្ចាត់គ្រាប់ក្រួសក្ដី ដែលមកហើយ ក្នុងវិភង្គនៃឱមសវាទ-សិក្ខាបទ ទើបរាប់បញ្ចូលបានដូចគ្នាដែរ ។ ជាងត្បាញផែងឈ្មោះថា នឡការ ក្នុងពាក្យ ថា "**នឡការាទិសិប្បញ្ចេវ**" នោះ ។ សូម្បីសិប្បៈរបស់ជាងត្បាញផែងនោះ ក៏ឈ្មោះថាជាមង្គលដែរ ព្រោះជាហេតុនាំមកនូវប្រយោជន៍ ។

ក្នុងដំណើរនោះ មានរឿងទាំងនេះ ( ជាឧទាហរណ៍ ) ÷

## ( រឿង ព្រះថេរៈថ្វាយកន្ទេល )

ក្នុងអតីតកាល ជាងត្បាញផែងម្នាក់ ក្នុងក្រុងតីវរនគរ បាន

ថ្វាយនូវកន្ទេល ដើម្បីបូជាចំពោះព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ព្រោះកម្មនោះ ទើបអន្ទោលទៅតែក្នុងសុគតិភព រហូត ៩៤ កប្ប ប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះ កើតជាកុលបុត្រ បានបួសក្នុងព្រះសាសនាហើយ ក៏បានសម្រេចព្រះអរហត្ត ។ ព្រះថេរៈនោះ កាលនឹងប្រកាស នូវការប្រព្រឹត្តិមិនដាច់រយៈក្នុងកាលមុន របស់ខ្លួន ទើបបានពោលគាថាទាំងនេះ ក្នុងចតុព្វីសមវគ្គ នៃអបទាន (១) ថា ៖

"ក្នុងកាលនោះ ខ្ញុំបានកើតជាអ្នកត្បាញផែង ក្នុងតីវរបុរី ដែលជាទីរមណីយដ្ឋាន, ឯប្រជុំជន បានជ្រះថ្លាហើយ ចំពោះព្រះសិទ្ធត្ថសម្ពុទ្ធ ព្រះអង្គទ្រង់បំភ្លឺលោក ក្នុងកាលនោះ ។ ប្រជុំជននាំគ្នាស្វែងរកកន្ទេល ដើម្បីបូជា ចំពោះព្រះលោកនាថ, ខ្ញុំបានឲ្យកន្ទេលដល់ពួកជនអ្នកធ្វើពុទ្ធបូជាហើយ ។ រហូត ៩៤ កប្ប អំពីកប្បនេះទៅ ព្រោះកម្មដែលខ្ញុំបានធ្វើហើយ ក្នុងកាលនោះ ទើបខ្ញុំមិនដែលបានស្គាល់ទុគ្គតិឡើយ, នេះជាផលនៃកន្ទេល ។ ក្នុងកប្បទី ៧៧ ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ព្រះនាមថាជលន្ធរៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ

១ ត្រៃបិដក ភាគទី ៧៣ / ទំព័រទី ១៧២ ។

ជាអ្នកមានកម្លាំងច្រើន ។ ធម៌ទាំងឡាយនេះ គឺបដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ គឺខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ " ។

រឿង ព្រះថេរៈ ថ្វាយកន្ទេល ចប់ ។

## ( រឿង ព្រះបាទមហាបនាទៈ )

(១៣៩) ក្នុងអតីតកាល ក្នុងទីក្រុងពារាណសី ជាងត្បាញផែង កាលទៅស្រែ បានឃើញនូវព្រះបច្ចេកពុទ្ធមួយអង្គ ទើបបានបញ្ជូននូវទាសាទាសី ដោយបញ្ជាថា "ចូរអ្នកទាំងឡាយព្រោះចុះ" ដូច្នេះហើយ ខ្លួនឯងក៏បានត្រឡប់ទៅវិញហើយ នាំព្រះបច្ចេកពុទ្ធអង្គនោះទៅផ្ទះ ញ៉ាំងព្រះអង្គឲ្យឆាន់ហើយ នាំទៅកាន់មាត់ទន្លេគង្គាម្តងទៀត ព្រមទាំងកូន បានធ្វើនូវបណ្ណសាលា ដែលមានជើងជញ្ជាំងធ្វើដោយដើមឧទុម្ពរ មានជញ្ជាំងធ្វើដោយដើមបបុស និងធ្វើនូវទីចង្ក្រមហើយ និមន្តព្រះបច្ចេកពុទ្ធអង្គនោះ ឲ្យគង់ចាំវស្សាក្នុងទីនោះ រហូត ៣ ខែ ។ បិតានិងបុត្រទាំង ២ នាក់ ញ៉ាំងព្រះបច្ចេកពុទ្ធដែលទ្រង់ចាំព្រះវស្សាហើយ ឲ្យគ្រងចីវរហើយ ទើបបានជូនទៅ, បិតានិងបុត្រទាំង ២ នាក់នោះ ញ៉ាំងព្រះបច្ចេកពុទ្ធ

ទាំងឡាយ ៧ អង្គ ឲ្យនៅចាំវស្សាហើយ ក្នុងទីនោះ បានប្រគេនហើយនូវត្រ័យចីពរ ដោយទំនងនេះ ។ អាចារ្យពួកខ្លះ ពោល ថា "បិតានិងបុត្រទាំង ២ នាក់ កើតជាជាងត្បាញផែង កំពុងតែស្រង់ឫស្សី ក្បែរមាត់ច្រាំងទន្លេគង្គា ក៏បានឃើញព្រះបច្ចេកពុទ្ធហើយ បានធ្វើ យ៉ាងនេះ" ដូច្នេះក៏មាន ។ ជនទាំង ២ នោះ ធ្វើកាលៈហើយ បានទៅកើត ក្នុងភពតាវត្តិង្ស ត្រាច់សោយសម្បត្តិទិព្វ ក្នុងឆកាមាវចរសួគ៌ ដោយអនុលោមបដិលោម ។ បណ្ដាជនទាំង ២ នាក់នោះ បិតាបានស្ថិតនៅហើយ ក្នុងទេវលោកនុ៎ះឯង ។ ឯបុត្រច្យុតចាកទេវលោកនោះហើយ បានមកកើត ក្នុងព្រះគភ៌នៃព្រះរាជទេវីព្រះនាមសុមេធា នៃព្រះរាជាព្រះនាមសុរុចិ ក្នុងទីក្រុងមិថិលា ក្នុងដែនវិទេហៈ ដោយកាលកន្លងទៅបាន ១០ ខែ ទើបបានប្រសូតចេញមកហើយ ។ ព្រះបិតានិងព្រះមាតា បានប្រទានព្រះនាម ដល់ព្រះរាជបុត្រនោះ ថា "ព្រះមហាបនាទៈ" ។ ព្រះរាជកុមារនោះ ក្នុងពេលដែលមានព្រះជន្មាយុបាន ១៦ ព្រះវស្សា ទ្រង់បានដល់ហើយនូវសេចក្ដីសម្រេច ក្នុងសិល្បសាស្ត្រគ្រប់យ៉ាង ។ ព្រះរាជា ទ្រង់បានត្រាស់បញ្ជា ឲ្យពួកអាចារ្យដែលចេះដឹងវិជាត្រួតពិនិត្យផែនដី ថា "នៃអ្នកទាំងឡាយ ចូរអ្នកទាំងឡាយ រកជាងមកឲ្យកសាងប្រាសាទ ដើម្បីព្រះរាជបុត្រ (របស់យើង) យើងនឹង

អភិសេកព្រះរាជបុត្រនោះ ក្នុងរាជសម្បត្តិ ” ។ ពួកអាចារ្យទាំងនោះ ទទួលព្រះរាជឱង្ការ ថា “ប្រពៃហើយ” ទើបទៅត្រួតពិនិត្យមើលភូមិប្រទេស ។

គ្រានោះ អាសនៈរបស់ស្ដេចសក្កទេវរាជ សំដែងហើយនូវអាការក្ដៅ ដោយអានុភាពនៃបុណ្យ របស់ព្រះរាជកុមារនោះ ។ ស្ដេចសក្កទេវរាជនោះ ទ្រង់ជ្រាបរឿងនោះហើយ ទើបទ្រង់ត្រាស់បញ្ជូនវិស្សុកម្មទេវបុត្រទៅ ដោយព្រះតម្រាស់ ថា “ចូរអ្នកទៅកសាងប្រាសាទចុះ” ។ ព្រះវិស្សុកម្មទេវបុត្រនោះ បានប្រែក្រឡាជាជាង ទៅកាន់សំណាក់ នៃពួកជាងហើយ ប្រាប់ ថា “ពួកអ្នកបរិភោគអាហារពេលព្រឹកហើយ ចូរមកចុះ” ហើយ បានបញ្ជូនពួកជាងទាំងនោះទៅហើយ យកឈើពគ្រាបផែនដី ។

ក្នុងខណៈនោះឯង ប្រាសាទ ៧ ជាន់ សម្រេចដោយកែវ ៧ ប្រការ មានទទឹងនិងបណ្ដោយកន្លះយោជន៍ មានកំពស់ ២៥ យោជន៍ បានផុះឡើងហើយ ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សំដៅយកហើយ ក្នុងមហាបនាទជាតក នៃតិកនិបាត (១) ថា ៖

(១៤០) “ព្រះរាជាអង្គនោះ ទ្រង់ព្រះនាមបនាទៈ

មានប្រាសាទមាស មានទទឹងប្រវែងកិរិយាធ្លាក់

១ ត្រៃបិដក ភាគទី ៥៨ / ទំព័រទី ១៥០ ។

ចុះនៃកូនសរ ១៦ (កន្លះយោជន៍) អ្នកប្រាជ្ញទាំងឡាយ ពោលថា ប្រាសាទនោះកំពស់ ១ ពាន់តំណនៃកូនសរ ( ២៥ យោជន៍ ) ។ ប្រាសាទនោះកំពស់ ១ ពាន់តំណនៃកូនសរ មានជាន់ប្រាំពីរបរិបូណ៌ដោយទង់ ព័ទ្ធព័ទ្ធហើយដោយកែវមណីមានពណ៌ខៀវ, ពួកអ្នករបាំ ៦ ពាន់ ចែកជា ៧ ក្រុម បានរាំហើយ លើប្រាសាទនោះ " ។

បណ្ដាបទទាំងនោះ បទ ថា "យូបោ" ប្រែថា ប្រាសាទ ។ បាទគាថា ថា "តិរិយំ សោឡសុព្វេធោ" គឺ ដោយទទឹង មានប្រវែងកិរិយាធ្លាក់ចុះ នៃកូនសរ ១៦ ។ បាទគាថា ថា "ឧច្ចមាហុ សហស្សធា" គឺ អ្នកប្រាជ្ញទាំងឡាយ ពោលនូវកំពស់ ដោយការរាប់ នៃកិរិយាសាត់ទៅ នៃកូនសរ ១ ពាន់ ។ ក៏លោក សំដែងប្រមាណ ២៥ យោជន៍ ដោយការរាប់នូវកិរិយាសាត់ទៅ នៃកូនសរ ១ ពាន់, ព្រោះហេតុនោះ ទើបលោកសំដែងប្រមាណកន្លះយោជន៍ ដោយការរាប់ នូវកិរិយាសាត់ទៅនៃកូនសរ ១៦ ។ បទ ថា "សហស្សកណ្ឌោ" គឺ មានកំពស់ ១ ពាន់តំណនៃកូនសរ ។ បទ ថា "សត្តគេណ្ឌុ" គឺ ជាប្រាសាទ

៧ ជាន់ ។ បទ ថា “ធជាលុ” គឺ បរិបូណ៌ដោយទង់ ។ បទ ថា “ហរិតាមយោ” គឺ ប៉ិទជុំវិញហើយដោយកែវមណីពណ៌ខៀវ ។ បាលីក្នុងអដ្ឋកថា ថា “សសាលុ” ដូច្នេះក៏មាន ។ អធិប្បាយ ថា “ដែលប្រកបព្រមហើយ ដោយមេទ្វារនិងបង្អួច ដែលធ្វើដោយកែវមណីពណ៌ខៀវ ។ បានពួថា ពាក្យ ថា “សស” ជាឈ្មោះនៃមេទ្វារនិងបង្អួច ។ បទ ថា “អនច្ចុំ” គឺ រាំហើយ ដើម្បីញ៉ាំងសេចក្តីត្រេកអរឲ្យកើតឡើងដល់ព្រះរាជា ។ បទ ថា “តត្ថ” បានដល់ ក្នុងប្រាសាទនោះ គឺ ក្នុងជាន់ទី ៧ នៃប្រាសាទនោះ ។ ពួកអ្នករបាំ ឈ្មោះថា គន្ធព្វា ។ បាទគាថា ថា “ឆ សហស្សានិ សត្តធា” បានដល់ អ្នករបាំ ៦ ពាន់ បែងចែកជា ៧ ក្រុម ។

(១៤១) ព្រះបាទមហាបនាទៈ ទ្រង់បានបំពេញបុណ្យ មានទានជាដើម សោយទិវង្គតហើយ ក៏បានទៅកាន់ទេវលោកតាមដើម ។ ប្រាសាទនោះ បានធ្លាក់ទៅតាមខ្សែទឹកនៃទន្លេគង្គាហើយ ។ ក្នុងទីត្រង់មុខជណ្តើរក្បែរប្រាសាទនោះ គេបានកសាងនគរ ឈ្មោះថា បយាគប្បតិដ្ឋាន, ក្នុងទីត្រង់កំពូលប្រាសាទនោះ មានស្រុកឈ្មោះកោដិគ្រាម ។ ក្នុងពុទ្ធុប្បាទនេះ នឡការទេវបុត្រនោះ ច្យុតចាកទេវលោកហើយ បានកើតជាបុត្រ របស់ភទ្ទិយសេដ្ឋី អ្នកមានសម្បត្តិ ៨០ កោដិ ក្នុងភទ្ទិយនគរ ឈ្មោះ ភទ្ទជិកុមារ ។

ក្នុងកាលនោះ ព្រះដ៏មានព្រះភាគ ទ្រង់អាស្រ័យភទ្ទិយនគរ គង់នៅក្នុងជាតិយាវ័ន ។ ពួកអ្នកនគរ បានកសាងមណ្ឌបសម្រាប់ធ្វើទាន ត្រង់កណ្ដាលព្រះនគរហើយ ថ្វាយមហាទាន ។ ព្រះសាស្ដាទ្រង់ធ្វើភត្តកិច្ច ក្នុងទីនោះរួចហើយ ទ្រង់បានធ្វើអនុមោទនា ។ ចំណែកភទ្ទជិកុមារ ចូលទៅគាល់ព្រះសាស្ដាហើយ ស្ដាប់ធម៌ក៏បានសម្រេចព្រះអរហត្ត បានទៅកាន់ព្រះវិហារព្រមជាមួយនឹងព្រះសាស្ដា បានបួសឧបសម្បទហើយ ។ ព្រះសាស្ដា ទ្រង់គង់នៅ ក្នុងទីនោះអស់ ៧ ថ្ងៃហើយ កាលស្ដេចចារិកទៅដល់កោដិគ្រាម ទ្រង់បានធ្វើភត្តកិច្ចហើយ ទ្រង់បានធ្វើនូវអនុមោទនា ។ ព្រះភទ្ទជិត្ថេរ ក្នុងពេលព្រះអង្គធ្វើអនុមោទនា បាននិមន្តទៅខាងក្រៅផ្ទះ អធិដ្ឋានក្នុងចិត្ត ថា "ក្នុងពេលដែលព្រះសាស្ដាស្ដេចយាងមកភ្លាម អាត្មាអញនឹងក្រោកទទួល" ដូច្នេះហើយ គង់ចូលឈាន ក្រោមគល់ឈើ ក្បែរកំពង់ទន្លេគង្គា, សូម្បីកាលបើពួកព្រះថេរៈដែលចាស់ជាង និមន្តមក, ក៏មិនក្រោកទទួល ក្នុងពេលដែលព្រះសាស្ដាស្ដេចយាងមកដល់ភ្លាម ទើបបានក្រោកទទួល ។ ពួកភិក្ខុជាបុថុជ្ជន បានលើកទោសព្រះភទ្ទជិត្ថេរនោះហើយ ។ ព្រះសាស្ដា ទ្រង់គង់នៅលើទូកហើយ ទ្រង់បានត្រាស់ ថា "ម្នាលភទ្ទជិ អ្នកចូរមក ចូរឡើងជិះទូកមួយ ជាមួយនឹងតថាគត" ។ ព្រះថេរៈ ផ្ទានហោះឡើង

ទៅគង់លើទូកជាមួយព្រះអង្គ ។ ក្នុងពេលទៅដល់ពាក់កណ្ដាលទន្លេគង្គា ព្រះសាស្ដាទ្រង់ត្រាស់ ថា "ម្នាលភទ្ទជិ ក្នុងពេលដែលអ្នកជាព្រះរាជាព្រះនាមមហាបនាទៈ ប្រាសាទដែលអ្នកនៅគ្រប់គ្រង តើនៅក្នុងទីឯណា ?" ។ ព្រះថេរៈនោះ ក្រាបទូល ថា "បពិត្រព្រះអង្គដ៏ចំរើន ប្រាសាទនោះលិចហើយក្នុងទីនេះ" ហើយ ថ្វាយបង្គំព្រះសាស្ដា ទៅដោយកម្លាំងនៃឫទ្ធិ បានយកម្រាមដៃកៀវកំពូលប្រាសាទ ហោះឡើងទៅលើអាកាសហើយ សំដែងដើម្បីកាត់សេចក្ដីសង្ស័យរបស់ពួកបុថុជ្ជន ហើយទើបបានទំលាក់ចោល ។ ប្រាសាទស្ថិតនៅហើយ ក្នុងទីដើមនុ៎ះឯង មិនអន្តរធានហើយ រហូតដល់សព្វថ្ងៃនេះ ។ សួរ ថា "ព្រោះហេតុអ្វី ទើបមិនអន្តរធាន ?" ។ ឆ្លើយ ថា "ព្រោះអានុភាពនៃនឡការទេវបុត្រ ដែលកើតជាបិតាក្នុងកាលមុន ។ ក៏ទេវបុត្រនោះ នឹងបានជាស្ដេចចក្រពត្តិព្រះនាមសង្ខៈ ក្នុងអនាគតកាល, ប្រាសាទនោះ នឹងផុសឡើងដើម្បីជារបស់ប្រើប្រាស់របស់ព្រះអង្គ, ព្រោះហេតុនោះ ប្រាសាទនោះ ទើបមិនបានអន្តរធានទៅ" ។

បន្ទាប់អំពីនេះទៅ គប្បីញ៉ាំងពាក្យដែលលោកពោលហើយក្នុងចក្កវត្តិសូត្រ ព្រមទាំងអដ្ឋកថា ឲ្យពិស្ដារ ។

ចំណែកសេចក្ដីសង្ខេប ក្នុងរឿងនេះ មានដូចតទៅនេះ ÷

ព្រះរាជាអង្គនោះ នឹងទ្រង់គ្រប់គ្រងប្រាសាទនោះ ទ្រង់ជ្រាបថា ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមមេត្តេយ្យ ស្តេចកើតឡើងហើយ ទ្រង់មានព្រះបំណងចង់ព្រះរាជទានប្រាសាទនោះហើយ ទើបទ្រង់ព្រះផ្ទុស ទ្រង់ញ៉ាំងព្រះទ័យ ឲ្យកើតឡើង ថា "ប្រាសាទនេះ ចូរខ្ទាត់ខ្ទាយទៅចុះ" ។ ប្រាសាទនោះ នឹងខ្ទាត់ខ្ទាយទៅជាកំណាត់តូច-ធំ ។ ព្រះរាជា ទ្រង់មិនមានព្រះទ័យជាប់ជំពាក់នឹងប្រាសាទនោះឡើយ នឹងទ្រង់ប្រកាស ថា "បុគ្គលណា ប្រាថ្នាប៉ុន្មាន, បុគ្គលនោះ ចូរប្រមូលយកប៉ុណ្ណោះចុះ" ហើយ ទ្រង់ព្រះរាជទានដល់សមណៈ ព្រាហ្មណ៍ មនុស្សកំព្រា មនុស្សដើរផ្លូវ វណិព្វកៈ និងយាចកទាំងឡាយ ទ្រង់ផ្នួសក្នុងសំណាក់នៃព្រះមានព្រះភាគព្រះនាមមេត្តេយ្យហើយ ទ្រង់បានសម្រេចព្រះអរហត្ត ដូច្នេះឯង ។

រឿង ជាងត្បាញផែង មកក្នុងអដ្ឋកថាសុរុចិជាតក ក្នុងចកិណ្ណកនិបាត ក្នុងអដ្ឋកថាមហាបនាទជាតក និង ក្នុងអដ្ឋកថាចក្កវត្តិសូត្រ ។

(១៤២) ចំណែកសិប្បៈនៃការផ្ទាត់គ្រាប់គ្រួស ដែលបុគ្គលប្រកបហើយ ក្នុងឋានៈ ក៏ចាត់ថាជាមង្គល, ដែលបុគ្គលប្រកបហើយក្នុងទីមិនមែនជាឋានៈ មិនចាត់ថា ជាមង្គលឡើយ ។

រឿងដែលសំដែងនូវសេចក្តីនោះ (មានដូចតទៅនេះ) ÷

( រឿង បុរសខ្វិន ផ្ទាត់គ្រាប់ក្រួស )

ក្នុងអតីតកាល ក្នុងទីក្រុងពារាណសី មានបុរសខ្វិនម្នាក់ ជាអ្នកឆ្លាតក្នុងសិល្បៈផ្ទាត់គ្រាប់ក្រួស ។ ពួកក្មេងអ្នកស្រុក លើកបុរសខ្វិននោះឡើងលើរថហើយ បាននាំទៅកាន់ដើមជ្រៃធំ ដែលស្ថិតនៅក្បែរមាត់ទ្វារព្រះនគរហើយ ឲ្យទ្រព្យមានមួយកាកណិកជាដើម ពោលហើយ ថា "ចូរអ្នកធ្វើរូបដំរី, ចូរអ្នកធ្វើរូបសេះ" ។ បុរសខ្វិននោះ ផ្ទាត់គ្រាប់ក្រួស សំដែងរូបផ្សេង ៗ លើស្លឹកជ្រៃទាំងឡាយ ។ ព្រះរាជា កាលទ្រង់ស្តេចយាងទៅព្រះឧទ្យាន ទ្រង់ស្តេចយាងទៅដល់ទីនោះហើយ ។ ពួកក្មេង ៗ បានរត់ចេញទៅគ្រប់គ្នាហើយ ព្រោះខ្លាចចំពោះការត្រួតត្រា ។ បុរសខ្វិនបានដេកនៅក្នុងចន្លោះក្រោមដើមជ្រៃ ។ ព្រះរាជា ទ្រង់ទតឃើញស្លឹកឈើទាំងឡាយមានប្រហោង ទើបទ្រង់ត្រាស់សួរ ថា "ស្លឹកឈើទាំងឡាយនេះ តើអ្នកណាធ្វើហើយ យ៉ាងនេះ ? " ។ ពួករាជបុរស បានក្រាបទូល ថា "បពិត្រព្រះសម្មតិទេព បុរសខ្វិនបានធ្វើហើយ " ។ ព្រះរាជា ទ្រង់ត្រាស់បញ្ជាឲ្យហៅបុរសខ្វិននោះមកហើយ ទ្រង់ត្រាស់សួរ ថា "នៃអ្នក បុរោហិតរបស់យើង ជាអ្នកមាត់រឹង ជាអ្នកនិយាយច្រើន, បើបុរោហិតនោះ ផ្តើមនិយាយឡើង, អ្នកដទៃ មិនបាននូវឱកាសឡើយ, តើអ្នកអាចដើម្បី

នឹងធ្វើឲ្យបុរោហិតនោះស្ងាត់សំឡេងបានឬទេ ? ” ។ បុរសខ្វិន នោះ ក្រាលទូល ថា “បពិត្រព្រះសម្មតិទេព កាលបើទូលព្រះបង្គំបាន នូវអាចម៍ពពែប្រមាណ ១ នាឡិ នឹងអាចធ្វើបាន ” ។ ព្រះរាជា ទ្រង់នាំបុរសខ្វិនទៅកាន់ព្រះតំណាក់ហើយ ទ្រង់បានឲ្យគាត់អង្គុយ ខាងក្នុងវាំងនន ទ្រង់ត្រាស់ឲ្យធ្វើប្រហោងវាំងននហើយ ទ្រង់ត្រាស់ ឲ្យដាក់អាចម៍ពពែស្ងួត ប្រមាណ ១ នាឡិ នៅក្បែរបុរសខ្វិននោះ ទ្រង់ត្រាស់ឲ្យក្រាលអាសនៈ ដល់បុរោហិត មានមុខត្រង់ប្រហោង ទ្រង់ឲ្យបុរោហិតនោះដែលមកហើយ ក្នុងពេលឧបដ្ឋាក អង្គុយហើយ លើអាសនៈនោះ ទ្រង់បានត្រាស់សន្ទនាហើយ ។ បុរោហិត មិនឲ្យឱកាស ដល់អ្នកណាមួយឡើយ ផ្ដើមសន្ទនាជាមួយនឹងព្រះ រាជាហើយ ។

គ្រានោះ បុរសខ្វិន ក៏បានផ្ទាត់អាចម៍ពពែ ម្ដងមួយគ្រាប់ ៗ ចូលទៅក្នុងមាត់ របស់បុរោហិតនោះ ។ បុរោហិត ទើបលេប អាចម៍ពពែដែលមកហើយ ៗ ដូចជានំបង់ល្ង ។ ឯអាចម៍ពពែទាំង អស់ក៏បានអស់ហើយ ។ ព្រះរាជា ទ្រង់ជ្រាបថា អាចម៍ពពែទាំង នោះ អស់ហើយ ទើបទ្រង់ត្រាស់ ថា “នែអាចារ្យ ព្រោះខ្លួនលោក ជាអ្នកមានមាត់រឹង សូម្បីលោកលេបអាចម៍ពពែ មានប្រមាណមួយ នាឡិ ក៏មិនដឹងអ្វីបន្តិចឡើយ, ក៏ឥឡូវនេះ លោកអាចារ្យ នឹង

មិនអាចញ៉ាំងអាចម៍ពពៃដែលច្រើនជាងនេះ ឲ្យរលាយបានឡើយ, ចូរលោកអាចារ្យ អញ្ជើញទៅចុះ ចូរពិសាទឹកប្រយង្គសម្រកចេញហើយ ធ្វើខ្លួនកុំឲ្យមានរោគចុះ " ។ តាំងអំពីពេលនោះមក បុរោហិតនោះ ដូចជាមានមាត់បិទជិតហើយ ជាអ្នកមិនសូវសន្ទនាជាប្រក្រតី ជាមួយព្រះរាជាសូម្បីទ្រង់ត្រាស់រកក៏ដោយ ។ ព្រះរាជាទ្រង់ព្រះតម្រិះ ថា "បុរសខ្វិននេះ ធ្វើឲ្យអាត្មាអញសប្បាយត្រចៀកហើយ" ដូច្នេះ ទ្រង់បានព្រះរាជាទានហើយ នូវស្រុកសួយ ៤ កន្លែង ក្នុងទិសទាំង ៤ ដែលមានសួយសារអាករឡើង ១ សែន ដល់បុរសខ្វិន ។

ក្នុងគ្រានោះ អមាត្យជាបណ្ឌិតម្នាក់ បានចូលទៅគាល់ព្រះរាជាហើយ ក្រាបទូល ថា "បពិត្រព្រះសម្មតិទេព ធម្មតាសិល្បៈក្នុងលោក ពួកបណ្ឌិតត្រូវសិក្សា, សូម្បីដោយសិល្បៈត្រឹមតែការផ្ទាត់គ្រាប់គ្រួស ក៏បុរសខ្វិនបានសម្បត្តិយ៉ាងនេះទៅហើយ, នឹងកំណត់នូវអានិសង្ស នៃសិល្បៈទាំងឡាយ យ៉ាងដូចម្តេចបាន" ដូច្នេះហើយ កាលសំដែងគុណ នៃសិល្បសាស្ត្រ ទើបបានពោលគាថានេះ ថា ÷

"ធម្មតាសិល្បសាស្ត្រ យ៉ាងណាក៏ដោយ សុទ្ធតែ(១)
សម្រេចប្រយោជន៍ពិត, សូមព្រះអង្គទ្រង់ទតព្រះ

១ ត្រៃបិដក ភាគទី ៥៨ / ទំព័រទី ៤៨ ។

នេត្រមើលចុះ ស្រុកសួយទាំង ៤ ទិស ដែលបុរស
ខ្វិនបានហើយ ដោយការផ្ទាត់អាចម៌ពពែ " ។

បណ្ដាបទទាំងនោះ បទ ថា "**បស្ស**" មានសេចក្ដីថា បពិត្រព្រះមហារាជ សូមព្រះអង្គទ្រង់ទតមើលចុះ ។ បទ ថា "**អជប្បហារេន**" មានសេចក្ដីថា អាមាត្យនោះ ពោលនូវគុណនៃសិល្បសាស្ត្រ ថា "ស្រុកសួយ ៤ ទាំង ៤ ទិស គឺបុរសខ្វិនបានហើយ ដោយការផ្ទាត់អាចម៌ពពែ, នឹងកំណត់រាប់នូវអានិសង្សនៃសិល្បសាស្ត្រទាំងឡាយ សូម្បីដទៃទៀត យ៉ាងដូចម្ដេចបាន" ។

រឿង បុរសខ្វិន ចប់ ។

## ( រឿង ភិក្ខុអ្នកសម្លាប់ហង្ស )

(១៤៣) បុរសខ្វិននោះឯង ឥឡូវនេះ កើតជាកុលបុត្រដែលឆ្លាតក្នុងសិល្បៈផ្ទាត់ក្រួសន៊ុះឯង ក្នុងក្រុងសាវត្ថី ថ្ងៃមួយបានស្ដាប់ធម៌ហើយ ក៏បួស បានឧបសម្បទ័ហើយ ។ ថ្ងៃមួយភិក្ខុនោះ បាននាំភិក្ខុកម្លោះ ១ រូប ទៅកាន់ស្ទឹងអចិរវតី ស្រង់ទឹកហើយ ក៏បានឈរនៅ ក្បែរមាត់ស្ទឹង ។

ក្នុងខណៈនោះឯង សត្វហង្ស ២ ហើរទៅក្នុងអាកាស ។

ភិក្ខុនោះ ពោលនឹងភិក្ខុកម្លោះនោះ ថា "ខ្ញុំនឹងយកក្រួសប្រហារហង្សដែលនៅក្រោយនេះ ត្រង់ភ្នែកហើយ ធ្វើឲ្យធ្លាក់ក្បែរជើង" ។ ភិក្ខុកម្លោះក្រៅនេះ ពោល ថា "លោកនឹងមិនអាច" ។ ភិក្ខុនោះពោល ថា "បើដូច្នេះ ចូរអ្នកចាំមើលចុះ" ហើយ បានផ្ទាត់ក្រួស ១ គ្រាប់ រាង ៣ ជ្រុង ទៅខាងក្រោយហង្សនោះ ។ គ្រាប់ក្រួសបានធ្វើសំឡេង "រុង ៗ" ។ ហង្សបានងាកមកក្រឡេកមើលហើយ ។ ក្នុងខណៈនោះឯង ភិក្ខុនោះ ក៏ផ្ទាត់គ្រាប់ក្រួសមូល ១ គ្រាប់ទៅ ត្រង់ភ្នែកម្ខាងទៀត របស់ហង្សដែលកំពុងតែងាកមកក្រឡេកមើលនោះ ។ គ្រាប់ក្រួស បានទម្លុះភ្នែកម្ខាងទៀតធ្លាយទៅហើយ ។ ហង្សស្រែកយ៉ាងខ្លាំង ធ្លាក់ហើយ ក្បែរជើងនុ៎ះឯង ។ ពួកភិក្ខុ ដឹងសេចក្ដីនោះហើយ ក៏បានក្រាបទូល ដល់ព្រះសាស្ដា ។ ព្រះសាស្ដា ទ្រង់តិះដៀលភិក្ខុនោះ ដោយអនេកបរិយាយ ។

រឿង ភិក្ខុសម្លាប់សត្វហង្ស មកក្នុងអដ្ឋកថាសាលិត្តកជាតក ។

## ( រឿង សដ្ឋិកូដប្រេត )

(១៤៤) បុរសម្នាក់ រៀនសិល្បសាស្ត្រនោះ ក្នុងសំណាក់របស់បុរសខ្វិននោះដូចគ្នាដែរ ។ គ្រានោះ បុរសខ្វិន ប្រាប់

បុរសនោះ ថា "នែអ្នក អ្នកកាលសាកល្បងសិល្បៈ ចូរត្រួតមើលបុគ្គលណាមួយ ដែលមិនមានម្ដាយនិងឪពុក កាលបើអ្នកប្រហារហើយ នឹងមិនមានពិន័យ ព្រោះបើអ្នកសម្លាប់គោ នឹងត្រូវដាក់ពិន័យ 100, បើសម្លាប់មនុស្ស ក៏នឹងត្រូវដាក់ពិន័យ ១ ពាន់នោះចុះ" ។ បុរសនោះ វេចគ្រាប់ក្រួសដាក់ក្នុងថ្នក់ កាលត្រួតមើលបុគ្គលបែបនោះ ថ្ងៃមួយ បានឃើញព្រះបច្ចេកពុទ្ធព្រះនាមសុនេត្ត កំពុងយាងទៅកាន់ព្រះនគរ ដើម្បីទ្រង់បិណ្ឌបាត ទើបគិត ថា "ព្រះបច្ចេកពុទ្ធអង្គនេះ ជាអ្នកមិនមានមាតាបិតា" ដូច្នេះហើយ ទើបបានផ្ទាត់គ្រាប់ក្រួសសំដៅរន្ធត្រចៀកខាងស្ដាំ របស់ព្រះបច្ចេកពុទ្ធអង្គនោះ ។ គ្រាប់ក្រួសចូលទៅហើយ ធ្លាយចេញទៅតាមរន្ធត្រចៀកខាងឆ្វេង ។ ព្រះបច្ចេកពុទ្ធអង្គនោះ កើតទុក្ខវេទនាហើយ កាលមិនអាចដើម្បីយាងទៅបិណ្ឌបាតបាន ទើបទ្រង់ហោះទៅតាមអាកាស ទ្រង់បានបរិនិព្វានហើយ ក្នុងបណ្ណសាលា របស់ព្រះអង្គ ។

ពួកមនុស្សក្នុងគោចរគ្រាម ដឹងថា ព្រះបច្ចេកពុទ្ធអង្គនោះ មិនយាងមក ទើបគិត ថា "ការមិនសប្បាយអ្វី ៗ គង់នឹងមាន" ដូច្នេះក៏បានទៅ ក្នុងទីនោះ ឃើញព្រះបច្ចេកពុទ្ធអង្គនោះ ទ្រង់បរិនិព្វានទើបខ្សឹកខ្សួលហើយ ។ បុរសអាក្រក់នោះឯង ចាំព្រះបច្ចេកពុទ្ធអង្គនោះបាន ក្នុងទីនោះ ទើបពោល ថា "ខ្ញុំកាលសាកល្បងមើល

នូវសិល្បៈ របស់ខ្លួន បានប្រហារហើយនូវព្រះបច្ចេកពុទ្ធអង្គនេះ" ។ ពួកមនុស្ស ស្តាប់ពាក្យនោះហើយ ក៏បានវាយបុរសអាក្រក់នោះ ឲ្យស្លាប់ហើយ ។ បុរសអាក្រក់នោះ ឆេះហើយក្នុងអវិចីនរក រហូតដល់ផែនដីនេះ ជុះឡើងបាន ប្រមាណ ១ យោជន៍ ក៏បានកើតជាសដ្ឋិកូដប្រេត លើភ្នំគិជ្ឈកូដ ដោយផលកម្មដែលសេសសល់, សរីរៈរបស់ប្រេតនោះ កំពស់ ៣ គាវុត, ដែកញញួរ ៦ ម៉ឺន ត្រូវភ្លើងឆេះ សន្ធោសន្ធៅហើយ បានធំហើយធំទៀត លើអំបែងក្បាលរបស់ប្រេតនោះហើយ ទំលាយនូវក្បាល, ក្បាលដែលបែកហើយ ៗ ក៏ត្រឡប់កើតឡើងជាថ្មីទៀត ។

រឿង សដ្ឋិកូដប្រេត មកក្នុងពាលវគ្គ នៃធម្មបទ ។

(១៤៥) ម្យ៉ាងទៀត ក្នុងគម្ពីរសុត្តវគ្គដីកាជាដើម សូម្បីជាងចាំង ក៏លោកហៅថា "អ្នកមានសិល្បៈ" យ៉ាងដូច្នេះ ថា ÷

"ជាងចាំង ជាងតម្បាញ ជាងជ្រលក់ ជាងកាត់សក់ ជាងស្បែកជាគម្រប់ ៥ លោកហៅថា 'ជាង អ្នកមានសិល្បៈ" ។

មែនពិត ជាងចាំងជាដើម លោកហៅថា "ជាង" ព្រោះអត្ថថា "តែងធ្វើ គឺ ស្ថាបនានូវរបស់ដែលគួរស្ថាបនា មានកិច្ចការ របស់

ជាងចាំងជាដើម" និងលោកហៅថា "អ្នកមានសិល្បៈ" ព្រោះអត្ថថា "ជនទាំងឡាយនោះ មានសិល្បៈ" ដូច្នេះ, ព្រោះហេតុនោះ សូម្បីការងារ របស់ជាងចាំង ក៏ឈ្មោះថា ជាសិល្បៈ ។ មែនពិត សូម្បីសិល្បៈនោះ ក៏ចាត់ថា ជាមង្គលដែរ ព្រោះជាហេតុនាំមក នូវប្រយោជន៍ ។

ក្នុងដំណើរនោះ មានរឿងទាំងនេះ ( ជាឧទាហរណ៍ ) ÷

## ( រឿង ព្រះបាទកដ្ឋវាហនៈទី ១ )

(១៤៦) ព្រះរាជកុមារ ដែលជាព្រះរាជបុត្រ នៃព្រះបាទ ពិម្ពិសារ ទ្រង់ព្រះនាមថាពោធិ ទ្រង់ត្រាស់បញ្ជាឲ្យកសាងប្រាសាទ ឈ្មោះកោកនទ មានរូបរាងមិនដូចប្រាសាទទាំងឡាយដទៃទៀត ក្នុងផ្ទៃនៃប្រឹថពី ប្រៀបដូចជាអណ្តែតឰដ៏អាកាស ទ្រង់ត្រាស់សួរ នូវជាង ថា "ប្រាសាទបែបនេះ តើអ្នកធ្លាប់បានធ្វើមកឬទេ ?, ឬក៏ នេះ ជាសិល្បៈលើកទី ១ បង្អស់ របស់អ្នក ?" ។

ជាងនោះ ក្រាបទូល ថា "បពិត្រព្រះសម្មតិទេព នេះ គឺជា សិល្បៈលើកទី១ របស់ទូលព្រះបង្គំមែនពិត" ។

ព្រះរាជកុមារ ទ្រង់ព្រះតម្រិះ ថា "បើជាងនេះ នឹងកសាង នូវប្រាសាទបែបនេះ ដល់ជនដទៃទៀត, ប្រាសាទនេះ ក៏នឹងមិន

ក្លាយជារបស់ដែលអស្ចារ្យ, ការដែលអាត្មាអញ សម្លាប់ជាងនេះចោល ឬកាត់ដៃនិងជើងរបស់ជាងនេះ ឬក៏ខ្វេះភ្នែកទាំងគូ របស់គាត់ចោល ទើបគួរ " ដូច្នេះហើយ ទើបទ្រង់ត្រាស់ប្រាប់រឿងនោះដល់មាណព ឈ្មោះសញ្ជិកាបុត្តិ ដែលជាសំឡាញ់ជាទីស្រឡាញ់របស់ព្រះអង្គ ។ មាណព គិត ថា "បុគ្គលអ្នកមានសិល្បៈជាអ្នករកតម្លៃដាក់គ្មាន, កាលបើអាត្មាអញឃើញ, ជាងនោះ ចូរកុំវិនាសឡើយ " ដូច្នេះហើយ ក៏បានឲ្យសញ្ញាដល់ជាង ។ ជាងពោល ថា "បពិត្រលោកចៅហ្វាយ លោកកាលប្រាប់ខ្ញុំ ឈ្មោះថាបានធ្វើកិច្ចល្អហើយ, ខ្ញុំបាទនឹងដឹងនូវកិច្ចដែលខ្ញុំបាទគប្បីធ្វើ ក្នុងរឿងនេះ " ។

ក្រោយមក ថ្ងៃមួយ ព្រះរាជកុមារ ទ្រង់ត្រាស់សួរ ថា "តើកិច្ចការកសាងប្រាសាទ បានសម្រេចហើយឬនៅ ? " ។

ជាង បពិត្រព្រះសម្មតិទេព មិនទាន់សម្រេចទេ, កិច្ចការមាននៅសេសសល់ជាច្រើនទៀត ។

ព្រះរាជកុមារ . តើកិច្ចការឈ្មោះអ្វីខ្លះ ដែលនៅសល់ ? ។

ជាង . បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំ នឹងក្រាបទូលនៅពេលក្រោយ, សូមព្រះអង្គ ទ្រង់ត្រាស់បញ្ជា ឲ្យរាជបុរសនាំយកឈើស្ងួតទាំងឡាយ ដែលមិនមានខ្លឹមមកជាមុនសិនចុះ ។

ព្រះរាជា ទ្រង់បញ្ជាឲ្យរាជបុរសនាំយកឈើទាំងនោះមកហើយ ។

គ្រានោះ ជាងទើបបានក្រាបទូលព្រះរាជកុមារអន្ធនោះ ថា "បពិត្រព្រះសម្មតិទេព ចាប់តាំងអំពីថ្ងៃនេះទៅ អ្នកណា ក៏មិនគួរមកកាន់សំណាក់ នៃទូលព្រះបង្គំឡើយ, ព្រោះថា កាលបើទូលព្រះបង្គំកំពុងធ្វើការងារដ៏ប្រណីត កាលនិយាយជាមួយនឹងអ្នកណាម្នាក់, សេចក្ដីរាយមាយចិត្ត ក៏នឹងមាន, តែក្នុងពេលបរិភោគអាហារ ភរិយារបស់ទូលព្រះបង្គំប៉ុណ្ណោះ នឹងនាំយកអាហារមក" ។

ព្រះរាជាកុមារអន្ធនោះ ទ្រង់ត្រាស់ ថា "ល្អហើយ" ហើយទ្រង់ដាក់ការរក្សា ឈោមជុំវិញផ្ទះ ដើម្បីប្រយោជន៍កុំឲ្យជាងនោះរត់ចេញទៅបាន ។ ចំណែកជាង អន្ធុយក្នុងបន្ទប់ ចាំងឈើទាំងនោះ ធ្វើជាសត្វគ្រុឌហើយ ប្រាប់ភរិយាដែលមកហើយ ក្នុងពេលអាហារ ថា "នែនាងដ៏ចំរើន ចូរអូនលក់របស់របរទាំងអស់ដែលមាននៅក្នុងផ្ទះហើយ យកប្រាក់និងមាសទុក" ដូច្នេះ ក្នុងពេលដែលសត្វគ្រុឌសម្រេចហើយ ទើបប្រាប់ ថា "ក្នុងថ្ងៃនេះ អូនគប្បីនាំយកកូនទាំងអស់មក" ។ ភរិយានោះ បានធ្វើហើយ យ៉ាងដូច្នោះ ។ នាយជាងនោះ ជាអ្នកបរិភោគអាហារព្រឹកហើយ ព្រមទាំងបុត្រនិងភរិយា អន្ធុយក្នុងពោះនៃសត្វ រត់ចេញទៅតាមបង្អួចហើយ ចុះក្នុងព្រៃហិមពាន្ត កសាងព្រះនគរហើយ គ្រប់គ្រង

